ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ គួរតែបានស្ដាប់ការពិតទាំងស្រុងរបស់ភាគីម្ខាងទៀត

◆ ថ្ងៃបើកសវនាការលើករណី០០២

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៤៤ ខែធ្នូ ឆ្នាំ២០១១

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៤៤ ខែធ្នូ ឆ្នាំ២០១១


## មាតិកា


◆គួរតែបានស្តាប់ការពិតទាំងស្រុងរបស់ភាគីម្ខាងទៀត ..................... ១

**ផ្នែកឯកសារ**

◆សុន្ទរកថារបស់ ខៀវ សំផន ប្រធានគណៈប្រតិភូ ..................... ២

◆សុន្ទរកថាសមមិត្ត អៀង សារី សមាជិករបស់គណៈអចិន្ត្រៃយ៍ ..................... ៥

◆គម្រប់ខួបកងទ័ពកម្ពុជា ..................... ៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ខ្ញុំមានវិប្បដិសារីសាមសិបពីរឆ្នាំព្រោះខ្ញុំបានសម្លាប់មនុស្ស ..................... ១៤

**ផ្នែកច្បាប់**

◆សវនាការលើករណី០០២ចាប់ផ្តើម ..................... ១៧

◆កម្ពុជាប្រជាធិបតេយ្យជាគុកឥតជញ្ជាំង ..................... ២៦

◆ខៀវ សំផន និង អៀង សារី ឆ្លើយតប ..................... ៣៦

**វេទិកាពិភាក្សាសាធារណៈ**

◆ការពិនិត្យមើលសាឡើងវិញលើការចរចាស្តោះទៅរកការបង្កើត ..................... ៤៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆រឿងរ៉ាវពិតរបស់ខ្ញុំ ..................... ៤៩




យោធារបស់កងយោធពលខេមរភូមិន្ទចូលរួមស្តាប់សវនាការ




## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ** ៖ ឆាយ ឈុនលី, រ៉េនដល ឌឹហ្វាល់កូ, គ្រីស្ទីន អុីវេន, ស៊ីវ ហេខើ, ឡៃ ហួត, **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ** ៖ ទែន សុខស្រីនិត **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ជំនួយការនិពន្ធនាយក** ៖ ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ** ៖ ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ** ៖ ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

# គួរតែបានស្តាប់ការពិតទាំងស្រុងរបស់ភាគីម្ខាងទៀត

មួយថ្ងៃក្រោយពីសាលាក្តីខ្មែរក្រហមចាប់ផ្តើមសវនាការសំណុំរឿង០០២ជាប្រវត្តិសាស្ត្រប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមគឺ អៀង សារី, នួន ជា, និង ខៀវ សំផន នៅថ្ងៃទី៦ ខែធ្នូនេះ បណ្តាញទូរទស្សន៍កម្ពុជា (ដែលជាទូទៅត្រូវបានស្គាល់ថាប៉ុស្តិ៍ទូរទស្សន៍ស៊ីធីអិន) បានបញ្ឈប់ការផ្សាយបន្តផ្ទាល់ប្រចាំថ្ងៃរបស់ខ្លួនពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សេចក្តីសម្រេចរបស់បណ្តាញទូរទស្សន៍ស៊ីធីអិនអាចយល់បានពីព្រោះបណ្តាញទូរទស្សន៍នេះគឺជាកម្មសិទ្ធិរបស់ក្រុមហ៊ុនឯកជន ។ យ៉ាងណាមិញ បញ្ហានេះគឺជាការទទួលខុសត្រូវរបស់សាលាក្តីខ្មែរក្រហម (ដែលក្នុងនោះគឺមានអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា) ក្នុងការធានាឲ្យបានថា ដំណើរការនៃអង្គជំនុំជម្រះក្តីពេញអង្គត្រូវបានផ្សាយផ្ទាល់ឲ្យសាធារណជនដឹងគ្រប់ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះគឺជាអង្គជំនុំជម្រះក្តីនៃបទឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ដ៏សំខាន់បំផុតនៃសតវត្សរ៍ទី២១ ហើយអង្គជំនុំជម្រះក្តីនេះកំពុងតែដំណើរការនៅក្នុងប្រទេសកម្ពុជាយើង ។ ជនរងគ្រោះបានរង់ចាំអស់រយៈពេលជាងសាមសិបឆ្នាំមកហើយដើម្បីស្តាប់នូវអ្វីដែលមេដឹកនាំខ្មែរក្រហមនឹងនិយាយ ហើយជនរងគ្រោះទាំងអស់មានសិទ្ធិក្នុងការស្តាប់សក្ខីកម្មរបស់ជនជាប់ចោទដើម្បីពិចារណាថាតើជនរងគ្រោះគួរតែជឿរឿងរ៉ាវទាំងអស់នោះរបស់មេដឹកនាំខ្មែរក្រហមប៉ុយ៉ាងណា ។ ជាមួយគ្នានេះ យុវជនកម្ពុជាទាំងអស់ក៏មានសិទ្ធិស្តាប់សក្ខីកម្មរបស់មេដឹកនាំខ្មែរក្រហមដែរដើម្បីធ្វើការស្វែងយល់ពីប្រទេសជាតិរបស់ខ្លួនកាន់តែប្រសើរឡើង ។

វាមិនគួរមានឧបសគ្គអ្វីមករារាំងជនរងគ្រោះក្នុងការស្តាប់រឿងរ៉ាវរបស់មេដឹកនាំខ្មែរក្រហមឡើយ ។ អង្គជំនុំជម្រះពេលនេះគឺជាអង្គជំនុំជម្រះក្តីលើកទីពីរ ហើយក៏អាចជាលើកចុងក្រោយដែរ ។ ហើយមានតែជនជាប់ចោទបួននាក់តែប៉ុណ្ណោះដែលអាចនឹងត្រូវបានកាត់ទោសសម្រាប់ការស្លាប់បាត់បង់ជីវិតរបស់ប្រជាជនកម្ពុជាប្រមាណជិតពីរលាននាក់ ។ តើវាមានប្រយោជន៍អ្វីសម្រាប់កិច្ចខំប្រឹងប្រែងរបស់អង្គជំនុំជម្រះក្តីនេះ ប្រសិនបើប្រជាជនកម្ពុជាមិនអាចតាមដានព្រឹត្តិការណ៍ដែលបានកើតឡើងនៅឯសាលាក្តីខ្មែរក្រហមផងនោះ? **ឆាំង យុ**


សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី និង ឆាំង យុ

# សុន្ទរកថារបស់ ខៀវ សំផន ប្រធានគណៈប្រតិភូ

## ដកស្រង់ចេញពីឯកសារស៊ុយអ៊ែត D២៧៣១៥


ខៀវ សំផន កំពុងថ្លែងសុន្ទរកថា

សមាជិកទាំងអស់នៃគណៈប្រតិភូរបស់យើងខ្ញុំមានអារម្មណ៍រំភើបនិងសប្បាយរីករាយដែលបានអញ្ជើញមកធ្វើដំណើរទស្សនកិច្ចនៅទីក្រុងប៉េកាំងដែលជានិមិត្តរូបដ៏ពិសិដ្ឋនៃរបបសង្គមនិយមថ្មីរបស់ប្រទេសចិន ។ ការទទួលស្វាគមន៍ដែលផ្តល់ឲ្យក្រុមគណៈប្រតិភូរបស់យើងដោយលោក លោកស្រីនិងប្រជាជនរបស់រាជធានីប៉េកាំងនិងដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនគឺជាការស្វាគមន៍ដ៏ខ្ពង់ខ្ពស់ដែលបានបង្ហាញនូវភាពសាមគ្គីដ៏កក់ក្តៅរីករាយនិងដ៏ជិតស្និទ្ធជាទីបំផុត ។ នេះគឺជាការបង្ហាញភាពស្មោះស្ម័គ្រដែលប្រជាជនចិនដ៏អស្ចារ្យ និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនបានបង្ហាញឲ្យឃើញជាបន្តបន្ទាប់ចំពោះយើងខ្ញុំប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាដែលកំពុងតែវាយប្រយុទ្ធក្នុងសមរភូមិប្រឆាំងនឹងពួកចក្រពត្តិអាមេរិកនិងបរិវាររបស់វា ។ យើងមានមោទកភាពយ៉ាងខ្លាំងក្នុងការបង្ហាញឲ្យឃើញចំណងមិត្តភាពដ៏កក់ក្តៅនិងសាមគ្គីភាពដ៏រឹងមាំរបស់ប្រជាជាតិនិងប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងកងកម្លាំងរំដោះជាតិកម្ពុជាជូនចំពោះប្រជាជនចិននិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនដ៏អង់អាចក្លាហាន ។

ក្នុងអំឡុងពេលតស៊ូប្រឆាំងនឹងពួកឈ្លានពានចក្រពត្តិអាមេរិក ប្រជាជាតិនិងប្រជាជនកម្ពុជាដែលបានលើកទង់យោធារំដោះជាតិយ៉ាងខ្ពស់ដោយភាពអង់អាចក្លាហាន ហើយដែលបានវាយប្រយុទ្ធប្រឆាំងនឹងពួកចក្រពត្តិអាមេរិកនិងពួកបរិវាររបស់វាទាំងអស់នៅតាមសមរភូមិដ៏ក្តៅគគុកនីមួយៗពិតជាបានទទួលជំនួយដ៏ស្មោះស្ម័គ្រនិងប្រកបដោយគុណភាព ព្រមទាំងការឧបត្ថម្ភជាច្រើនប្រភេទពីប្រជាជនចិននិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ។ សាធារណរដ្ឋប្រជាមានិតចិនគឺជាប្រទេសដ៏ធំមួយដែលមានចំនួនប្រជាជនសរុបចំនួនប្រាំបីរយលាននាក់ ។ យ៉ាងណាមិញ សាធារណរដ្ឋប្រជាមានិតចិនបានផ្តល់ជំនួយឧបត្ថម្ភដល់ប្រទេសកម្ពុជាដ៏តូចរបស់យើងដែលមានចំនួនប្រជាជនសរុបត្រឹមតែប្រាំពីរលាននាក់ដោយស្មោះស្ម័គ្រ គ្មានលក្ខខណ្ឌ និងដោយគោលជំហរស្មើភាព ។ សាធារណរដ្ឋប្រជាមានិតចិនគោរពបូរណភាពដែនដី និងសេចក្តីថ្លៃថ្នូររបស់ជាតិយើង ។ សេចក្តីគោរពនេះធ្វើឲ្យប្រជាជាតិ និងប្រជាជនកម្ពុជាយើងពេញចិត្តយ៉ាងខ្លាំង ។ ប្រជាជាតិនិងប្រជាជនកម្ពុជាយើងសូមកោតសរសើរដ៏ខ្ពង់ខ្ពស់ចំពោះការប្រកាន់គោលជំហរដ៏ត្រឹមត្រូវរបស់ប្រជាជនចិន និងសាធារណរដ្ឋប្រជាមានិតចិនប្រកបដោយភាតរភាព និងដ៏អស្ចារ្យក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់បក្សកុម្មុយនីស្តចិនដែលមានលោកប្រធានាអធិបតី ម៉ៅ សេទុង ជាមេដឹកនាំដ៏ល្បីល្បាញ ។ ដូច្នេះ ប្រជាជាតិ និងប្រជាជនកម្ពុជា ព្រមទាំងរណសិរ្សរួបរួមជាតិកម្ពុជាដែលមានប្រមុខរដ្ឋសម្តេច នរោត្តម សីហនុ ជាប្រធាននិងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាដែលមានសម្តេច ប៉ែន នុត ជានាយករដ្ឋមន្ត្រីមានមោទកភាពនិងសោមនស្សរីករាយយ៉ាងក្រៃលែងដែលមានប្រជាជនចិននិងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិនធ្វើជាសមមិត្តដ៏ជឿទុកចិត្តរបស់យើងក្នុងគ្រាជ័យជម្នះឬឧបសគ្គ ។ ចំណងមិត្តភាពរវាងប្រជាជនចិន និងប្រជាជនកម្ពុជាកើតឡើងដោយភាពស្មោះត្រង់ ដោយផ្អែកលើគោលការណ៍ដ៏ត្រឹមត្រូវនៃភាពស្មើគ្នា ប្រយោជន៍រួមគ្នា និងការគោរពគ្នាទៅវិញទៅមក ។ យើងខ្ញុំជឿជាក់ថា ចំណងមិត្តភាពរវាងប្រជាជនកម្ពុជា និងប្រជាជនចិនគឺជាគំរូដ៏ប្រសើរមួយនៅក្នុងពិភពលោក ហើយចំណងមិត្តភាពនេះទៀតសោតផ្តល់ជាមូលដ្ឋាននៃស្ថិរភាពសម្រាប់ពិភពលោកនាពេលបច្ចុប្បន្ន និងអនាគត ។

យើងខ្ញុំជាប្រជាជនកម្ពុជាតែងតែទទួលបានកិត្តិយសនិងការកោតសរសើរដ៏ខ្ពង់ខ្ពស់ជានិច្ច ។ យើងមានអរិយធម៌ខ្ពស់និងមានសមត្ថភាពក្នុងការកសាងប្រទេសជាតិដូចជាកេរមរតកដ៏មានតម្លៃនៃប្រាសាទអង្គរវត្តយើងដែលត្រូវបានថែរក្សារហូតមកដល់សព្វថ្ងៃនេះ ។ ប៉ុន្តែ នៅប៉ុន្មានសតវត្សរ៍កន្លងមកនេះ កិត្តិយសរបស់យើងត្រូវបានយាយីនិងបំផ្លិចបំផ្លាញជាបន្តបន្ទាប់ដោយពួកអាណានិគមបារាំង ពួកចក្រពត្តិជ្រុលនិយមជប៉ុន និងពួកចក្រពត្តិអាមេរិកដែលបានទម្លាក់ប្រទេសជាតិរបស់យើងឲ្យក្លាយជាប្រទេសអាណានិគមរបស់វា ។ ក្នុងនាមជាប្រទេសជាតិ និងប្រជាជនដែលមានភាពអង់អាចក្លាហានក្នុងការប្រយុទ្ធតស៊ូ យើងហ៊ានពលីជីវិតសម្រាប់ការរំដោះប្រទេសជាតិដើម្បីការពារនិងថែរក្សាកិត្តិយសដ៏ខ្ពង់ខ្ពស់របស់ជាតិយើង ។ យើងខ្ញុំមានក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលបានចងសម្ព័ន្ធភាពដ៏ស្មោះស្ម័គ្រជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិនដែលប្រកាន់ខ្ជាប់នូវគោលការណ៍ភាពស្មើគ្នាហើយដែលបានផ្តល់ជំនួយឧបត្ថម្ភដល់យើងយ៉ាងពេញទំហឹង ។ ប្រទេសជាតិ និងប្រជាជនកម្ពុជាត្រូវការយ៉ាងចាំបាច់នូវគោលការណ៍នៃការគោរពគ្នាទៅវិញទៅមក ។ យើងខ្ញុំជឿជាក់ថា បច្ចុប្បន្ននេះប្រជាជននៃបណ្តាប្រទេសទាំងអស់ ជាពិសេសប្រទេសតូចតាចតាមបណ្តាប្រទេសលោកទីបីបានចូលរួមក្នុងការតស៊ូរំដោះប្រទេសជាតិប្រឆាំងនឹងពួកអាណានិគមនិងពួកចក្រពត្តិនិយម ហើយស្របពេលជាមួយគ្នានោះប្រទេសតូចតាចទាំងនោះក៏ត្រូវការនូវការចងសម្ព័ន្ធភាពដូចគ្នានេះដែរ ។

សង្គ្រាមរំដោះជាតិដែលដឹកនាំដោយប្រជាជនកម្ពុជាប្រឆាំងនឹងសង្គ្រាមឈ្លានពានដ៏សាហាវព្រៃផ្សៃដែលធ្វើឡើងដោយពួកចក្រពត្តិអាមេរិកនិងពួកបរិវាររបស់វាទាំងអស់បានធ្វើឡើងក្នុងរយៈពេលបួនឆ្នាំមកហើយ ។ ក្នុងរយៈពេលបួនឆ្នាំនេះ ប្រជាជនកម្ពុជា និងកងកម្លាំងប្រជាជនរំដោះជាតិកម្ពុជាបានពុះពារគ្រប់ឧបសគ្គទាំងអស់ ពលីអ្វីៗគ្រប់បែបយ៉ាង ហើយបង្កើតកិច្ចខំប្រឹងប្រែងជាបន្តបន្ទាប់ដើម្បីប្រឆាំងនឹងចលនាចក្រពត្តិនិយមដ៏ព្រៃផ្សៃរបស់អាមេរិក និងបក្ខពួកក្បត់ដ៏ជូរជាតិរបស់ លន់ នល់, សិរិ មតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត, និង សុសស្តេន ហ្វឺណាន់ដេហ្ស ។ ក្នុងការតស៊ូរំដោះជាតិពីការបំផ្លិចបំផ្លាញនេះ ប្រជាជនកម្ពុជា និងកងកម្លាំងប្រជាជនរំដោះជាតិកម្ពុជាដ៏ក្លាហានបានទទួលបានជ័យជម្នះសំខាន់ៗជាច្រើនក្នុងវិស័យយោធា នយោបាយ សេដ្ឋកិច្ច និងការទូត ។ ជ័យជម្នះដែលប្រជាជនកម្ពុជាយើងសម្រេចបានគឺជាយុទ្ធសាស្ត្រដ៏មានសារសំខាន់ ។

យើងបានរំដោះទឹកដីកម្ពុជាបានរហូតដល់៩០ភាគរយ ហើយក៏បានរំដោះប្រជាជនបានប្រមាណប្រាំលានប្រាំសែននាក់ ។ តំបន់រំដោះរបស់យើងក្នុងប្រទេសមានទំហំធំធេង រីឯតំបន់ដែលកាន់កាប់ដោយពួកក្បត់មានទំហំតូចដែលមានតែទីក្រុងភ្នំពេញនិងទីប្រជុំជននៅតាមខេត្តមួយចំនួនតូចតែប៉ុណ្ណោះ ។

ពួកចក្រពត្តិអាមេរិកនិងបរិវាររបស់វា និងបក្ខពួកក្បត់នៅទីក្រុងភ្នំពេញត្រូវបានទទួលបរាជ័យ ។ ប៉ុន្តែដើម្បីរារាំងជ័យជម្នះជាស្ថាពររបស់យើង ពួកក្បត់ទាំងអស់នេះបានរិះរកយុទ្ធសាស្ត្រដ៏ពុតត្បុតនិងអត់ធ្មត់តាមរយៈចលនាយោធាដ៏សាហាវមួយចំនួនដូចជា កិច្ចព្រមព្រៀងបទឈប់បាញ់ ការចរចា និងកិច្ចព្រមព្រៀងសន្តិភាពបោកប្រាស់ ។

នាពេលបច្ចុប្បន្ននេះ ពួកក្បត់ទាំងអស់នេះបានកំពុងតែបន្តកិច្ចខំប្រឹងប្រែងរៀងៗខ្លួនដើម្បីបង្កើតឲ្យមានសង្គ្រាម «អរិយធម៌ខ្មែរ» នៅក្នុងប្រទេសកម្ពុជា ។ ទស្សនៈសាធារណជនមួយចំនួនបានយល់ខុសថា ក្រោយពីការបញ្ឈប់ការទម្លាក់គ្រាប់បែកកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៣ ពួកចក្រពត្តិអាមេរិកបានបើកដៃឲ្យពួកអាក្បត់ លន់ នល់, សិរិ មតៈ, សឺង ង៉ុកថាញ់, ចេង ហេង អ៊ិន បូរ៉េត, និង សុសស្តេន ហ្វឺណាន់ដេហ្ស បន្តធ្វើសង្គ្រាមប្រយុទ្ធប្រឆាំងជាមួយនឹងយើងដោយខ្លួនឯង ។ យ៉ាងណាមិញ ការពិតគឺថា ពួកចក្រពត្តិអាមេរិកបានចេញមុខផ្តល់យុទ្ធសាស្ត្រក្នុងសង្គ្រាមនេះដោយផ្ទាល់យ៉ាងសកម្មជាងមុនទៅទៀត ។ សព្វថ្ងៃនេះ នៅក្នុងទីក្រុងភ្នំពេញ និងតាមសមរភូមិទាំងអស់ឧទាហរណ៍ដូចជានៅតាមបណ្តាខេត្តជុំវិញទីក្រុងភ្នំពេញដូចជា ខេត្តកំពត កំពង់ធំ និងខេត្តស្វាយរៀង យើងឃើញមានអ្នកប្រឹក្សាយោធារបស់ពួកចក្រពត្តិអាមេរិកច្រើនបំផុត គឺចំនួនបីពាន់ប្រាំរយនាក់ដែលបានក្លែងខ្លួនជាបុគ្គលិកស៊ីវិលធម្មតា ។ ចលនាចក្រពត្តិនិយមអាមេរិកកំពុងតែគ្រោងពង្រីកចំនួនយោធារបស់ខ្លួនរហូតដល់ចំនួនមួយម៉ឺននាក់នៅក្នុងចុងឆ្នាំនេះ ។ ជារៀងរាល់ថ្ងៃ ពួកចក្រពត្តិអាមេរិក និងពួក

ក្បត់នៅទីក្រុងភ្នំពេញបានកំពុងតែប្រព្រឹត្តឧក្រិដ្ឋកម្មច្រើនសន្ធឹកសន្ធាប់មកលើប្រជាជនកម្ពុជា ។ ដូច្នេះស្ថានភាពសង្គ្រាមនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះមិនមានអ្វីផ្លាស់ប្តូរឲ្យប្រសើរឡើងទេ ។ សង្គ្រាមឈ្លានពានរបស់ពួកចក្រពត្តិអាមេរិកនៅតែអនុវត្តឡើងប្រឆាំងនឹងប្រជាជនកម្ពុជាដដែល ។

ដូច្នេះប្រជាជនយើងបានប្រកាន់គោលជំហរជាសមូហភាពថា ដោយសារតែពួកចក្រពត្តិអាមេរិកនៅតែជម្នះបន្តឲ្យមានសង្គ្រាម «អរិយធម៌ខ្មែរ» នៅក្នុងប្រទេសកម្ពុជាយើង និងប្រយុទ្ធយ៉ាងដាច់ខាតរហូតដល់ទីបញ្ចប់ដើម្បីសម្រេចសេចក្តីប្រកាសប្រាំចំណុចរបស់រណសិរ្សរួបរួមជាតិកម្ពុជាដែលចុះផ្សាយកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ដោយសម្តេចនរោត្តម សីហនុ ប្រធានប្រមុខរដ្ឋនិងប្រធានអធិបតីរបស់រណសិរ្សរួបរួមជាតិកម្ពុជា ។ ប្រជាជនរបស់យើងបានយល់យ៉ាងច្បាស់ថា ការតស៊ូរបស់យើងគឺជាការតស៊ូដ៏ក្រឹត្យក្រមមួយ ។ យើងធ្វើការប្រយុទ្ធប្រឆាំងក្នុងគោលបំណងសម្រេចយកមកវិញនូវសិទ្ធិសេរីភាព និងឯករាជ្យភាពជាតិរបស់យើងតែប៉ុណ្ណោះ ។ យើងមិនដែលឈ្លានពានប្រទេសណាមួយឡើយ ។ អស់រយៈកាលជាយូរណាស់មកហើយ ប្រទេសជាតិនិងប្រជាជនកម្ពុជាបានទាញទម្លាក់ស្ថិតនៅក្រោមអាណានិគមបរទេស ។ ហេតុដូចនេះយើងខ្ញុំចង់បាននូវឯករាជ្យភាព និងសេចក្តីគោរពកោតសរសើរ ។ ប៉ុន្តែ ប្រទេសកម្ពុជាមានចំនួនប្រជាជនតិចហើយប្រជាជនកម្ពុជាភាគច្រើនគឺជាប្រជាជនដែលមានសន្តានចិត្តល្អនិងស្រឡាញ់សន្តិភាព ។ ទោះជាយ៉ាងណាក្តី យើងចង់បាននូវឯករាជ្យភាពនិងសេចក្តីគោរពកោតសរសើរដ៏ពិតប្រាកដមួយដែលមិនមែនជាសន្តិភាពក្លែងក្លាយមួយដែលពួកខ្មាំងយកមកប្រើប្រាស់ដើម្បីស្តារ និងពង្រីកកងកម្លាំងរបស់វាដើម្បីបកមកវាយប្រហារយើងម្តងទៀតឡើយ ។ ក្នុងកាលៈទេសៈបច្ចុប្បន្ននេះ បញ្ហារបស់កម្ពុជាអាចនឹងត្រូវបានដោះស្រាយបានលុះត្រាតែពួកចក្រពត្តិនិយមជម្លៀសសមាសធាតុអ្នកប្រឹក្សាផ្នែកយោធា និងកងកម្លាំងយោធារបស់ខ្លួនទាំងអស់ចេញពីទឹកដីកម្ពុជា បញ្ឈប់ការឈ្លានពានមកលើកម្ពុជា និងបញ្ចប់ការផ្តល់ជំនួយគ្រប់បែបយ៉ាងដល់បក្ខពួកក្បត់នៅទីក្រុងភ្នំពេញ ហើយទុកឲ្យប្រជាជនកម្ពុជាដោះស្រាយបញ្ហារបស់ខ្លួនដោយខ្លួនឯង ។ មានតែធ្វើដូច្នេះទេ ទើបបញ្ហាប្រឈមមុខរបស់កម្ពុជាអាចដោះស្រាយបាន ។ គ្មានដំណោះស្រាយណាផ្សេងក្រៅពីនេះឡើយ ។

ប្រជាជនកម្ពុជាយើងទាំងអស់សូមកោតសរសើរចំពោះជំនួយឧបត្ថម្ភដ៏ខ្ពង់ខ្ពស់ដែលផ្តល់ឲ្យយើងខ្ញុំដោយប្រជាជនសប្បុរសគ្រប់បណ្តាប្រទេសទាំងអស់និងប្រជាជនជុំវិញពិភពលោក ។ ដោយផ្អែកលើគោលការណ៍គោរពបូរណភាពដែនដីរវាងគ្នាទៅវិញទៅមក ភាពស្មើគ្នានិងផលប្រយោជន៍ស្មើគ្នានេះគឺជាគោលជំហររបស់យើងខ្ញុំក្នុងការរួបរួមសាមគ្គីគ្នាជាមួយបណ្តាប្រទេសទាំងឡាយដែលគោរព ឯករាជ្យភាព និងបូរណភាពដែនដីរបស់កម្ពុជាដោយមិនរើសអើងប្រព័ន្ធនយោបាយរបស់ប្រទេសទាំងនោះឡើយ ។ ប្រទេសកម្ពុជានៅតែបន្តប្រកាន់គោលជំហរឯករាជ្យភាពសន្តិភាពអព្យាក្រឹត្យ និងមិនចូលបក្សសម្ព័ន្ធ ។

ដើម្បីថែរក្សាគោលជំហរនេះ យើងគាំទ្ររាល់ចលនារំដោះជាតិប្រឆាំងនឹងរបបចក្រពត្តិនិយម របបអាណានិគមនិងរបបអាណានិគមផ្នែកសេដ្ឋកិច្ចមានដូចជា ចលនាតស៊ូរំដោះជាតិវៀតណាមខាងត្បូងចលនាតស៊ូរំដោះជាតិឡាវ ចលនាតស៊ូរបស់ប្រជាជនចិនរំដោះតៃវ៉ាន់ ចលនាតស៊ូរបស់កូរេដើម្បីការរួបរួមប្រទេសដ៏ឯករាជ្យនិងសន្តិភាព ចលនារំដោះជាតិរបស់ប៉ាឡេស្ទីន ចលនាតស៊ូរបស់ប្រជាជនស៊ីរៀប្រឆាំងនឹងរបបចក្រពត្តិនិយមរបស់អ៊ីស្រាអែល ចលនាតស៊ូរបស់ប្រជាជនអារ៉ាប់ដោយប្រើអាវុធប្រេងរំអិលប្រឆាំងនឹងរបបចក្រពត្តិអាមេរិក និងចលនាតស៊ូរបស់ប្រជាជនគុយណេ-ប៊ីសូ ប្រជាជនអង់ហ្គោឡា ប្រជាជនម៉ូហ្សំប៊ីកប្រឆាំងនឹងរបបអាណានិគមព័រទុយហ្គាល់និងរបបអាណានិគមអាហ្វ្រិកខាងត្បូង ។

ជាចុងបញ្ចប់ ជួសមុខឲ្យប្រជាជនកម្ពុជា អ្នកវាយប្រយុទ្ធនៅសមរភូមិនិងកម្មាភិបាលរបស់កងកម្លាំងប្រជាជនរំដោះជាតិកម្ពុជា យើងខ្ញុំសូមអនុញ្ញាតថ្លែងអំណរគុណយ៉ាងអនេកប្បការសាជាថ្មីម្តងទៀតចំពោះបក្សកុម្មុយនីស្តចិន និងរដ្ឋាភិបាលចិនសម្រាប់ជំនួយឧបត្ថម្ភដ៏ស្មោះស្ម័គ្រទាំងឡាយដែលសាធារណរដ្ឋប្រជាមានិតចិនបានផ្តល់ឲ្យសម្រាប់ចលនាតស៊ូរំដោះជាតិរបស់ប្រជាជនកម្ពុជាយើងខ្ញុំ ។ យើងជឿជាក់ថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូយើងនឹងបន្តរឹតបន្តឹង និងពង្រឹងសាមគ្គីភាព និងចំណងមិត្តភាពយោធាដ៏ពិសេសនេះ ។

# សុន្ទរកថារបស់សមមិត្ត អៀង សារី សមាជិករបស់គណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា

*អៀង សារី ថ្លែងនាឱកាសបរិភោគអាហារពេលល្ងាចជាកិច្ចស្វាគមន៍កិត្តិយសដល់សមមិត្ត ដាញ៉ែល លីអូន ប៊ឺស្មៀន សមាជិករបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តម៉ាក្ស-លេនីន នៅភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៨*

**ដកស្រង់ចេញពីឯកសារស៊ុយរ៉េដ D២៩០៥៨**

សូមគោរពសមមិត្ត ដាញ៉ែល លីអូន ប៊ឺស្មៀន

សូមគោរពសមាជិកគណៈប្រតិភូនិងសូមគោរពសមមិត្តទាំងអស់

ជូនសមុខឲ្យគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ យើងមានក្តីសោមនស្សរីករាយនិងសូមស្វាគមន៍ដ៏កក់ក្តៅជាទីបំផុតចំពោះសមមិត្ត ដាញ៉ែល លីអូន ប៊ឺស្មៀន សមាជិកគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តម៉ាក្ស-លេនីនរបស់សហរដ្ឋអាមេរិក អ្នកកែសម្រួលអត្ថបទដែលមានចំណងជើងថា «ដឹក ខល» និងគណៈប្រតិភូរបស់លោកទាំងអស់ ។



អៀង សារី ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

សមមិត្តគឺជាជនជាតិអាមេរិកដំបូងបង្អស់ដែលបានអញ្ជើញមកធ្វើទស្សនកិច្ចក្នុងប្រទេសកម្ពុជាយើងចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលប្រជាជនកម្ពុជា និងកងទ័ពបដិវត្តន៍កម្ពុជាបានទទួលមហាជ័យជម្នះជាប្រវត្តិសាស្ត្រលើពួកចក្រពត្តិឈ្លានពានអាមេរិកនិងបរិវាររបស់វានិងបានរំដោះប្រទេសកម្ពុជាជាស្ថាពរ ។

យើងខ្ញុំសូមទទួលយកសមមិត្តមកធ្វើជាតំណាងឲ្យកងទ័ពស្រួចរបស់វណ្ណៈកម្មករអាមេរិកនិងប្រជាជនអាមេរិកដែលប្រកាន់គោលជំហរនៃបុព្វហេតុល្អរបស់ប្រជាជនកម្ពុជាយើង ។ កិច្ចទទួលស្វាគមន៍នេះរំឭកដល់យើងទាំងអស់គ្នានៃប្រជាជនអាមេរិកក្មេងៗដែលបានវាយប្រយុទ្ធតស៊ូដ៏មោះមុតប្រឆាំងនឹងសង្គ្រាមបំផ្លិចបំផ្លាញរបស់ពួកចក្រពត្តិអាមេរិកមកលើប្រទេសកម្ពុជា ហើយដែលបានគាំទ្រយ៉ាងសកម្មដល់ចលនាតស៊ូរំដោះជាតិរបស់ប្រជាជនកម្ពុជា ។ ជាពិសេស យើងខ្ញុំពិតជារំភើបនៅពេលដែលរៀបរាប់ឡើងវិញនូវអនុស្សាវរីយ៍របស់និស្សិតអាមេរិកនៃសាកលវិទ្យាល័យខេក-សាន់ និងសាកលវិទ្យាល័យ ខេន ។ ដូច្នេះ ដោយសារតែអារម្មណ៍រីករាយដ៏ស្មោះស្ម័គ្រដែលយើងមានចំពោះប្រជាជនអាមេរិកទាំងអស់នេះហើយដែលយើងបានសម្រេចចិត្តទទួលស្វាគមន៍អស់លោកទាំងអស់គ្នានៅក្នុងថ្ងៃនេះ ។

សមមិត្តទាំងអស់ជាទីគោរព អ្នកបានមកធ្វើដំណើរទស្សនកិច្ចដល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យរបស់យើងស្របពេលដែលស្ថានភាពប្រទេសរបស់យើងមានភាពល្អប្រសើរ ។ ក្រោយពីការប្រារព្ធពិធីគម្រប់ខួបលើកទីបីនៃមហាជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងខួបកំណើតបក្សកម្ពុជាប្រជាធិបតេយ្យមក ដោយស្ថិតនៅក្រោមការគ្រប់គ្រងដ៏ត្រឹមត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រជាជននិងកងបដិវត្តន៍កម្ពុជាបានបន្តអនុវត្តកិច្ចការការពាររបបកម្ពុជាប្រជាធិបតេយ្យរបស់ខ្លួនយ៉ាងសកម្មដើម្បីសម្រេចកសាងបដិវត្តន៍សង្គមនិយមនិងស្ថាបនារបបសង្គមនិយមដោយគោរពយ៉ាងម៉ឺងម៉ាត់តាមគោលជំហរសមូហភាពនិងឯករាជ្យភាព អធិបតេយ្យភាព និងពឹងផ្អែកលើខ្លួនឯងបាន និងធ្វើជាអ្នកគ្រប់គ្រងអនាគតរបស់ខ្លួនឯង ។

នៅក្នុងការបំពេញកិច្ចការការពារកម្ពុជាប្រជាធិបតេយ្យ យើងបានកម្ចាត់រាល់សកម្មភាពស៊ើបការណ៍និងបំផ្លិចបំផ្លាញរបស់ខ្មាំងទាំងអស់ រួមទាំងសកម្មភាពរបស់ សេអ៊ីអា និងវៀតណាម ដែលបានរួបរួមគ្នាចង់បំផ្លិចបំផ្លាញបដិវត្តន៍កម្ពុជា និងធ្វើរដ្ឋប្រហារផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងបានការពារ ពង្រីងអភិវឌ្ឍនិងពង្រឹករដ្ឋអំណាចបក្សកម្មករ-កសិករបានយ៉ាងជោគជ័យ ។ ក្រោយពីមហាជ័យជម្នះនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ របស់កងបដិវត្តន៍កម្ពុជាលើសកម្មភាពរបស់ពួកឈ្លានពានប្រតិកិរិយា និងពួកខ្មាំងលេបទឹកដីវៀតណាមមក ប្រជាជននិងកងទ័ពបដិវត្តន៍កម្ពុជាបានឆ្លងកាត់គ្រប់ឧបសគ្គទាំងអស់ដើម្បីក្លាយជាអ្នកគ្រប់គ្រងកិច្ចការការពារឯករាជ្យ អធិបតេយ្យភាព និងបូរណភាពដែនដីរបស់កម្ពុជាប្រជាធិបតេយ្យនិងដើម្បីធានាវត្តមានរបស់ប្រទេសជាតិកម្ពុជាយើង ។

នៅក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់សមមិត្ត សមមិត្តនឹងបានយល់ដឹងដោយផ្ទាល់ពីកិច្ចខំប្រឹងប្រែងរបស់ប្រជាជនយើងដោយពឹងផ្អែកលើកម្លាំងខ្លួនឯងក្នុងការស្ថាបនាប្រទេស លើកកម្ពស់បទដ្ឋានរស់នៅ និងកសាងសង្គមថ្មីមួយដោយភាពស្មើគ្នា យុត្តិធម៌និងលទ្ធិប្រជាធិបតេយ្យពិតប្រាកដដោយគ្មានវណ្ណៈកេងប្រវ័ញ្ចឡើយ ។ តាមរយៈលទ្ធផលដែលយើងសម្រេចបានក្នុងអំឡុងពេលបីឆ្នាំកន្លងមកនេះ យើងបានបង្កើតមូលដ្ឋានបន្ថែមទៀតដើម្បីដោះស្រាយភាពខុសគ្នារវាងក្រុង និងជនបទ រវាងកម្មករ-កសិករ រវាងពលករនិងអ្នកបញ្ញវន្ត រវាងមូលដ្ឋានសេដ្ឋកិច្ចនិងរនាសម្ព័ន្ធជាន់ខ្ពស់ និងរវាងកម្មាភិបាលនិងប្រជាជនដោយជោគជ័យ ។ ដើម្បីសម្រេចបានលទ្ធផលជាប្រវត្តិសាស្ត្រដ៏អស្ចារ្យនិងខ្ពង់ខ្ពស់នៃមនុស្សជាតិ យើងចាំបាច់ត្រូវតែប្រមូលកម្លាំងនិងរៀបចំពេលវេលារបស់យើងឲ្យបានរឹងមាំ ។ យើងគ្មានមូលហេតុអ្វីនឹងធ្វើការយាយីលើប្រទេសណាមួយឡើយ ។ យើងត្រូវការតែសន្តិភាពជាកិត្តិយស និងសេចក្តីថ្លៃថ្នូរ ឯករាជ្យ អធិបតេយ្យភាព ភាពនិងបូរណភាពដែនដីរបស់ប្រទេសយើងតែប៉ុណ្ណោះ ។ ទោះបីជាឆ្លងកាត់អតីតកាលដ៏ឈឺចាប់ក៏ដោយ ក៏ប្រជាជនកម្ពុជាសម្លឹងមើលតែពីបច្ចុប្បន្នកាលនិងអនាគតកាលរបស់ខ្លួនតែប៉ុណ្ណោះ ។ កម្ពុជាប្រជាធិបតេយ្យមានបំណងចងសម្ព័ន្ធភាពដ៏ជិតស្និទ្ធជាមួយគ្រប់បណ្តាប្រទេសទាំងអស់ មិនថាជិតមិនថាឆ្ងាយដោយផ្អែកលើគោលការណ៍នៃភាពស្មើគ្នានិងការគោរពគ្នាទៅវិញទៅមក ។ ប៉ុន្តែយើងប្រកាន់ជំហរយ៉ាងហ្មត់ចត់ក្នុងការតស៊ូប្រឆាំងរាល់គ្រប់សកម្មភាពឈ្លានពានលើឯករាជ្យភាព អធិបតេយ្យភាពនិងបូរណភាពដែនដីរបស់កម្ពុជាប្រជាធិបតេយ្យ ។ បក្សកុម្មុយនីស្តម៉ាក្ស-លេនីន របស់សហរដ្ឋអាមេរិក និងអត្ថបទរបស់អ្នកដែលមានចំណងជើងថា «ដីក៏ ខល» បានបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវការគាំទ្រដល់កិច្ចខំប្រឹងប្រែងគ្រប់កិច្ចការងាររបស់យើងនៅក្នុងដំណាក់កាលថ្មីនៃបដិវត្តន៍កម្ពុជា ។

យើងសូមកោតសរសើរយ៉ាងស្មោះស្ម័គ្រនិងសូមអរគុណច្រើនចំពោះការគាំទ្រនេះ ។ ដំណើរទស្សនកិច្ចរបស់អ្នកគឺជាការជំរុញលើកទឹកចិត្តឲ្យយើងទាំងអស់គ្នា និងជាឱកាសមួយសម្រាប់ការស្វែងយល់គ្នាទៅវិញទៅមកដើម្បីបន្តពង្រឹងចំណងមិត្តភាពរវាងប្រជាជនកម្ពុជា និងប្រជាជនអាមេរិក ។

នៅក្នុងបរិយាកាសដ៏មហោឡារិកនេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យដល់ការអភិវឌ្ឍនៃចំណងមិត្តភាពរវាងប្រជាជនកម្ពុជានិងប្រជាជនអាមេរិក សុខភាពរបស់សមមិត្ត ម៉ៃឃើល ក្លូនស្គាយ មេដឹកនាំបក្សកុម្មុយនីស្តម៉ាក្ស-លេនីន របស់សហរដ្ឋអាមេរិក សុខភាពនិងការស្នាក់ដ៏ប្រសើរនៅក្នុងកម្ពុជាប្រជាធិបតេយ្យរបស់សមមិត្ត ដាញ៉ែល ប៊ីស្សៀ និងសមាជិកគណៈប្រតិភូទាំងអស់ និងសុខភាពសមមិត្តទាំងអស់ដែលមានវត្តមាននៅទីនេះ ។

# គម្រប់ខួបកងទ័ពកម្ពុជា

## *សុន្ទរកថារបស់ នួន ជា នៅក្នុងអង្គប្រជុំប្រារព្ធពិធីនៅភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៧*

**ដកស្រង់ចេញពីឯកសារស៊ុយអែដ D២៨៩៧៦**

*របាយការណ៍ដកស្រង់ចេញពីសន្ទរកថារបស់ នួន ជា ប្រធានរដ្ឋសភាតំណាងប្រជាជននៃគណៈមជ្ឈិមនិងជានាយករដ្ឋមន្ត្រីនាំមុខនៅក្នុងអង្គប្រជុំនៅថ្ងៃទី១៦ខែមករាដើម្បីប្រារព្ធពិធីគម្រប់ខួបកងទ័ពបដិវត្តន៍កម្ពុជា ។*

*នៅក្នុងឱកាសនេះ និងស្ថិតនៅក្នុងស្ថានភាពនាពេលបច្ចុប្បន្ន ខ្ញុំសូមលើកឡើងពីបញ្ហាសំខាន់ៗចំនួនពីរ ។ ទីមួយ ការប្រារព្ធគម្រប់ខួបកងទ័ពយើងដែលមានអាយុប្រាំបួនឆ្នាំរំឭកឲ្យយើងបានដឹងពីស្មារតីវីរភាពរបស់កងទ័ពបដិវត្តន៍របស់យើង ។ នាពេលបច្ចុប្បន្ននេះ យើងធ្វើការគិតគូពិចារណាដោយមនោសញ្ចេតនាជ្រាលជ្រៅនិងប្រកបដោយស្មារតីបដិវត្តន៍ចំពោះសមមិត្តជួរមុខ និងយុទ្ធជន យុទ្ធនារីនិងកម្មាភិបាលនៃកងទ័ពរបស់យើងដែលបានពលីគ្រប់បែបយ៉ាងសម្រាប់ការតស៊ូបដិវត្តន៍ដ៏លំបាកនិងស្មុគស្មាញ ដោយរងទុក្ខវេទនារហូតដល់រំដោះប្រទេសកម្ពុជាបានជាស្ថាពរ ដោយផ្តល់សិទ្ធិសេរីភាពដល់ប្រជាជនកម្ពុជាទាំងកម្មករនិងកសិករ ហើយនាំមកនូវភាពម្ចាស់ការលើប្រទេសជាតិនិងជោគវាសនារបស់យើងជារៀងរាបទៅ ។ ទីពីរ អ្វីដែលយើងគួរតែពិចារណានាឱកាសនេះគឺថា បើយើងគិតពីកងទ័ពបាតដៃទទេពីអតីកាលនិងស្ថានភាពកងទ័ពរបស់យើងនាពេលបច្ចុប្បន្ននេះ យើងគួរតែមានក្តីសោមនស្សរីករាយចំពោះគោលការណ៍របស់យើងពីព្រោះថា ប្រទេសកម្ពុជាមិនដែលមានកងទ័ពយោធាដ៏អង់អាចក្លាហានដូចកងទ័ពបដិវត្តន៍ពេលបច្ចុប្បន្ននេះទេ ។ កងទ័ពបដិវត្តន៍នេះគឺជាកងទ័ពដែលមានអត្តចរិតបដិវត្តន៍ពិតប្រាកដ អង់អាចក្លាហានមានសមត្ថភាព និងជាកងទ័ពដ៏អស្ចារ្យដែលស្មោះស្ម័គ្រនឹងអង្គការបដិវត្តន៍ប្រជាជនកម្មករ-កសិករយើង រដ្ឋអំណាចយើង និងទឹកដីជាទីស្រឡាញ់របស់យើង ។ កងទ័ពបដិវត្តន៍យើងត្រូវបានបង្កើតឡើង ពង្រីងពង្រីកនិងប្រែក្លាយពីកងកម្លាំងការពារសម្ងាត់មកជាកងឈ្លបកងទ័ពក្នុងតំបន់ដែលបានវាយប្រយុទ្ធក្នុងសង្គ្រាមឈ្លបសង្គ្រាមទ្រង់ទ្រាយធំ សង្គ្រាមផ្ទៃក្នុង និងសង្គ្រាមបដិវត្តន៍ប្រឆាំងនឹងពួកចក្រពត្តិអាមេរិក និងបរិវាររបស់វាដើម្បីរំដោះប្រទេសជាតិ និងប្រជាជនកម្ពុជារហូតដល់ថ្ងៃដែលយើងបានទទួលមហាជ័យជម្នះដ៏អស្ចារ្យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។*



នួន ជា កំពុងថ្លែងសុន្ទរកថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

*ជាមួយគ្នានេះ យើងក៏បានពង្រីង និងអភិវឌ្ឍកងទ័ពនេះទាំងផ្នែកនយោបាយ មនោគមន៍វិជ្ជា និងផ្នែកគ្រប់គ្រង ។ បច្ចុប្បន្ននេះ កងទ័ពរបស់យើងមានអត្តចរិតជាអ្នកស្នេហាបដិវត្តន៍ពិតប្រាកដ ។ នេះគឺជាកងទ័ពអង្គការពិតប្រាកដដែលក្នុងនោះរួមមានកងទ័ពជើងគោក កងទ័ពជើងទឹក និងកងទ័ពជើងអាកាសដែលបានការពារដែនដីដែនអាកាសនិងដែនទឹកកម្ពុជានិងទឹកដីទាំងមូលរបស់កម្ពុជាយើង ។ អស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ ប្រជាជនយើងមិនមានកងទ័ពដែលអាចប្រៀបធៀបនឹងកងទ័ពរបស់យើងនាពេល*

បច្ចុប្បន្ននេះទេ ។ ដោយយល់ច្បាស់ពីបញ្ហានេះ យើងមានមោទកភាព និងពេញចិត្តយ៉ាងខ្លាំងចំពោះប្រជាជនយើង កងទ័ពយើង និងអង្គការបដិវត្តន៍របស់យើងដែលបានប្រយុទ្ធតស៊ូមិនរាថយ ដើម្បីកសាងកម្ពុជាប្រជាធិបតេយ្យ ប្រជាកម្មករ-កសិករ រដ្ឋអំណាចបដិវត្តន៍ និងកងទ័ពបដិវត្តន៍ដ៏អង់អាច ហើយដែលពោរពេញដោយសមត្ថភាពនេះ ។

ដើម្បីជាការដឹងគុណដល់កងទ័ពរបស់យើង យើងខ្ញុំទាំងអស់គ្នាមិនថានៅខាងក្នុងឬខាងក្រៅ ត្រូវតែប្ដេជ្ញាចិត្តខ្លួនឯងធ្វើការចងចាំដល់យុទ្ធជនរបស់យើង និងប្រជាជនរបស់យើងក្នុងការបន្តវប្បធម៌ជាវីរជនដែលវាយប្រយុទ្ធដ៏អង់អាចក្លាហានក្នុងការតស៊ូពីមុនមក ដោយបន្តបំពេញកិច្ចការបដិវត្តន៍ដ៏ត្រឹមត្រូវរបស់ខ្លួននិងស្វែងរកដំណោះស្រាយល្អៗសម្រាប់កិច្ចការការពារនិងកសាងប្រទេសជាតិ ។ ប្រសិនបើយើងសម្រេចកិច្ចការនេះបានដោយយកចិត្តទុកដាក់បំផុត និងដោយស្មារតីទទួលខុសត្រូវខ្ពស់ យើងទាំងអស់គ្នាសូមសម្ដែងការដឹងគុណដល់វីរជនរបស់យើង ។ នេះគឺជាការប្ដេជ្ញាចិត្តរបស់យើង ។

នៅក្នុងឱកាសនេះផងដែរ យើងក៏បានសម្រេចបន្តពង្រឹង និងពង្រីកគោលជំហរបដិវត្តន៍របស់យើង ។ គ្រប់សកម្មភាពនិងកិច្ចការរបស់យើងទាំងអស់មិនថាធំមិនថាតូច យើងត្រូវតែប្រកាន់ខ្ជាប់នូវគោលជំហរតស៊ូនិងចាត់ទុកការប្ដេជ្ញាចិត្តនេះជាកម្លាំងជំរុញរបស់យើងជានិច្ច ។ យើងត្រូវតែប្រើប្រាស់ការប្ដេជ្ញាចិត្តនេះជាចងចាំដល់វីរជនរបស់យើងនេះធ្វើជាកម្លាំងជំរុញដើម្បីពង្រឹងឆន្ទៈរបស់យើង ។ យើងមានភាពខ្លាំងហើយ ប៉ុន្តែកម្លាំងជំរុញនេះអាចនឹងជួយឲ្យយើងមានភាពខ្លាំងប្រសើរជាងមុនទៀត ។

ហេតុអ្វីបានយើងសម្រេចកិច្ចការបដិវត្តន៍បាននៅក្នុងរបបសម័យថ្មីនេះ? យើងសម្រេចកិច្ចការទាំងនេះគឺដើម្បីលុបបំបាត់វណ្ណៈទាសករដែលមានអស់រយៈពេលច្រើនទសវត្សរ៍មកហើយ ។ យើងបានរំដោះប្រទេសជាតិយើងចេញពីភាពជាទាសករនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយប្រជាជនរបស់យើងត្រូវបានរំដោះនៅថ្ងៃនោះដែរ ។ យើងសម្រេចវាបានដើម្បីការពារកម្ពុជាប្រជាធិបតេយ្យ កម្មករកម្ពុជា និងកសិករសហករណ៍នៅក្នុងសតវត្សរ៍ ទសវត្សរ៍ និងសហសវត្សរ៍ និងរាប់ម៉ឺនឆ្នាំខាងមុខទៀតជារៀងរាប ។ យើងសម្រេចវាបានដើម្បីកសាងកម្ពុជាប្រជាធិបតេយ្យដោយជំហានលោតផ្លោះទៅមុខៗ ។ ទាំងអស់នេះហើយជាហេតុផលដែលយើងគួរតែបំពេញកិច្ចការរបស់យើង ។

តើនេះគឺជាមោទកភាពរបស់យើងមែនឬ? មែន នេះគឺជាមោទកភាពរបស់យើង ។ មហាជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បាននាំឲ្យប្រទេសជាតិប្រជាជន និងកងទ័ពរបស់យើងមកនូវមោទកភាពដ៏អស្ចារ្យដែលយើងត្រូវតែថែរក្សាពង្រឹងពង្រីកនិងការពារកុំឲ្យខូចខាតនិងបាត់បង់ឲ្យសោះ ។ ការសម្រេចកិច្ចការរបស់យើងគឺមានគោលដៅដំបូងគេបង្អស់គឺគោរពដល់យុទ្ធជននិងកម្មាភិបាលដ៏អង់អាចក្លាហានប្រុសស្រីរបស់យើងដែលបានពលីនិងទីពីរគឺការពារមោទកភាពជាតិនិងប្រជាជនយើងជារៀងរាបតទៅ ។

ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ គឺជាថ្ងៃកំណើតរបស់កងទ័ពបដិវត្តន៍កម្ពុជា ។ នៅដើមឆ្នាំ១៩៦៧ បក្ខពួកក្បត់ លន់ នល់ បានធ្វើសង្គ្រាមផ្ទៃក្នុងដោយគាបសង្កត់ បាញ់ប្រហារនិងសម្លាប់ប្រជាជនស្លូតត្រង់និងអ្នកស្នេហាជាតិនិងស្នេហាបដិវត្តន៍កម្ពុជាដ៏សាហាវព្រៃផ្សៃក្នុងសកម្មភាពជាប្រព័ន្ធនិងទ្រង់ទ្រាយធំ ។ ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ គឺជាថ្ងៃកងការពារសម្ងាត់របស់បដិវត្តន៍យើងត្រូវបានប្រែក្លាយជាកងឈ្លបដែលបានបង្គាប់បញ្ជាពីអង្គការបដិវត្តន៍របស់យើងឲ្យវាយប្រយុទ្ធនឹងគោលជំហររបស់ខ្មាំងនៅឯគ្រើយម្នាងស៊ីងសង្កែដែលមានចម្ងាយដប់មួយគីឡូម៉ែត្រពីខេត្តបាត់ដំបង គោលជំហររបស់បាយដំរីដែលយើងបានបំផ្លិចបំផ្លាញ ប្រមូលយកអាវុធខ្មាំងធ្វើជាកម្មសិទ្ធិរបស់យើង ។ នេះគឺជាការប្រមូលយកលើកទីមួយរបស់កងទ័ពយើង... ។

ការចាប់ផ្ដើមតស៊ូកងទ័ពនៅថ្ងៃទី១៧ ខែមករា ឆ្នាំ ១៩៦៨ គឺមិនមែនជាព្រឹត្តិការណ៍ដោយចៃដន្យនោះទេ ។ ចាប់តាំងពីឆ្នាំ១៩៦០មកអង្គការបដិវត្តន៍របស់យើងបានជ្រើសរើសមាគ៌ាខាងយុទ្ធសាស្ត្រនិងយុត្តិសាស្ត្រសម្រាប់បដិវត្តន៍ជាតិប្រជាធិបតេយ្យ ។ យើងបានដឹងថា ពួកចក្រពត្តិអាមេរិក បរិវាររបស់វា និងវណ្ណៈជិះជាន់ទាំងអស់បានប្រើប្រាស់អំណាចផ្ដាច់ការនិងកងកម្លាំងក្នុងគោលបំណងសម្លាប់និងវាយប្រហារលើប្រជាជនយើង ។ គោលជំហរ

របស់យើងគឺថាសកម្មភាពនយោបាយតែម្យ៉ាងមិនអាចជម្នះនឹងការវាយប្រហារនិងផ្តួលរលំពួកចក្រពត្តិអាមេរិកបរិវាររបស់វានិងវណ្ណៈជិះជាន់ទាំងអស់នោះបានទេ ។ ខ្មាំងបានប្រើប្រាស់កងទ័ពនិងមធ្យោបាយផ្តាច់ការរបស់វា ដែលបានគាបសង្កត់និងសម្លាប់ប្រជាជនយើង ។ ក្រោយពីឆ្នាំ១៩៦០មក អង្គការបដិវត្តន៍យើងបានម្រេចចិត្តយ៉ាងច្បាស់លាស់ថាសកម្មភាពនយោបាយនិងអំពើហិង្សាប្រដាប់អាវុធត្រូវតែយកមកអនុវត្តដើម្បីផ្តួលរលំនិងកម្ចាត់ពួកខ្មាំង ។ យើងត្រូវតែប្រែក្លាយកងកម្លាំងបដិវត្តន៍ទាំងនេះមកជាកងទ័ពបដិវត្តន៍ ។ បន្ទាប់ពីឆ្នាំ១៩៦១ យើងក៏បានចាប់ផ្តើមរៀបចំកងការពារសម្ងាត់របស់យើង ។

កងការពារសម្ងាត់ទាំងនោះត្រូវបានលាក់ខ្លួននៅតាមភូមិមូលដ្ឋាននិងទីប្រជុំជន ។ កងការពារសម្ងាត់ខ្លះមានប្រដាប់ដោយអាវុធ ប៉ុន្តែមួយភាគធំមានប្រដាប់ដោយកាំបិត ដំបង និងដុំថ្ម ។ កងការពារសម្ងាត់ទាំងនេះទៀតសោតមានកាតព្វកិច្ចការពារកម្មាភិបាល និងប្រជាជន ហើយវាយកម្ទាត់បណ្តាញស៊ើបការណ៍របស់ខ្មាំងនិងកងកម្លាំងរបស់ខ្មាំងផ្សេងៗដែលបានបង្កភាពច្របូកច្របល់ដល់ប្រជាជន... ។

ឆ្មាំការពារសម្ងាត់មួយចំនួនត្រូវបានបាត់បង់ដោយសារតែខ្មាំងបានចាប់ខ្លួន ។ យុទ្ធជនរបស់យើងបានបន្តសម្រេចកាតព្វកិច្ចរបស់ខ្លួនជាកងការពារសម្ងាត់ដើម្បីធានាសុវត្ថិភាពរបស់កម្មាភិបាលមន្ទីរយាមទីកន្លែងជួបប្រជុំរបស់យើង និងដើម្បីបំពេញតួនាទីជាអ្នកនាំសារ ។ កិច្ចការទាំងនេះគឺមានគ្រោះថ្នាក់បំផុត ។ កម្មាភិបាលរបស់យើងត្រូវតែផ្លាស់ទីពីភូមិមួយទៅភូមិមួយដើម្បីបំពេញកិច្ចការរបស់ខ្លួន ។ ប្រសិនបើគ្មានកងការពារសម្ងាត់នេះទេ កម្មាភិបាលរបស់យើងមិនអាចរួចរស់មានជីវិតបានទេ ។ យើងទាំងអស់គ្នាអាចនឹងត្រូវបានសម្លាប់ដោយខ្មាំង ។ ប៉ុន្តែកងការពារសម្ងាត់របស់យើងបានដឹងយ៉ាងច្បាស់ពីស្ថានភាពនៅក្នុងភូមិ និងឃុំ គោលជំហរនៃកងកម្លាំងយោធានិងកម្លាំងប៉ូលិសរបស់ខ្មាំង ។ កងការពារសម្ងាត់របស់យើងក៏បានដើរតួជាអ្នកត្រួសត្រាយផ្លូវឲ្យយើងដោយបំពេញកិច្ចការសំខាន់របស់កងទ័ពយើង ។ ជានិច្ចជាកាលកងការពារសម្ងាត់របស់យើងបានស្ម័គ្រចិត្តនាំផ្លូវកម្មាភិបាលរបស់យើងទៅគ្រប់ទីកន្លែងទាំងអស់ ។

ពីមួយឆ្នាំទៅមួយឆ្នាំ យើងបានពង្រីកកងការពារសម្ងាត់របស់យើង ។ ចាប់តាំងពីឆ្នាំ១៩៦១ដល់ឆ្នាំ១៩៦៦ មូលដ្ឋានបដិវត្តន៍ទូទាំងប្រទេសនិងនៅគ្រប់តំបន់ទាំងអស់សុទ្ធតែមានកងការពារសម្ងាត់របស់ខ្លួន ។ កងការពារនីមួយៗមានយ៉ាងហោចណាស់សមាជិកចំនួនបីនាក់ ។ កងការពារសម្ងាត់ទាំងនេះគឺជាកងស្នូលរបស់កងទ័ពយើង ។

ថ្ងៃកំណើតកងទ័ពបដិវត្តន៍របស់យើងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨មិនមែនកើតឡើងដោយចៃដន្យ ឬដោយប្រឌិតឡើយ ។ ថ្ងៃនោះគឺជាការចាប់ផ្តើមនៃចលនាតស៊ូជាប្រព័ន្ធនិងដ៏ជោគជ័យដែលដើរស្របតាមមាគ៌ាយុទ្ធសាស្ត្រនិងយុត្តិសាស្ត្ររបស់យើង ។ កងការពារសម្ងាត់បានចាប់កំណើតឡើងនៅថ្ងៃនេះ ។ កងការពារទាំងអស់នេះត្រូវបានប្រែក្លាយជាកងឈ្លបដែលបានចាប់ផ្តើមវាយប្រយុទ្ធដំបូងបង្អស់នៅខេត្តបាត់ដំបង និងធ្វើសង្រ្គាមឈ្លបទូទាំងប្រទេសកម្ពុជា ។ ខ្មាំងមិនអាចទប់ទល់នឹងកងកម្លាំងរបស់យើងបានទេ ។ ប្រសិនបើព្រឹត្តិការណ៍នេះកើតឡើងដោយចៃដន្យឬបើការវាយប្រយុទ្ធនេះអនុវត្តឡើងដោយគ្មានផែនការយុទ្ធសាស្ត្រនិងយុត្តិសាស្ត្រច្បាស់លាស់នោះ យើងអាចនឹងត្រូវបានពួកខ្មាំងកម្ទាត់ចោលទៅហើយ ។ តាមការពិត ខ្មាំងមិនអាចកម្ទាត់យើងបានទេ ពីព្រោះថានៅក្នុងឆ្នាំ១៩៦៨ បើទោះបីជាយើងមិនបានវាយដណ្តើមអាវុធពីពួកខ្មាំងឲ្យបានច្រើនក៏កត្តាសំខាន់ក្នុងការវាយប្រហារនេះគឺមិនមែនអាស្រ័យតែលើអាវុធម្យ៉ាងទេ តែជាក៏អាស្រ័យទៅលើការរួបរួមសាមគ្គីរបស់យើងទាំងអស់គ្នាប្រឆាំងនឹងខ្មាំងដែរ ។

ដូចដែលខ្ញុំបាននិយាយពីខាងដើម នៅដើមខែដំបូងយើងបានវាយប្រហារពួកខ្មាំងនៅភូមិភាគពាយព្យ ហើយនៅខែទីពីរយើងបានបន្តវាយប្រហារកម្លាំងខ្មាំងនៅភូមិភាគនិរតី ។ ក្រោយមកពួកខ្មាំងមិនអាចពង្រឹងកងកម្លាំងរបស់វានៅភូមិភាគពាយព្យបានទេ នៅពេលដែលការតស៊ូប្រដាប់អាវុធបានផ្ទុះឡើងនៅភូមិភាគបូព៌ា ពួកខ្មាំងបានចល័តកងកម្លាំងរបស់វាខ្លះទៅការពារសមរភូមិភូមិភាគបូព៌ា ។ នៅពេលដែលការតស៊ូប្រដាប់អាវុធបានរីករាលដាលដល់ភូមិភាគឦសាន ពួកខ្មាំងបានផ្លាស់កងកម្លាំងរបស់វាខ្លះទៅតំបន់នោះ ហើយទៅភូមិភាគឧត្តរ ។

នៅខែមេសា ឆ្នាំ១៩៦៨ កងឈ្លបរបស់យើងបានធ្វើសង្គ្រាមឈ្លបនៅតាមខេត្តចំនួនដប់ប្រាំពីរនៅក្នុងចំណោមខេត្តដប់ប្រាំបួនទាំងអស់ទូទាំងប្រទេស ។ ស្ថិតនៅក្រោមស្ថានភាពទាំងនេះ តើកងកម្លាំងរបស់ខ្មាំងអាចវាយប្រហារមកលើកងឈ្លបរបស់យើងនៅទូទាំងប្រទេសបានដែរឬទេ? ពួកខ្មាំងគឺពិតជាមិនអាចវាយប្រហារមកលើយើងបានឡើយ ។ មានតែកងកម្លាំងរបស់យើងតែប៉ុណ្ណោះដែលមានគោលជំហរវាយប្រយុទ្ធរហូត ។ ដូច្នេះ តើហេតុអ្វីបានជាខ្មាំងមិនអាចកម្ចាត់យើងបាន? មូលហេតុគឺដោយសារតែយើងមានរចនាសម្ព័ន្ធជាប្រព័ន្ធ ។ មានន័យថាកងទ័ពរបស់យើងត្រូវបានបង្កើតឡើងដោយមូលដ្ឋានយុទ្ធសាស្ត្រនិងយុត្តិសាស្ត្រដ៏ត្រឹមត្រូវមួយដោយរួមមាន ការបង្កើតជាកងសម្ងាត់ហើយក្រោយមកកងទ័ពទាំងនេះក៏ត្រូវបានសាកល្បងអនុវត្តយុទ្ធសាស្ត្ររបស់ខ្លួន ហើយវិវត្តទៅមុខរហូតមកដល់សព្វថ្ងៃនេះ ។

កងទ័ពនេះដែលត្រូវបានវិវត្តឡើងដោយចលនាបដិវត្តន៍គឺពិតជាមានឥទ្ធិពលខ្លាំងណាស់ ។ នាពេលនោះ យើងមិនមានអាវុធគ្រប់គ្រាន់ ហើយកងកម្លាំងរបស់មានចំនួនតិច ប៉ុន្តែមាគ៌ាដ៏ត្រឹមត្រូវនៃសង្គ្រាមប្រជាជនបានធ្វើឲ្យយើងទាំងអស់គ្នាមានភាពខ្លាំងក្លា ។ ជនទាំងឡាយណាដែលបានគោរពតាមមាគ៌ាអង្គការបានឆ្លងកាត់ដំណាក់កាលទាំងអស់នៃកងសម្ងាត់ត្រូវបានលុតដំនៅក្នុងចលនាយោធា ហើយបានស្រូបយកចំណេះដឹងស្តីពីវិធីសាស្ត្រធ្វើសង្គ្រាមឈ្លបរបស់អង្គការបដិវត្តន៍ ។ ប្រជាជនទាំងនេះគឺជាអនាគតមេដឹកនាំរបស់កងកម្លាំងនិងកងឈ្លបរបស់យើង ហើយក៏ជាកងទ័ពស្នូលរបស់យើងដែរ ។

តាមពិត កងទ័ពនេះមិនមែនកើតចេញពីតាមការហ្វឹកហាត់របស់មន្ទីរយោធាទេ ។ ជាក់ស្តែង កងទ័ពនេះកើតចេញពីចលនាតស៊ូបដិវត្តន៍មួយដែលបានចាប់ផ្តើមឡើងដោយបាតដៃទទេ ។ ប្រជាជនទាំងអស់នេះបានរួបរួមគ្នាដោយដើរតាមមាគ៌ារបស់អង្គការបដិវត្តន៍ ហើយចាប់យករាល់គោលជំហរទាំងអស់របស់អង្គការ ។ យើងត្រូវបានវាយប្រហារដោយខ្មាំងដោយបាតដៃទទេ ។ ប៉ុន្តែកងទ័ពរបស់យើងមានភាពខ្លាំងក្លាណាស់ ។ កងទ័ពមួយដែលវាយខ្មាំងដោយកាំភ្លើងធំនិងដោយប្រើប្រាស់គ្រាប់រំសេវច្រើនសន្ធឹកសន្ធាប់មិនខ្លាំងក្លានោះទេ ។

កងទ័ពដែលចាប់ផ្តើមដោយបាតដៃទទេ និងដោយឆ្លងកាត់ការតស៊ូបដិវត្តន៍ជាបន្តបន្ទាប់ ហើយវិវត្តខ្លួនឯងគឺជាកងទ័ពដែលមានអំណាចខ្លាំងក្លាមួយ ។ នេះគឺជាប្រវត្តិសាស្ត្ររបស់កងទ័ពយើង ។

យើងទាំងអស់គ្នាត្រូវតែស្រូបយកនិងស្វែងយល់ពីលក្ខណៈនិងលទ្ធផលរបស់បដិវត្តន៍យើង ។ នៅពេលដែលយើងទទួលបានមហាជ័យជម្នះលើពួកចក្រពត្តិអាមេរិក...យើងមិនមាននាវាឬកំនើនយន្តទេ ។ សម្រាប់កាំភ្លើងធំ យើងមានតែមួយចំនួនប៉ុណ្ណោះដែលយើងបានរឹបអូសពីខ្មាំង ។ កងទ័ពនេះ ក៏គ្មានយន្តហោះរថក្រោះឬកាំភ្លើងធំ ហើយថែមទាំងខ្វះខាតគ្រាប់រំសេវទៀតផង ។ ប៉ុន្តែការវាយប្រហាររបស់យើងទទួលបានជោគជ័យ ។ យើងត្រូវតែចងចាំរាល់ព្រឹត្តិការណ៍នេះដើម្បីឲ្យយើងដឹងថា កងទ័ពនេះមានកម្លាំងខ្លាំងក្លាណាស់ ។ តើហេតុអ្វីបានជាកងទ័ពនេះមានកម្លាំងខ្លាំងម៉្លេះ? មនោគមន៍វិជ្ជា គោលនយោបាយ ការដឹកនាំនិងយុត្តិសាស្ត្រវាយប្រហារដ៏ត្រឹមត្រូវនិងខ្លាំងក្លាទាំងអស់នេះ ហើយដែលធ្វើឲ្យកងទ័ពនេះមានភាពខ្លាំងក្លា ។ ការយល់ដឹងពីប្រវត្តិសាស្ត្រនៃកងទ័ពនេះធ្វើឲ្យយើងបានដឹងពីឥទ្ធិពលនិងអំណាចរបស់កងទ័ពបដិវត្តយើង ។ ប្រសិនបើយើងពង្រឹង និងពង្រីកកងទ័ពនេះឲ្យស្របតាមនិន្នាការនេះ នោះគ្មានខ្មាំងណាអាចយកឈ្នះយើងបានទេ ។ កងទ័ពរបស់យើងមិនដែលឈ្លានពានលើប្រទេសណាមួយឡើយ ។ ប៉ុន្តែនៅក្នុងព្រឹត្តិការណ៍នៃការឈ្លានពានដោយប្រទេសផ្សេងវិញកងទ័ពនិងប្រជាជនរបស់យើងអាចវាយប្រយុទ្ធបានអស់រយៈពេលជាច្រើនឆ្នាំឲ្យតែយើងទាំងអស់គ្នាគោរពតាមមាគ៌ានេះ ។ ប្រសិនបើយើងមានយន្តហោះ នាវាចម្បាំងរថក្រោះ កាំភ្លើងធំ ប៉ុន្តែមិនគោរពតាមគោលការណ៍របស់សង្គ្រាមប្រជាជននិងមាគ៌ាយោធារបស់អង្គការបដិវត្តន៍នោះ យើងនឹងមិនអាចមានកងទ័ពមួយដ៏ខ្លាំងក្លាដែលបានធ្វើការតស៊ូប្រឆាំងពួកចក្រពត្តិអាមេរិកហើយ កងទ័ពនោះក៏មិនអាចមានភាពខ្លាំងក្លាខណៈពេលដែលយើងគ្មានយន្តហោះ រថក្រោះ និងនាវាចម្បាំងដែរ ។ ដោយសារមូលហេតុនេះ យើងត្រូវតែចងចាំការវាយប្រយុទ្ធរបស់យើងប្រឆាំងនឹងពួកចក្រពត្តិអាមេរិក ។

តើនេះឬជាទីបញ្ចប់នៃភារកិច្ចរបស់កងទ័ពយើង? តើកងទ័ពនេះគួរតែបន្តបំពេញកិច្ចការរបស់ខ្លួនទៀតដែរឬទេ? គុណភាពនៃកងទ័ពនេះបានឈានទៅដល់ដំណាក់កាលបច្ចុប្បន្ននេះរួចហើយ ។ តើយើងគួរតែបញ្ចប់ត្រឹមដំណាក់កាលនេះ ឬក៏យើងគួរតែបន្តទៅមុខទៀត? យើងគួរតែមានមោទកភាព ហើយពេញចិត្តនឹងគុណភាពនៃកងទ័ពរបស់យើង ។ យើងត្រូវតែខិតខំកសាងពង្រឹងពង្រីក និងអភិវឌ្ឍកងទ័ពនេះហើយធ្វើឲ្យកងទ័ពនេះមានសមត្ថភាពក្នុងការការពារ និងកសាងប្រទេស ។

បទពិសោធន៍អតីតកាលបង្ហាញឲ្យឃើញថា យើងបានអនុវត្តតាមគោលការណ៍បដិវត្តន៍របស់យើងយ៉ាងរលូន ហើយការរំដោះជាតិនិងកិច្ចការការពារ និងកសាងប្រទេសត្រូវបានធ្វើឡើងដោយស្មារតីម្ចាស់ការលើខ្លួនឯង ។ នៅក្នុងអំឡុងវេលាគ្រោះដោយការបំផ្លិចបំផ្លាញដោយពួកចក្រពត្តិអាមេរិកកាលពីប្រាំឆ្នាំកន្លងទៅនេះ យើងអាចដោះស្រាយបញ្ហាសេដ្ឋកិច្ចបាន ។ យើងមិនដែលនាំចូលស្រូវទេ ។ យើងអាចធានាបាននូវការខបត្ថម្ភខ្លួនឯង ។ ក្រោយសង្គ្រាមយើងបានប្រឈមមុខនឹងឧបសគ្គខ្លះ ។ ប៉ុន្តែបញ្ហាទាំងនោះត្រូវបានដោះស្រាយរួចរាល់អស់ហើយ ។ បន្ទាប់មក យើងក៏ជួបនឹងបញ្ហាមួយទៀត ។ តើយើងអាចដោះស្រាយបញ្ហាមួយទៀតនេះដោយរបៀបណា? តើយើងបានសម្រេចគម្រោងឆ្នាំ១៩៧៦របស់យើងបានឬនៅ? តើយើងអាចអនុវត្តគោលការណ៍របបអាហារដែលរៀបចំឡើងដោយរដ្ឋបានដែរឬទេ? គោលការណ៍ទីមួយ គឺផ្ដល់របបអង្ករចំនួនសាមសិបគីឡូឲ្យប្រជាជនម្នាក់ ។ គោលការណ៍ទីពីរគឺម្ភៃគីឡូ និងគោលការណ៍ទីបីគឺម្ភៃគីឡូ ។ យោងតាមរបាយការណ៍ដែលទទួលនៅដើមខែនេះពីភូមិភាគនីមួយៗ ហើយបើយោងតាមការស្រាវជ្រាវរបស់យើងក្រោយពីដំណើរទស្សនកិច្ចតាមមូលដ្ឋានទាំងអស់ យើងបានដឹងថាគោលការណ៍របបអាហារនេះមានលក្ខណៈសមហេតុផល ។ ជារួម ប្រជាជនកម្ពុជាម្នាក់ទទួលបានអង្ករបីរយដប់ពីរគីឡូសម្រាប់បរិភោគក្នុងរយៈពេលមួយឆ្នាំ ។ នេះគឺជាចំនួនអង្ករដ៏ច្រើន ។ ស្ថានភាពរស់នៅរបស់ប្រជាជនយើងបានវិវត្តពីមួយឆ្នាំទៅមួយឆ្នាំ ។ម្យ៉ាងវិញទៀត ប្រជាជនយើងមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ ។ យើងបានស្តុកទុកអង្ករពីរតោនឲ្យប្រជាជនម្នាក់ៗសម្រាប់ឆ្នាំ១៩៧៧ ។ ស្របពេលជាមួយគ្នានោះ យើងមានទិន្នផលស្រូវលើសរហូតដល់ទៅមួយសែនប្រាំម៉ឺនតោនសម្រាប់ការនាំចេញ ។ នេះមានន័យថា យើងបានសម្រេចផែនការសម្រាប់ឆ្នាំ១៩៧៦របស់យើងបានដោយជោគជ័យ ។

ផលិតកម្មកៅស៊ូបានកើនឡើងស្របទៅតាមផែនការឆ្នាំ១៩៧៦ ហើយផលិតកម្មធញ្ញជាតិ និងដំណាំកសិកម្មបែបឧស្សាហកម្មផ្សេងទៀតក៏បានកើនឡើងដែរ ។ ជោគជ័យទាំងអស់នេះគឺសម្រេចបានដោយប្រជាជនរបស់យើងបើទោះបីជាយើងបានប្រឈមមុខនឹងឧបសគ្គរាប់មិនអស់ដែលជាលទ្ធផលនៃការបំផ្លិចបំផ្លាញដោយសារសង្គ្រាមក៏ដោយ ។ យើងត្រូវតែថែរក្សាគោលដៅនិងគោលជំហររបស់យើងជាដាច់ខាតដោយពង្រឹងនិងពង្រីកគោលជំហរនេះដើម្បីការពារជាតិនិងកិច្ចការកសាងជាតិនាពេលអនាគត ។ ខណៈពេលយើងនឹងមានបទពិសោធន៍ច្រើននោះភាពខ្លាំងរបស់យើងនឹងកើនឡើងទៅតាមនោះដែរ ។

ស្ថានភាពសម្រាប់បដិវត្តន៍កម្ពុជារបស់យើងបានកំពុងតែវិវត្តទៅមុខ ហើយវាកាន់តែរឹងមាំជាងមុននិងអភិវឌ្ឍទៅមុខគ្រប់វិស័យទាំងអស់ ។ នេះគឺជាស្ថានភាពបច្ចុប្បន្ន ហើយទស្សនវិស័យសម្រាប់បដិវត្តន៍កម្ពុជានៅក្នុងឆ្នាំ១៩៧៧នេះល្អប្រសើរជាងឆ្នាំ១៩៧៦ ។ សូមជូនពរឲ្យសមមិត្តយុទ្ធជន យុទ្ធនារី និងកម្មាភិបាលកងទ័ពបដិវត្តទាំងអស់មិនថានៅដីគោកឬជើងទឹកឲ្យមានសុខភាពមាំមួន និងសម្រេចបានជោគជ័យនៅពេលបំពេញកិច្ចការរបស់ខ្លួនក្នុងដំណាក់កាលថ្មីនៃបដិវត្តន៍របស់យើង ដើម្បីការពារនិងកសាងកម្ពុជាប្រជាធិបតេយ្យ ។


នួន ជា ក្នុងក្រុបសវនាការខែធ្នូ ឆ្នាំ២០១១(រូបថត អ.វ.ត.ក)



កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១១ មួយ
សំណុំរឿង០០២ចាប់ផ្តើម ដើមបណ្តឹងរដ្ឋប្ប
០០២បានជួបប្រជុំគ្នានៅវាលពិឃាតជើ
ដើម្បីគោរពវិញ្ញាណក្ខន្ធដល់អ្នកដែលបានស្លាប
និងដើម្បីជំរុញតុលាការដំណើរការទៅមុខឲ្យ
ដល់អ្នកដែលបានស្លាប់ និងអ្នកដែលធ្លាប់ឆ្ល
បណ្តឹងរដ្ឋប្បវេណីក៏បានស្នើឲ្យភាគីរបស់ខ្
សវនាការដែរ ។







១១ មួយថ្ងៃមុនសវនាការលើអង្គសេចក្តីក្នុង
ណ្តឹងរដ្ឋប្បវេណីចំនួន១៦០នាក់ក្នុងសំណុំរឿង
ាឃាតជើងឯកដើម្បីធ្វើពិធីបង្សុកូលមួយ
ប បានស្លាប់កាលពីរបបកម្ពុជាប្រជាធិបតេយ្យ
រទៅមុខឲ្យបានលឿនដើម្បីស្វែងរកយុត្តិធម៌
លធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ។ ភាគីដើម
ាគីរបស់ខ្លួនមានឱកាសនិងនិយាយនៅក្នុង









# “ខ្ញុំមានវិប្បដិសារីសាមសិបពីរឆ្នាំព្រោះខ្ញុំបានសម្លាប់មនុស្ស”

ឈឹម ផន ធ្លាប់ធ្វើជាគណៈឃុំព្រះនេត្រព្រះនៅក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់១៩៧៩ ។ សាមសិបឆ្នាំបានកន្លងផុតទៅ ទើបតែថ្មីៗនេះ ផន បានសារភាពថាគាត់គឺជាអ្នកសម្លាប់គូសង្សារមួយគូដោយផ្ទាល់ដៃនៅខាងមុខទីធ្លាវត្តព្រះនេត្រព្រះនៅក្នុងឆ្នាំ១៩៧៧ដែលបានចោទថា អ្នកទាំងពីរនោះបានប្រព្រឹត្តខុសសីលធម៌ ។ ផន បានអះអាងថា តា សំអាត ដែលជាគណៈស្រុកព្រះនេត្រព្រះអ្នកបញ្ជាឲ្យគាត់សម្លាប់អ្នកទាំងពីរនៅក្នុងពិធីមិទ្ទីងមួយដែលមានការចូលរួមពីគណៈស្រុកព្រះនេត្រព្រះរួមមាន តាម៉ោង, តាសំអាត, តាខូ និង តាក្រក ប្រធានឃុំព្រះនេត្រព្រះ ។

លើសពីនេះទៅទៀត ខ្មែរក្រហមបានកោះហៅប្រជាជនរាប់រយនាក់នៅក្នុងឃុំទាំងមូលឲ្យមកមើលការសម្លាប់គូសង្សារនេះដើម្បីចង់ព្រមានដល់បុរសនារីផ្សេងទៀតកុំឲ្យយកគំរូតាម ប្រសិនបើនរណាហ៊ានប្រព្រឹត្តខុសពីបទបញ្ជារបស់ខ្មែរក្រហមនឹងមានវាសនាមិនខុសពីអ្នកទាំងពីរនេះទេ ។ អ្នកចូលរួមមើលការសម្លាប់នេះ រួមមានលោក ឆាំង យុ ដែលក្នុងសម័យនោះលោកមានអាយុ១៤ឆ្នាំ ហើយរស់នៅក្នុងភូមិត្រពាំងវែងនៅក្នុងឃុំព្រះនេត្រព្រះនេះដែរ ។


ឈឹម ផន នៅសាលាក្តីខ្មែរក្រហមខែវិច្ឆិកា ឆ្នាំ២០១១

សព្វថ្ងៃ ផន មានអាយុ៧២ឆ្នាំរស់នៅក្នុងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ ផន មានស្រុកកំណើតនៅក្នុងស្រុកកោះធំ ខេត្តកណ្តាល ។ កើតនៅក្នុងត្រកូលកសិករ ផន មានតែប្អូនស្រីម្នាក់ ។ ប្អូនស្រីនេះជាអ្នករកប្រាក់មកជួយឧបត្ថម្ភដល់ការរៀនសូត្ររបស់ ផន បន្ទាប់ពីម្តាយនិងឪពុកបានស្លាប់បាត់បង់ជីវិតទៅ ។ ផន រៀនដល់ថ្នាក់ទី៣នៅវិទ្យាល័យព្រះយុគន្ធរនាទីក្រុងភ្នំពេញក្នុងជំនាន់សង្គមរាស្ត្រនិយម ។ ផន បានស្នាក់នៅកុដអាចារ្យ ឆិ ក្នុងវត្តលង្កា ។ ផន បានឈប់រៀននៅ ឆ្នាំ១៩៦២ ដោយសារមិនមានប្រាក់គ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ដល់ការរៀនសូត្រ ។

បន្ទាប់ពីឈប់រៀន ផន បានទៅរកការងារធ្វើជាកម្មករជីកត្បូងនៅខេត្តប៉ៃលិនតាមរយៈការណែនាំរបស់មិត្តភក្តិ ប៉ុន្តែមិនទាន់បានទៅដល់ប៉ៃលិនផង ផន បានជួបគ្រួសារខ្មែរចិនមួយនៅក្នុងស្រុករតនៈមណ្ឌលហើយ ផន បានសម្រេចចិត្តនៅស៊ីឈ្នួលធ្វើការងារផ្ទះវិញដោយទទួលបានកម្រៃប្រាំមួយរយរៀលក្នុងមួយខែ ។ ដោយ ផន ធ្លាប់បានរៀនដល់ថ្នាក់ទី៣នោះ ផន បានបង្រៀនភាសាខ្មែរនិងភាសាបារាំងដល់កូនចិនដែលខ្លួនរស់នៅបម្រើដើម្បីរកប្រាក់បន្ថែម ។ រស់នៅទីនោះបានរយៈតែបីខែ ផន បានផ្លាស់ទៅធ្វើការនៅចម្ការមួយទៀតដែលមានឈ្មោះថា រស្មីសង្ហា នៅឃុំដំណាក់ស្តៅក្នុងស្រុករតនៈមណ្ឌលនេះដែរ នៅទីនោះ ផន ធ្វើជាកម្មករជម្រះស្មៅ ក្នុងចម្ការក្រូច ពោតនិងសណ្តែក ។ ធ្វើការបានមួយរយៈ ផន បានចាប់ចិត្តស្រឡាញ់ក្មួយរបស់ម្ចាស់ចម្ការ ។ អ្នកទាំងពីរបានរៀបការនៅឆ្នាំ១៩៧០ ។ ប្រពន្ធរបស់ ផន ឈ្មោះ ដួន រិន ។ បន្ទាប់ពីរៀបការ ផន បានសុំថៅកែមករស់នៅបែកដោយប្រកបរបរដាំបន្លែនៅក្នុងឃុំទឹកពុះ ។

នៅឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពេលនោះសង្គ្រាមបានកើតឡើង ហើយកម្លាំងខ្មែរក្រហមក៏បានប្រមូលផ្តុំនិងមានចំនួនកាន់តែកើនឡើង ។ ផន រកស៊ីដាំបន្លែបានតែមួយឆ្នាំ ខ្មែរក្រហមបានចូលមកដល់ស្រុកភូមិដែល ផន រស់នៅ ហើយបានចាត់តាំង ផន ឲ្យធ្វើប្រធានសេដ្ឋកិច្ចពីព្រោះ ផន ជាអ្នកដាំបន្លែ ។ ចំណែកខាង

រដ្ឋាភិបាល លន់ នល់ បានចាត់ឲ្យ ជន ធ្វើមេហាសិបខ្នង (មេក្រុម) ។ ជន មិនចង់ធ្វើជាមេហាសិបខ្នងរបស់ លន់ នល់ ហើយ ក៏មិនចង់ចូលរួមជាកម្លាំងជាមួយខ្មែរក្រហមដែរ ។ ដូច្នេះ ជន និងគ្រួសារបានភៀសខ្លួនទៅនៅឪម៉ាល់ផ្លូវកាត់ដែលជាស្រុកកំណើតខាងប្រពន្ធ ។ ជន គិតថាបើបន្តរស់នៅទីនេះអាចនឹងមានគ្រោះថ្នាក់ដល់អាយុជីវិត ។ ពេលទៅដល់ភូមិឪម៉ាល អ្នកស្រុកនៅទីនោះបាននាំគ្នាចូលរួមជាមួយខ្មែរក្រហមទាំងអស់ហើយអ្នកភូមិគេបានចូលទៅក្នុងព្រៃដើម្បីតស៊ូ ។ ដូច្នេះ ជន បានសម្រេចចិត្តចូលជាមួយខ្មែរក្រហមនៅចុងឆ្នាំ១៩៧១ ។ ជន ត្រូវបានចាត់តាំងឲ្យធ្វើការខាងរកម្ហូបនិងទឹកឃ្មុំសម្រាប់ក្រុមដែលមានសមាជិកប្រមាណដប់គ្រួសារ ។ ចំណែកប្រពន្ធរបស់ ជន ត្រូវធ្វើការខាងដកស្ទូង និងច្រូត ។

នៅឆ្នាំ១៩៧៤ ជន ត្រូវបានបញ្ជូនឲ្យទៅនៅខាងភូមិកៀនស្វាយក្បែរជងស្ទឹងមង្គលបុរី ។ នៅទីនោះ មានកម្លាំងចម្រុះរបស់ខ្មែរក្រហមប្រមាណជា៤១០០នាក់ ។ នៅដើមឆ្នាំ១៩៧៥ ជន ត្រូវបានចាត់តាំងឲ្យនៅក្នុងក្រុមឃ្វាលគោដែលមានមនុស្សចំនួន១៤ទៅ១៥នាក់ ដើម្បីឃ្វាលគោចំនួន៥០ទៅ៦០នឹម ។ ជន បាននិយាយថា មុនពេលបែកទីក្រុងភ្នំពេញមួយថ្ងៃស្រាប់តែមានកងស្មាយត្រាណរបស់ លន់ នល់ មួយក្រុមបានចូលមកចាប់កៀងគោយកទៅទាំងអស់ ។ ពេលនោះ ជន និងសមាជិកឃ្វាលគោដទៃទៀតភ័យយ៉ាងខ្លាំង ហើយមេក្រុមម្នាក់បានទៅរាយការណ៍ប្រាប់ថ្នាក់លើរបស់ខ្មែរក្រហម ប៉ុន្តែមេក្រុមនោះមិនត្រូវបានស្ដីបន្ទោសអ្វីឡើយ ។ ជន រៀបរាប់ថា «ប្រធានគេអត់ថាអីទេ ហើយគេប្រាប់ថាកុំភ័យ យើងវ៉ៃយកភ្នំពេញបានអស់ហើយ មិនបាច់ភ័យអីទៀតទេ ចាំយើងទៅប្រមូលយកមកវិញឲ្យអស់ទៅ « អានេះ យើងនិយាយទៅតាមភាសារបស់គេណា!» ។

ពេលខ្មែរក្រហមទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ ជន និងអ្នកឯទៀតបានត្រឡប់មករស់នៅភូមិឪម៉ាល់ផ្លូវកាត់វិញ ។ ជន បានដឹងឮថាអ្នកដែលបានចេញទៅតស៊ូនៅក្នុងព្រៃពេលដែលត្រឡប់មកវិញត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានពួក, ក្រុម, ភូមិ និងឃុំស្ទើរតែគ្រប់ៗគ្នា ។ នៅទីនោះមានរៀបចំប្រជុំចំនួនបីថ្ងៃដែលមាន តា ក្រុក ដែលជាអតីតកងទ័ពស្រុកព្រះនេត្រព្រះជាអ្នកដឹកនាំប្រជុំ ។ ដោយ តា ក្រុក ធ្លាប់ស្គាល់ ជន កាលនៅឃ្វាលគោនៅក្នុងព្រៃនោះ តា ក្រុក បានហៅ ជន ឲ្យមកធ្វើការជាមួយ ។ ម្យ៉ាងដោយសារ ជន ចេះអក្សរជ្រៅជ្រះជងនោះ តាក្រុក បានចាត់តាំង ជន ឲ្យធ្វើជាប្រធានភូមិមួយនៅក្នុងស្រុកក្រឡាញ់ ប៉ុន្តែនៅមិនទាន់ដឹងច្បាស់ថានៅភូមិណានៅឡើយទេ ។ នៅទីនោះបានតែពីរថ្ងៃ តា ក្រុក បានផ្លាស់មកធ្វើជាប្រធានឃុំព្រះនេត្រព្រះក្នុងស្រុកព្រះនេត្រព្រះ ហើយ តាក្រុក បានហៅ ជន ឲ្យមកធ្វើជាគណៈឃុំព្រះនេត្រព្រះជាមួយដែរ ។ តា ក្រុក ជាប្រធាន, តា សន ជាអនុប្រធាន និង ជន ជាសមាជិក ។ តា ក្រុក ជាអ្នកគ្រប់គ្រងការងារទូទៅ ចំណែក តា សន តែងតែដើរធ្វើការជាមួយ តា ក្រុក ។ ចំណែក ជន ទទួលជាអ្នកសរសេររបាយការណ៍និងចុះពិនិត្យមើលកងភ្ជួរ ។ ជន បានរៀបរាប់ថា «ខ្ញុំមិនសូវដឹងអំពីរឿងរ៉ាវដែលទាក់ទងនឹងនយោបាយរបស់អង្គការថ្នាក់លើនោះទេ ហើយមួយរយៈក្រោយមកទៀតមានឈ្មោះ តា ចាម ម្នាក់ទៀតដែលមានខ្សែរយៈមកខាងតំបន់៥ត្រូវបានចាត់តាំងឲ្យមកធ្វើជាសមាជិកនៅឃុំព្រះនេត្រព្រះដែរ ។ តា ចាម តែងតែដើរធ្វើការជាមួយ តា ក្រុក និង តា សន ដែរ» ។ នៅពេលប្រជាជនថ្មីដែលខ្មែរក្រហមជម្លៀសមកពីកន្លែងផ្សេងៗមក ជន គឺជាអ្នកកត់ឈ្មោះនិងសរសេររបាយការណ៍ ប៉ុន្តែគាត់មិនដឹងថា តាក្រុក បែងចែកឲ្យប្រជាជនទាំងនោះធ្វើការងារយ៉ាងម៉េចៗនោះទេ ពីព្រោះគាត់ធ្វើអ្វីតាមតែបញ្ជាតែប៉ុណ្ណោះ ។ គណៈស្រុកព្រះនេត្រព្រះនៅពេលនោះមាន តា ម៉ោង, តា សំអាត និង តា ខូ ។ ជន បាននិយាយទៀតថា «ខ្ញុំត្រូវបាន តា ក្រុក បញ្ជូនឲ្យទៅមើលការខុសត្រូវខាងការងារលើកទំនប់នៅអាងត្រពាំងថ្មប្រហែលមួយឆ្នាំ ដូច្នេះខ្ញុំមិនសូវដឹងថានៅក្នុងភូមិឃុំនេះមានរឿងអ្វីខ្លះកើតឡើងនោះទេ» ។

នៅក្នុងឆ្នាំ១៩៧៧ ស្ថានភាពមានការច្របូកច្របល់ដោយសារមានការមិនទុកចិត្តគ្នា មេដឹកនាំក្នុងឃុំនិងស្រុកត្រូវបានចាប់ខ្លួននិងសម្លាប់ ខណៈពេលដែលពួកនិរតីបានចូលមកកាន់នៅតំបន់៥ ។ តា ក្រុក ត្រូវបានចាប់ខ្លួននៅខែវស្សាឆ្នាំ១៩៧៧ ចំណែកអ្នកដែលពាក់ព័ន្ធក៏ត្រូវបានគេចាប់ខ្លួនយកទៅមួយចំនួនដែរ ។ តា សន ដែលជាអនុឃុំត្រូវបានសម្លាប់មុនពេលចាប់ខ្លួន តាក្រុក ដោយសារបានប្រព្រឹត្តខុសសីលធម៌ ។ តា ម៉ោង, តា សំអាត និង

តា ខូ ដែលជា គណៈស្រុកព្រះនេត្រព្រះ ក៏ត្រូវបានហៅយកទៅរៀនសូត្របន្តបន្ទាប់ ហើយមិនបានឃើញត្រឡប់មកវិញឡើយ ។ ដោយឡែក ផន មិនត្រូវបានគេចាប់យកទៅជាមួយ តា ក្រុក ទេ តែត្រូវបានបញ្ជូនទៅនៅភ្នំលៀប ដើម្បីដឹកនាំប្រជាជនធ្វើការខាងទំនប់នៅស្ពានស្រែងមានកម្លាំង៣០នាក់ ។ ក្រោយមក យាយ ចែម បានមកទទួលជាគណៈស្រុកជំនួស តា ម៉ោង ។ ចំណែកឃុំព្រះនេត្រព្រះត្រូវជំនួសដោយ តា ណុញ និងនារី ថា ។ ចំណែក ផន នៅរក្សាតួនាទីដដែល និងត្រូវបានចាត់តាំងឲ្យទៅមើលការងារខាងកងចល័ត ។ ផន នៅចាំបានថា ពេលមួយដែលជារដូវដកស្ទូងសភាពការណ៍កាន់តែអាក្រក់ទៅ ដោយសារកងទ័ពវៀតណាមជិតចូលមកដល់ អ៊ឹម ចែម លេខាស្រុកព្រះនេត្រព្រះដឹកនាំប្រជុំដោយមានការចូលរួមចាប់តាំងពីប្រធានក្រុមឡើងទៅនិងមានខាងទ័ពស្រុកបានមកចូលរួមនៅផ្ទះរបស់ យាយ ចែម ។ ពេលនោះ យាយ ចែម បាននិយាយថា «តើមិត្តណាដែលស្ម័គ្រចិត្តទៅច្បាំងជាមួយយួនសូមលើកដៃ» នៅខណៈនោះ អ្នកដែលចូលរួមបានលើកដៃទាំងអស់គ្នា ។ ប៉ុន្តែក្រោយមក យាយ ចែម មិនបានបញ្ជូនទៅវៃយួនតាមផែនការនោះទេ ។ បន្ទាប់ពីប្រជុំចប់ ផន បានត្រឡប់មកឃុំព្រះនេត្រព្រះដើម្បីប្រមូលផលស្រូវវិញ ទោះបីជាទិន្នផលស្រូវដែលប្រមូលបានមានចំនួនច្រើនក៏ដោយ ប៉ុន្តែប្រជាជននៅតែហូបចុកមិនគ្រប់គ្រាន់ សូម្បីតែ ផន ផ្ទាល់ក៏តម្រូវឲ្យហូបបបរមួយកាតូមានគ្នាពី៥ ទៅ៧នាក់ដូចប្រជាជនធម្មតាដែរលើកលែងតែពេលទៅប្រជុំម្តងៗទើប ផន បានហូបបាយ ។ ផន បានបញ្ជាក់បន្ថែមថា ទោះបីជានៅជំនាន់នោះគាត់មានតួនាទីជាសមាជិកឃុំពិតមែន ប៉ុន្តែមិនសូវមានអ្នកណាមករវីរវល់ជាមួយគាត់ទេ ដូច្នេះកិច្ចការភាគច្រើនគាត់មិនបានដឹងឡើយ ។

នៅពេលកងទ័ពវៀតណាមចូលមកនៅឆ្នាំ១៩៧៩ ផន បានភៀសខ្លួនទៅជាមួយ តា ណុញ នារីថា និងកងទ័ពជាច្រើននាក់ទៀតទៅនៅតំបន់ព្រៃមាន់ ។ នៅពេលមានការច្បាំងគ្នាកាន់តែខ្លាំង ផន បានបន្តទៅលាក់ខ្លួននៅជួរភ្នំដងរែក ។ បន្ទាប់មក ផន បានចូលទៅរស់នៅក្នុងជំរំសាយអេច ។ នៅឆ្នាំ១៩៩៣ប្រជាជនបានធ្វើមាតុភូមិនិវត្តន៍មកកាន់ស្រុកកំណើតរៀងៗខ្លួនវិញ ។ ប៉ុន្តែ ផន បានសម្រេចចិត្តបន្តរួមរស់នៅជាមួយខ្មែរក្រហមរស់នៅក្នុងស្រុកម៉ាឡៃរហូតដល់បច្ចុប្បន្ន ។

នៅថ្ងៃបើកសវនាការបឋមលើសំណុំរឿង០០២ទៅលើជនជាប់ចោទបីនាក់រួមមាន នួន ជា, ខៀវ សំផន និង អៀង សារី គឺជាលើកទីមួយហើយដែល ផន មានឱកាសបានមកឃើញតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដោយផ្ទាល់ភ្នែក ។ គាត់មានការសប្បាយរីករាយនៅក្នុងចិត្តក្រៃលែងចំពោះវត្តមានរបស់គាត់នៅឯតុលាការបន្ទាប់ពីបាននិយាយនូវរឿងរ៉ាវពិតដែលបានលាក់ទុកនៅក្នុងចិត្តអស់រយៈពេលជាងសាមសិបឆ្នាំ ក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំ ។ ផន មានវិប្បដិសារីដែលបានសម្លាប់គូសង្សារទាំងពីរ ហើយខឹងសម្បាចំពោះមេដឹកនាំខ្មែរក្រហមដែលបានធ្វើឲ្យគាត់ក្លាយទៅជាឃាតករបែបនេះ ។ ផន និងអ្នកស្រុកជាច្រើនទៀតត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជានាំមកសង្កេតដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលជាដំណើរការផ្សះផ្សាមួយរវាងជនដៃដល់និងជនរងគ្រោះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។



ឈីម ផន និង ឆាំង យុ

**ឆាយ ឈុនលី**

# សវនាការលើករណី០០២ចាប់ផ្តើម
## ព្រះរាជអាជ្ញាធ្វើសេចក្តីថ្លែងការណ៍ចោទប្រកាន់

នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១នេះ សវនាការជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ផ្តើមដំណើរការសវនាការលើសំណុំរឿង០០២ ដែលសាធារណជនទូទៅបានទន្ទឹងរង់ចាំជាយូរនិងមានសារសំខាន់បំផុត ។ នៅក្នុងករណី០០២នេះ ជនជាប់ចោទទាំងបីរូប នួន ជា, អៀង សារី និង ខៀវ សំផន គឺជាមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់បំផុតដែលនៅរស់រានមានជីវិត ។ ជុំវិញបរិវេណតុលាការទាំងមូលពោរពេញទៅដោយក្តីរំពឹងទុកក្នុងថ្ងៃបើកសវនាការដំបូងដែលថ្ងៃដំបូងនេះគឺបម្រុងទុកសម្រាប់សេចក្តីថ្លែងការណ៍បើករបស់ភាគីព្រះរាជអាជ្ញា ។

នៅពេលសវនាការពេលព្រឹកចាប់ផ្តើម អ្នកចូលរួមទាំងអស់ដែលមានដូចជា ដើមបណ្តឹងរដ្ឋប្បវេណី ព្រះសង្ឃ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ សិស្ស និស្សិត មន្ត្រីស្ថានទូត និងអ្នកតំណាងសង្គមស៊ីវិលកម្ពុជាបានចូលទៅខាងក្នុងសាល ហើយអង្គុយយ៉ាងពេញប្រៀបនៅក្នុងបន្ទប់សម្រាប់អ្នកមកចូលរួម ។

ដំណើរការជាប្រវត្តិសាស្ត្រនៅថ្ងៃនេះចាប់ផ្តើមដោយមានភាពរអាក់រអួលខ្លះដោយសារប្រព័ន្ធប្រដាប់បំពងសំឡេងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនាំមុខមានកំហុសបច្ចេកទេសក្នុងអំឡុងពេលនៃការពិភាក្សាអំពីបញ្ហារដ្ឋបាល ។ អ្នកបច្ចេកទេសរបស់តុលាការបានចំណាយពេលជាច្រើននាទីដើម្បីកែសភាពរអាក់រអួលទាំងនោះ ប៉ុន្តែអង្គជំនុំជម្រះនៅតែបន្តកិច្ចការទៅមុខទៀតដោយមិនបានគិតដល់ដំណាក់ការនីតិក្រមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនាំមុខដែលបានស្នើជាផ្លូវការឲ្យមានការទទួលស្គាល់មេធាវីអន្តរជាតិរបស់ខ្លួនទេ ។ ទស្សនិកជនរក្សាភាពអត់ធ្មត់លែងបានហើយដោយសារតែការពន្យារពេលនិងកំហុសផ្នែកប្រព័ន្ធសំឡេងទាំងនេះ ។ មេធាវីដើមមណ្តឹងរដ្ឋប្បវេណីបានប្រៀបធៀបកំហុសបច្ចេកទេសនេះទៅនឹងការបំបាត់សំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាសមូហភាពដែលសិទ្ធិរបស់ជនរងគ្រោះមិនត្រូវបានផ្តល់ឲ្យបញ្ចេញមតិនៅឯតុលាការ ។

ក្រោយពីការពន្យារពេលដោយសារកំហុសបច្ចេកទេសរួចមក អង្គជំនុំជម្រះបានរៀបរាប់សាឡើងវិញនូវប្រធានបទដែលនឹងត្រូវយកមកពិភាក្សាអំពីសំណុំរឿង០០២នៅថ្ងៃនេះ ។ ប្រធានបទទាំងនោះរួមមាន ៖

ក) ប្រវត្តិសាស្ត្រទូទៅរបស់ខ្មែរក្រហម

ខ) រចនាសម្ព័ន្ធរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

គ) តួនាទីរបស់ជនជាប់ចោទនីមួយៗក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

ឃ) គោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

ង) បទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទទាក់ទងទៅនឹងដំណាក់កាលទី១ និងទី២ នៃការជម្លៀសប្រជាជនចេញពីទីកន្លែងមួយទៅកន្លែងមួយដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ច) បទចោទប្រកាន់ពិតប្រាកដនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការបំផ្លិចបំផ្លាញ ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ និងការបាត់ខ្លួន ។

អង្គជំនុំជម្រះក៏បានធ្វើការកត់សម្គាល់ដែរថានឹងរក្សាសិទ្ធិក្នុងការថ្លែងអំពី «ប្រធានបទផ្សេងទៀត» ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថាមានរឿងរ៉ាវទាក់ទងនឹងប្រធានបទសំខាន់ចាំបាច់ណាមួយ ប៉ុន្តែអង្គជំនុំជម្រះមិនបានពិភាក្សាលម្អិតអំពីកត្តាអ្វីមួយដែលចៅក្រមនឹងយកមកពិចារណាអំពីការអនុវត្តសិទ្ធិបែបណាមួយនោះទេ ។ ចំណុចនេះនៅតែបង្កឲ្យមានការមិនដឹងពីដែនកំណត់ពិតប្រាកដនៃករណី០០២ដដែលហើយធ្វើឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីនិងភាគីព្រះរាជអាជ្ញា និងអ្នកតាមដានដំណើរការតុលាការ

នៅតែមិនដឹងអំពីសេចក្ដីណែនាំនៃដំណើរការទៅមុខក្នុងសវនាការ ។

## ការជំទាស់បឋមរបស់ក្រុមការពារក្ដីទាក់ទងនឹងចៅក្រម ខាត់ វ៉ាំយត់

ក្រោយពីអង្គជំនុំជម្រះរៀបរាប់សាឡើងវិញអំពីព័ត៌មានបឋមទាក់ទងនឹងករណី០០២ ប៉ុន្តែមុននឹងព្រះរាជអាជ្ញាចាប់ផ្ដើមធ្វើសេចក្ដីថ្លែងការណ៍បើក ក្រុមការពារក្ដីរបស់ អៀង សារី និង នួន ជា បាន ក្រោកឡើង ហើយនិយាយកាត់ដោយបានលើកអំពីការជំទាស់បឋមមួយចំនួន ។ មេធាវីការពារក្ដីអន្តរជាតិរបស់ នួន ជា ឈ្មោះ ម៉ៃឃើល ផេស្ដមេន បានជូនដំណឹងទៅតុលាការថា ក្រុមការពារក្ដីរបស់ខ្លួនបានដាក់សំណើជូនកាលពីព្រឹកថ្ងៃនេះទៅអង្គជំនុំជម្រះដើម្បីស្នើឲ្យចៅក្រម ខាត់ វ៉ាំយត់ លាលែងពីមុខតំណែងដោយសារតែមានភ័ស្ដុតាងថាលោកស្រីចៅក្រមបានចូលរួមប្រជុំជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី ហើយនិងអគ្គលេខាធិការរងរបស់អង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់លោកស្រី ប៉ាទីស្យា អូប្រាយអិន អំឡុងពេលដែលលោកស្រីធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ។ មេធាវី ផេស្ដមេន បានអះអាងថា កិច្ចប្រជុំនោះបានបង្កើតឲ្យមានភាពខុសឆ្គងហើយហេតុដូចច្នេះ មេធាវីទាមទារឲ្យចៅក្រម ខាត់ វ៉ាំយត់ លាលែងពីមុខតំណែងដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងមាត្រា៥៥៧នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ។ មេធាវី ផេស្ដមេន បានអះអាងថា បញ្ហានេះត្រូវតែដោះស្រាយឲ្យរួចសិន ហើយចៅក្រមអង្គជំនុំជម្រះអន្តរជាតិ កាធីកា ឡាហ៊ូ គួរតែមកជំនួសចៅក្រម ខាត់ វ៉ាំយត់ ចំពោះកោអីនេះ ។


កងនគរបាលកំពុងទទួលយកឯកសារមុនពេលចូលបន្ទប់សវនាការ

មេធាវីការពារក្ដីរបស់ អៀង សារី បានចូលរួមទាមទារបែបនេះជាមួយក្រុមមេធាវីរបស់ នួន ជា ដែរ ប៉ុន្តែមានលក្ខណៈស្រាលជាងបន្តិចដោយស្នើឲ្យមានការស៊ើបអង្កេតខ្លះៗទាក់ទងនឹងកិច្ចប្រជុំដែលបានកើតឡើងទាក់ទងនឹងចៅក្រម ខាត់ វ៉ាំយត់ ដោយអនុលោមតាមវិធាន៣៥ជាជាងស្នើឲ្យមានការលាលែងពីមុខតំណែងជាបន្ទាន់របស់លោកស្រីចៅក្រម ខាត់ វ៉ាំយត់ ។ ម៉ៃឃើល ខាណាវ៉ាស មេធាវីអន្តរជាតិរបស់ អៀង សារី បានអះអាងថា កិច្ចប្រជុំណាមួយរវាងចៅក្រមអង្គជំនុំជម្រះនិងអ្នកតំណាងណាមួយរបស់ព្រះរាជអាជ្ញាបង្កឲ្យមានការសន្និដ្ឋានថា ព្រះរាជអាជ្ញាមានការរីករាយនឹង «អភ័យឯកសិទ្ធិ» ពិសេសដែលមេធាវីការពារក្ដីមិនបានរីករាយ ។ ការអះអាងនេះមានលក្ខណៈយ៉ាងស័ក្ដិសមទៅនឹងសំណើដែលដាក់ជូនកាលពីលើកមុនដោយក្រុមមេធាវីការពារក្ដីរបស់ អៀង សារី ដែលបានអះអាងដូចគ្នាថា សាលាក្ដីខ្មែរក្រហមមិនបានធ្វើតាមមូលដ្ឋានគ្រឹះនៃតម្រូវការសវនាការយុត្តិធម៌នៃ «ភាពស្មើគ្នា» រវាងភាគីទាំងអស់នៅចំពោះមុខតុលាការទេ ដោយមិនបានផ្ដល់ជូនដល់ភាគីការពារក្ដីនូវធនធានដូចគ្នាដែលភាគីដទៃមាន ។ ម៉ៃឃើល ខាណាវ៉ាស បានអះអាងយ៉ាងត្រង់ៗថា យ៉ាងហោចណាស់ចៅក្រម ខាត់ វ៉ាំយត់ គួរតែផ្ដល់ការពន្យល់ណាមួយអំពីមូលហេតុដែលគាត់បានជួបជាមួយសហព្រះរាជអាជ្ញា អេនឌ្រូ ខេលី ។ ម៉ៃឃើល ខាណាវ៉ាស ក៏បានស្នើផងដែរថាកំណត់ហេតុកិច្ចប្រជុំនោះគួរតែផ្ដល់ជូនដល់ភាគីការពារក្ដីនៅចំពោះមុខតុលាការឲ្យបានឆាប់រហ័ស ។

អង្គជំនុំជម្រះទទួលស្គាល់ថា ខ្លួនយល់ពីអ្វីដែលក្រុមការ

ពារក្តីដាក់សំណើជូន តែបានបញ្ជាក់ទៀតថា រាល់បញ្ហាទាំងអស់ដែលបានលើកឡើងនៅពេលនេះគួរតែយកមកពិភាក្សាដាច់ដោយឡែកពីគ្នា ហើយក៏មិនត្រូវធ្វើឲ្យប៉ះពាល់ផ្ទាល់ដល់ការធ្វើសេចក្តីថ្លែងបើករបស់ព្រះរាជអាជ្ញាដែរ ។ អង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួនសូមធ្វើការបដិសេធ «ការប៉ុនប៉ងណាមួយក្នុងការបន្ទាក់ដំណើរការរបស់សវនាការ» ហើយអង្គជំនុំជម្រះមិនទទួលយកសំណើណាមួយក្រៅអំពីសេចក្តីថ្លែងការណ៍បើកនេះទេ ។ ក្រោយពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះ ម៉ៃឃើល ខាណាវ៉ាស បានស្នើសុំឱកាសធ្វើសេចក្តីថ្លែងការណ៍ដែលត្រៀមរៀបចំដោយ អៀង សារី រួចហើយដើម្បីថ្លែងទៅកាន់តុលាការ ។ អ្នកចូលរួមទស្សនាម្នាក់ៗបានអើតកឡើងចង់ដឹងថាតើ អៀង សារី អាចមានឱកាសធ្វើសេចក្តីថ្លែងនៅក្នុងតុលាការបានដែរឬទេ ដោយសារតែថ្មីៗនេះ ក្រុមការពារក្តីរបស់ខ្លួនបានប្រកាសថាជនជាប់ចោទ អៀង សារី នឹងមិនធ្វើសក្ខីកម្មនៅក្នុងអង្គសវនាការទេ ។ ប៉ុន្តែចៅក្រមបានបដិសេធនូវសំណើរបស់មេធាវីការពារក្តីនេះ ហើយបញ្ជាក់ថា អៀង សារី ត្រូវរង់ចាំ និងធ្វើសេចក្តីថ្លែងការណ៍ណាមួយក៏បានដោយសារតែថ្ងៃនេះអង្គសវនាការបានប្រគល់ជូនភាគីព្រះរាជអាជ្ញារួចទៅហើយ ។

**ទិដ្ឋភាពទូទៅនៃករណី០០២របស់ព្រះរាជអាជ្ញា ៖ កម្ពុជាប្រជាធិបតេយ្យជារដ្ឋទាសករ**

ក្រោយពីបញ្ហាជាបឋមបានដោះស្រាយរួច វេទិកាត្រូវបានផ្តល់ជូនទៅព្រះរាជអាជ្ញាដើម្បីធ្វើសេចក្តីថ្លែងការណ៍បើក ។ អង្គជំនុំជម្រះបានបន្តាប់កាលពីដំបូងថា សេចក្តីថ្លែងការណ៍បើកនេះត្រូវតែរៀបរាប់គ្រប់ប្រធានបទនិងបទឧក្រិដ្ឋទាំងអស់ដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយដែលចោទប្រកាន់ជនជាប់ចោទដោយមិនកំណត់ការបន្តាប់ដាច់ណាត់ណាមួយពីអង្គជំនុំជម្រះទេ ។

ផ្នែកដំបូងនៃសេចក្តីថ្លែងការណ៍បឋមរបស់ព្រះរាជអាជ្ញាត្រូវបានរៀបរាប់ដោយសហព្រះអាជ្ញាជាតិ ជា លាង ។ ជា លាង បានរៀបរាប់ពីទស្សនៈរបស់ព្រះរាជអាជ្ញានៅក្នុងទិដ្ឋភាពទូទៅនៃកម្ពុជាដែលជារដ្ឋទាសករដែលកាលនោះជីវិតមនុស្សម្នាក់ៗត្រូវបានបន្ថោកយ៉ាងតូចទាបជាទីបំផុតបញ្ហារដោយមជ្ឈិមបក្សរបស់ខ្មែរក្រហម ។ ព្រះរាអាជ្ញាបានបន្តអះអាងបន្ថែមទៀតថា បទឧក្រិដ្ឋដែលប្រព្រឹត្តឡើងនៅក្នុង «រដ្ឋទាសករ» នេះត្រូវបានចាត់ថ្នាក់ជាសោកនាដកម្មដ៏អាក្រក់បំផុតនៅក្នុងប្រវត្តិសាស្ត្រទំនើបនេះ ហើយជាលទ្ធផលបង្កឲ្យមានការស្លាប់ «ដ៏ធំសម្បើម» ដែលតាមការប៉ាន់ស្មានអាចមានចំនួនពី១,៧ទៅ២,២ លាននាក់ឬមួយភាគបួននៃប្រជាជនកម្ពុជាទាំងមូល ។

ដោយសារនេះជាផ្នែកមួយនៃការរៀបរាប់ពីអំពើទាសភាពក្នុងអំឡុងថ្ងៃបើកសវនាការនេះ ព្រះរាជអាជ្ញាបានរៀបរាប់ប្រធានមួយចំនួននៃការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញនិងទីប្រជុំជននានា ប្រធានបទអំពីលក្ខខណ្ឌជីវិតនៅឯសហករណ៍ និងការដ្ឋានការងារ ការបង្កើតប្រព័ន្ធសន្តិសុខទូទាំងប្រទេស ការបង្ខំឲ្យរៀបការ និងបទល្មើសឧក្រិដ្ឋកម្មប៉ះពាល់ផ្លូវភេទមួយចំនួនរួមទាំងការរំលោភផ្លូវភេទ ការធ្វើទុកបុកម្នេញដល់ពុទ្ធសាសនា អំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តឡើងដើម្បីប្រឆាំងនឹងជនជាតិភាគតិច ចាមមូស្លីម និងជនជាតិភាគតិចវៀតណាម-ខ្មែរ និងអំពើព្រៃផ្សៃប្រព្រឹត្តឡើងដើម្បីប្រឆាំងជនជាតិវៀតណាមស្លូតត្រង់ក្នុងអំឡុងពេលដែលយោធាខ្មែរក្រហមវាយលុកចូលប្រទេសវៀតណាម ។

**ប្រវត្តិនិងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងទូទាំងប្រទេស**

ព្រះរាជអាជ្ញាចាប់ផ្តើមធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួនដោយរៀបរាប់អំពីបទឧក្រិដ្ឋជាក់លាក់ជាច្រើនដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ដោយបង្ហាញអំពីការរៀបរាប់តាមរយៈក្រាហ្វិកនៅលើផ្ទាំងអេក្រង់ដែលបង្ហាញអំពីការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង ។ ការជម្លៀសប្រជាជននេះកើតឡើងដោយហេតុការណ៍ពីរផ្សេងគ្នា ។ ក្រោយពីខ្មែរក្រហមទទួលជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ការជម្លៀសកើតមានឡើងតាមរយៈការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនដែលរស់នៅទីក្រុងដោយបង្ខំឲ្យទៅកាន់ទីជនបទទូទាំងប្រទេសកម្ពុជា ។ ជា លាង បានបន្តទៀតថា ព្រះរាជអាជ្ញានឹងបញ្ជាក់ថា ខ្មែរក្រហមបានកាន់កាប់ទីក្រុងដែលពោរពេញទៅដោយជនភៀសខ្លួនជាច្រើនដោយសារសង្គ្រាមស៊ីវិលដែលជនភៀសខ្លួនទាំងនោះកំពុងតែប្រឈមមុខនឹងវិបត្តិខ្វះជំនួយមនុស្សធម៌រួចទៅហើយ ហើយក្រោយមកជនភៀស

ខ្លួននោះមិនទទួលបានជំនួយមនុស្សធម៌ពីសហគមន៍អន្តរជាតិទេ ។ ជា លាង បានរៀបរាប់អំពីស្ថានភាពរបៀបដែលជនស៊ីវិលនៅក្នុងទីក្រុងកាលពីដំណាក់កាលដំបូងប្រជាជនទាំងនោះមានក្តីសុទិដ្ឋិនិយមថា ទីបំផុតសន្តិភាពបានមកដល់ប្រទេសកម្ពុជា ហើយតែក្តីសង្ឃឹមនេះត្រូវបានរលាយសាបសូន្យទៅវិញដោយរបបដ៏ព្រៃផ្សៃមួយនេះដែលភ្លាមៗនោះប្រជាជនត្រូវបានបង្ខំឲ្យចាកចេញពីលំនៅដ្ឋានទៅកាន់ទីជនបទដោយមិនបានផ្តល់តម្រូវការចាំបាច់សម្រាប់ការរស់រានមានជីវិតឡើយ ។ ព្រះរាជអាជ្ញាបានអះអាងទៀតថា អ្នកជំនាញអំពីរបបខ្មែរក្រហមម្នាក់ឈ្មោះ ប៉ែន យៀវនិន បានធ្វើការប៉ាន់ប្រមាណថាប្រជាជនប្រមាណជាមួយម៉ឺននាក់បានស្លាប់អំឡុងពេលនៃការជម្លៀសនាដំណាក់កាលដំបូង ហើយព្រះរាជអាជ្ញាបានសង្កត់ធ្ងន់ថា អៀង សារី ផ្ទាល់ក៏បានសារភាពនៅក្នុងបទសម្ភាសន៍កាលពីឆ្នាំ១៩៧៧ដែរថាប្រជាជនពីពីរពាន់ទៅបីពាន់នាក់បានស្លាប់ក្នុងអំឡុងពេលនៃការជម្លៀសនោះ ។ ព្រះរាជអាជ្ញាក៏បានបន្តទៀតថា ថ្នាក់ដឹកនាំខ្មែរក្រហមបានកុហកបោកប្រាស់ដោយចេតនាដោយប្រកាសថា អតីតទាហាននិងមន្ត្រីរបស់របប លន់ នល់ ក្រៅពី «ជនក្បត់» ទាំងប្រាំពីរនាក់ដែលជាមន្ត្រីជាន់ខ្ពស់របស់ លន់ នល់ នឹងទុកជីវិតបើសិនជាមន្ត្រីទាំងនោះយល់ព្រមចុះចាញ់ ។ តែការពិត អ្នកដែលព្រមចុះចាញ់ត្រូវបានយកទៅសម្លាប់ចោលតាមការបញ្ជារបស់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យទៅវិញ ។

### លក្ខខណ្ឌជីវិតនៅឯការដ្ឋានការងារ និងតាមសហករណ៍

ប្រធានបទបន្ទាប់របស់ព្រះរាជអាជ្ញាគឺអំពីលក្ខខណ្ឌរស់នៅឯការដ្ឋានការងារនិងនៅតាមសហករណ៍ទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជា លាង បានអះអាងថា ភ័ស្តុតាងបានបញ្ជាក់ថា «ទុរ្គតភាពនៃជីវិត» នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំខ្មែរក្រហមដែលបានបង្វែរប្រទេសរបស់ខ្លួនឲ្យធ្លាក់ចូលទៅក្នុង «គុកឥតជញ្ជាំង» ។ ព្រះរាជអាជ្ញាបានបន្តទៀតថា រដ្ឋាភិបាលមជ្ឈិមរបស់ខ្មែរក្រហម «ដឹងយ៉ាងច្បាស់» និង «បានគ្រប់គ្រង» ទីតាំងឧក្រិដ្ឋកម្មរបស់ករណី០០២ដែលលក្ខខណ្ឌរស់នៅគឺមានលក្ខណៈលំបាកជាខ្លាំង ។ ទោះបីជាមានការទទួលស្គាល់ពីភាពទុក្ខសោកនិងការស្លាប់ប្រជាជនរាប់ពាន់នាក់ក៏ដោយ ក៏ប្រជាជនស្លូតត្រង់នៅតែធ្វើការងារយ៉ាងលំបាកដោយកង្វះអនាម័យនិងជួបប្រទះនូវការអត់ឃ្លាន ។ ព្រះរាជអាជ្ញាបានបកស្រាយថា មេដឹកនាំនៅតែបន្តផលិតកម្មស្រូវដោយគ្មានគិតពីតម្លៃជីវិតមនុស្សដែលចេះតែស្លាប់បន្តបន្ទាប់នោះទេ ។ ក្រោយពីព្រះរាជអាជ្ញាធ្វើសេចក្តីថ្លែងការណ៍ទាក់ទងនឹងការដ្ឋានការងារនិងនៅតាមសហករណ៍ចប់ អង្គជំនុំជម្រះបានបង្គាប់ឲ្យមានអង្គសវនាការទាំងមូលសម្រាកនៅម៉ោង១០ៈ៣០ព្រឹក ។

### សំណើរបស់ អៀង សារី សុំចាកចេញពីបន្ទប់សវនាការ



អៀង សារី ក្នុងសវនាការខែវិច្ឆិកា ឆ្នាំ២០១១ (រូបថត អ.វ.ត.ក)

ក្រោយពីសម្រាករួច អៀង សារី បានស្នើតាមរយៈមេធាវីរបស់ខ្លួនដើម្បីចាកចេញពីបន្ទប់សវនាការទៅកាន់បន្ទប់រង់ចាំដែលខ្លួនអាចចូលរួមស្តាប់ពីចម្ងាយបានតាមរយៈបច្ចេកវិជ្ជាសំឡេងរបស់តុលាការដោយសារតែខ្លួនឈឺខ្នងមិនអាចអង្គុយយូរបាន ។ អង្គជំនុំជម្រះបានបដិសេធសំណើនេះដោយបញ្ជាក់ថា នេះគឺជារឿងសំខាន់ណាស់ដែលជនជាប់ចោទម្នាក់ៗស្តាប់អំពីបទចោទប្រកាន់មកលើខ្លួនដែលកំពុងតែរងការចោទប្រកាន់ ។

អៀង សារី ត្រូវបានមើលឃើញថាមានការអល់អែកក្នុងចិត្តដោយសារតែសំណើរបស់ខ្លួនត្រូវបានបដិសេធ ហើយ អៀង សារី មើលទៅដូចជាមានភាពជ្រួលច្រាលក្នុងចិត្តខុសពីធម្មតាដែរ ។ អង្គសវនាការបានអនុញ្ញាតឲ្យព្រះរាជអាជ្ញាបន្តសេចក្តីថ្លែងរបស់ខ្លួនទៅមុខទៀត ។ ប៉ុន្តែនៅតែមានការរំខានដែលមិននឹកស្មានដល់ដដែលខណៈពេលដែលអ្នកយាមជាច្រើននាក់និងបុគ្គលិករបស់តុលាការដើរទៅជិត អៀង សារី ដើម្បីជួយសម្រួលកៅអីរបស់គាត់ពេលដែល អៀង សារី អាចរំកិលកៅអីរបស់គាត់បានតិចតួច ។

តុលាការបានចាត់វិធានការសំខាន់មួយនៅពេលដែលបុគ្គលិកទទួលការបណ្តុះបណ្តាលយ៉ាងហ្មត់ចត់របស់តុលាការចូលទៅកាន់ អៀង សារី ដើម្បីជួយសម្រួលខ្នងរបស់គាត់ហើយជួយសម្រួលកៅអីរបស់គាត់ ។ ព្រះរាជអាជ្ញាបានពិភាក្សាអំពីការមិនអើពើដោយរបបខ្មែរក្រហមចំពោះមនុស្សគ្រប់រូបដោយមិនយល់ថាអ្នកនោះគឺជាចាស់ជរាខ្សោយឬអ្នកជំងឺឡើយ ។

## ការជម្លៀសប្រជាជនលើកទីពីរទៅកាន់ភូមិភាគពាយព្យ

ក្រោយពីរៀបរាប់អំពីអវត្តមាននៃការថែទាំសុខភាពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជា លាង បានងាកទៅរកការរៀបរាប់ពីភាពឃោរឃៅ ការអត់ឃ្លាន ភាពបន្ថោកខ្លួនដែលជាលទ្ធផលនៃការបង្ខំឲ្យមានការផ្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាជនកម្ពុជារាប់ពាន់នាក់ជាលើកទីពីរទៅកាន់ភូមិភាគពាយព្យ ។ ព្រះរាជអាជ្ញាបានបញ្ជាក់ថា ការផ្លាស់ប្តូរលំនៅដ្ឋានដោយបង្ខំបែបនេះបង្កឲ្យមានការរងទុក្ខយ៉ាងធំធែងចំពោះប្រជាជនទូទៅដោយសារតែភូមិភាគនោះមិនបានត្រៀមទុកជាមុនសម្រាប់ទទួលប្រជាជនរាប់សែននាក់នោះទេ ។ ការអត់ឃ្លានបានកើតឡើងជាទូទៅនៅភូមិភាគពាយព្យហើយព្រះរាជអាជ្ញាបានដកស្រង់អ្នកដែលបានឃើញហេតុការណ៍នេះផ្ទាល់ភ្នែកជាច្រើនរូបដែលបានជួបប្រទះនូវការអត់ឃ្លាន ហើយក៏កើតមានហេតុការណ៍ស៊ីសាច់មនុស្សផងដែរ ។ ព្រះរាជអាជ្ញាក៏បានអះអាងផងដែរថា ជនស៊ីវិលដែលត្រូវបានបញ្ជូនទៅភូមិភាគពាយព្យត្រូវបានចាត់ទុកថាជាជន «គ្មានតម្លៃនិងរស់នៅ» របស់ថ្នាក់ដឹកនាំខ្មែរក្រហម ដោយសារតែអ្នកនោះជាអតីតអ្នកធ្លាប់រស់នៅទីក្រុងដែលមិនត្រូវបានទុកចិត្តដោយរបបកម្ពុជាប្រជាធិបតេយ្យទេ ។

## ការធ្វើទុក្ខបុកម្នេញដល់ពុទ្ធសាសនា

បន្ទាប់មក ព្រះរាជអាជ្ញាបានពិភាក្សាអំពីបទចោទប្រកាន់របស់ខ្លួននៃការធ្វើទុក្ខបុកម្នេញមកលើពុទ្ធសាសនានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលព្រះរាជអាជ្ញាបានពិពណ៌នាថាបានកើតឡើង «ជាប្រព័ន្ធ» ទូទាំងប្រទេស ។ ព្រះរាជអាជ្ញាបានរៀបរាប់ឡើងវិញអំពីហេតុការណ៍ផ្ទាល់ភ្នែកជាច្រើន ហើយបានបង្ហាញភ័ស្តុតាងជាឧទាហរណ៍នៃពាក្យស្លោកឃោសនារបស់ខ្មែរក្រហមដែលបានចាត់ទុកពុទ្ធសាសនាជាគ្មានប្រយោជន៍នៃរូប «ស៊ីម៉ង់ត៍» ហើយបានចាត់ទុកពុទ្ធសាសនាជាជនខ្ជិលច្រអូសដែលគេចផុតពីពលកម្មនៅក្នុងសង្គម ។ ព្រះរាជអាជ្ញាបានបញ្ជាក់ទៀតថា ព្រះសង្ឃត្រូវបានបង្ខំឲ្យសឹកក្រោមការគំរាមកំហែងនិងកាប់សម្លាប់ ខណៈពេលដែលទីតាំងសាសនាមួយចំនួនដូចជា វត្តអារាមត្រូវបានបំផ្លិចបំផ្លាញនិងផ្លាស់ប្តូរទៅជាឃ្លាំងផ្ទុកសម្ភារៈ គុក ឬជាកន្លែងពិឃាតមនុស្ស ។

## ការបង្ខំឲ្យរៀបការ និងបទឧក្រិដ្ឋទាក់ទងនឹងផ្លូវភេទ

ការរៀបការដោយបង្ខំគឺជាប្រធានបទបន្ទាប់ដែលត្រូវយកមកពិភាក្សាដោយព្រះរាជអាជ្ញា ។ ជា លាង បានបញ្ជាក់ថា គោលនយោបាយរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហមបានប៉ះពាល់ដល់ប្រជាជនកម្ពុជា «រាប់ពាន់នាក់» ដែលទទួលរងនូវការធ្វើបាបដល់រាងកាយនិងផ្លូវចិត្ត ។ ការរៀបការដោយបង្ខំត្រូវបានកំណត់ថាជាទិដ្ឋភាពមួយនៃទស្សនៈរបស់ព្រះរាជអាជ្ញាអំពីរបបកម្ពុជាប្រជាធិបតេយ្យថាជារដ្ឋទាសករ ។ ដោយសារតែជាទិដ្ឋភាពមួយនៃគោលនយោបាយរៀបការដោយបង្ខំ ព្រះរាជអាជ្ញាបានចោទប្រកាន់ថា ស្ត្រីត្រូវបានផ្តល់ជា «រង្វាន់» ដល់យោធិនពិការដែលត្រូវបានផ្តល់សិទ្ធិឲ្យជ្រើសរើសស្ត្រីដែលចាត់តាំងដោយអង្គការ ។ ព្រះរាជអាជ្ញាបានកត់សម្គាល់ថា ខ្មែរក្រហមបានតម្រូវឲ្យគូស្នេហ៍រួមភេទ ហើយខ្មែរក្រហមក៏បានតាមដានមើលដំណើរការរួមភេទនោះដែរចំពោះគូស្នេហ៍ដែលទើបរៀបការរួច ។ ប្រការនេះបង្កឲ្យមានការរំលោភផ្លូវភេទជាច្រើនករណីនៅក្នុងបុព្វបទនៃការរៀបការដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ផ្ទុយមកវិញ គូស្នេហ៍ដែលមានទំនាក់ទំនងស្នេហាក្រៅរង្វង់រៀបការដែលរៀបចំដោយខ្មែរក្រហមត្រូវបានចាត់ទុកថាមាន

កំហុសឧក្រិដ្ឋ "ខុសសីលធម៌" ដោយរបបខ្មែរក្រហម ។ ព្រះរាជអាជ្ញាបានអះអាងទៀតថា ជនរងគ្រោះទាំងនេះគឺត្រូវទទួលរងនូវការដាក់គុក ឬសម្លាប់ដោយសារតែបានស្រឡាញ់គ្នាមិនមានការយល់ព្រមពីរបបនេះ ។

## មន្ទីរសន្តិសុខ និងទីតាំងពិឃាត

ក្រោយមក ព្រះរាជអាជ្ញាបានងាកមកបកស្រាយអំពីប្រព័ន្ធសន្តិសុខទូទាំងប្រទេសនិងទីតាំងពិឃាតដែលបង្កើតឡើងដោយខ្មែរក្រហមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ព្រះរាជអាជ្ញាបានអះអាងថា ទារុណកម្ម និងការសម្លាប់គឺជាបែបផែនអនុវត្តរបស់ខ្មែរក្រហមមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ទៅទៀត តែសកម្មភាពព្រៃផ្សៃទាំងអស់នេះកើតឡើងយ៉ាងខ្លាំងក្រោយពេលដែលរបបនេះទទួលបានជ័យជម្នះទាំងស្រុងទូទាំងប្រទេស ។ ព្រះរាជអាជ្ញាបានអះអាងទៀតថា មន្ទីរសន្តិសុខជាង២០០កន្លែងត្រូវបានបង្កើតឡើងភ្លាមៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្រោយពេលដែលខ្មែរក្រហមទទួលបានអំណាច ។ មន្ទីរសន្តិសុខរបស់ខ្មែរក្រហមគឺមានលក្ខណៈព្រៃផ្សៃនិងមានគោលដៅច្បាស់លាស់ដោយសារតែអ្នកដែលត្រូវចាប់ខ្លួនម្នាក់ៗត្រូវបានចោទប្រកាន់ដោយកំហុសតូចតាច ឬចាត់ទុកអ្នកនោះថា "មានសក្តានុពលជាសត្រូវ" ដែលត្រូវតែចាប់ខ្លួនធ្វើទារុណកម្មនិងឬសម្លាប់ចោលដោយគ្មានការពិចារណាត្រឹមត្រូវអំពីភ័ស្តុតាងដែលមានថាតើជននោះបានប្រព្រឹត្តដូចដែលបានចោទប្រកាន់ដែរឬអត់ ។ មន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យគឺជាកន្លែងដែលអ្នកទោសត្រូវធ្វើពលកម្មធ្ងន់ធ្ងរ ការរំលោភបំពាន ការធ្វើទារុណកម្ម និងលក្ខខណ្ឌជីវិតប្រកបដោយអមនុស្សធម៌ទូទៅផ្សេងទៀត និងការសម្លាប់ក្រៅប្រព័ន្ធតុលាការ ។ ព្រះរាជអាជ្ញាបានផ្តល់នូវឧទាហរណ៍មួយចំនួននៃការរំលោភ ការធ្វើទារុណកម្ម និងការសម្លាប់ នៅមន្ទីរសន្តិសុខ នៅក្នុងក្រាហ្វិកយ៉ាងលម្អិតដែលនាំមកនូវភាពព្រៃផ្សៃដែលខ្មែរក្រហមបានប្រព្រឹត្តនៅក្នុងគុករបស់កម្ពុជាប្រជាធិបតេយ្យទៅកាន់អ្នកចូលរួមនៅក្នុងតុលាការ ។

## អំពើប្រល័យពូជសាសន៍ចំពោះជនជាតិភាគតិចចាមនិងវៀតណាម

ព្រះរាជអាជ្ញាបានបង្ហាញគ្រួសៗអំពីទស្សនៈរបស់ខ្លួនចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ដែលបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទដោយបានផ្តល់ការអំណះអំណាងពីការគោលដៅនៃការបំផ្លិចបំផ្លាញមកលើជនជាតិចាមមូស្លីមនៅកម្ពុជានិងសហគមន៍ជនជាតិភាគតិចវៀតណាម ។ ថ្នាក់ដឹកនាំខ្មែរក្រហមមានបំណងលុបបំបាត់ចោលជាតិពន្ធុផ្សេងៗនៅក្នុងប្រទេសកម្ពុជាហើយដើម្បីធ្វើកិច្ចការនេះ ខ្មែរក្រហមបានបំផ្លាញទាំងស្រុងនូវក្រុមជនជាតិភាគតិចចាមនិងវៀតណាម ។

## អំពើប្រល័យពូជសាសន៍លើជនជាតិចាម

ព្រះរាជអាជ្ញាបានរៀបរាប់អំពីករណីប្រល័យពូជសាសន៍មកលើជនជាតិចាមយ៉ាងលម្អិតដោយរួមបញ្ចូលទាំងការចោទប្រកាន់យ៉ាងជាក់ច្បាស់ថាជនជាប់ចោទផ្ទាល់បានចេញសេចក្តីសម្រេចឲ្យមានអំពើប្រល័យពូជសាសន៍ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យដោយបញ្ជាឲ្យកម្មាភិបាលថ្នាក់ក្រោមធ្វើការបំផ្លិចបំផ្លាញជនជាតិចាមជាក្រុម ។ ការបំផ្លិចបំផ្លាញនេះរួមមានថ្នាក់ដឹកនាំខ្មែរក្រហមបានតាមដានគ្រប់ជំហានយ៉ាងយកចិត្តទុកដាក់ក្នុងការកំណត់រកអត្តសញ្ញាណនិងសម្លាប់ជនជាតិចាម ហើយសហគមន៍ចាមត្រូវបានកំណត់ទិសដៅក្នុងការសម្លាប់ជាទ្រង់ទ្រាយធំ ប្រសិនបើបុគ្គលណាម្នាក់ត្រូវបានស្គាល់ថាជាចាម ។ ជា លាង បានកំណត់សម្គាល់ផងដែរថា ជនជាតិចាមមូស្លីមបានស្លាប់ក្នុងអត្រាច្រើនជាងជនជាតិកម្ពុជាទៅទៀតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យបើតាមការសិក្សាផ្នែកប្រជាសាស្ត្រ ។

## អំពើប្រល័យពូជសាសន៍មកលើកជនជាតិភាគតិចវៀតណាម-ខ្មែរ

ដូចគ្នាទៅនឹងជនជាតិចាមមូស្លីមដែរ ព្រះរាជអាជ្ញាបានអះអាងថា ជនជាតិភាគតិចវៀតណាម-ខ្មែរគឺជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ក្រោមស្នាដៃរបស់ខ្មែរក្រហមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ព្រះរាជអាជ្ញាបានកត់សម្គាល់ថា ជនជាតិភាគតិចវៀតណាមបានរស់នៅក្នុងតំបន់ដីជាក់លាក់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាយូរមកហើយ ហើយថា តំបន់ទាំងនេះមានលក្ខណៈធម្មតា ហើយត្រូវបានដឹងទូទៅមុនឆ្នាំ១៩៧៥ ។ ព្រះរាជអាជ្ញាបានរៀបរាប់ពីទីតាំងឧក្រិដ្ឋកម្មនៃករណី០០២នៅក្នុងខេត្តព្រៃវែងនិងស្វាយរៀងថាជាតំបន់ដីជាក់លាក់មួយដែលអំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិ

ភាគតិចវៀតណាម-ខ្មែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ព្រះរាជអាជ្ញាបានចោទប្រកាន់ថាគោលនយោបាយទូទៅរបស់ខ្មែរក្រហមគឺដើម្បីសម្លាប់គ្រប់ជនជាតិភាគតិចវៀតណាមទាំងអស់ឲ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន ។ ថ្នាក់ដឹកនាំខ្មែរក្រហមក៏បានហៅជនជាតិវៀតណាមនោះដោយប្រើភាសាក្នុងន័យបន្ថោកតម្លៃគឺ «យួន» ។ លើសពីនេះ បើតាមប្រសាសន៍របស់ព្រះរាជអាជ្ញាថ្នាក់ដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យបានចេញបញ្ជាថាក្មេងៗដែលកើតចេញពីការរៀបការរវាងខ្មែរនិងវៀតណាម-ខ្មែរត្រូវចាត់ទុកថាជាប់សាច់យាមម្តាយ ។ ថ្នាក់ដឹកនាំខ្មែរក្រហមអះអាងថា ប្រសិនបើម្តាយមានឈាមជ័រជាជនជាតិភាគតិចវៀតណាមនោះកូនដែលកើតមកគឺជាវៀតណាមហើយកូននោះត្រូវតែសម្លាប់ចោលព្រោះកូននោះបានថ្មដោះម្តាយដែលជាជនជាតិវៀតណាម ។

## ការវាយប្រហារមកលើជនស៊ីវិលវៀតណាមអំឡុងពេលការវាយលុកចូលទឹកដីវៀតណាម

ព្រះរាជអាជ្ញាក៏បានពិភាក្សាផងដែរអំពើភាពឃោឃៅដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមប្រឆាំងនឹងជនជាតិវៀតណាមអំឡុងពេលជម្លោះប្រដាប់អាវុធដែលកើតឡើងរវាងកម្ពុជានិងវៀតណាម ។ ព្រះរាជអាជ្ញាបានអះអាងទៀតថាជនស៊ីវិលវៀតណាមត្រូវបានចាប់ខ្លួនអំឡុងពេលការវាយឆ្លក់តាមព្រំដែន ហើយអ្នកទាំងនោះត្រូវបានយកមកដាក់គុក ធ្វើទារុណកម្ម និងសម្លាប់ ។ ព្រះរាជអាជ្ញាបានបញ្ជាក់ថា សកម្មភាពទាំងនេះគឺជាបទល្មើសឧក្រិដ្ឋកម្មសង្គ្រាមដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។

## បន្សុទ្ធកម្មនៅភូមិភាគបូព៌ាឆ្នាំ១៩៧៨

ការប្រយុទ្ធគ្នាតាមបណ្តោយព្រំដែនវៀតណាមគឺពាក់ព័ន្ធនឹងការធ្វើបន្សុទ្ធកម្មដ៏ធំមួយនៅភូមិភាគបូព៌ានៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៨ ។ ព្រះរាជអាជ្ញាបានបញ្ជាក់ទៀតថា ថ្នាក់ដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យមានមន្ទិលសង្ស័យចំពោះភាពស្មោះត្រង់ទៅលើកម្មាភិបាលភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៧ ហើយក្រោយមកបានចេញបទបញ្ជាឲ្យមានការធ្វើបន្សុទ្ធកម្មដ៏ធំនៅក្នុងភូមិភាគនេះ ។ បន្សុទ្ធកម្មចាប់ផ្តើមឡើងក្នុងឆ្នាំ១៩៧៨ ហើយទីបំផុតបានឆក់យកជីវិតមនុស្សអស់ពីមួយសែនទៅពីរសែនប្រាំម៉ឺននាក់ដែលធ្វើឲ្យបន្សុទ្ធកម្មនេះក្លាយជាឧទាហរណ៍តែមួយគត់នៃការសម្លាប់ដ៏ទ្រង់ទ្រាយធំដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ។ ព្រះរាជអាជ្ញាបានផ្តល់មតិថា មេដឹកនាំខ្មែរក្រហមរួមទាំងជនជាប់ចោទផងបានបញ្ជាក់ថាសេអ៊ីអាកំពុងតែប្រត្តិបត្តិការទូទាំងភូមិភាគបូព៌ា ហេតុដូច្នេះគ្មាននរណាម្នាក់អាចគេចផុតពីបទសង្ស័យបានទេ ជាពិសេសកម្មាភិបាលខ្មែរក្រហម ។ ជនជាប់ចោទគឺជាមនុស្សដែលបានពាក់ព័ន្ធ និងដឹងយ៉ាងច្បាស់ពីការធ្វើបន្សុទ្ធកម្មនេះ ដោយធ្វើឲ្យជនជាប់ចោទទាំងបីនេះត្រូវទទួលខុសត្រូវដោយផ្ទាល់ ។ ព្រះរាជអាជ្ញាបានបញ្ជាក់ទៀតថា អំពើបន្សុទ្ធកម្មទាំងនេះគឺជាទម្ងន់មួយដែលតម្រូវឲ្យមានការគិតទុកនិងរៀបចំទុកជាមុនមុននឹងអនុវត្តការងារនេះបាន ។ ឧទាហរណ៍ដូចជាមានសាក្សីម្នាក់បានរៀបរាប់អំពីរទេះគោជាច្រើនត្រូវបានប្រើប្រាស់ដើម្បីដឹកមនុស្សទៅសម្លាប់នៅទីតាំងពិឃាតពីព្រោះចំនួននៃជនរងគ្រោះដែលបានគ្រោងទុកមានចំនួនយ៉ាងច្រើន ។ ព្រះរាជអាជ្ញាក៏បានគូសបញ្ជាក់ត្រង់ៗថា ខ្លួននឹងបង្ហាញសក្ខីកម្មដែលបានអះអាងថា ជនជាប់ចោទ នួន ជា បានចូលរួមក្នុងដំណើរការនោះផ្ទាល់នៅក្នុងសកម្មភាពបន្សុទ្ធកម្មក្នុងភូមិភាគបូព៌ា ។



សហព្រះរាជអាជ្ញាជាតិ ជា លាង

## សេចក្តីថ្លែងការណ៍បញ្ចប់ដោយព្រះរាជអាជ្ញាជាតិ

សហព្រះរាជអាជ្ញាជាតិ ជា លាង បានធ្វើការសន្និដ្ឋាន ដោយធ្វើការសង្ខេបអំពីបទឧក្រិដ្ឋដែលបានចោទប្រកាន់រួមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មសង្គ្រាម ។

ជា លាង បានអះអាងថា ជនជាប់ចោទគឺពាក់ព័ន្ធនៅក្នុងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិភាគតិចចាមមូស្លីមនិង



សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី

ជនជាតិភាគតិចវៀតណាម-ខ្មែរព្រមទាំងការរាតត្បាតនៃការរីករាលដាលនិងការវាយប្រហារជាលក្ខណៈប្រព័ន្ធមកលើជនស៊ីវិលកម្ពុជាដែលជាសមាសភាពចាំបាច់ក្នុងការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ការវាយប្រហារទាំងអស់នេះបង្កឲ្យមានមនុស្សស្លាប់ពី១,៧លាន ទៅ ២,២លាននាក់ ហើយបានប្រព្រឹត្តឡើងដោយសារតែអ្នកនោះមានការជាប់ពាក់ព័ន្ធផ្នែកនយោបាយ និងជាតិពន្ធុណាមួយដោយសារតែថ្នាក់ដឹកនាំខ្មែរក្រហមចាត់ទុកជនស៊ីវិលនិងជនជាតិដែលរស់នៅកម្ពុជាដែលមិនមែនជាខ្មែរទាំងអស់គឺជាជនដែលអាចជាសត្រូវ ។ ទីបំផុត ព្រះរាជអាជ្ញាបានអះអាងថា ភ័ស្តុតាងនឹងបង្ហាញថា ជនជាប់ចោទត្រូវទទួលខុសត្រូវពីបទឧក្រិដ្ឋកម្មសង្គ្រាមផ្សេងៗដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម ។

ជា លាង បានបញ្ជាក់ថា ភ័ស្តុតាងបានបង្ហាញថា «គ្មានអ្វីគួរឲ្យសង្ស័យទេត្រង់ថា ជនជាប់ចោទគឺជាកត្តាជំរុញ» ដែលនៅពីក្រោយខ្នងគោលនយោបាយរបស់ខ្មែរក្រហមហើយ ជនជាប់ចោទទាំងនេះត្រូវទទួលខុសត្រូវពីបទឧក្រិដ្ឋនីមួយៗ នៅក្នុងដីកាដំណោះស្រាយ ហើយបានបញ្ជាក់ទៀតថា ព្រះរាជអាជ្ញានឹងចាត់ទុកបទឧក្រិដ្ឋទាំងនេះជា «វិធានការតូចមួយនៃភាពយុត្តិធម៌» សម្រាប់ជនរងគ្រោះរាប់លាននាក់នៃរបបខ្មែរក្រហម ។ ជា លាង បានផ្តល់ឱកាសបន្តទៅសហភាគាព្រះរាជអាជ្ញាអន្តរជាតិគឺ អេនឌ្រូ ខេលី ។

## សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី

ព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី ទទួលបានឱកាសក្នុងការនិយាយដើម្បីធ្វើការសង្កេតនិងពិភាក្សាពីតួនាទីដ៏ជាក់លាក់និងការទទួលខុសត្រូវរបស់ជនជាប់ចោទនៃសំណុំរឿង ០០២ ។ លោក ខេលី បានបញ្ជាក់ថា ការកើតឡើងនៃករណី០០២ គឺឈរលើគោលការណ៍ថា «បុគ្គលគ្រប់រូបគឺជាលទ្ធផលនៃតម្លៃ» ហើយសិទ្ធិជាមូលដ្ឋាននៃបុគ្គលម្នាក់ៗពិតជាមានតម្លៃខ្លាំងណាស់ ។ លោក ខេលី បានបញ្ជាក់ផងដែរថា ភាពឃោរឃៅនៃរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ជាក់អំពីឧក្រិដ្ឋភាពនៃការឲ្យតម្លៃទៅលើសេចក្តីត្រូវការរបស់រដ្ឋជាជាងការផ្តល់សិទ្ធិជាមូលដ្ឋានដល់បុគ្គលម្នាក់ៗ ។ លោក ខេលី បានចោទប្រកាន់ទៅជនជាប់ចោទថា ដោយភាពងងឹតងងុល ដើម្បីសម្រេចទិសដៅបដិវត្តន៍ដាច់ខាតរបស់ខ្លួនជនជាប់ចោទ និងមេដឹកនាំខ្មែរក្រហមដទៃទៀត «បានកេងចំណេញពីមនុស្សគ្រប់បែបយ៉ាងទាំងអស់នូវអ្វីដែលមនុស្សទាំងនោះនៅរស់» ។ លោក ខេលី បានអះអាងថា «ដែនកំណត់នៃភាពមហន្តរាយយ៉ាងធំធេងដែលបានកើតឡើងយ៉ាងអំពើចិត្ត» ក្រោមការប្រព្រឹត្តរបស់ជនជាប់ចោទនៅលើទឹកដីកម្ពុជា «មិនមានតម្លៃស្មើនឹងសម័យទំនើបទេ» ដែលបុគ្គលគ្រប់រូបត្រូវទទួលបានទេ ។

ទាក់ទងទៅនឹងភាពជាក់លាក់នៃករណី០០២ លោក ខេលី បានធ្វើការសង្ខេបពីទិដ្ឋភាពទូទៅរបស់ភាគីព្រះរាជអាជ្ញាទាក់ទងនឹង

សហឧក្រិដ្ឋកម្មរួមដែលភាគីព្រះរាជអាជ្ញាបានចោទប្រកាន់ជនជាប់ចោទថាជាសមាជិកនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សហឧក្រិដ្ឋកម្មរួមមានប្រធានបទទូទៅចំនួនប្រាំគឺ ៖

១ ការជម្លៀសដោយបង្ខំ

២) ការដាក់ជាទាសភាពនៅការដ្ឋានការងារនិងសហករណ៍មកជនស៊ីវិល

៣) ការប្រើប្រាស់អំពើហិង្សាដើម្បីកម្ទេចអ្នកដែលចោទជាសត្រូវ

៤) ការធ្វើទុកបុកម្នេញពុទ្ធសាសនិក អ្នកកាន់សាសនាចាមមូស្លីម ជនជាតិភាគតិចវៀតណាម និងក្រុមជនជាតិភាគតិចនិង

៥) ការរៀបការដោយបង្ខំដើម្បីបង្កើតកម្លាំងមនុស្ស

លោក ខេលី បានរៀបរាប់ប្រវត្តិសង្ខេបនៃចលនាបក្សកុម្មុយនីស្តកម្ពុជាដោយពង្រាងអំពីប្រវត្តិរូបរបស់ជនជាប់ចោទនីមួយៗដើម្បីបញ្ជាក់ឲ្យច្បាស់ពីការជាប់ពាក់ព័ន្ធគ្នាទៅនឹងមេដឹកនាំដែលបានស្លាប់ ហើយគឺ សាឡុត ស ហៅ ប៉ុល ពត ។ លោក ខេលី បានអះអាងថា ប្រវត្តិដ៏វែងឆ្ងាយនៃចលនាខ្មែរក្រហមដែលបានផ្លាស់ប្តូរទៅជាខ្មែរក្រហមនិងការជាប់ពាក់ព័ន្ធដ៏យូរអង្វែងរបស់ជនជាប់ចោទជាមួយគ្នានឹងមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ផ្សេងទៀត និងបញ្ជាក់អំពីគម្រោងដែលបានរៀបចំទុកជាមុននៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

បន្ទាប់មក លោក ខេលី បានបង្ហាញពីគំនូសព្រាងអំពីប្រវត្តិរូបដោយសង្ខេបរបស់ជនជាប់ចោទនីមួយៗដើម្បីបញ្ជាក់ឲ្យច្បាស់អំពីការអះអាងរបស់ព្រះរាជអាជ្ញាដែលថាជនជាប់ចោទទាំងអស់គឺជាសមាជិករបស់ថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យហើយគឺជាអ្នកដែលដឹងឮគ្រប់បែបយ៉ាងអំពីបទឧក្រិដ្ឋដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ថ្ងៃទីមួយបានបញ្ចប់ភ្លាមបន្ទាប់ពីលោក ខេលី ផ្តល់ទិដ្ឋភាពរួមនៃតួនាទីរបស់ ខៀវ សំផន នៅក្នុងចលនាខ្មែរក្រហមនិងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលហាក់បីដូចជាធ្វើឲ្យ ខៀវ សំផន មានអារម្មណ៍អន្ទះសានិងធ្វើឲ្យគាត់ងាកខ្លួនទៅពិភាក្សាជាមួយមេធាវីរបស់ខ្លួនជាច្រើនសា ។ នៅថ្ងៃបន្ទាប់ អ្នកចូលរួមអាចនឹងដឹងច្បាស់ពីធាតុពិតនៃការជំទាស់របស់ ខៀវ សំផន ទៅនឹងការលើកឡើងរបស់ព្រះរាជអាជ្ញាស្តីអំពីតួនាទីរបស់ខ្លួន ហើយមេធាវីការពារក្តីរបស់ ខៀវ សំផន នឹងធ្វើសេចក្តីថ្លែងការណ៍បើកនៅពេលក្រោយ ។ សេចក្តីថ្លែងការណ៍របស់ព្រះរាជអាជ្ញានឹងបញ្ចប់សេចក្តីសន្និដ្ឋាននៅថ្ងៃទី២២ ខែវិច្ឆិកា ហើយក្រោយមកនឹងមានការថ្លែងរបស់មេធាវីការពារក្តី ។

## សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ព្រះរាជអាជ្ញាបានបញ្ជាក់នូវអ្វីដែលមានសារសំខាន់ក្នុងការចោទប្រកាន់ទៅលើជនជាប់ចោទក្នុងករណី០០២ ។ ការបកស្រាយថា សម័យកម្ពុជាប្រជាធិបតេយ្យជារដ្ឋទាសករនោះគឺជាការហុងអំបោះដ៏មានឥទ្ធិពលមួយដែលអាចដេរភ្ជាប់ឧក្រិដ្ឋកម្មផ្សេងៗនៃគោលនយោបាយខ្មែរក្រហមរួមគ្នាឲ្យចូលទៅក្នុងផែនការទូទៅរបស់ខ្មែរក្រហមដែលភ្ជាប់ជនជាប់ចោទទៅនឹងឧក្រិដ្ឋកម្មទាំងអស់ដូចបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ។ បន្ថែមលើនោះ ការប្រើប្រាស់ប្រព័ន្ធជំនួយសំឡេងរបស់ព្រះរាជអាជ្ញានៅពេញអំឡុងនៃការធ្វើសេចក្តីថ្លែងការណ៍បើកសវនាការនេះបានផ្តល់ឲ្យមានការចាប់អារម្មណ៍បន្ថែមពីអ្នកទស្សនានិងផ្តល់ភាពជាមនុស្សដល់ភាពទុក្ខសោកដែលតែងមានការភន័ច្រឡំនឹងបច្ចេកទេសផ្លូវច្បាប់ ។ ខណៈពេលដែលថ្ងៃទីមួយនេះហាក់បីដូចជាថ្ងៃចាប់ផ្តើមដ៏ល្អនៃសវនាការករណី០០២ ការដាក់ជូនសំណើដោយក្រុមការពារក្តីរបស់ នួន ជា និង អៀង សារី ទាក់ទងទៅនឹងចៅក្រម ខាតព្រ៊ាយត៍ គឺជាការរំឭកឲ្យឃើញឡើងអំពីភាពចម្រូងចម្រាសដែលកំពុងកើតឡើងនៅសាលាក្តីខ្មែរក្រហមរាល់ថ្ងៃ ។

**រ៉ែនដល ឌីហ្វាល់កូ**

### កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

*វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយ ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។*

# កម្ពុជាប្រជាធិបតេយ្យជាគុកឥតជញ្ជាំង

*ថ្ងៃទីពីរនេះបានចាប់ផ្តើមដោយមេធាវីរបស់ អៀង សារី ឡើងបកស្រាយអំពីការរំលោភសិទ្ធិមកលើកូនក្តីរបស់ខ្លួន ហើយមេធាវីរូបនេះនៅតែបន្តបកស្រាយទៀតសម្រាប់ថ្ងៃទីពីរនេះ ដោយផ្តើការសន្និដ្ឋានទៅលើសេចក្តីថ្លែងការណ៍បើករបស់ភាគីព្រះរាជអាជ្ញា និងការពិភាក្សាដ៏ក្តៅគគុករវាងមេធាវីរបស់ នួន ជា និងតុលាការ ហើយទីបញ្ចប់នៃថ្ងៃនេះមានជនជាប់ចោទម្នាក់ឡើងអានសេចក្តីថ្លែងការណ៍របស់ខ្លួន ។*

***ចំណុចផ្តើមនៃកិច្ចដំណើរការ ៖ វត្តមានរបស់ជនជាប់ចោទនៅក្នុងតុលាការ***

*ប្រធានតុលាការ និល ណុន បានចាប់ផ្តើមដំណើរការក្រោយម៉ោងប្រាំបួនបន្តិចហើយគាត់ក៏បានទទួលស្គាល់សហមេធាវីអន្តរជាតិរបស់ អៀង សារី ឈ្មោះ ម៉ៃឃើល ខាណាវ៉ាស ដែលនៅពេលនោះកំពុងតែឈរនៅឡើយក្រោយពីចៅក្រមបានដើរចូលក្នុងបន្ទប់សវនាការ ។*

*ម៉ៃឃើល ខាណាវ៉ាស បានចាប់ផ្តើមបកស្រាយសម្រាប់កិច្ចការថ្ងៃនេះដោយពិនិត្យមើលឡើងវិញនូវសំណើមួយដែលបានដាក់ជូនតុលាការកាលពីម្សិលមិញដោយស្នើឲ្យជនជាប់ចោទ អៀង សារី ចូលទៅអង្គុយក្នុងបន្ទប់រង់ចាំដើម្បីតាមដានដំណើរការសវនាការជំនួសវិញ ។ ខាណាវ៉ាស បាននិយាយថា «តុលាការកំពុងតែបង្ខំ អៀង សារី ឲ្យអង្គុយនៅទីនេះ» ទោះបីជាជនជាប់ចោទនេះបានសុំសិទ្ធិចេញពីបន្ទប់សវនាការរួចហើយក៏ដោយ ហើយ ខាណាវ៉ាស បានអះអាងទៀតថា បើនៅតែធ្វើដូច្នេះតុលាការពិតជារំលោភសិទ្ធិរបស់ជនជាប់ចោទទាំងស្រុងតែម្តង ។ ខាណាវ៉ាស បានអះអាងថា «សេចក្តីថ្លែងការណ៍បើកកាលពីម្សិលមិញគ្មានភ័ស្តុតាងច្បាស់លាស់ឡើយ» ហើយក៏គ្មានសារសំខាន់អ្វីដែរ ។ ខាណាវ៉ាស បានអះអាងថា «តើអ្វីទៅដែលជាសារសំខាន់នៃសិទ្ធិរបស់ជនជាប់ចោទនោះ» ។ ដោយបកស្រាយឡើងវិញទៅនឹងសំណើមួយចំនួនដែលបានដាក់ជូនទៅអង្គសវនាការដោយមេធាវី របស់ អៀង សារី សវនាការបឋមក្នុងសំណុំរឿង០០២កាលពីខែមិថុនា ឆ្នាំ២០១១ ខាណាវ៉ាស បានទទួចឲ្យអង្គជំនុំជម្រះពិចារណាសំណើទាំងអស់នោះឡើងវិញ ។*

*ដើម្បីឆ្លើយតបទៅនឹងការអះអាងរបស់ ខាណាវ៉ាស សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បានធ្វើការរំឭកតុលាការឡើងវិញថា ការសង្កេតដែលដាក់ជូនដោយក្រុមរបស់ អៀង សារី ត្រូវបានតុលាការជំទាស់រួចទៅហើយ ។ ពេលនោះ ខាណាវ៉ាស បានក្រោកឈរឡើងដើម្បីបកស្រាយពីយោបល់របស់គាត់ ហើយគាត់នៅតែឈរដដែលទោះបីជា អេនឌ្រូ ខេលី ស្នើទៅគាត់ឲ្យព្រះរាជអាជ្ញានិយាយចប់សិនក៏ដោយ ។ លោក ខេលី បានបន្តបកស្រាយថា ជំហររបស់ព្រះរាជអាជ្ញាគឺថាជនជាប់ចោទទាំងអស់ត្រូវតែមានវត្តមាននៅក្នុងសាលសវនាការ ប៉ុន្តែបើសិនជាតុលាការមានចិត្តនិងអនុញ្ញាតឲ្យ អៀង សារី ចូលរួមតាមដានដំណើរការតុលាការពីបន្ទប់រង់ចាំវិញនោះទាល់តែមានលិខិតសុំជាលាយលក្ខណ៍អក្សរមួយដូច្នេះជនជាប់ចោទមិនអាចទាមទារប្តឹងទៅតុលាការទទួរណ៍បានទេថា ខ្លួនមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងដំណើរការសវនាការនោះ ។*

*គ្រាន់តែលោក ខេលី និយាយចប់ភ្លាម ខាណាវ៉ាស បានបន្ថែមយោបល់ទៀតដោយពេលនោះមិនទុកពេលឲ្យដើមបណ្តឹងរដ្ឋប្បវេណីនាំមុខ ពេជ អង្គ ដែលកំពុងតែឈរដើម្បីឆ្លើយតបទៅនឹងអ្វីដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីនិយាយឡើយ ។ ខាណាវ៉ាស បានបញ្ជាក់ថា គាត់សុំធ្វើការកែតម្រូវ «ការពិតស្មើរ» ដែលបកស្រាយដោយព្រះរាជអាជ្ញាត្រង់ថា ការសង្កេតដែលដាក់ជូនតុលាការត្រូវបានបដិសេធរួចទៅហើយនោះ ។ ខាណាវ៉ាស បានបង្ហាញថា ជនជាប់ចោទបានដាក់ពាក្យក្នុងការមិនមានវត្តមាននៅក្នុងតុលាការដោយភ្ជាប់ជាមួយនូវការអង្កេតដែលអាចយកមកប្រើនៅពេលណាមួយដូចជា នៅពេលនេះជាដើម ។ ខាណាវ៉ាស បានទទូចថា គាត់មិនស្នើសុំឲ្យអាណិតកូនក្តីរបស់ខ្លួនទេ តែតុលាការត្រូវវាយតម្លៃបញ្ហានេះដោយសុចរិតនិងយុត្តិធម៌ដោយទទូចឲ្យតុលាការថា មិនត្រូវចំណាយលុយ «រាប់លានដុល្លារពីអ្នក*

បង់ពន្ធ។ ទៅចំណាយ ទៅលើបច្ចេកទេសនៅក្នុងបន្ទប់រង់ចាំក្នុងតុលាការ ហើយមិនធ្វើការប្រើប្រាស់នោះទេ ។ ខាណាវ៉ាស អះអាងថាជនជាប់ចោទមិនអាចចូលរួមក្នុងដំណើរការសវនាការបានទេ «បើសិនជាគាត់មានវត្តមានហើយតែក្នុងចិត្តរបស់គាត់មិនបានត្រងត្រាប់ស្តាប់នោះ» ។

មុននឹងអនុញ្ញាតឲ្យ ពេជ អង្គ ឆ្លើយតប ប្រធាន និល ណុន បានស្តីបន្ទោស ខាណាវ៉ាស ថាបើសិនជានៅនិយាយរឿងនេះចុះឡើងៗ ទៀតនោះសវនាការនេះអាចស៊ីពេលរាប់ខែឯណោះ ។ និល ណុន បានណែនាំដល់មេធាវីជនជាប់ចោទឲ្យចាំការឆ្លើយតបពីភាគីព្រះរាជអាជ្ញានិងដើមបណ្តឹងរដ្ឋប្បវេណីជាមុនសិនមុន នឹងឡើងនិយាយទៀត ។ ទីបញ្ចប់ ពេជ អង្គ ត្រូវបានផ្តល់សិទ្ធិឲ្យនិយាយ ហើយបញ្ជាក់ថាជាការចាំបាច់ណាស់ដែល អៀង សារី ត្រូវមានវត្តមាននៅក្នុងបន្ទប់សវនាការ ហើយក៏ជារឿងចាំបាច់ដែរដែល អៀង សារី ត្រូវដឹងពត្ពីបទចោទប្រកាន់មកលើគាត់ដោយផ្ទាល់និងដើម្បីបង្ហាញដល់សាធារណជននិងដើមបណ្តឹងរដ្ឋប្បវេណីថាជនជាប់ចោទម្នាក់នេះមានឆន្ទៈនឹងចូលរួមក្នុងដំណើរការសវនាការ ។

ក្រោយពីពិភាក្សាគ្នា នៅកន្លែងចៅក្រមបន្តិចរួមមក ប្រធានចៅក្រម និល ណុន បានបញ្ជាក់ថា ដើម្បីបង្ហាញខ្លួនដល់គ្រប់ភាគីទាំងអស់និងសាធារណជនថាជនជាប់ចោទបានដឹងពត្ពីបទចោទប្រកាន់ទាំងអស់មកលើខ្លួនសំណើរបស់ អៀង សារី ដែលចង់ចាកចេញពីបន្ទប់សវនាការត្រូវបានបដិសេធ ។ ទង្វើនេះបានធ្វើឲ្យអ្នកចូលរួមម្នាក់នៅក្នុងសាលសម្រាប់អ្នកចូលរួមមានចិត្តរីករាយយ៉ាងខ្លាំងក្រោយមកអ្នកចូលរួមម្នាក់នោះបានឈប់ទៅវិញដោយសារតែមានសន្តិសុខម្នាក់សម្លឹងមកមើល ។

## សហព្រះរាជអាជ្ញាបន្តសេចក្តីថ្លែងការណ៍បើក

ក្រោយពីបញ្ចប់រឿងរ៉ាវបឋមទាំងអម្បាលម៉ានតុលាការបានជូនពេលវេលាទៅសហព្រះរាជអាជ្ញាឲ្យបញ្ចប់សេចក្តីថ្លែងការណ៍ដែលបន្តពីថ្ងៃម្សិលមិញ ។ សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បានក្រោកឈរដើម្បីបន្តសេចក្តីថ្លែងការណ៍របស់គាត់ ។ ខណៈពេលដែលនិយាយឡើងវិញនូវពាក្យពេចន៍មួយចំនួនដែលបានលើកឡើងដោយព្រះរាជអាជ្ញាជាតិកាលពីម្សិលមិញទាក់ទងទៅនឹងពាក្យដែលថា កម្ពុជាប្រជាធិបតេយ្យគឺជារដ្ឋទាសករ និងជា «គុកឥតជញ្ជាំង» នោះ លោក ខេលី បានចំណាយពេលរៀបរាប់ពីភស្តុតាងខ្លះដែលព្រះរាជអាជ្ញានឹងបង្ហាញអំឡុងពេលកិច្ចដំណើរការសវនាការ ជាពិសេសបង្ហាញពីចំណុចសំខាន់មួយចំនួនដែលព្រះរាជអាជ្ញាបានអះអាងនិងបង្ហាញពីតួនាទី និងអំណាចរបស់ជនជាប់ចោទទាំងបីរូបនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជានិងរបបកម្ពុជាប្រជាធិបតេយ្យ ។

ដោយសម្អាងទៅលើតារាងរចនាសម្ព័ន្ធចាត់តាំងរបស់បក្សកុម្មុយនីស្តកម្ពុជា លោក ខេលី បានអះអាងថាបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តអំណាចរបស់ខ្លួនទាំងបីផ្នែកគឺអាជ្ញាធរដឹកនាំនៅមូលដ្ឋាន អំណាចយោធា និងស្ថាប័នរដ្ឋាភិបាលទាំងអស់ ។

ដោយបញ្ជាក់ពីចំណុចសំខាន់នៃរចនាសម្ព័ន្ធចាត់តាំងនៅមូលដ្ឋានរបស់បក្សកុម្មុយនីស្តកម្ពុជា លោក ខេលី បានបកស្រាយថាខណៈពេលដែលព័ត៌មានទាំងឡាយបញ្ជូនពីក្រោមឡើងទៅលើនៅក្នុងរចនាសម្ព័ន្ធនេះ បទបញ្ជាទាំងឡាយមានប្រភពចេញពីថ្នាក់លើចុះមកថ្នាក់ក្រោមវិញទៅកាន់ភូមិភាគ តំបន់ ស្រុក ហើយនិងឃុំដែលទាំងនេះបង្កើតឲ្យមានរបបកម្ពុជាប្រជាធិបតេយ្យ ។ លោក ខេលី បានបញ្ជាក់ថាលក្ខន្តិកៈនិងបទបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាបានតម្រូវថាតំបន់នីមួយៗត្រូវរាយការណ៍ទៅថ្នាក់លើរបស់ខ្លួនជានិច្ច ហើយមកដល់ខែមីនាឆ្នាំ ១៩៧៦ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានចេញបទបញ្ជាឲ្យមានការរាយការណ៍ទៅថ្នាក់លើរៀងរាល់សប្តាហ៍ ។ លោក ខេលី បានបន្ថែមទៀតថាអ្នកបញ្ជូនទូរលេខផ្ទាល់ដែលធ្លាប់បានបញ្ជូនរបាយការណ៍ទាំងអស់នោះនឹងចូលមកធ្វើសក្ខីកម្មនៅក្នុងអង្គសវនាការនេះដែលបែបផែននៃការបញ្ជូនរបាយការណ៍នោះសុទ្ធតែមានឈ្មោះជនជាប់ចោទទាំងបីនាក់ ហើយលោក ខេលី បានបន្ថែមទៀតថា ជាពិសេស នួន ជា គឺជាអ្នកឆ្លើយតបទៅនឹងទូរលេខទាំងនោះដោយចាត់ទុកនរណាម្នាក់ជា «ខ្មាំង» នៅក្នុងភូមិភាគនីមួយៗ ។ លោក ខេលី បានសម្អាងទៅលើឯកសារជាភស្តុតាងនៅក្នុងសណ្ឋានជាទូរលេខមួយចំនួនដែលព្រះរាជអាជ្ញាចោទប្រកាន់ជនជាប់ចោទទាំងបីនេះថាមានជាប់ពាក់ព័ន្ធទៅនឹងការធ្វើបន្សុទ្ធកម្មនិងការសម្លាប់ទាំងទាហានវៀតណាមនិងជនសង្ស័យដែលត្រូវចោទថាជា «ជនបង្កប់» ក្នុងជួរបក្ស

កុម្មុយនីស្តកម្ពុជា ។

លោក ខេលី បានគូសបញ្ជាក់ទៀតថា រចនាសម្ព័ន្ធយោធា និងទីភ្នាក់ងាររដ្ឋាភិបាលត្រូវបានតម្រូវឲ្យបញ្ជូនរបាយការណ៍ទៅថ្នាក់ដឹកនាំបក្សជាប្រចាំ ជាពិសេសបញ្ជូនទៅកាន់គណៈមជ្ឈិមបក្ស ។ លោក ខេលី បានបញ្ជាក់ថា សាក្សីមកពីរចនាសម្ព័ន្ធយោធា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនឹងចូលខ្លួនមកធ្វើសក្ខីកម្មអំពីតួនាទីរបស់ជនជាប់ចោទក្នុងការបញ្ជូនរបាយការណ៍នេះផងដែរ ។

លោក ខេលី បានអះអាងទៀតថា តម្រូវការនៃការបញ្ជូនរបាយការណ៍នេះបានបង្ហាញថា ជនជាប់ចោទមិនអាចអះអាងពីភាពស្អាតស្អំរបស់ខ្លួនថាមិនដឹងពីអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយក៏មិនអាចបដិសេធថា ខ្លួនមិនដឹងពីហេតុការណ៍ដែលបានកើតឡើងទាំងអស់នោះដែរ ។ ផ្ទុយមកវិញ ការគ្រប់គ្រងរបស់ជនជាប់ចោទគឺមានលក្ខណៈ «គួរឲ្យភ័យខ្លាចជ្រួតជ្រាបនិងហ្មត់ចត់» ។ ជនជាប់ចោទត្រូវបានជូនដំណឹងនូវហេតុការណ៍គ្រប់យ៉ាងទាំងអស់ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោក ខេលី បានអះអាងដោយធ្ងន់ៗថា បើសិនជាជនជាប់ចោទចង់ហូបផ្លែក្រូចមួយនោះនឹងមានអ្នកបេះផ្លែក្រូចយកទៅជូនជនជាប់ចោទនៅភ្នំពេញមិនខាន» ប៉ុន្តែបើសិនជាម្តាយឬឪពុកបេះក្រូចមួយផ្លែឬចាប់ត្រីមួយឲ្យកូនម្នាក់ហូបដើម្បីជីវិតរស់ឪពុកឬម្តាយនោះនឹងត្រូវចាប់ខ្លួនចាត់ទុកជាខ្មាំង ហើយត្រូវទទួលទារុណកម្មនិងសម្លាប់ផង ។ រាល់សកម្មភាពទាំងអស់ដែលជាអំពើមិនស្តាប់តាមអង្គការនោះនឹងត្រូវទទួលបាននូវការគំរាមកំហែងដោយបក្សកុម្មុយនីស្តកម្ពុជា ហើយត្រូវទទួលរងនូវការធ្វើទារុណកម្មជាក់ជាមិនខានឡើយ ។

### ករណីរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួម

លោក ខេលី បានអះអាងថា ការគ្រប់គ្រងគ្រប់ច្រកល្ហកបែបនេះមិនត្រូវបន្ទោសលើ ប៉ុល ពត តែម្នាក់ឯងបានទេ ។ ផែនការនិងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានរៀបចំនិងអនុវត្តជាប្រព័ន្ធនៅថ្នាក់តំបន់ថ្នាក់យោធានិងរដ្ឋាភិបាល ។ លោក ខេលី បានបង្ហាញថា «អំពើឃោរឃៅទាំងនេះមិនមែនធ្វើឡើងដោយមនុស្សតែម្នាក់នោះទេ» តែតាមរយៈ «ផែនការរួមមួយឬសហកម្មឧក្រិដ្ឋកម្មរួម» ដែលជនជាប់ចោទទាំងបីនាក់សុទ្ធតែដឹងនិងចូលរួមប្រព្រឹត្តដោយសុឆន្ទៈ» ។ ខណៈពេលដែលជនជាប់ចោទទាំងបីនាក់កំពុងត្រង់ត្រាប់ស្តាប់ដោយមិនបានបញ្ចេញកាយវិការឆ្លើយតបណាមួយ លោកព្រះរាជអាជ្ញាបានបញ្ជាក់សាឡើងវិញអំពីបទចោទប្រកាន់ទាំងអម្បាលម៉ានប្រឆាំងនឹងជនជាប់ចោទនិងបង្ហាញសាឡើងវិញអំពីភ័ស្តុតាងនិងសកម្មភាពផ្ទាល់ខ្លួនរបស់ជនជាប់ចោទដែលព្រះរាជអាជ្ញាទាមទារនិងបង្ហាញអំពីការចូលរួមប្រព្រឹត្តរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួមព្រមទាំងការទទួលខុសត្រូវជាបុគ្គលពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ ។

ទាក់ទងទៅនឹងបទចោទប្រកាន់អំពីការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង លោក ខេលី បានអះអាងថាគោលនយោបាយនេះកើតឡើងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាមុននឹងការជម្លៀសទីក្រុងភ្នំពេញមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ទៅទៀត ហើយគោលនយោបាយនេះចាប់ផ្តើមឡើងដោយយុទ្ធសាស្ត្រមានផែនការយ៉ាងហ្មត់ចត់ដែលបានគ្រោងទុកជាច្រើនឆ្នាំមកហើយ ហើយបានអនុវត្តជាច្រើនកន្លែងរួចមកហើយដែរ នៅក្នុងតំបន់ដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា ។ លោក ខេលី បានគូសបញ្ជាក់ពីចំណុចសំខាន់ៗថា នៅក្នុងសេចក្តីថ្លែងសុន្ទរកថាមួយកាលពីឆ្នាំ១៩៧៨នៅប្រទេសកូរ៉េខាងជើងដែលធ្វើឡើងដោយ ខៀវ សំផន ដែលនៅក្នុងនោះគាត់បាននិយាយពី «ការអួតអាង» ពីភាពជោគជ័យរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងឲ្យទៅកាន់ទីជនបទ ។ លោក ខេលី ក៏បានគូសបញ្ជាក់ អំពីការថ្លែងសុន្ទរកថារបស់ នួន ជា ក្នុងឆ្នាំ១៩៧៧ ដែលនៅពេលនោះគាត់បានរៀបរាប់ពីការជម្លៀសប្រជាជនគឺជាផ្នែកមួយនៃ «ការតស៊ូវណ្ណៈ» និងជាយុទ្ធសាស្ត្រដ៏សំខាន់របស់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដោយសារតែមាន «សត្រូវតិចតួចនៅជនបទ» តែមានច្រើនកំពុងលាក់ខ្លួនក្នុងទីក្រុង ។

ទាក់ទងទៅនឹងអ្វីដែលគាត់ហៅថា «គោលនយោបាយទីពីរនៃសហកម្មឧក្រិដ្ឋកម្មរួម» ដោយការបង្កើតឡើងនូវសហករណ៍និងការដ្ឋានការងារដូចទាសករ ព្រះរាជអាជ្ញាបានរំឭកអំពីជំហានជាច្រើនដែលច្រើនប្រព្រឹត្តឡើងដោយបក្សកុម្មុយនីស្តកម្ពុជាដើម្បីធ្វើឲ្យប្រទេសជាតិទាំងមូលទៅជា «គុកឥតជញ្ជាំង» ។ លោក ខេលី បានដកស្រង់ពាក្យដែលថ្លែងដោយ នួន ជា កាលពីឆ្នាំ១៩៧៧

ដែលបាននិយាយអំពីការបង្កើតនិងការអនុវត្តសហករណ៍ដែលគ្មាននរណាម្នាក់នឹងត្រូវអនុញ្ញាតឲ្យដាំបន្លែខ្លួនឯងដើម្បីហូប ។ លោក ខេលី បានបញ្ជាក់ថា នៅក្នុងអំឡុងនៃការថ្លែងសុន្ទរកថាកាលពីឆ្នាំ១៩៧៧ នួន ជា បានសំដៅទៅលើកម្មាភិបាលភូមិភាគបស្ចិមដែលបានរិះគន់នៅក្នុងសហករណ៍ដែលកាលនោះកម្មាភិបាលនោះក៏នៅទីនោះដែរដោយកម្មាភិបាលនោះបញ្ជាក់ថា គោរបស់ឯកជនធាត់ជាងគោនៅសហករណ៍ ហើយបន្ទាប់ពីនោះមក កម្មាភិបាលនោះត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១ ហើយបង្ខំឲ្យកម្មាភិបាលនោះសរសេរចម្លើយសារភាពយ៉ាងវែងនិងឲ្យសារភាពថាជាជនក្បត់ ។

លោក ខេលី បានបញ្ជាក់ឲ្យច្បាស់ថា «ការរំពឹងទុកដែលគ្មានតថភាព» របស់មជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជាដែលបានអះអាងអំពី «បីតោនក្នុងមួយហិកតា» នៃទិន្នផលស្រូវ ហើយនិងផែនការក្នុងការបង្កើនបរិមាណទឹកពី២០០ទៅ៣០០ភាគរយក្នុងរយៈពេលមួយឆ្នាំដោយការសាងសង់ទំនប់ប្រឡាយធំៗ ។ ការរំពឹងទុកទាំងអស់នេះបានធ្វើឲ្យប្រជាជនកម្ពុជាធ្វើការយ៉ាងនឿយហត់ទាំងថ្ងៃទាំងយប់ទោះបីជាអ្នកនោះមានជំងឺហេវហត់និងជួបគ្រោះអត់ឃ្លានយ៉ាងណាក៏ដោយ ។ ជនជាប់ចោទទាំងបីសុទ្ធតែដឹងពីស្ថានភាពអមនុស្សធម៌ទាំងអស់ព្រោះជនជាប់ចោទធ្លាប់ទៅទស្សនានិងត្រួតពិនិត្យមើលការដ្ឋានការងារជាញឹកញាប់ដែលសាក្សី និងចូលមកបំភ្លឺអំពីរឿងនេះដែរ ។

គោលនយោបាយទីពីរ គឺសហកម្មខុក្រិដ្ឋកម្មរួមដូចជាការយកទៅអប់រំចំពោះអ្នកដែលមាន «សមាសភាពមិនល្អ» និងការសម្លាប់សត្រូវដែលរួមមានការចាប់ខ្លួនមនុស្សដោយខុសច្បាប់ ការឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់នរណាម្នាក់ដែលត្រូវបានចោទថាជាជនក្បត់ជនបង្កប់ឬជាខ្មាំង ។ គោលនយោបាយនេះបានចាប់ផ្តើមក្នុងខែវិច្ឆិកា ឆ្នាំ១៩៦០នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបង្កើតក្រុមឈ្លបយកការណ៍របស់ខ្លួនដើម្បីប្រើអំពើហិង្សាដោយអាវុធដើម្បីកម្ចាត់សត្រូវ ។ មាគ៌ារបស់បក្សគឺ «ជាគ្រឹះនៃរបៀបវារៈរបស់ជនជាប់ចោទ» ហើយគ្រប់សមាជិកបក្សទាំងអស់ត្រូវតម្រូវឲ្យទទួលយកនូវមាគ៌ាទាំងអស់នេះ ។

លោក ខេលី បានបញ្ជាក់ដែរថា ថ្ងៃនេះ នួន ជា បានទទូចថា អ្នកដែលត្រូវសម្លាប់នៅក្នុងរបបខ្មែរក្រហមគឺជាសត្រូវឬជនក្បត់ ។ ក្រោយមក ព្រះរាជអាជ្ញាបានបង្ហាញខ្សែវីដេអូខ្លីមួយអំពីបទសម្ភាសន៍ដែលនៅក្នុងនោះ នួន ជា ផ្ទាល់បានបញ្ជាក់ថាមានក្រុមបង្កប់ខ្លួនជាច្រើនដែលដំបូងគឺក្រុមម្ចាស់ដី នាយទុននិងបញ្ញវន្ត ហើយបង្កប់នៅក្នុង «សត្រូវផ្ទៃក្នុង» ដូចជា ខ្មែរក្រោម និងជនជាតិភាគតិចចាមនិងស្ទើរតែមនុស្សគ្រប់គ្នានៅភូមិភាគបូព៌ា «ដែលបទល្មើសរបស់អ្នកទាំងនោះគឺការជិតស្និទ្ធជាមួយវៀតណាម» ។

លោក ខេលី បានអះអាងថា ជនជាប់ចោទបានចូលរួមក្នុងការអនុវត្តដោយផ្ទាល់នៅក្នុងគោលនយោបាយនេះតាមរយៈតួនាទីរបស់ខ្លួនជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ។ លោក ខេលី បានណែនាំសាក្សីសំខាន់មួយគឺជាប្រធានមន្ទីរស-២១ដែលបានរៀបរាប់អំពីជនជាប់ចោទម្នាក់ៗ ហើយជាពិសេស នួន ជា ដែលបានជាប់ពាក់ព័ន្ធទៅនឹងការចាប់ខ្លួននិងការផ្តល់សិទ្ធិឲ្យធ្វើការ «កម្ទេច» និងឲ្យអនុវត្តការសម្លាប់ ។

លោក ខេលី បានបញ្ជាក់ត្រង់ៗពីតួនាទីផ្ទាល់របស់ អៀង សារី នៅក្នុងគោលនយោបាយជារដ្ឋមន្ត្រីក្រសួងការបរទេស ។ លោក ខេលី បានពិពណ៌នាអំពីអ្វីដែល អៀង សារី ទទួលខុសត្រូវក្នុងការកំណត់ពីអត្តសញ្ញាណរបស់សត្រូវនៅក្នុងក្រសួងការបរទេសនិងជាអ្នកសម្រេចថាតើនរណានឹងត្រូវបញ្ជូនទៅធ្វើការនៅសហករណ៍ឬទៅមន្ទីរស-២១ ។ ពេលនោះ អៀង សារី បានស្តាប់ដោយមិនដឹងអ្វីទាំងអស់ដោយអង្គុយនៅកៅអីរបស់ខ្លួន ។ អៀង សារី មានសិទ្ធិអំណាចនិង «កំណត់ជីវិតរបស់កម្មាភិបាលរបស់គាត់» ហើយគាត់មានសិទ្ធិនឹងការពារពីការចាប់ខ្លួននៃសមាជិកមិត្តភក្តិដែលគាត់ស្គាល់កាលពីពេលដែលគាត់រៀននៅប្រទេសបារាំងជាមួយគ្នា ។ ដោយទទួលស្គាល់ថា អៀង សារី គួរតែត្រូវបានសរសើរដោយសារតែគាត់បានជួយជីវិតមនុស្សជាច្រើននាក់លោក ខេលី បាន បញ្ជាក់ថា អៀង សារី បានប្រើសិទ្ធិអំណាចរបស់ខ្លួនដើម្បីការពារជីវិតមនុស្សបានជាច្រើននាក់នៅក្រសួងការបរទេសដើម្បីបញ្ជូនអ្នកទាំងនោះទៅកន្លែងមួយសម្រាប់អ្នកដែលជាប់សង្ស័យដែលមានឈ្មោះថា «បន្ទប់មរណៈ» ។

បន្ថែមពីនេះទៀត នៅក្នុងតួនាទីរបស់គាត់ជា «អ្នកតំណាងដ៏ខ្ពង់ខ្ពស់ទៅកាន់សហគមន៍អន្តរជាតិ» របស់បក្សកុម្មុយ

នីស្តកម្ពុជា លោក ខេលី បានអះអាងថា អៀង សារី តែងតែបដិសេធអំពីការសម្លាប់ពេលដែលគាត់ត្រូវបានសួរនាំដោយសហគមន៍អន្តរជាតិហើយគាត់បានច្រានចោលការចោទប្រកាន់ទាំងឡាយអំពីការរំលោភសិទ្ធិមនុស្សជា «មាស៊ីនឃោសនារបស់ពួកចក្រពត្តិ» ។

ដូចគ្នានេះដែរ ទាំង ខៀវ សំផន និង នួន ជា សុទ្ធតែបានចូលរួមដោយផ្ទាល់ក្នុងផែនការយកទៅអប់រំនិងសម្លាប់សត្រូវ ។ ដកស្រង់ចេញពីសម្តីរបស់ ខៀវ សំផន ក្នុងឆ្នាំ១៩៧៧ លោក ខេលី បានរាយការណ៍ថា ខៀវ សំផន បានទទូចឲ្យសមាជិកបក្សរបស់ខ្លួនដើម្បី «បោសសម្អាតសត្រូវ» ។ សម្រាប់ នួន ជា លោក ខេលី បានរៀបរាប់ដោយត្រួសៗអំពីការរំពឹងទុកក្នុងការធ្វើសក្ខីកម្មរបស់ ឌុច ដែលនិងចូលមកបង្ហាញថា គាត់ត្រូវបញ្ជូនចម្លើយសារភាពទៅ នួន ជា រៀងរាល់បីទៅប្រាំថ្ងៃម្តងដើម្បីត្រួតពិនិត្យ ។ ហើយនៅក្នុងបទសម្ភាសន៍មួយក្នុងឆ្នាំ២០០៥ដែលបង្ហាញដោយព្រះរាជអាជ្ញាទៅកាន់តុលាការ នួន ជា បាននិយាយថា ខ្មែរក្រហម «សម្លាប់តែសមាសភាពអាក្រក់តែប៉ុណ្ណោះ ជនក្បត់ទាំងនេះមិនដើរតាមមាគ៌ានយោបាយរបស់យើងទេ» ។

ក្រោយមក លោក ខេលី បានពិភាក្សាអំពីគោលនយោបាយទីបួនរបស់បក្សកុម្មុយនីស្តកម្ពុជាដែលកំណត់គោលដៅក្នុងការសម្លាប់ចំពោះជនជាតិចាម វៀតណាម និងអ្នកដែលគោរពពុទ្ធសាសនា ។ ដោយរៀបរាប់ឡើងវិញនូវអ្វីដែល ជា លាង បានរៀបរាប់កាលពីម្សិលមិញ លោក ខេលី បានរំឭកម្តងទៀតពីគោលនយោបាយបិទទ្វារវត្តអារាមទាំងអស់និងការផ្សឹកលោកសង្ឃហើយក្រោយមក សម្លាប់ជនជាតិវៀតណាម ។ លោក ខេលី បានបញ្ជាក់ត្រង់ៗថា នៅក្នុងទូរលេខមួយកាលពីខែវិច្ឆិកាឆ្នាំ១៩៧៥ ដែលចម្លងជូន នួន ជា បានបញ្ជាឲ្យបញ្ជូនចេញជនជាតិចាមចំនួនប្រាំម៉ឺននាក់ពីភូមិភាគបូព៌ា ។

ឆ្លើយតបទៅនឹងសំណួរណាមួយអំពីថាតើការសម្លាប់ជនជាតិភាគតិចចាមនិងវៀតណាមអាចជាអំពើប្រល័យពូជសាសន៍ដែរឬទេនោះ ឬថាតើនេះជាផែនការដ៏ធំធែងដើម្បីបន្សុទ្ធសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជាមែននោះ លោក ខេលី បានអះអាងថា ចំណុចទាំងពីរខាងលើគឺសុទ្ធតែត្រូវ ។ លោក ខេលី បានបកស្រាយថា ខៀវ សំផន បានអំពាវនាវឲ្យ «មានការស្អប់ជនជាតិវៀតណាម» នៅក្នុងការថ្លែងសុន្ទរកថារបស់គាត់ដោយរៀបរាប់ពីអំពើប្រល័យពូជសាសន៍មកលើជនជាតិវៀតណាម ។ លោក ខេលី ក៏បានបញ្ជាក់ផងដែរថា ក្រុមជនជាតិភាគតិចចាមមិនត្រូវបានចាត់ទុកស្មើគ្នាទៅនឹងជនសង្ស័យដែលជាសត្រូវផ្សេងទៀតទេ ដោយលោកបានធ្វើការប៉ាន់ប្រមាណថា «បើសិនអ្នកគឺចាម អ្នកគឺជាខ្មាំង» ។

ទីបញ្ចប់ទាក់ទងទៅនឹងបទបញ្ជានៃការរៀបការ លោក ខេលី បានរៀបរាប់រឿងរ៉ាវរបស់ស្ត្រីមួយចំនួនដែលបានទទួលរងផលប៉ះពាល់ដោយការចាប់បង្ខំឲ្យរៀបការហើយ ជាពិសេសមានស្ត្រីម្នាក់ត្រូវបានសម្លាប់ដោយសារតែគាត់បានលួចស្រឡាញ់មនុស្សប្រុសម្នាក់ដោយគ្មានការអនុញ្ញាតពីអង្គការ ។ គោលនយោបាយទាំងអស់នេះត្រូវបានលោក ខេលី ហៅថា «សុបិន្តអាក្រក់ហួសនិស្ស័យរបស់បក្សកុម្មុយនីស្តកម្ពុជា» ។



សាធារណជនដើរចេញពីបន្ទប់សវនាការខែវិច្ឆិកា ឆ្នាំ២០១១

នៅក្នុងសេចក្តីសន្និដ្ឋាន លោក ខេលី បានទទូចឲ្យតុលាការ «នាំយកមកនូវវិធានការតូចៗនៃភាពយុត្តិធម៌» ដើម្បីជូនចំពោះប្រជាជនកម្ពុជា ។ លោកបានបញ្ជាក់ថា តុលាការមាន «ឱកាសតែមួយគត់ដើម្បីដោះស្រាយទៅនឹងបញ្ហានិទ្ទណ្ឌភាពទាំងនេះ» និងដើម្បីផ្តល់ការព្រមានមួយពីអតីតកាលទៅអនាគត ។ ខណៈពេលដែលសហព្រះរាជអាជ្ញាទាំងពីរមិនបានធ្វើការអះអាងថាប្រទេសផ្សេងទៀតបានរួមចំណែកក្នុងអំពើសោកនាដកម្មនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជាដែរនោះ លោក ខេលី បាន បញ្ជាក់ថា ជនជាប់ចោទមិនអាចយកលេសប្រទេសក្រៅដើម្បីមកដោះសារពីអ្វីដែលបានកើតឡើងចំពោះប្រជាជនកម្ពុជាបានទេ ។

ដោយសំឡេងញ័រៗដែលបង្ហាញពីអារម្មណ៍រំជួលចិត្តរបស់គាត់ លោក ខេលី បានរំឭករឿងរ៉ាវរបស់បុរសម្នាក់ដែលជាមនុស្សម្នាក់គត់ដែលបានរួចផុតពីការកាប់សម្លាប់រង្គាលមួយនៅក្នុងខេត្តសៀមរាបកាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ដែលនៅក្នុងនោះសមាជិកគ្រួសាររបស់គាត់ទាំងមូលត្រូវបានសម្លាប់ដោយការវាយនឹងដំបងឲ្យស្លាប់ ។ នាពេលបច្ចុប្បន្ននេះ បុរសម្នាក់នេះកំពុងតែកសាងសាលារៀនបច្ចេកទេសមួយនៅលើទីតាំងដែលសមាជិកគ្រួសាររបស់គាត់ត្រូវបានសម្លាប់ ។ លោក ខេលី បានប្រកាសថា «តើម្នាក់ៗបាត់បង់ច្រើនប៉ុនណា» ដោយស្នាដៃ «ចោរនៃការសម្លាប់មនុស្សគ្រប់ជំនាន់បែបនេះ ។ គ្មាននរណាម្នាក់មិនទទួលសោកនាដកម្មដោយស្នាដៃជនជាប់ចោទចំណាស់ទាំងបីនាក់នេះទេ» ។

## សំណើរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធ

ក្រោយពីការធ្វើសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញានៅក្នុងសេចក្តីថ្លែងការណ៍បើកតុលាការបានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីនាំមុខ ពេជ អង្គ ឲ្យឡើងនិយាយ ។ ពេជ អង្គ បានស្នើឲ្យមានការបញ្ជាក់ឲ្យច្បាស់ឡើងវិញពីតុលាការត្រង់ពីរចំណុច ។ ទីមួយថាតើពេលណាទើបភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យទទួលស្គាល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិថ្មីទាំងបីនាក់ ។ ទីពីរ ពេជ អង្គ បានស្នើទៅតុលាការឲ្យពិចារណាសេចក្តីសម្រេចរបស់ខ្លួនឡើងវិញចំពោះការមិនឲ្យភាគីបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីថ្លែងការណ៍នៅក្នុងអង្គសវនាការ ។

ឆ្លើយតបទៅនឹង ពេជ អង្គ ប្រធានចៅក្រម និល ណុន បានបញ្ជាក់ថាការណែនាំខ្លួនអាចធ្វើនៅចុងបញ្ចប់នៃដំណើរការសវនាការនេះដោយការណែនាំខ្លួនត្រូវបានពន្យារពេលកាលពីថ្ងៃម្សិលមិញដោយសារកំហុសបច្ចេកទេស ។ ចំពោះសំណើទីពីរ និល ណុន បានឆ្លើយតបដោយបញ្ជាក់ម្តងទៀតថា វិធានផ្ទៃក្នុង៨៩ស្ទួនមិនបានបញ្ជាក់សិទ្ធិណាមួយរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីធ្វើសេចក្តីថ្លែងការណ៍បើកនោះទេ ហើយថាអង្គសវនាការបានជម្រាបជាលាយលក្ខណ៍អក្សរច្បាស់ហើយថាការធ្វើសេចក្តីថ្លែការណ៍បើកឬការកត់សម្គាល់ណាមួយដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនយកមកពិចារណាដោយអង្គសវនាការបានឡើយ ។ ដូច្នេះតុលាការសូមធ្វើការជំទាស់សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដោយសារតែ ពេជ អង្គ នៅតែឈរនៅឡើយ និល ណុន បានប្រកាសឲ្យសម្រាកថ្ងៃត្រង់ ។

## ការឆ្លើយតបរបស់ នួន ជា ទៅនឹងសេចក្តីថ្លែងការណ៍របស់ព្រះរាជអាជ្ញា

ក្រោយពីសម្រាកអាហារថ្ងៃត្រង់រួច ដំណើរការសវនាការចាប់ផ្តើម ។ និល ណុន បាន ប្រកាសថា ពេលនេះជនជាប់ចោទម្នាក់ៗ នឹងត្រូវបានផ្តល់ឱកាសដើម្បីឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍របស់ព្រះរាជអាជ្ញា ។ បន្ទាប់មក និល ណុន បានផ្តល់ឱកាសនេះទៅមេធាវីការពារក្តីរបស់ នួន ជា ដើម្បីធ្វើការឆ្លើយតបមុនគេដោយបញ្ជាក់ថា នួន ជា នឹងត្រូវអនុញ្ញាតឲ្យអង្គុយអំឡុងពេលអានសេចក្តីថ្លែងរបស់ខ្លួនដោយសារតែគាត់មានភាពចាស់ជរា ។

ម៉ៃឃើល ផេស្តមេន សហមេធាវីអន្តរជាតិរបស់ នួន ជា បានបញ្ជាក់ថា «សេចក្តីថ្លែងការណ៍ដ៏ខ្លីកំប៉ុត» របស់សហព្រះរាជអាជ្ញាបានធ្វើឲ្យក្រុមរបស់ នួន ជា មានការភ្ញាក់ផ្អើល ។ ដោយសារតែក្រុមមេធាវីរបស់ នួន ជា មិនទាន់មានឱកាសនឹងពិភាក្សាអំពីសេចក្តីថ្លែងការណ៍ជាមួយកូនក្តីរបស់ខ្លួនផង មេធាវី ផេស្តមេន បានស្នើទៅចៅក្រមដើម្បីបែងចែកការឆ្លើយតបរបស់ខ្លួនជាពីរវគ្គ ៖ ទីមួយ នួន ជា នឹងធ្វើការឆ្លើយតបនៅរសៀលនេះដែលមានរយៈពេលប្រហែលជាពីរម៉ោងរួមទាំងពេលសម្រាកផងដោយសារតែគាត់មានការលំបាកក្នុងការអាន ទីពីរមេធាវីនឹងឡើងនិយាយនៅព្រឹកស្អែកដែលនឹងត្រូវចំណាយពេល៤៥នាទី ។

ក្រោយពីពិភាក្សាជាមួយចៅក្រមផ្សេងទៀតរួចមក និល ណុន បានឆ្លើយតបទៅវិញថា អង្គជំនុំជម្រះបានកំណត់កាលវិភាគរួចហើយសម្រាប់ដំណើរការកាត់ក្តីនេះ ម្យ៉ាងវិញទៀត មេធាវីការពារក្តីគួរតែដឹងមុនថា ខ្លួនមានពេលកន្លះថ្ងៃប៉ុណ្ណោះដើម្បីឆ្លើយតប ។ មេធាវី ផេស្តមេន បានបញ្ជាក់សំណើរបស់ខ្លួនឡើងវិញដោយបញ្ជាក់ថា ខ្លួនមិនសុំម៉ោងបន្ថែមទេ តែខ្លួនសុំបន្តនៅថ្ងៃស្អែកទៀត ដោយសារតែនៅថ្ងៃស្អែកនេះភាគីការពារក្តីនឹងត្រូវអនុញ្ញាតឲ្យឆ្លើយតប ។

តុលាការបានស្នើទៅមេធាវីការពារក្តីឲ្យបង្ហាញភ័ស្តុតាងឯកសារណាមួយដែលបញ្ជាក់ថា មេធាវីការពារក្តីមិនត្រូវឆ្លើយតបទេរហូតដល់ថ្ងៃស្អែក ។ នៅពេលដែលមេធាវី ផេស្តមេន មិនអាចផ្តល់ឯកសារពិតប្រាកដណាមួយ និល ណុន បានបញ្ជាក់ថា អង្គសវនាការមិនយកសំណើនោះទៅលេងសើចទេ ហើយថា ក្រុមរបស់ នួន ជា នឹងត្រូវតែឡើងថ្លែងក្នុងពេលវេលារបស់ខ្លួននៅរសៀលនេះ ។

ទោះបីជាចម្លើយរបស់ចៅក្រម និល ណុន ធ្វើឲ្យគាត់មានអារម្មណ៍បង្អាក់ទឹកចិត្តក៏ដោយ មេធាវី ផេស្តមេន បានបន្តទៅមុខទៀតដោយឲ្យ នួន ជា ឡើងឆ្លើយតបទៅនឹងសេចក្តីថ្លែងរបស់ព្រះរាជអាជ្ញាដោយបញ្ជាក់ថាខុសពីព្រះរាជអាជ្ញាដែលរៀបរាប់ពីបទចោទប្រកាន់ទាំងអស់នៅក្នុងដីកាដំណោះស្រាយក្រុមការពារក្តីសម្រេចចិត្តថានឹងធ្វើការរៀបរាប់ដោយកំណត់ត្រឹមតែនៅបញ្ហាមួយចំនួនដែលនឹងត្រូវយកមកនិយាយនៅក្នុងសវនាការដាក់ដោយឡែកប៉ុណ្ណោះដូចជា ប្រវត្តិរបស់បក្សកុម្មុយនីស្តកម្ពុជាបុព្វបទប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យការជម្លៀសប្រជាជនចេញពីទីក្រុង និង «ដំណាក់កាលទីពីរ» នៃការចល័តប្រជាជន ។ មេធាវី ផេស្តមេន បានរាយការណ៍ថា ក្រុមការពារក្តីរបស់ នួន ជា បានស្នើឲ្យចៅក្រម ខាត់ វ៉្រាយត៍ លាលែងពីតំណែងកាលពីម្សិលមិញ ហើយនៃពេលនេះក្រុមការពារក្តីបានលើកយកបញ្ហានេះមកនិយាយម្តងទៀត ដោយឲ្យចៅក្រម ខាត់វ៉្រាយត៍ លាលែងពីតំណែង ។ ទីបញ្ចប់ មុននឹងហុចឱកាសនេះទៅ នួន ជា មេធាវី ផេស្តមេន បានកំណត់ថា ខណៈពេលដែលក្រុមរបស់ខ្លួន «កម្រយល់ស្រប» ជាមួយភាគីដើមបណ្តឹងរដ្ឋប្បវេណីខ្លួនក៏មានជំនឿថាដែរភាគីដើមបណ្តឹងរដ្ឋប្បវេណីគួរតែផ្តល់ឱកាសដើម្បីធ្វើសេចក្តីថ្លែងការណ៍ឬឆ្លើយតបនៅក្នុងតុលាការ ។

ក្រោយពី មេធាវី ផេស្តមេន បានបញ្ចប់យោបល់ និល ណុន បានណែនាំឲ្យសន្តិសុខនាំខ្លួន នួន ជា មកកាន់ទីក្រចកសេះ ។ ដោយមានជំនួយពីកងសន្តិសុខពីរនាក់ នួន ជា ត្រូវបានរំកិលខ្លួនទៅកាន់ទីក្រចកសេះដោយអង្គុយបែរខ្នងទៅអ្នកចូលរួមដែលអមដោយកងការពារពីរនាក់ ។ ដោយដឹងថាជនជាប់ចោទម្នាក់ត្រូវបានផ្តល់ឱកាសនិងធ្វើសេចក្តីថ្លែងការណ៍ដ៏វែងមួយអ្នកចូលរួមជាច្រើន



នួន ជា នៅក្នុងបន្ទប់សវនាការខែវិច្ឆិកា ឆ្នាំ២០១១ (រូបថត អ.វ.ត.ក)

នាក់មានអារម្មណ៍អន្ទះសានិងចង់ឮនូវអ្វីដែល នួន ជា នឹងនិយាយទៅនឹងអ្វីដែលបានចោទប្រកាន់មកលើខ្លួននោះ ។ តែដោយសារតែសេចក្តីថ្លែងរបស់ នួន ជា ដែលមានរយៈពេលពីរម៉ោងនៅតែបន្តបរិយាកាសនៅក្នុងបន្ទប់អ្នកចូលរួមកាន់តែស្ងាត់ទៅៗ ដោយមិនដឹងថាមកពីសេចក្តីថ្លែងនោះមិនពាក់ព័ន្ធគ្នាឬក៏បណ្តាលមកពីបានចំណាយពេលច្រើនពេកនោះទេ ។

នៅក្នុងសេចក្តីថ្លែងការណ៍នោះ នួន ជា បាននិយាយអំពី

បីចំណុចដែលក្រុមការពារក្តីរបស់គាត់ទំនងជាការពារខ្លួននូវអ្វីគាត់បានពាក់ព័ន្ធនៅក្នុងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ៖ ១) គោលនយោបាយវាតទីនិយមរបស់វៀតណាមដែល នួន ជា អះអាងថាបានធ្វើការគំរាមកំហែងដល់ប្រទេសកម្ពុជាហេតុដូច្នេះកម្ពុជាប្រជាធិបតេយ្យត្រូវតែធ្វើការឆ្លើយតប ២) ការវាយប្រហារតាមអាកាសរបស់សហរដ្ឋអាមេរិកកាលពីទសវត្សរ៍៧០បណ្តាលឲ្យមានវិបត្តិមនុស្សធម៌ពេញផ្ទៃប្រទេសនិង ៣) ការជ្រៀតចូលក្នុងបក្សកុម្មុយនីស្តកម្ពុជានិងចលនាខ្មែរក្រហមដោយជនក្បត់គិញ



និងខ្មាំងក្នុងចំណោមប្រជាជនដែលត្រូវតែលុបបំបាត់ចោល ។ ទោះបីជា នួន ជា ផ្តោតជាសំខាន់ទៅលើតែកិច្ចប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ក៏ប្រធានបទទាំងបីនេះត្រូវបានយកមកនិយាយស្ទើរតែគ្រប់ចម្លើយរបស់ នួន ជា ទាំងអស់ ។

នួន ជា បានឆ្លើយតបដោយការធ្វើភារកិច្ចទៅកាន់តុលាការគ្រប់ភាគីទាំងអស់ និងជនជាតិកម្ពុជាទាំងមូល ។ នួន ជា ក៏បានសម្តែងការគោរពដល់បុព្វការីជនខ្មែរទាំងអស់ «ដែលបានបូជាជីវិត» ដើម្បីធ្វើឲ្យប្រទេសកម្ពុជាមានថ្ងៃនេះនិងដើម្បីជួយប្រទេសនេះ «គេចផុតពីគោលនយោបាយបំបាត់ពូជសាសន៍ ការរឹបអូសដីធ្លី និងចក្រពត្តិនិយម» របស់វៀតណាម និងប្រទេសផ្សេងទៀតដែលមានមហិច្ឆតាបំផ្លិចបំផ្លាញប្រទេសកម្ពុជា ។ ដោយបញ្ជាក់ថាអ្វីដែលខ្លួននឹងនិយាយនេះគឺសម្រាប់ប្រវត្តិសាស្រ្ត និងមែនមែនសម្រាប់ហេតុផលនយោបាយ នួន ជា បានប្រកាន់ជំហរថាដំណើរការទាំងអស់ ហើយនិងតុលាការគឺមានលក្ខណៈ «មិនស្មើភាព» ត្រង់ថា មានតែប្រធានបទណាមួយប៉ុណ្ណោះដែលនឹងយកមកពិភាក្សា ហើយហេតុការណ៍ផ្សេងៗទៀតមុនឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៩ មិនត្រូវបានអើពើទេ ។ នួន ជា បានបកស្រាយថា «មានតែសាកសពខ្លួនក្រពើប៉ុណ្ណោះដែលនឹងត្រូវយកមកពិភាក្សាដោយមិនយកកន្ទុយ និងក្បាលទេ» ។ ក្រោយមក នួន ជា បានឈានចូលទៅរៀបរាប់យ៉ាងលម្អិតអំពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជានៅអាស៊ីអាគ្នេយ៍ ដោយចាប់ផ្តើមពីការផ្តាច់ខ្លួនចេញពី «បក្សកុម្មុយនីស្តឥណ្ឌូចិន» ក្នុងឆ្នាំ១៩៥១ ដោយផ្តាច់ចេញជាបីបក្សផ្សេងៗគ្នាគឺនៅប្រទេសវៀតណាម ឡាវ និងកម្ពុជា ។ តែ នួន ជា បានអះអាងថា កាលនោះបក្សរបស់វៀតណាមនៅតែព្យាយាមចង់គ្រប់គ្រងបក្សទាំងពីរនោះដដែល ។

ដោយប្រើប្រាស់របៀបវារៈនៃកិច្ចប្រជុំរដ្ឋសភានិងកិច្ចប្រជុំបក្សកាលពីទសវត្សរ៍៦០និង៧០ នួន ជា ហាក់បីដូចជាព្យាយាមពន្យល់ពីហេតុផលនៅពីក្រោយគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែការឆ្លើយតបរបស់គាត់បានរំលងសម័យកាលធំៗជាច្រើនដោយរៀបរាប់តែបន្តិចបន្តួចប៉ុណ្ណោះអំពីគោលនយោបាយដែលបានអនុវត្តនៅសម័យកម្ពុជាប្រជាធិបតេយ្យ ហើយក៏បានឆ្លើយតបតិចតួចដែរចំពោះបទឧក្រិដ្ឋដែលបានចោទប្រកាន់មកលើគាត់នៅក្នុងសេចក្តីថ្លែងការណ៍បើករបស់ព្រះរាជអាជ្ញា ។

ជាពិសេស ពេលពិភាក្សាអំពីការប្រជុំសភាឆ្នាំ១៩៧៣ ដែលពេលនោះផែនការជម្លៀសទីក្រុងភ្នំពេញត្រូវបានយកមកពិភាក្សានិងបង្កើតឡើង នួន ជា បានអះអាងបញ្ជាក់ថាបក្សកុម្មុយនីស្តកម្ពុជាត្រូវ «ធ្វើឲ្យអស់ពីសមត្ថភាព» ដើម្បីរំដោះទីក្រុងមុនវៀតណាមអាចរំដោះទីក្រុងរបស់ខ្លួនបាន ព្រោះវៀតណាមនឹង

ប្រើការ «រំដោះ» យកទីក្រុងភ្នំពេញជាលេសក្នុងការវាយប្រហារប្រទេសកម្ពុជា ។ ក្រោយពីទីក្រុងភ្នំពេញរំដោះបានភ្លាមទីក្រុងត្រូវតែធ្វើការជម្លៀសប្រជាជនចេញដើម្បី «ឲ្យដឹងពីចរិតពិតប្រាកដរបស់វៀតណាម»និងដើម្បីបង្កើននូវការសាមគ្គីភាពក្នុងចំណោមប្រជាជនកម្ពុជា ។ ប៉ុន្តែ នួន ជា មិនបាននិយាយពីផលប៉ះពាល់នៃសេចក្តីសម្រេចក្នុងការជម្លៀសប្រជាជននេះ ឬហេតុការណ៍ផ្សេងទៀតដែលបានកើតឡើងដោយសារតែការជម្លៀសនេះទេ ។

បន្ទាប់បញ្ចប់ការរៀបរាប់ពីប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជានិងសេចក្តីសម្រេចរបស់បក្សចប់ នួន ជា បានធ្វើសេចក្តីសន្និដ្ឋានដោយនិយាយថាវិធានការដែលគាត់បានធ្វើក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យគឺដើម្បីបម្រើជាតិនិងប្រជាជនកម្ពុជា ។ នួន ជា បានរក្សាជំហររបស់ខ្លួនថា «អំពើគាបសង្កត់និងអំពើអយុត្តិធម៌បានបង្ខំខ្ញុំឲ្យប្រយុទ្ធប្រឆាំងដើម្បីប្រទេសរបស់ខ្ញុំដោយចាកចេញពីគ្រួសារដើម្បីរំដោះជាតិ» ។ បន្ទាប់មក នួន ជា បានអំពាវនាវឲ្យវៀតណាម «បោះបង់ចោលបំណងប្រាថ្នារបស់ខ្លួនជាបងប្រុស» ហើយបញ្ចប់គោលនយោបាយវាតទីមកលើប្រទេសកម្ពុជា ។ នួន ជា ក៏បានលើកទឹកចិត្តឲ្យប្រជាជនកម្ពុជាទាំងអស់ឲ្យ «បោះបង់ចោលសេចក្តីស្អប់» ចំពោះជនជាតិវៀតណាមធ្វើដូច្នេះទើបប្រជាជនកម្ពុជាទាំងអស់ធ្វើដំណើរទៅមុខទៀតបានទៅថ្ងៃអនាគត ។ ដោយមានសំឡេងអ៊ូៗតិចៗនៅក្នុងបន្ទប់អ្នកសម្រាប់អ្នកមើលក្រោយមក នួន ជា បានបញ្ចប់សេចក្តីឆ្លើយតបរបស់ខ្លួន និងត្រឡប់ទៅកាន់កៅអីរបស់គាត់វិញ ដែលមានទីតាំងនៅពីក្រោយមេធាវីការពារក្តីរបស់គាត់ ។

បន្ទាប់ពី នួន ជា បញ្ចប់សេចក្តីថ្លែងការណ៍របស់គាត់ មេធាវី ដេស្តមេន បានងាកមកនិយាយអំពីសំណើរបស់ខ្លួនដែលបានដាក់ជូនទៅអង្គជំនុំជម្រះរួចហើយក្នុងការអនុញ្ញាតឲ្យមេធាវីការពារក្តីបន្តផ្តល់ចម្លើយឆ្លើយតបទៅសហព្រះរាជអាជ្ញានៅព្រឹកស្អែក ។ ដោយរៀបរាប់ពីលំដាប់លំដោយនៃកាលវិភាគរវាងពីថ្ងៃទី១៨ និង២៥ ខែតុលា ព្រមទាំងកាលវិភាគដែលបានផ្សាយនៅលើគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងបានបិទផ្សាយទូទាំងបន្ទប់សវនាការ មេធាវី ដេស្តមេន បានអះអាងថា មេធាវីការពារក្តីនិងប្រជាជនដែលនៅខាងក្រៅបន្ទប់សវនាការត្រូវធ្វើឲ្យជឿថាចម្លើយឆ្លើយតបរបស់ភាគីការពារក្តីនឹងមិនចាប់ផ្តើមទេរហូតដល់ថ្ងៃទី២៣ ខែវិច្ឆិកានេះ ។

ចៅក្រមបានពិភាក្សាគ្នាម្តងទៀតអំពីបញ្ហានេះហើយភ្លាមនោះ និល ណុន បានឆ្លើយតបទៅវិញថា ខណៈពេលដែល «មានការសោកស្តាយ» ដែលមេធាវីការពារក្តីមិនមានពេលដើម្បីបំពេញចម្លើយតបរបស់ខ្លួន នួន ជា ត្រូវបានផ្តល់ឱកាសដើម្បីធ្វើការឆ្លើយតប ។ និល ណុន បានបញ្ជាក់ទៀតថា អង្គជំនុំជម្រះបានទុកពេលវេលាសម្រាប់ក្រុមការពារក្តីហើយបើសិនជាក្រុមការពារក្តីមិនចង់ប្រើប្រាស់ពេលវេលានោះខ្លួនអាចធ្វើការសម្រេចចិត្ត ។

**ការទទួលស្គាល់សហមេធាវីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី**

ដោយមិនបានផ្តល់ឱកាសទៅមេធាវី ដេស្តមេន ដើម្បីធ្វើការឆ្លើយតប និល ណុន បានបន្តដំណើរការទៅមុខដើម្បីឲ្យមានការទទួលស្គាល់សហមេធាវីអន្តរជាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ពេជ អង្គ បានបង្ហាញខ្លួនមេធាវីបីនាក់ ។ ក្នុងនោះគឺមេធាវីជនជាតិខាំមេរូនដែលមកពីស្ថាប័នក្រុមមេធាវីគ្មានព្រំដែននិងមេធាវីជនជាតិបារាំងពីរនាក់ដែលធ្វើការនៅសហព័ន្ធអន្តរជាតិ



និស្សិតតម្រង់ជួរចូលបន្ទប់សវនាការ

បារាំងដើម្បីសិទ្ធិមនុស្ស ។ ពេជ អង្គ បានណែនាំមេធាវីទាំងបីនាក់ដើម្បីឲ្យតុលាការទទួលស្គាល់ ។ និល ណុន បានទទួលស្គាល់មេធាវីទាំងបីនាក់ ។

## ចម្លើយឆ្លើយតបរបស់ អៀង សារី ទៅនិងសេចក្តីថ្លែងការណ៍បើករបស់ព្រះរាជអាជ្ញា

អាង ឧត្តម ដែលជាសហមេធាវីជាតិរបស់ អៀង សារី បានងើបឡើងដើម្បីថ្លែងទៅកាន់តុលាការដោយរាយការណ៍ថា មេធាវីការពារក្តីនឹងមិនឆ្លើយតបឬធ្វើការសង្កេតទៅនឹងសេចក្តីថ្លែងការណ៍របស់ព្រះរាជអាជ្ញាអន្តរជាតិទេ ។ អាង ឧត្តម បានបញ្ជាក់ថា សេចក្តីថ្លែងការណ៍របស់ព្រះរាជអាជ្ញាគឺគ្មានភ័ស្តុតាងច្បាស់លាស់ទេ ហើយគាត់បានរាយការណ៍ថា សេចក្តីសម្រេចរបស់ខ្លួនក្នុងការមិនឆ្លើយតបគឺមិនមែនមកពីយល់ស្របឬយល់ព្រមទៅនឹងសេចក្តីថ្លែងការណ៍បើករបស់សហព្រះរាជអាជ្ញាទេ ។

អាង ឧត្តម ក៏បានលើកពីបញ្ហាមួយទាក់ទងនឹងភ័ស្តុតាងដែលព្រះរាជអាជ្ញាអន្តរជាតិបានលើកនៅក្នុងសេចក្តីថ្លែងការណ៍របស់គាត់ ។ អាង ឧត្តម បានថ្លែងថា មេធាវីការពារក្តីរបស់ អៀង សារី បានផ្ញើសំបុត្រមួយច្បាប់កាលពីថ្ងៃទី២១ ខែវិច្ឆិកា ទៅការិយាល័យសហព្រះរាជអាជ្ញារួចហើយ ដោយស្នើសុំបញ្ជីឈ្មោះសាក្សី ឯកសារ និងហេតុការណ៍មួយចំនួននៅក្នុងភ័ស្តុតាងដែលនឹងលើកមកនិយាយនៅក្នុងសេចក្តីថ្លែងការណ៍បើកនេះ ។ ព្រះរាជអាជ្ញាបានឆ្លើយតបដោយអនុស្សារណៈមួយដោយបញ្ជាក់ថាឯកសារទាំងអស់នេះផ្ទុកនៅក្នុងសំណុំឯកសារនិងបញ្ជាក់ទៀតថា សហព្រះរាជអាជ្ញាមានទំនុកចិត្តថាឯកសារទាំងអស់នេះគឺទាក់ទងទៅនឹងការហេតុការណ៍នៅចំពោះមុខតុលាការ ។ ដោយសារតែក្រុមមេធាវីការពារក្តី «មិនស្ថិតក្នុងជំហរណាមួយដើម្បីធ្វើការស្រាវជ្រាវសំណុំភ័ស្តុតាងទាំងអស់» ដែលមាននៅក្នុងបណ្តុំឯកសារនោះហើយការផ្តល់ព័ត៌មានទាំងនោះគឺជារឿង «ស្រួលដូចបកចេក» សម្រាប់ព្រះរាជអាជ្ញា អាង ឧត្តម បានស្នើទៅតុលាការឲ្យណែនាំព្រះរាជអាជ្ញាឲ្យផ្តល់ព័ត៌មានទាំងនោះទៅកាន់ក្រុមការពារក្តីរបស់ អៀង សារី ។

និល ណុន បានឆ្លើយតបទៅ អាង ឧត្តម ដោយសម្អាងលើវិធានផ្ទៃក្នុង៨៩ស្ទួន(២) ដែលផ្តល់ដល់ជនជាប់ចោទនូវឱកាសដើម្បីឆ្លើយតបតែមិនមែនចាំបាច់ត្រូវតែធ្វើនោះទេ ។ បន្ទាប់មក និល ណុន បានស្នើឲ្យមានការបញ្ជាក់ឲ្យច្បាស់ពី អាង ឧត្តម ថាតើ អៀង សារី ចង់ឡើងនិយាយទៅថ្ងៃស្អែកឬក៏អត់ ។

អាង ឧត្តម បញ្ជាក់ថា ស្របពេលដែល អៀង សារី មិនឆ្លើយតបទៅនឹងសេចក្តីថ្លែងបើករបស់ភាគីព្រះរាជអាជ្ញាដោយផ្ទាល់ អាង ឧត្តម បានស្នើសុំពេលឱកាសអានសេចក្តីថ្លែងការណ៍ដែល អៀង សារី មិនត្រូវបានផ្តល់ជូនកាលពីថ្ងៃបើកវគ្គដំបូងពេលវេនគាត់ត្រូវឆ្លើយតប ។

ដោយបញ្ជាក់ថា ពេលនេះកិច្ចដំណើរការត្រូវផ្តល់ជូនទៅជនត្រូវចោទក្នុងការធ្វើសេចក្តីថ្លែងតាមសេចក្តីប្រាថ្នារបស់ខ្លួន និល ណុន បានបញ្ជាក់ថា អៀង សារី នឹងត្រូវផ្តល់ឱកាសដើម្បីអាន សេចក្តីថ្លែងការណ៍នៅថ្ងៃទី២៣ ។

## ការបញ្ជាក់សាឡើងវិញទាក់ទងនឹងពេលវេលារបស់ នួន ជា ដើម្បីឆ្លើយតប

មុននឹងសវនាការផ្អាកកិច្ចដំណើរការសម្រាប់ថ្ងៃទីពីរនេះ ចៅក្រម ខាត់ស៊្រាយត៍ បានធ្វើការបញ្ជាក់ឲ្យច្បាស់មួយសម្រាប់តុលាការទាក់ទងទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា ដើម្បីបន្តសេចក្តីថ្លែងដើម្បីឆ្លើយតបនៅព្រឹកស្អែក ។ ចៅក្រម ខាត់ស៊្រាយត៍ បានបញ្ជាក់ថា អង្គជំនុំជម្រះបានយល់ពីសេចក្តីថ្លែងរបស់មេធាវី ដេស្តមេន ដលចង់អះអាងថា ក្រុមរបស់ នួន ជា មិនមានបំណងចង់ប្រើប្រាស់ពេលវេលាដែលសល់សម្រាប់ថ្ងៃនេះទេ ។ ចៅក្រម ខាត់ស៊្រាយត៍ បានបញ្ជាក់សាឡើងវិញថា នួន ជា នឹងមិនត្រូវផ្តល់ឱកាសឡើងថ្លែងទៀតទេ ដើម្បីឆ្លើយតបទៅនឹងសេចក្តីថ្លែងរបស់ព្រះរាជអាជ្ញានោះ ។ តែលោកស្រីចៅក្រមបញ្ជាក់ថានឹងមានឱកាសផ្សេងទៀតក្នុងអំឡុងសវនាការនេះ ។

មេធាវី ដេស្តមេន បានក្រោកឈរ ហើយស្នើសុំពេលដើម្បីឆ្លើយតបទៅអ្វីដែលចៅក្រម ខាត់ស៊្រាយត៍ «បានសង្កេតឃើញ» ។ បន្ទាប់មក ចៅក្រម ខាត់ស៊្រាយត៍ បានជូនដំណឹងដោយសង្ខេបទៅ មេធាវី ដេស្តមេន ថាសេចក្តីថ្លែងរបស់គាត់មិនមែនជា «ការសង្កេតឃើញទេ តែជាច្បាប់» ហើយក្រោយមកបានបញ្ចប់យោបល់ទាំងស្រុងរាល់បញ្ហានានា ហើយថ្ងៃទីពីរនេះបានបញ្ចប់ជាស្ថាពរ ។ **គ្រីស្ទីន អ៊ីវេន**

# ខៀវ សំផន និង អៀង សារី ឆ្លើយតប

សេចក្តីថ្លែងការណ៍បើកនៅក្នុងសវនាការលើសំណុំរឿង ០០២បានបញ្ចប់នៅថ្ងៃនេះនិងប្រកបទៅដោយការពិភាក្សាយ៉ាងស៊ិតស្វាញនិងពាក្យសម្តីប្រកបដោយចម្រូងចម្រាសខ្លាំងជាងថ្ងៃម្សិលមិញ ។ ដោយសារតែក្រុមការពារក្តីរបស់ នួន ជា បដិសេធមិនទទួលយកឱកាសដើម្បីធ្វើការឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍បើករបស់ភាគីសហព្រះរាជអាជ្ញាតុលាការបានផ្តល់ឱកាសនេះទៅ អៀង សារី និង ខៀវ សំផន ដើម្បីធ្វើការកត់សម្គាល់និងរៀបរាប់ពីការការពារខ្លួនដែលជនជាប់ចោទទាំងពីចង់និយាយ ។

នៅក្នុងបន្ទប់ដែលមានអ្នកចូលរួមអង្គុយពេញប្រៀបដែលភាគច្រើនជាសិស្សវិទ្យាល័យ និងអ្នកភូមិមកពីខេត្តនានានឹងមានអារម្មណ៍មិនស្រណុកក្នុងខ្លួនទេ ហើយនាំគ្នាជជែកគ្នាស្ទើរពេញមួយព្រឹកសូម្បីតែអំឡុងពេលនៃដំណើរការសវនាការក៏ដោយ ហើយហេតុផលដែលអ្នកចូលរួមនាំគ្នាជជែកគ្នានោះ នៅតែមិនដឹងដដែល ។ ទោះបីជាអ្នកចូលរួមមានអារម្មណ៍បែបនេះក៏ដោយ ក៏អ្នកចូលរួមទាំងអស់បានចូលរួមស្តាប់សេចក្តីថ្លែងការណ៍របស់ អៀង សារី និង ខៀវ សំផន យ៉ាងយកចិត្តទុកដាក់ដែលមើលទៅអ្នកចូលរួមហាក់បីដូចជាចង់ឮពាក្យពេចន៍របស់ជនជាប់ចោទទាំងពីរនេះជាខ្លាំង ហើយអ្នកចូលរួមប្រហែលជាចង់ដឹងពីការពន្យល់អំពីហេតុការណ៍នានានិងអំពើឃោរឃៅដែលបានកើតឡើងក្រោមរបបខ្មែរក្រហម ។

**បញ្ហាបឋម ៖ ការទទួលស្គាល់មេធាវីការពារក្តី**

ប្រធាន និល ណុន បានបង្គាប់ឲ្យតុលាការចាប់ផ្តើមដំណើរការទៅមុខទៀត ដែលភ្លាមៗនោះបានផ្តល់ឱកាសទៅមេធាវីជាតិរបស់ នួន ជា ឈ្មោះ សុន អារុណ ដែលកំពុងតែឈរ ។ សុន អារុណ បានរៀបរាប់ប្រាប់តុលាការម្តងទៀតនូវសំណើដែលខ្លួនដាក់ជូនកាលពីលើកមុន ដោយស្នើទៅអង្គសវនាការឲ្យទទួលស្គាល់មេធាវីអន្តរជាតិម្នាក់ដែលនឹងចូលរួមជាមួយក្រុមការពារក្តីរបស់ នួន ជា ។ ពេលនោះ សុន អារុណ បាននិយាយថាឯកសារដែលត្រូវការឥឡូវនេះនឹងត្រូវផ្តល់ជូនទៅតុលាការហើយ ។ និល ណុន បានឆ្លើយតបវិញថា ទោះបីជាចៅក្រមបានពិនិត្យឯកសារនោះរួចហើយក៏ដោយ ឯកសារទាំងនោះត្រូវរង់ចាំការបកប្រែជាមុនសិនមុននឹងចុះហត្ថលេខាទទួលស្គាល់ ហើយ និល ណុន បានអះអាងទៀតថា ការទទួលស្គាល់បែបណាមួយនៅពេលនេះគឺមិនអាចធ្វើបានទេ ។

**អៀង សារី បញ្ជាក់អំពីព្រះរាជទានទោសនិងការលើកលែងទោស**

ក្រោយមក ប្រធានចៅក្រម និល ណុន បានបន្តដំណើរការទៅមុខទៀតសម្រាប់ថ្ងៃទីបីនេះដោយផ្តល់ឱកាសទៅមេធាវីជាតិរបស់ អៀង សារី ឈ្មោះ អាង ឧត្តម ដើម្បីរៀបរាប់អំពីសេចក្តីថ្លែងការណ៍របស់ អៀង សារី ទៅកាន់តុលាការដែលគម្រោងនោះត្រូវបានពន្យារពេលតាំងពីរសៀលម្សិលមិញមក ។ អាង ឧត្តម បានឆ្លើយតបទៅវិញថា អៀង សារី បានស្នើឲ្យមេធាវីការពារក្តីរបស់ខ្លួនអានសេចក្តីថ្លែងការណ៍របស់គាត់ជំនួសវិញ ហើយ អៀង សារី ចង់ស្នើទៅតុលាការឲ្យធ្វើបែបនេះ ។

ក្រោយពីពិភាក្សាជាមួយសហចៅក្រមរួចមក និល ណុន បានប្រកាសថាចៅក្រមបានសម្រេចថា ជនជាប់ចោទត្រូវអានសេចក្តីថ្លែងការណ៍ដោយខ្លួនឯងដោយសារតែពេលនេះជនជាប់ចោទក៏មានវត្តមាននៅក្នុងតុលាការដែរ ។ ក្រោយមក និល ណុន បានបង្គាប់ឲ្យសន្តិសុខនាំនិងអមខ្លួន អៀង សារី ទៅកាន់ក្រចកសេះ ។ សន្តិសុខចំនួនប្រាំមួយនាក់បានអម អៀង សារី ដែលក្នុងនោះសន្តិសុខបីនាក់បានជួយ អៀង សារី ដែលកំពុងអង្គុយក្នុងកៅអីរបស់គាត់ ហើយនាំគាត់ទៅកាន់ក្រចកសេះ ។ អ្នកចូលរួមម្នាក់ៗដែលកំពុងតាមដានដំណើរការនេះបានផ្តេកខ្លួនផ្អែកលើកៅអីរបស់ខ្លួនវិញដែរ ហើយទន្ទឹងរង់ចាំមើលថាមានរឿងអ្វីកើតឡើង ។

គ្រាន់តែមកដល់កន្លែងអង្គុយក្នុងក្រចកសេះភ្លាម អៀង សារី បានសម្តែងការកិច្ចចំពោះតុលាការ និងសាធារណជន ហើយចាប់ផ្តើមធ្វើសេចក្តីថ្លែងការណ៍ ។ ក្រោយពីបញ្ជាក់ថា ខ្លួនត្រូវបានផ្តល់ព្រះរាជទានទោសនិងការលើកលែងទោសដោយព្រះមហាក្សត្រនរោត្តម សីហនុ ក្នុងឆ្នាំ១៩៩៦ រួចហើយ អៀង សារី បានបញ្ជាក់ថា «ខ្ញុំហត់នឿយណាស់ ។ ខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងណាទេ ។ ខ្ញុំមិនមានចិត្តអានសេចក្តីថ្លែងការណ៍នេះទេ» ។ ក្រោយមក អៀង សារី បានស្នើទៅតុលាការដោយសុំការអនុញ្ញាតសម្រាក ហើយអានសេចក្តីថ្លែងការណ៍របស់គាត់ពេលក្រោយជំនួសវិញ ។

និល ណុន បានសួរទៅ អាង ឧត្តម ថាតើនៅសល់ប៉ុន្មានកថាខណ្ឌទៀតដែលនឹងត្រូវអាននៅក្នុងសេចក្តីថ្លែងការណ៍របស់ អៀង សារី ។ ជាជាងឆ្លើយទៅនឹងសំណួររបស់ចៅក្រម អាង ឧត្តម បានស្នើម្តងទៀតទៅតុលាការដើម្បីអានសេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួនជំនួសវិញ ។ និល ណុន បាន បដិសេធសំណើនេះដោយបញ្ជាក់ថាច្បាប់បានកំណត់រួចហើយ ។ ដោយទទួលស្គាល់ថា អៀង សារី ទទួលរងនូវជំងឺដង្ហើមខ្លី និល ណុន បានអនុញ្ញាតឲ្យ អៀង សារី សម្រាកតាមចិត្តរបស់គាត់ ។

ខណៈពេលដែលចៅក្រម និល ណុន កំពុងតែនិយាយ អាង ឧត្តម បានដើរទៅកាន់ក្រចកសេះនិងនិយាយតិចៗជាមួយកូនក្តីរបស់ខ្លួន ។ មើលទៅប្រហែលជាចង់អះអាងថា អៀង សារី អាចបន្តអង្គុយនៅក្នុងក្រចកសេះនេះបាន អាង ឧត្តម បានត្រឡប់ទៅកាន់កៅអីរបស់គាត់វិញ ហើយ អៀង សារី បានបន្តអានសេចក្តីថ្លែងការណ៍របស់ខ្លួន ។

អៀង សារី បានបញ្ជាក់ថា ខណៈពេលដែលគាត់មិនយល់ស្របទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលបានអះអាងថាព្រះរាជទានទោស និងការលើកលែងទោសមិនអាចយកមកប្រើប្រាស់បាននៅក្នុងអង្គជំនុំជម្រះនេះ អៀង សារី បានគោរពសិទ្ធិអំណាចរបស់តុលាការដើម្បីទុកភារៈនេះទៅតុលាការដើម្បីសម្រេចចិត្ត ។ អៀង សារី បានប្រកាសថា គាត់មិនស្រណុកចិត្តទេដែលអង្គជំនុំជម្រះបដិសេធមិនផ្តល់សិទ្ធិឲ្យគាត់អាចបន្តដំណើរការប្តឹងឧទ្ធរណ៍បានទាក់ទងនឹងបញ្ហាលើកលែងទោសនេះ ។ ដោយបញ្ជាក់ថា អៀង សារី ត្រូវបានឃុំខ្លួននៅក្នុងសវនាការនេះអស់រយៈពេលជាងបួនឆ្នាំមកហើយ ដើម្បីរង់ចាំការកាត់ទោស អៀង សារី បានរិះគន់នូវអ្វីដែលគាត់បានឃើញអំពីកង្វះខាតរបស់តុលាការដែលមិនទទួលស្គាល់សេចក្តីសម្រេចចំពោះព្រះរាជទានទោសនិងការលើកលែងទោសរបស់ព្រះមហាក្សត្រ ហើយតុលាការនេះបានចាប់ផ្តើមដំណើរការដោយបញ្ហាមួយចំនួនមិនទាន់បានដោះស្រាយនៅឡើយទេ ។ ទោះបីជាមានសេចក្តីសម្រេចនេះក៏ដោយ អៀង សារី បានបញ្ជាក់ថា ខ្លួននឹងបន្តចូលរួមក្នុងដំណើរការតុលាការនេះបន្តទៀតដោយ «ការគោរពចំពោះស្ថាប័នមួយនេះ» ។

គ្រាន់តែ អៀង សារី បញ្ចប់សេចក្តីថ្លែងការណ៍របស់ខ្លួនភ្លាម អាង ឧត្តម បានក្រោកឈរឡើងដើម្បីធ្វើការកែតម្រូវអក្ខរាវិរុទ្ធពីកន្លែងដែលកូនក្តីរបស់ខ្លួនអានខុស ។ គ្រាន់តែ អាង ឧត្តម ហៀបនឹងអានសេចក្តីថ្លែងការណ៍ម្តងទៀត និល ណុន បាននិយាយកាត់គាត់ ហើយប្រាប់ទៅគាត់ឲ្យបញ្ជាក់ឲ្យច្បាស់ត្រង់ចំណុចដែលចង់ធ្វើការកែតម្រូវ ។ អាង ឧត្តម បានអានប្រយោគទាំងពីរដែលទាមទារឲ្យមានការកែតម្រូវដោយសារតែ អៀង សារី អានខុស ។ អាង ឧត្តម បញ្ជាក់ថា អៀង សារី អានច្រឡំពាក្យ «អនុវត្ត» និង «រហូតដល់» ដែលធ្វើឲ្យអ្នកចូលរួមផ្ទុះសំណើចឡើង ។



ភី ភួន(រូបខាងស្តាំ) អតីតនិសាររបស់ ប៉ុល ពត និង អៀង សារី កំពុងដើរចូលក្នុងបន្ទប់សវនាការ

## ក្រុមការពារក្តីរបស់ នួន ជា អានបញ្ជាក់ជាថ្មីម្តងទៀតអំពីការបដិសេធនឹងសំណើរបស់ខ្លួន

ក្រោយពី អៀង សារី ត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយនៅពីក្រោយមេធាវីការពារក្តីវិញ ចៅក្រម និល ណុន បានផ្តល់ឱកាសទៅ ខៀវ សំផន ដើម្បីធ្វើការឆ្លើយតបនឹងសេចក្តីថ្លែងការណ៍បើករបស់សហព្រះរាជអាជ្ញា ។ ទាំង ខៀវ សំផន និង ម៉ៃឃើល ផេស្តមេន ដែលជាមេធាវីអន្តរជាតិរបស់ នួន ជា បានឈរលើជំហរដូចគ្នា ។ ដោយសម្លឹងទៅកាន់មេធាវី ផេស្តមេន ចៅក្រម និល ណុន មិនបានខ្វល់នឹងមេធាវី ផេស្តមេន ទេរហូតដល់មេធាវីនោះចាប់ផ្តើមនិយាយទៅកាន់អង្គសវនាការផ្ទាល់តែម្តង ។ និល ណុន បានអនុញ្ញាតឲ្យមេធាវី ផេស្តមេន ឡើងនិយាយ តែសុំឲ្យខ្លី ដោយសារពេលនោះចៅក្រមបានសុំឲ្យ ខៀវ សំផន អង្គុយដែលខណៈពេលនោះគាត់បានចូលមកដល់ក្រចកសេះរួចហើយ ។

មេធាវី ផេស្តមេន បានបកស្រាយថាគាត់សុំធ្វើការបញ្ជាក់សេចក្តីជំទាស់របស់ខ្លួនម្តងទៀតទៅនឹងអង្គហេតុរបស់សវនាការកាលពីម្សិលមិញ ទាក់ទងនឹងសំណើរបស់ខ្លួនដើម្បីសុំបន្តការផ្តល់ចម្លើយតប របស់ នួន ជា ទៅនឹងសេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងកាលពីព្រឹកមិញរួចហើយ ។ សំដៅទៅលើ ចៅក្រម ខាតវ្រ៉ាយត៍ ដែលនិយាយថា តុលាការចង់ដកសិទ្ធិរបស់ នួន ជា ក្នុងការឲ្យគាត់ឡើងធ្វើការឆ្លើយតប មេធាវី ផេស្តមេន បានប្រកាសថា «ការដកសិទ្ធិមិនអាចនិយាយសំដៅបែបនេះបានទេ» តែត្រូវអះអាងឲ្យច្បាស់ ។ ដោយបញ្ជាក់អំពីការដាក់ពាក្យសុំរបស់ក្រុមមេធាវីខ្លួន ទាក់ទងចៅក្រម ខាតវ្រ៉ាយត៍ ដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើជាចៅក្រមនោះវាមិនត្រូវបានចៅក្រមយកមកពិចារណាទេ ។ ពេលនោះ មេធាវី ផេស្តមេន បានបញ្ជាក់ថាកូនក្តីរបស់ខ្លួនគួរតែផ្តល់សិទ្ធិពេញលេញដើម្បីនិយាយឆ្លើយតប ។

ឆ្លើយតបទៅនឹងមេធាវី ផេស្តមេន ចៅក្រម និល ណុន បានបញ្ជាក់សាឡើងវិញថា ក្រុមការពារក្តីរបស់ នួន ជា ត្រូវបានផ្តល់ពេលវេលារួចទៅហើយកាលពីម្សិលមិញដើម្បីធ្វើសេចក្តីថ្លែងការណ៍ ។ ខណៈពេលដែល នួន ជា ផ្ទាល់បានប្រើប្រាស់ពេលវេលាមួយម៉ោងដើម្បីធ្វើការឆ្លើយតប មេធាវីរបស់ នួន ជា មិនបានចំណាយពេលដែលនៅសេសសល់ឲ្យបានត្រឹមត្រូវទេ ទោះបីជាតុលាការបានប្រាប់ទៅមេធាវីនោះច្រើនដងហើយក៏ដោយ ។ និល ណុន បានបញ្ជាក់ដោយក្តីសង្ឃឹមថាអ្វីដែលខ្លួននិយាយនៅពេលនេះគឺច្បាស់ហើយ ហើយបន្ទាប់មក និល ណុន បានផ្តល់សិទ្ធិឲ្យ ខៀវ សំផន ចាប់ផ្តើមធ្វើសេចក្តីថ្លែងការណ៍តបទៅព្រះរាជអាជ្ញា ។


ខៀវ សំផន នៅក្នុងបន្ទប់សវនាការខែវិច្ឆិកា ឆ្នាំ២០១១ (រូបថត អ.វ.ត.ក)

### ខៀវ សំផន ឆ្លើយតប

ខុសគ្នាទាំងស្រុងទៅនឹងចម្លើយតបរបស់ នួន ជា កាលពីម្សិលមិញ ខៀវ សំផន បានផ្តោតការឆ្លើយតបរបស់ខ្លួនដើម្បីតបទៅនឹងអ្វីដែលព្រះរាជអាជ្ញាបានអះអាងដោយនិយាយចំៗទៅកាន់ព្រះរាជអាជ្ញាដោយផ្ទាល់ និងនិយាយពីបញ្ហាយ៉ាងចំចំណុចដែលព្រះរាជអាជ្ញាបានអះអាង ។ ខៀវ សំផន បានរៀបរាប់យ៉ាងច្បាស់លាស់ដើម្បីការពារនូវបទឧក្រិដ្ឋដែលបានចោទមកលើខ្លួនដោយបញ្ជាក់ថាខ្លួនមិនបានដឹងពីបទឧក្រិដ្ឋដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយថាគាត់ក៏មិនមានសិទ្ធិធ្វើការសម្រេចចិត្តអ្វីដែរកាលពីរបបកម្ពុជាប្រជាធិបតេយ្យនោះ ។ នៅពេលនោះដែរ អ្នកចូលរួមបានត្រៀមត្រងត្រាប់ស្តាប់ជានិច្ចពេលដែល ខៀវ សំផន កំពុងនិយាយ ហើយសាធារណជនចូលរួមហាក់បីដូចជាតាមដានស្តាប់

ប្រសាសន៍របស់ ខៀវ សំផន យ៉ាងយកចិត្តទុកដាក់ដែលខុសពីពេលដែល នួន ជា ឡើង អានសេចក្តីថ្លែងការណ៍ ។

ខៀវ សំផន បានបញ្ជាក់ថា ខ្លួនមិនបានដឹងច្បាស់ពីដំណើរការកាត់ទោសនេះទេ ហើយបញ្ជាក់ទៀតថា តាមអ្វីដែលគាត់បានឃើញមកដល់ពេលនេះគ្មាននរណាម្នាក់យល់ច្បាស់ពីដំណើរការតុលាការនេះទេ ។ អស់រយៈពេលពីរថ្ងៃមកហើយ ខៀវ សំផន បាននិយាយថា «អ្វីៗទាំងអស់គឺហួសពីក្តីរំពឹងទុករបស់ខ្ញុំទៅទៀត» ។

ដោយវាយប្រហារពាក្យដែលខ្លួនហៅថា «កិច្ចការស្មានៗ» របស់ព្រះរាជអាជ្ញា ខៀវ សំផន បានតតាំងជាមួយសហព្រះរាជអាជ្ញាទៅនឹងសាក្សីដែលមិនបានផ្តល់ឈ្មោះត្រឹមត្រូវនិងឯកសារដែលខ្វះប្រភពច្បាស់លាស់ដូចជាអត្ថបទសារព័ត៌មាននិងសៀវភៅជាដើម ។ ខៀវ សំផន បានបកស្រាយថា «បើតាមខ្ញុំដឹង អ្នកប្រវត្តិសាស្ត្រ អ្នកសារព័ត៌មានអ្នកចុះកាលវិភាគប្រវត្តិសាស្ត្រ និងអ្នកប្រលោមលោកមិនមែនជាចៅក្រមទេ ។ អ្នកទាំងនោះមិនបានធ្វើការស្បថស្បែដើម្បីធ្វើជាចៅក្រមស៊ើបអង្កេតគាំទ្របទចោទប្រកាន់នៅក្នុងសំណើរបស់ខ្លួនទេ» ។ ខៀវ សំផន បាននិយាយតតាំងថា ដោយសារតែអ្នកសរសេរទាំងនោះមិនមានលក្ខណៈត្រឹមត្រូវផ្នែកច្បាប់អ្នកទាំងនោះអាចលម្អៀង និងមិនពេញលេញ ហើយបានប្រើប្រាស់ការសរសេរទាំងនោះដើម្បីឆ្លុះបញ្ចាំងពីគំនិតរបស់ខ្លួនមិនមែនដើម្បីឆ្លុះបញ្ចាំងពីការពិតដែលបានកើតឡើងទេ ។ ដោយនិយាយទៅកាន់សហព្រះរាជអាជ្ញាជាតិចំៗ ខៀវ សំផន បានបញ្ជាក់ថា «ខ្ញុំសូមរំឭកជូនលោកស្រីសហព្រះរាជអាជ្ញាជាតិថា ក្រោយថ្ងៃ១៧ មេសា មានកាសែតបារាំងមួយឈ្មោះ ឡឺម៉ុងដ៍ បានបោះពុម្ពផ្សាយអត្ថបទមួយដែលមានចំណងជើងថា «ភ្នំពេញរំដោះហើយ» ។ ខ្ញុំដឹងច្បាស់ថាលោកស្រីអាចយកឱកាសនេះនឹងធ្វើការរិះគន់ខ្ញុំ បើសិនជាខ្ញុំពឹងទៅលើអត្ថបទសារព័ត៌មាននោះ» ។

ក្រោយមក ខៀវ សំផន បានអំពាវនាវឲ្យមានយុត្តិធម៌នៅក្នុងសាលសវនាការថា «មិនត្រូវជឿលើសាក្សីដែលមិនបង្ហាញឈ្មោះនិងអត្ថបទនិងសៀវភៅដែលសរសេរដោយអ្នកសារព័ត៌មាននោះទេ» ។

ក្រោយមក ខៀវ សំផន បានបកស្រាយទៅកាន់សហព្រះរាជអាជ្ញាថា ចំណាប់អារម្មណ៍របស់គាត់ក្នុងបក្សកុម្មុយនីស្តកាលពីពេលដែលគាត់ជានិស្សិតនៅទីក្រុងប៉ារីស គឺជាសញ្ញានៃការចាប់ផ្តើមរបស់សហកម្មខក្រិដ្ឋកម្មរួមដែលជនជាប់ចោទទាំងបីនាក់ត្រូវបានចោទប្រកាន់ថាបានចូលពាក់ព័ន្ធជាមួយគ្នា ។ ដោយសង្កេតឃើញថា នៅពេលនោះ កុម្មុយនីស្ត «គឺជាចលនាមួយដែលផ្តល់ក្តីសង្ឃឹមដល់យុវជនរាប់លាននាក់ទូទាំងពិភពលោក» ខៀវ សំផន បានការពារខ្លួនថា ការចូលជាសមាជិកបក្សកុម្មុយនីស្តរបស់គាត់គឺជាវិធីមួយដើម្បីជួយប្រទេសកម្ពុជានិងគូរបដិបក្ខរបស់ខ្លួនប្រឆាំងនឹង លន់ នល់ និងកងកម្លាំងនានាដែលចង់មកធ្វើការគ្រប់គ្រងប្រទេសកម្ពុជា ។

ក្រោយមក ខៀវ សំផន បានទទូចទៅសហព្រះរាជអាជ្ញាថា មិនត្រូវបំភ្លេចបុព្វបទប្រវត្តិសាស្ត្រដែលកើតឡើងមុនរបបកម្ពុជាប្រជាធិបតេយ្យទេ ។ ដោយនិយាយសំដៅទៅលើការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាដោយសហរដ្ឋអាមេរិកពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៣ ខៀវ សំផន បានសួរទៅព្រះរាជអាជ្ញាអន្តរជាតិថា «លោកអាចប្រមើលឃើញទេថា ប្រទេសរបស់ខ្ញុំប្រឈមមុខបែបណាក្រោយពីការសម្លាប់និងសង្គ្រាមបង្ហូរឈាមបែបនេះ?» មិនអាចទេ ខ្ញុំដឹងថាលោកមិនអាចប្រមើលឃើញទេ ។ លោកមិនបានគិតដល់និងថែមទាំងបានប្រឌិតរឿងរ៉ាវកាលពីពេលនោះ ។ ខៀវ សំផន បានបញ្ជាក់ថា «ការទម្លាក់គ្រាប់បែកគោលនយោបាយវាតទីរបស់វៀតណាមនិងរដ្ឋប្រហារយោធាដឹកនាំដោយ លន់ នល់ និងចលនាប្រឆាំងនិង លន់ នល់ គឺជាកត្តាដែលបង្កឲ្យមានភាពវឹកវរ» នៅក្នុងប្រទេសកម្ពុជា ។ ខៀវ សំផន បានលាតត្រដាងថាស្ថានភាពបែបនេះដែលកើតឡើងមុននឹងគាត់មកដល់ទីក្រុងភ្នំពេញអាចនឹងដោះសានូវ «ការទទួលខុសត្រូវតិចតួច» អំពីអ្វីដែលបានកើតឡើងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុង ហើយធ្វើឲ្យសហព្រះរាជអាជ្ញាអាចនាំការចោទប្រកាន់មកលើខ្លួន ។ ខៀវ សំផន បានអះអាងបញ្ជាក់ថា «ក្តីសង្ឃឹមរបស់ខ្ញុំមិនមានរយៈពេលយូរទេ» ។

ដែលមើលទៅនេះប្រហែលជាអ្វីដែលគាត់ចង់ធ្វើការការពារខ្លួនឯង ខៀវ សំផន បានតតាំងនូវអ្វីដែលខ្លួនមើលឃើញថាជាការខ្វះខាតភស្តុតាងនៅក្នុងករណីសំណុំរឿងដែលបង្ហាញថាគាត់ជាមនុស្សដែលអាចធ្វើការសម្រេចចិត្តនៅក្នុងរបបកម្ពុជា

ប្រជាធិបតេយ្យនោះ ឬក៏ការពិតនៃអំពើឃោរឃៅដែលបានកើតឡើងក្នុងប្រទេសពីឆ្នាំ១៩៧៥ដល់១៩៧៩ ។ ខៀវ សំផន បានអះអាងថា ក្នុងចំណោមឯកសាររាប់ពាន់ទំព័រនៅក្នុងសំណុំរឿង (ដែលគាត់និយាយថា ឯកសារខ្លះមិនទាន់បានបកជាភាសាអង់គ្លេស ឬបារាំងនៅឡើយនោះ) គ្មានឯកសារមួយទំព័រណាមួយដែលអះអាងថា គាត់គឺជាសមាជិកជាន់ខ្ពស់នៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ឬគ្មានឯកសារណាមួយអះអាងថាគាត់បានបម្រើជាប្រធានមន្ទីរនយោបាយមជ្ឈិម៨៧០ដែរ ។

ខៀវ សំផន បានបញ្ជាក់ថា ក្តីបារម្ភរបស់គាត់ជាមួយសហព្រះរាជអាជ្ញាក្នុងការប្រើប្រាស់ពាក្យ «មជ្ឈិមបក្ស» ដែលជាពាក្យមួយ ខៀវ សំផន អះអាងថា សហព្រះរាជអាជ្ញាបានបង្កើតពាក្យនេះសម្រាប់សវនាការនេះ តែពាក្យនេះមិនបានកើតឡើងកាលពីរបបកម្ពុជាប្រជាធិបតេយ្យទេ ។ ដោយអះអាងថា សហព្រះរាជអាជ្ញាប្រើពាក្យនេះខុស ដែលចង់ជំនួសពាក្យ «គណៈកម្មាធិការអចិន្ត្រៃយ៍» ខៀវ សំផន បានប្រកាសថា «លោកព្រះរាជអាជ្ញាកំពុងតែធ្វើឲ្យសាធារណជនជឿថា អ្នករាល់គ្នាកំពុងតែប្រកក្នុងស្បោងតែមួយហើយ ។ តែនេះគឺជារឿងកុហកជារឿងបោកប្រាស់ ។ តាមពិតលោកដឹងច្បាស់ណាស់ថា កម្ពុជាប្រជាធិបតេយ្យ...គឺបែកជាច្រើនថ្នាក់ ហើយអ្វីៗគឺជាការសម្ងាត់» ។

ទាក់ទងទៅនឹងអំពើឃោរឃៅដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ខៀវ សំផន បាននិយាយថា តំណែងរបស់គាត់ដែលជាប្រធានរដ្ឋគឺស្មើទៅនឹងតំណែងរបស់អតីតព្រះមហាក្សត្រនរោត្តម សីហនុ ពេលដែលព្រះអង្គជាព្រះមហាក្សត្រដែរ ។ ដោយបញ្ជាក់ថា ការដ្ឋានការងារត្រូវបានរៀបចំឡើងសម្រាប់ដំណើរទស្សនកិច្ចដែលគាត់បានអមដំណើរព្រះមហាក្សត្រទៅទស្សនា ។ ខៀវ សំផន បានសួរថា «លោកជឿទេថាប្រជាជនកម្ពុជាត្រូវបានសម្លាប់នៅពីមុខយើងនោះ?» ។ ខៀវ សំផន ហៅការបកស្រាយ «ពិតជាឆ្កួត» ដោយប្រៀបធៀបទៅនឹងការចោទប្រកាន់ «ឆ្កួត» ដោយព្រះរាជអាជ្ញាថា អង្គការគឺជាអ្នកចាត់តាំងឲ្យមានការរៀបការដោយបង្ខំ ហើយបានអះអាងទៀតថា ការរៀបការទាំងនេះគឺតម្រូវឲ្យមានការរួមភេទនោះ ។ ខៀវ សំផន បានអះអាងថា «ខ្ញុំមិនមែនជាផ្នែកមួយរបស់អង្គការទេ តែខ្ញុំស្រមើស្រមៃឃើញថា ដើម្បីធ្វើឲ្យប្រទេសជាតិទៅមុខបានកម្មាភិបាលម្នាក់ៗត្រូវមានកិច្ចការជាច្រើនដែលត្រូវធ្វើជាជាងគ្រាន់តែដើម្បីមើលថាតើមនុស្សបានរួមភេទឬក៏អត់នោះ» ។

ក្រោយមក ខៀវ សំផន បកស្រាយនូវអ្វីដែលបានអះអាងដោយសហព្រះរាជអាជ្ញានិងអ្នកផ្សេងទៀតដែលនិយាយគាត់បានប្តូរពាក្យសម្តីនៅក្នុងសេចក្តីថ្លែងការណ៍និងនៅក្នុងសៀវភៅ ។ដោយបញ្ជាក់ថាការផ្លាស់ប្តូរនេះអាចឆ្លុះបញ្ចាំងពីការវិវឌ្ឍចំណេះដឹងនិងការយល់ដឹងនូវអ្វីដែលបានកើតឡើងកាលពីពេលនោះ ក្រោយមក ខៀវ សំផន បានសួរថា «តើការគិតរបសខ្ញុំប្រឆាំងនឹងខ្ញុំដែរឬយ៉ាងណា?» ក្រោយមក ខៀវ សំផន បានទទូចទៅចៅក្រមដោយចំៗថា «ក្នុងរយៈពេល៣៦ឆ្នាំមនុស្សបានរៀនសូត្រនិងបានផ្លាស់ប្តូរ» ។

ទីបញ្ចប់ ខៀវ សំផន បានបញ្ចប់ការបកស្រាយរបស់ខ្លួនដោយអំពាវនាវទៅសាធារណជនថា គាត់សង្ឃឹមថាអង្គសវនាការនឹងផ្តល់ឱកាសដល់គាត់ដើម្បីធ្វើការពន្យល់ថាតើគាត់កាន់តំណែងជាន់ខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយរបៀបណាដោយមិនមែនជាអ្នកដែលអាចធ្វើការសម្រេចចិត្តនិងដោយគ្មានការប្រាប់ដំណឹងពីមូលដ្ឋាននូវអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកាលពីពេលនោះ ។ ទីបញ្ចប់ ខៀវ សំផន បានសន្និដ្ឋានថា «ខ្ញុំនឹងធ្វើឲ្យអស់ពីសមត្ថភាពដើម្បីចូលរួមក្នុងដំណើរការសវនាការ» ។ ក្រោយពី ខៀវ សំផន ថ្លែងចប់ តុលាការប្រកាសសម្រាក ។

## មេធាវីការពារក្តីរបស់ ខៀវ សំផន ឆ្លើយតប

ក្រោយពីចៅក្រមបន្តាប់ឲ្យចាប់ផ្តើមដំណើរការសវនាការវិញ សហមេធាវីជាតិរបស់ ខៀវ សំផន ឈ្មោះ គង់ សំអុន ចាប់ផ្តើមឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍បើករបស់សហព្រះរាជអាជ្ញា ។ ខណៈពេលដែលមេធាវីរូបនេះនិយាយបន្ទរនូវអ្វីដែល ខៀវ សំផន និយាយហើយនោះ គង់ សំអុន បានផ្តោតទៅលើជាពិសេសទៅលើបុព្វបទប្រវត្តិសាស្ត្រនៃសវនាការនិងបញ្ហានៃសិទ្ធិអំណាចរបស់កូនក្តីរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ដំបូង គង់ សំអុន បានទាញចំណាប់អារម្មណ៍ពីតុលាការឲ្យគិតគូដល់ពេលវេលាសម្រាប់ភ័ស្តុតាងនិងសម្រាប់ការយល់ដឹង

ចំពោះព្រឹត្តិការណ៍ដែលបានកើតឡើងកាលពីរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-១៩៧៩ ។ ដោយបញ្ជាក់ឲ្យច្បាស់នូវអ្វីដែល ខៀវ សំផន បានអះអាងរួចហើយ គង់ សំអុន បាន បញ្ជាក់ថា ដំណើរការសវនាការនេះគឺ «ជាសវនាការរវាងមនោគមន៍វិជ្ជាកុម្មុយនីស្តនិងមនោគមន៍សេរី» ។ ពេញមួយសតវត្សរ៍កន្លងទៅ មនោគមន៍វិជ្ជាកុម្មុយនីស្តដែលធ្លាប់តែជាកម្លាំងដ៏ស្រួចស្រាលទូទាំងពិភពលោកចាប់ផ្តើមសាបរលាបបន្តិចម្តងៗខណៈពេលដែលមនោគមន៍វិជ្ជាសេរីចាប់ផ្តើមវាយលុក ។ ចំណែកឯតុលាការនេះវិញកើតឡើងចេញពីមនោគមន៍វិជ្ជាសេរីរបស់បស្ចិមប្រទេស ។ គង់ សំអុន បានទទូចថា តុលាការត្រូវចាំថា កុម្មុយនីស្តបានបង្កើតនូវការគិតផ្សេង ។ សម្រាប់លទ្ធិកុម្មុយនីស្ត អំពើហិង្សា នយោបាយគឺចាត់ទុកជារឿងធម្មតា ហើយជាអ្នកកំណត់ថា នរណាជាស្តេច ហើយនរណាត្រូវចាប់ខ្លួន ឬសម្លាប់ ។ ការអនុវត្តច្បាប់នាពេលបច្ចុប្បន្នទៅនឹងអ្វីដែលកើតឡើងកាលពីពាក់កណ្តាលសតវត្សរ៍មុន បានបង្កើតនូវ «ទស្សនៈស្មុគស្មាញ» ទៅវិញ ។ តែបើសិនជាមើលនៅក្នុងបុព្វបទប្រវត្តិសាស្ត្រក្នុងឆ្នាំ១៩៧៥វិញ សកម្មភាពរបស់ ខៀវ សំផន និង «ស្មារតីស្នេហាជាតិ» អាចមានលក្ខណៈសមស្របទៅវិញ ។

ក្រោយមក គង់ សំអុន បានងាកមកនិយាយពីបញ្ហាសិទ្ធិអំណាចនិងការគ្រប់គ្រងរបស់ ខៀវ សំផន ក្នុងនាមជាប្រធានរដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យវិញ ។ ដូចអ្វីដែល ខៀវ សំផន បានធ្វើរួច ហើយ គង់ សំអុន បានអំពាវនាវឲ្យតុលាការចាប់អារម្មណ៍ទៅនឹងតួនាទីរបស់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ ក្នុងនាមជាប្រមុខរដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យនេះ ។ ដោយដឹងថាតុលាការមិនអាចកោះហៅអតីតព្រះមហាក្សត្រមកបំភ្លឺក្នុងតុលាការបាននោះ គង់ សំអុន បានស្នើតុលាការឲ្យពិនិត្យមើលកំណត់ត្រានិងសេចក្តីថ្លែងការណ៍ដែលបោះពុម្ពដោយព្រះមហាក្សត្រទាក់ទងនឹងបញ្ហានេះ ។ គង់ សំអុន បានអះអាងថាកំណត់ត្រាទាំងអស់នោះបង្ហាញថាអតីតព្រះមហាក្សត្រនរោត្តម សីហនុ មិនមានអំណាចអ្វីទេក្នុងនាមជាប្រមុខរដ្ឋនោះហើយឋានៈដែលមិនមានអំណាចរបស់ព្រះអង្គត្រូវបានជំនួសដោយ ខៀវ សំផន ។ គង់ សំអុន បានទទូចឲ្យតុលាការពិនិត្យមើលឲ្យច្បាស់អំពីកំណត់ហេតុកិច្ចប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជាដែលសហព្រះរាជអាជ្ញានឹងសម្អាងនៅអំឡុងពេលនៃដំណើរការសវនាការដើម្បីកំណត់ថា តើកំណត់ហេតុកិច្ចប្រជុំនោះគឺជាកំណត់ហេតុដ៏ត្រឹមត្រូវនៃកិច្ចប្រជុំដែរឬអត់ទេ ។ ដោយសារតែឯកសារខ្វះមានការខ្វះខាតនូវហត្ថលេខាអ្នកសរសេរ គង់ សំអុន បាននិយាយសាឡើងវិញថា ឯកសារខ្វះគឺក្លែងក្លាយ ហើយត្រូវបានវាយចូលក្នុងម៉ាស៊ីនអង្គុយលីលេខ ក្រោយមកដែលបន្តឲ្យមានការមិនច្បាស់លាស់នៅក្នុងឯកសារទាំងនោះ ។

គង់ សំអុន បានអះអាងថា ខៀវ សំផន ដឹងតែអ្វីដែលគាត់ត្រូវបានអនុញ្ញាតឲ្យដឹងតែប៉ុណ្ណោះ កាលពីសម័យនោះ ។ កម្មាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យដឹងច្បាស់ថា ម្នាក់ដឹងតែពីអ្វីដែលជាកិច្ចការរបស់ខ្លួនប៉ុណ្ណោះនិង «ខ្លួនទីពឹងខ្លួន» ហើយគ្មាននរណាដឹងរឿងរបស់អ្នកផ្សេងទៀតទេ ។ ខៀវ សំផន ក៏បាននិយាយបែបនេះដែរ ។

ក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ គង់ សំអុន បានទាញចំណាប់អារម្មណ៍តុលាការម្តងទៀតអំពី «ស្ថានភាពវឹកវរ» ដែលបានកើតឡើងនៅកម្ពុជាដោយសារការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកព្រមទាំងជម្លោះផ្ទៃក្នុងនិងខាងក្រៅដែលបានកើតឡើងនាដើមទសវត្សរ៍៧០ ។ ភាពវឹកវរទាំងអស់នេះបង្កើតឲ្យមានការសង្ស័យអំពីថាតើអំពើកាប់សម្លាប់និងអំពើឧក្រិដ្ឋកើតឡើងយ៉ាងដូចម្តេចនៅក្នុងបក្សនិងភាគីនានានៅប្រទេសកម្ពុជានិងការជំទាស់ប្រឆាំងទៅនឹងរបបខ្មែរក្រហមថា អាចប្រព្រឹត្តអំពើឃោរឃៅនេះដែរ ។ សំណើចុងក្រោយរបស់មេធាវី គង់ សំអុន ទៅតុលាការគឺថាតុលាការត្រូវតែពិនិត្យមើលព័ត៌មានលម្អិតគ្រប់សាក្សីដែលនឹងត្រូវធ្វើសក្ខីកម្មទាំងអស់ ហើយឯកសារមួយចំនួនទៀតដើម្បីធានាថា សេចក្តីថ្លែងការណ៍ទាំងនេះគឺមិនមែនទទួលបានតាមរយៈការធ្វើទារុណកម្មទេ ហើយត្រូវតែធ្វើឡើងដោយត្រឹមត្រូវ ។

ក្រោយពី គង់ សំអុន បញ្ចប់សេចក្តីថ្លែងការណ៍របស់ខ្លួន មេធាវីអន្តរជាតិរបស់ ខៀវ សំផន ឈ្មោះ ហ្សាក់ វែរហ្សេ បានឆ្លើយតបទៅវិញដែរ ។ មេធាវី វែរហ្សេ ចាប់ផ្តើមដោយការនិយាយពីការទទួលស្គាល់ «អ្នកស្លាប់ដែលត្រូវបានបំភ្លេច» ដែលជាជនរងគ្រោះដោយការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក

លើទឹកដីកម្ពុជាក្នុងទសវត្សរ៍៧០ និងក្មេងៗទាំងឡាយដែលបានកើតនៅលើផ្លូវលំហូដីមិញ ដែលទទួលរងនូវភាពពិការភ្នែក និងគថ្លង់ដោយសារសារធាតុពណ៌ទឹកក្រូច ។ មេធាវី វែរហេ្វ បានបញ្ជាក់ថា សាធារណជនត្រូវតែដឹងថា អ្នកស្លាប់ទាំងនេះមិនត្រូវបានបំភ្លេចដោយតុលាការទេ ។

ដូចគ្នានឹងសេចក្តីថ្លែងការណ៍បើករបស់ព្រះរាជអាជ្ញានិងប្រលោមលោកមួយដែលនិពន្ធដោយជនជាតិបារាំងម្នាក់ឈ្មោះ អាឡិចសង់ទ្រើ ឌុយម៉ាស់ ដែរ មេធាវី វែរហេ្វ បានថ្លែងពីអ្វីដែលគាត់ហៅថា «ទស្សនៈអស្ចារ្យនៃភាពពិត» ដែលលាបពណ៌ដោយសហព្រះរាជអាជ្ញាដែលមនុស្សទូទៅត្រូវបានគាបសង្កត់ដោយ «បិសាចទាំងបី» នៃជនជាប់ចោទ ។ មេធាវី វែរហេ្វ បានប្រកាសថាការអះអាងដែលថា ប្រជាពលរដ្ឋទាំងអស់ត្រូវទទួលរងនិងចូលរួមពាក់ព័ន្ធក្នុងព្រឹត្តិការណ៍ដែលបានកើតឡើងកាលពីសម័យកម្ពុជាប្រជាធិបតេយ្យ «គឺជាការប្រឌិតប្រវត្តិសាស្ត្រទាំងស្រុង» ។ ខណៈពេលដែលមនុស្សបានប្រព្រឹត្តកំហុសនិងបានប្រព្រឹត្តបទល្មើសពិតមែនតែអ្នកទាំងនោះមិនមែនជាបិសាចទេ ។ ការលាបពណ៌ជនជាប់ចោទទាំងបីជាបិសាចដែលទទួលខុសត្រូវទាំងស្រុងក្នុងបទល្មើសនោះគឺជារឿងខុសទាំងស្រុង ។ មេធាវី រូបនេះបានអះអាងថា ខៀវ សំផន ដែលជាអតីតប្រមុខរដ្ឋមិនមានអ្វីត្រូវសុំទោសទេ ។ មេធាវី វែរហេ្វ បានសន្និដ្ឋានដោយមានឃ្លាមួយរបស់ ណាប៉ូឡេអុង ថា «អ្វីៗដែលលើសគឺឥតប្រយោជន៍» ហើយគាត់បានអំពាវនាវឲ្យចៅក្រមមើលពីសេចក្តីថ្លែងការណ៍ដែលមាន «ភាពលើសលប់» របស់សហព្រះរាជអាជ្ញា ហើយមេធាវី វែរហេ្វ ចង់និយាយថា ព្រះរាជអាជ្ញាទាំងពីរគឺឥតប្រយោជន៍ ។

## បំណងរបស់ជនជាប់ចោទក្នុងការធ្វើសក្ខីកម្ម

ក្រោយពីក្រុម ខៀវ សំផន ធ្វើសេចក្តីថ្លែងការណ៍ចប់ និល ណុន គិតឃើញថាពេលនេះមិនមែន ជាពេលត្រឹមត្រូវល្មមដែលត្រូវបន្តដំណើរការទៅមុខទៀតទេ ។ ក្រោយមក ព្រះរាជអាជ្ញា ជា លាង បានស្នើសុំការបញ្ជាក់ច្បាស់ឡើងវិញ ពីជនជាប់ចោទទាក់ទងនឹងទៅបំណងក្នុងការធ្វើសក្ខីកម្មក្នុងអំឡុងពេលដំណើរការសវនាការលើភស្តុតាង ។ ជា លាង បានកត់សម្គាល់ឃើញថា ខៀវ សំផន និង អៀង សារី បានបញ្ជាក់ពីឆន្ទៈក្នុងការចូលរួមក្នុងដំណើរការសវនាការក្នុងអំឡុងពេលនៃការធ្វើសេចក្តីថ្លែងការណ៍ទៅកាន់តុលាការនៅថ្ងៃនេះ ទោះបីជា អៀង សារី បានបញ្ជាក់ជាលាយលក្ខណ៍អក្សររួចហើយថា ខ្លួននឹងមិនធ្វើសក្ខីកម្មនោះ ។ នួន ជា មិនបានផ្តល់ការបញ្ជាក់ណាមួយក្នុងបំណងនៃការចូលរួមក្នុងដំណើរការនេះទេ ។

ឆ្លើយតបទៅព្រះរាជអាជ្ញាវិញ ម៉ៃឃើល ខារណាវ៉ាស ដែលជាសហមេធាវីរបស់ អៀង សារី បានឆ្លើយថា គាត់មានចិត្ត «រន្ធត់» ដែលសហព្រះរាជអាជ្ញាជាតិមានការយល់ច្រឡំដោយពាក្យ «ចូលរួម» របស់ អៀង សារី ។ ក្នុងទឹកដមសំឡេងក្នុងន័យថាខ្លួនឆ្ងាតជាងព្រះរាជអាជ្ញាជាតិ ម៉ៃឃើល ខារណាវ៉ាស បាន «បញ្ជាក់ឲ្យច្បាស់» ទៅកាន់សហព្រះរាជអាជ្ញាអំពីអត្ថន័យនៃពាក្យថាការចូលរួមមិនមែនមានន័យថា ចូលរួមទេ តែជាការចូលរួមក្នុងដំណើរការសវនាការនេះតាមរយៈសកម្មភាពមួយចំនួនដូចជាមានវត្តមានក្នុងតុលាការនិងបង្ហាញពីការណែនាំផ្សេងៗក្នុងតុលាការជាដើម ។ ម៉ៃឃើល ខារណាវ៉ាស បានអះអាងឡើងវិញថា អៀង សារី បានបញ្ជាក់ជាលាយលក្ខណ៍អក្សររួចហើយថា គាត់មិនអាចធ្វើសក្ខីកម្មទេ ហើយគាត់នៅតែមានសិទ្ធិក្នុងការចូលរួមក្នុងដំណើរការ


ព្រឹទ្ធាចារ្យសហគមន៍ចាមអ៊ីម៉ាំសាន់និងព្រះសង្ឃចេញពីបន្ទប់សវនាការ

ដដែលដោយមិនចាំបាច់ធ្វើសក្ខីកម្មទេ ។

ក្រោយមក ម៉ៃឃើល ជេស្តមេន បានងើបដើម្បីឆ្លើយតបសម្រាប់ក្រុមរបស់ នួន ជា ដោយនិយាយថា «ខ្ញុំមិនច្បាស់ទេថាត្រូវទុកពេលវេលាប៉ុន្មានសម្រាប់ឲ្យខ្ញុំឆ្លើយ» ។ បន្ទាប់មក មេធាវី ជេស្តមេន បានធ្វើឲ្យតុលាការខឹងដោយស្នើម្តងទៀតសុំពេលវេលាឥឡូវនេះដើម្បីបង្ហាញពីការឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍បើករបស់សហព្រះរាជអាជ្ញា ។ និល ណុន បាននិយាយកាត់មេធាវី ជេស្តមេន ភ្លាមដែរដើម្បីនិយាយឲ្យច្បាស់ ហើយ និល ណុន បាននិយាយដោយព្រួៗថា តុលាការបានផ្តល់ឱកាសទៅក្រុមរបស់ នួន ជា ឆ្លើយរួចហើយ ។ ដោយកាយវិការខឹងចំពោះមេធាវី ជេស្តមេន និល ណុន បាននិយាយទៅកាន់មេធាវី ជេស្តមេន ដើម្បីឲ្យគាត់ឆ្លើយទៅនឹងសំណួរនាពេលនេះនៅចំពោះមុខតុលាការអំពីបំណងរបស់កូនក្តីរបស់ខ្លួនដើម្បីធ្វើសក្ខីកម្ម ។

ពេលនោះ និល ណុន បានបញ្ជាក់ថាយោបល់ផ្សេងៗឥឡូវនេះមានលក្ខណៈច្បាស់ហើយ ហើយក្រុមមេធាវីរបស់ នួន ជា មិនអាចមានយោបល់អ្វីបន្ថែមទៀតទេ ។

មេធាវី ជេស្តមេន មិនអើពើទៅនឹងសម្តីរបស់ និល ណុន ទេ ទោះបីជាក្នុងសម្តីប្រកបដោយកលល្បិចបានអរគុណតុលាការដែលបាន "ជួយ" បញ្ជាក់ឲ្យច្បាស់នោះក៏ដោយ ។ មេធាវីរូបនេះបានបញ្ជាក់បន្ថែមថា គាត់នឹងមិន «មិនសប្បាយចិត្តដែលតុលាការរៀបចំពេលវេលាបែបនេះទេ» ។ ទាក់ទងនឹងបំណងរបស់កូនក្តីខ្លួនក្នុងការធ្វើសក្ខីកម្មអ្វីដែលមេធាវី ជេស្តមេន ចង់និយាយគឺថា «យើងនឹងឆ្លងស្ពានពេលដែលយើងទៅដល់» ។

បន្ទាប់មក ខៀវ សំផន បានឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាជាតិសម្រាប់ខ្លួនគាត់ផ្ទាល់ដោយបញ្ជាក់ថាគាត់មិនអាចផ្តល់ការឆ្លើយតបបែបណាមួយទេ ។ ខៀវ សំផន បានបញ្ជាក់ទៀតថា គាត់ចង់រង់ចាំរហូតដល់គាត់ឃើញភស្តុតាងរបស់សហព្រះរាជអាជ្ញា ហើយក្រោយមកគាត់ប្តេជ្ញាចិត្តថាជា «ពេលដ៏ត្រឹមត្រូវ» ដើម្បីឆ្លើយតប ។

## មេធាវីដើមបណ្តឹងរដ្ឋប្បវេណីធ្វើឲ្យភាគីការពារក្តីខឹង

និល ណុល បានផ្តល់សិទ្ធិឲ្យទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីផ្តល់យោបល់ទាក់ទងទៅនឹង បញ្ហានេះ ។ អេលីហ្សាបែត ស៊ីម៉ូណូ ហុក ដែលជាសហមេធាវីអន្តរជាតិនាំមុខបានឆ្លើយតបថាភាគីដើមបណ្តឹងរដ្ឋប្បវេណីមានជំនឿថា «ដោយក្តីគោរពចំពោះប្រជាជនកម្ពុជាដែលជនជាប់ចោទអះអាងថា ស្រឡាញ់នោះ» ជនជាប់ចោទគួរតែផ្តល់ការពន្យល់ខ្លះៗអំពីសកម្មភាពរបស់ខ្លួននៅឯតុលាការនេះ ។ លោកស្រីបាននិយាយថា «ប្រសិនបើជនជាប់ចោទនិយាយការពិតមែននោះទើបជាការប្រសើរ» ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិនាំមុខ ពេជ អង្គ ក៏បានឆ្លើយតបក្នុងនាមភាគីដើមបណ្តឹងរដ្ឋប្បវេណីដោយបញ្ជាក់ថា បើសិនជាជនជាប់ចោទជ្រើសរើសវិធីដោយមិនឆ្លើយតប នោះមានន័យថាជនជាប់ចោទនោះបានសារភាពកំហុសរបស់ខ្លួនរួចហើយ ។

សម្តីរបស់ ពេជ អង្គ បានធ្វើឲ្យ ខាណាវ៉ាស ងើបឆ្លើយតបយ៉ាងលឿន ហើយ ខាណាវ៉ាស បានហៅសហមេធាវីនាំមុខរបស់ដើមបណ្តឹងរដ្ឋប្បវេណីថា "គ្មានការយល់ដឹងច្បាស់" អំពីសិទ្ធិនៃតុលាការយុត្តិធម៌ទេ ។ ដោយបញ្ជាក់ថា សិទ្ធិមិនបញ្ចេញមតិគឺត្រឹមត្រូវ ហើយការស្ងាត់ស្ងៀមគឺមិនមានន័យថា មានកំហុសនោះទេ ។ ខាណាវ៉ាស បានចោទទៅលោកស្រី អេលីហ្សាបែត ស៊ីម៉ូណូ ហុក និង ពេជ អង្គ ថា «ធ្វើដើម្បីផ្គាប់ចិត្តអ្នកចូលរួម» ព្រោះតែអ្នកទាំងពីរនេះត្រូវបានបដិសេធនឹងផ្តល់ឱកាសក្នុងការឡើងថ្លែង ។ ខាណាវ៉ាស បានស្នើទៅតុលាការឲ្យព្រមានអ្នកទាំងពីរដោយសារតែ «បានផ្តល់យោបល់មិនសមស្រប» ។

ទោះបីជា ពេជ អង្គ បានងើបឈរម្តងទៀតដើម្បីឆ្លើយតបក៏ដោយ ក៏ និល ណុន បានបិទការតវ៉ាទាំងអស់ ហើយបានព្រមានទៅភាគីដើមបណ្តឹងរដ្ឋប្បវេណីឲ្យឈប់ធ្វើការផ្តល់យោបល់បែបនេះទៀត ទៅកាន់ជនជាប់ចោទថ្ងៃក្រោយ ។ និល ណុន បានទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀមហើយនិងសិទ្ធិរបស់ជនជាប់ចោទក្នុងការអនុវត្តសិទ្ធនូវអ្វីដែលជនជាប់ចោទចង់ធ្វើ ។

ក្រោយពីបញ្ចប់យោបល់និងសេចក្តីថ្លែងការណ៍នានាចៅក្រម និល ណុន បានបញ្ចប់កិច្ចការសម្រាប់ថ្ងៃនេះ ។ សវនាការលើភស្តុតាងនឹងចាប់ផ្តើមនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ ខាងមុខនេះ ។ **គ្រីស្ទីន អ៊ីវេន**

# ការពិនិត្យមើលសារឡើងវិញលើការចរចារឆ្ពោះទៅរកការបង្កើត យុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

*(តពីលេខមុន)*

### *ការចូលរួមរបស់អង្គការសហប្រជាជាតិ និងការដួលរលំនៃខ្មែរក្រហម*

*ការអភ័យទោសនិងការលើកលែងទោសរបស់ អៀង សារី បានញុំាងឲ្យការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាធ្វើការស្នើសុំទៅអ្នកតំណាងពិសេសឯករាជ្យផ្នែកសិទ្ធិមនុស្សនៃអគ្គលេខាធិការអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាគឺលោក ថូម៉ាស់ ហាំម៉ាប៊ើក ដោយយោងទៅតាមតួនាទីដែលគាត់គួរតែកាន់នៅក្នុងការធ្វើរបាយការណ៍របស់គាត់ទៅកាន់ការិយាល័យអង្គការសហប្រជាជាតិនៅលើបញ្ហានៃការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ នៅក្នុងកិច្ចពិភាក្សាដំបូងនៅខែវិច្ឆិកា ឆ្នាំ១៩៩៦ ការិយាល័យសិទ្ធិមនុស្សបានរៀបរាប់ត្រួសៗទៅកាន់ ថូម៉ាស់ ហាំម៉ាប៊ើក ថា រដ្ឋាភិបាលបានធ្វើការបែងចែកជាយូរមកហើយនូវភាពខុសគ្នា “រវាងក្រុមមេដឹកនាំ (ប៉ុល ពត, នួន ជា, តាម៉ុក, អៀង សារី និងប្រហែលជាសុន សេន និង ខៀវ សំផន)” ដែលមកដល់ពេលនេះជា “អ្នកសំខាន់បំផុតដែលមិនអាចលើកលែងទោសឲ្យបាន” និង “កម្មាភិបាលព្រមទាំងទាហានដែលនៅសល់” ដែលអាចផ្តល់ការលើកលែងទោស ។ ប៉ុន្តែ ដូចគ្នានឹងរាជរដ្ឋាភិបាលកម្ពុជា ការិយាល័យសិទ្ធិមនុស្សក៏បានធ្វើការបែងចែកភាពខុសគ្នារវាងការដឹកនាំបីថ្នាក់ គឺអ្នកដែលជាមេដឹកនាំកំពូលដែលចាត់ទុកថាជា “មេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម” រួមមាន អៀង សារី ។ ថ្នាក់ក្រោមបន្ទាប់គឺអ្នកដែលបានចូលរួមជាមួយអំណាចថ្នាក់តំបន់ និងយ៉ាងហោចណាស់មានពាក់ពន្ធ័នឹងបទល្មើស “កម្រិតធ្ងន់” ។ ហើយកម្មាភិបាលថ្នាក់ក្រោមបំផុតគឺបានទទួលបន្ទុកដោយផ្ទាល់នៃ “តំណែងនិងសំណុំរឿង” ខ្មែរក្រហម ។*

*កិច្ចពិភាក្សារបស់ការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅតែបន្តទៅមុខដដែល ខណៈពេលដែលកម្មាភិបាលខ្មែរក្រហមច្រើនឡើងៗ បានផ្តាច់ខ្លួនទៅក្នុងកងទ័ពរាជរដ្ឋាភិបាលនៅអំឡុងដើមឆ្នាំ១៩៩៧ ហើយទង្វើនេះនឹងញុំាងឲ្យលោក ថូម៉ាស ហាំម៉ាប៊ើក ជំរុញលទ្ធភាពនៃការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុងដំណើរការនៃការទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះបទឧក្រិដ្ឋនាសម័យកម្ពុជាប្រជាធិបតេយ្យ ។ ជាលទ្ធផលនៃការខិតខំប្រឹងប្រែងរបស់លោកសេចក្តីសម្រេចកាលពីខែមេសា ១៩៩៧ ដោយគណៈកម្មាធិការរបស់អង្គការសហប្រជាជាតិអន្តររដ្ឋាភិបាលទទួលបន្ទុកខាងសិទ្ធិមនុស្សបានអំពាវនាវឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ដើម្បី “ពិនិត្យលើសំណើរបស់កម្ពុជាក្នុងការសុំជំនួយដើម្បីឆ្លើយតបទៅលើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរកាលពីអតីកាលទៅលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ដែលរួមមានការស្នើសុំជំនួយរបស់កម្ពុជាក្នុងការស៊ើបអង្កេតការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអន្តរជាតិកាលពីអតីតកាល” ដោយបានប្រើប្រាស់រូបមន្តដែលមិនផ្តល់នូវការណែនាំចំពោះកម្រិតនៃការទទួលខុសត្រូវនៃឧក្រិដ្ឋកម្មទាំងនោះទេ ។ ក្នុងអំឡុងកិច្ចពិភាក្សានាដើមខែមិថុនា ឆ្នាំ១៩៩៧ រវាងអ្នកតំណាងពិសេសអង្គការសហប្រជាជាតិ ថូម៉ាស់ ហាំម៉ាប៊ើក និង សហនាយករដ្ឋមន្ត្រីនរោត្តម រណឫទ្ធិ និង ហ៊ុន សែន ទាក់ទងទៅនឹងសេចក្តីសម្រេចខាងលើនោះ ថូម៉ាស់ ហាំម៉ាប៊ើក គឺមិនអាចកំណត់បានដូចគ្នា ដោយគាត់តាំងចិត្តដើម្បីគ្រាន់តែជួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីស្វែងរក “មធ្យោបាយសមស្របណាមួយ...ដើម្បីស្តាបនាការពិតអំពីអំពើយង់ឃ្នង” និង “ដើម្បីនាំយកអ្នកដែលមានពិរុទ្ធទៅកាន់តុលាការ” នៃការប្រព្រឹត្តអំពើទាំងនោះ ។*

កិច្ចពិភាក្សាកើតឡើងដំណាលគ្នាទៅនឹងការផ្ដាច់ខ្លួនរបស់មេដឹកនាំ«មេដឹកនាំក្បាលរឹង» ខ្មែរក្រហមដែលបានបង្កើតឡើងដោយដំណើរការខិតខំប្រឹងប្រែងរបស់គណបក្សប្រជាជនកម្ពុជា និង គណបក្សហ៊្វុនស៊ិនប៉ិចដើម្បីទាក់ទាញយកអ្នកផ្ដាច់ខ្លួនបន្តទៀតដែលរួមមានជនក្បាលរឹងខ្លួនឯងផ្ទាល់ផង ។ ដោយសារភ័ស្តុតាងនៃទង្វើបែបនេះ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៩៧ វិទ្យុខ្មែរក្រហមបានប្រកាសនូវអ្វីដែលគេចាត់ទុកថាជាផែនការ «ចារកិច្ច» ដែលបានគំរាមដល់ការតស៊ូរបស់ចលនាខ្មែរក្រហម ហើយនៅថ្ងៃទី៩ ខែមិថុនា ប៉ុល ពត បានកោះហៅ នួន ជា, តាម៉ុក, និង សុន សេន ដើម្បីមកប្រជុំនៅអន្លង់វែង ។ សុន សេន បានបដិសេធការអញ្ជើញនេះដោយខ្លាចថាគាត់នឹងអាចត្រូវចាប់ខ្លួន ។ នៅយប់ដដែលនោះ ប៉ុល ពត បានបញ្ជាមេបញ្ជាការកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យជាច្រើននាក់ ដែលធ្លាប់បានទទួលការឧបត្ថម្ភពី សុន សេន ឲ្យធ្វើឃាត សុន សេន។ មេបញ្ជាការដែលជាពេជ្ឈឃាតនោះបានទៅដល់កន្លែងស្នាក់នៅរបស់ សុន សេន ហើយបានសម្លាប់គាត់ និងអ្នកដទៃទៀតដែលមានវត្តមាននៅក្នុងផ្ទះនោះ រួមមានទាំងភរិយានិងកូនៗរបស់ សុន សេន ផង ។ នៅព្រឹកថ្ងៃទី១០ ខែមិថុនា ខៀវ សំផន បានស្ដាប់ឮ «ការប្រកាស» តាមវិទ្យុពីការ «ចាប់ខ្លួនខ្សែរយៈក្បត់របស់ សុន សេន» ដែលគាត់បានចាត់ទុកថាគ្រាន់តែជា «ខ្សែរយៈមួយក្នុងចំណោមខ្សែរយៈក្បត់សំខាន់នៃភាពគួរឲ្យស្អប់ខ្ពើម... អាយ៉ងរបស់ ហ៊ុន សែន» ដែលលើកឡើងថា នឹងមានការចាប់ខ្លួន និងការសម្លាប់ច្រើនទៀត ។

យោធានៅក្រោមការបង្គាប់បញ្ជារបស់ តាម៉ុក មួយចំនួនមានប្រតិកម្មតបនឹងការសម្លាប់ សុន សេន ហើយបានបញ្ជាក់ថា តាម៉ុក ក៏នឹងត្រូវសម្លាប់ដោយសារតែការកៀងគរទ័ពប្រឆាំងនឹង ប៉ុល ពត ទោះបីក្នុងនាមជាកងកម្លាំងតបតនឹង ប៉ុល ពត ដែលការពិតធ្វើការរៀបចំដើម្បីដណ្ដើមអំណាច និងសម្លាប់ តាម៉ុក ទៅវិញទេ ។ នៅថ្ងៃទី១៨ ខែមិថុនា យោធានៅក្រោមបង្គាប់របស់ តាម៉ុក មួយក្រុមបានបង្កើតការត្រួតត្រាតំបន់អន្លង់វែងនិងបង្កើតវិទ្យុបញ្ជូនសាររបស់ខ្មែរក្រហមនៅទីនោះ ។ ប៉ុល ពត បានភៀសខ្លួនទៅខាងភាគឧត្តរឆ្ពោះទៅព្រំដែនថៃរួមដំណើរដោយ នួន ជា និង ខៀវ សំផន ក្រោមការការពារដោយកងទ័ពដែលបានធ្វើឃាត សុន សេន។ នៅថ្ងៃបន្ទាប់ កងកម្លាំងដែលត្រួតត្រាអន្លង់វែងបានធ្វើសេចក្ដីថ្លែងការណ៍ដោយប្រកាសថា «អំពើក្បត់របស់ ប៉ុល ពត» បាន «កើតមានឡើងចាប់ពីយប់ថ្ងៃទី៩ ខែមិថុនា ដល់ថ្ងៃទី១៨ ខែមិថុនា ១៩៩៧» ។ ប៉ុន្តែ ឧបទ្ទវហេតុនេះត្រូវបាន «ដោះស្រាយនិងស្រោចស្រង់ឲ្យមានប្រក្រតីវិញនៅថ្ងៃទី១៨ ខែមិថុនា ១៩៩៧» ។

បីថ្ងៃក្រោយមក មានសេចក្ដីប្រកាសជាពិសេសមួយបានបញ្ជាក់ថា ប៉ុល ពត ត្រូវបានឃាត់ខ្លួននៅតាមព្រំដែនថៃ និង បាន «សុំចុះចាញ់» ។ នៅពេលដែល ប៉ុល ពត ដឹងថាគាត់ត្រូវបានវាយប្រហារ «គាត់បានត្រឡប់ទៅរកយុទ្ធសាស្ត្រសម្របសម្រួល» ដោយសង្ឃឹមថាកំហឹងរបស់ តាម៉ុក ប្រឆាំងនឹងគាត់អាចត្រូវបានបន្ធូរបន្ថយ ។ ប៉ុល ពត បានបញ្ជូនប្រេសិតពីររូបដើម្បីជួបនឹង តាម៉ុក និងពន្យល់គាត់ថា «ប៉ុល ពត ចង់ស្នើជូន» ថា គាត់ «សុខចិត្តទទួលស្គាល់ តាម៉ុក ជាអ្នកជំនួសឲ្យខ្លួនក្នុងនាមជា...មេដឹកនាំ» ហើយប្រេសិតទាំងពីរបានប្រាប់ទៅ តាម៉ុក ដែរថា «ប៉ុល ពត បានរៀបចំខ្លួនរួចជាស្រេចនឹងឲ្យវិទ្យុផ្សាយសំឡេងនៅអន្លង់វែងប្រកាសថា គាត់ជាជនក្បត់ត្រូវបានចាប់និងឃុំខ្លួន» ហើយបញ្ជាក់ទៀតថា ប៉ុល ពត ត្រៀមខ្លួនរួចជាស្រេចដើម្បីប្រឈមមុខនឹង «ក្រុមប្រជាជនបះបោរនៅអន្លង់វែង» ដែលគាត់នឹងធ្វើការប្រកាសថាជាជនក្បត់ ។

លក្ខខណ្ឌទាំងនេះត្រូវបានយល់ព្រម ហើយត្រូវបានប្រកាសថា ប៉ុល ពត ត្រូវបាន «ចាប់ខ្លួន» នៅថ្ងៃទី១៩ ខែមិថុនា ។ វិទ្យុខ្មែរក្រហមបានប្រកាសថា «ប្រជាជននិងក្រុមមហាជន» កម្ពុជា នឹង «ស្វាគមន៍យ៉ាងពិតប្រាកដនូវយុគសម័យថ្មីបន្ទាប់ពីការបញ្ចប់នូវរបបផ្ដាច់ការ ប៉ុល ពត» ។ ការផ្សព្វផ្សាយនេះបានធ្វើឲ្យ «ក្រុមមហាជននៅអន្លង់វែងស្វាគមន៍នូវការបញ្ចប់អំពើក្បត់ជាតិនិងភាពផ្ដាច់ការរបស់ ប៉ុល ពត» ។ ដោយ ប៉ុល ពត និង ម៉ុក បានព្រមព្រៀងគ្នា អ្នកតំណាងនៃ «ក្រុមមហាជន» បានប្ដូរវេនគ្នាម្ដងម្នាក់ៗបរិហារ ប៉ុល ពត ទៅកាន់សាធារណជនដែលរួមមានទាំង តាម៉ុក ផង ប៉ុន្តែមិនមាន ខៀវ សំផន ទេ ដោយគាត់បដិសេធមិនចូលរួម ។

**លិខិតជូនទៅកាន់អគ្គការសហប្រជាជាតិកាលពីខែមិថុនា ឆ្នាំ**

## ១៩៩៧ និងទិសានវាទនៃ ចលនាខ្មែរក្រហម

នៅពេលដែល ប៉ុល ពត ត្រូវបានបណ្តេញចេញពីចលនាខ្មែរក្រហម សហនាយករដ្ឋមន្ត្រីទាំងពីរបានចុះហត្ថលេខានៅលើលិខិតមួយដែលព្រាងដោយមន្ត្រីរបស់ការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅទីក្រុងភ្នំពេញ ។ នៅក្នុងលិខិតនោះ សហនាយករដ្ឋមន្ត្រីទាំងពីរស្នើសុំ “ជំនួយពីអង្គការសហប្រជាជាតិ” ដើម្បីឆ្លើយតបទៅនឹងការរំលោភដ៏ធ្ងន់ធ្ងរកាលពីអតីតកាលទៅលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ជាមធ្យោបាយក្នុងការនាំមកនូវការបង្រួបបង្រួមជាតិ ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងដោះស្រាយបញ្ហានៃការទទួលខុសត្រូវជាលក្ខណៈបុគ្គល ។ ដោយទទួលស្គាល់ថា រដ្ឋាភិបាលកម្ពុជា “មិនមានធនធាន និងអ្នកជំនាញ” ដែលចាំបាច់ក្នុងការធ្វើកិច្ចការដ៏ធំនេះ ខ្លឹមសារនៅក្នុងលិខិតនោះបានបង្ហាញពីក្តីរំពឹងក្នុងការទទួលបានជំនួយ “ស្រដៀងគ្នា” ទៅនឹងអ្វីដែលជាលទ្ធផលនៅក្នុងការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី និងប្រទេសរ៉្វាន់ដា ។ លិខិតនោះមិនបានរៀបរាប់អំពីជនសង្ស័យដែលមានសក្តានុពលក្នុងការយកមកទទួលខុសត្រូវតាមផ្លូវច្បាប់ទេ ។ ប៉ុន្តែ តាមសំណើរបស់មន្ត្រីមួយរូបទទួលបន្ទុកការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ខ្ញុំបានព្រាងអនុស្សរណៈមួយក្នុងនាមខ្លួនឯងផ្ទាល់ដោយស្នើថា ការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិគួរតែធ្វើកិច្ចការនេះដោយចាប់ផ្តើមប្រមូលព័ត៌មានភស្តុតាង ដែលទាក់ទងផ្ទាល់ជាមួយនឹងកម្មាភិបាល និងអតីតថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានប្រព្រឹត្តបទល្មើសទាក់ទងទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទប្រល័យពូជសាសន៍ ។ អនុស្សរណៈនោះបានផ្តល់និយមន័យទាំងស្រុងថា មេដឹកនាំដែលជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម រួមទាំងសមាជិកនៃគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាដែលនៅក្រោមបង្គាប់ផង និងសំដៅទៅលើកម្មាភិបាលនៃមន្ទីរសន្តិសុខស–២១ផង ។

អនុស្សរណៈនោះបានរៀបរាប់ឈ្មោះអតីតសមាជិកអចិន្ត្រៃយ៍ទាំងបួនរូបដូចជា ប៉ុល ពត, នួន ជា, ម៉ុក និង អៀង សារី ហើយក៏បានកំណត់អត្តសញ្ញាណមនុស្សប្រាំបីនាក់ទៀតដែលបានស្គាល់ ឬក៏ជាអតីតសមាជិកគណៈកម្មាធិការមជ្ឈិមបក្សដោយមិនដឹងថានៅរស់ឬក៏ស្លាប់មានដូចជា ៈ ខៀវ សំផន, កែ ពក, សំ ប៊ិត, កែ មុត ហៅ មាស មុត, សៅ ម៉េត ហៅ ស៊ូ ម៉េត, ទិត ហៅ ឃឹម ទិត, សូ សារឿន ហៅ សៅ សារឿន និង ខាត់ វ៉ែន ។ អនុស្សរណៈនោះក៏បានរាយឈ្មោះកម្មាភិបាលរបស់មន្ទីរស–២១ចំនួនប្រាំនាក់ទៀតទោះបីមិនដឹងថានៅរស់ឬក៏ស្លាប់ ដោយរាប់ចាប់ពី កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលត្រូវបានស្គាល់ថាជាប្រធាន ។ ក្រោយមកទើបដឹងថា មនុស្សដែលរាយនៅក្នុងអនុស្សរណៈនោះជាច្រើននាក់បានស្លាប់ទៅហើយ រួមមាន សូ សារឿន និង វ៉ែន ជាដើម ។

ការដែលលេចឡើងនៃកិច្ចព្រមព្រៀងរបស់សហនាយករដ្ឋមន្ត្រីទាំងពីរទាក់ទងទៅនឹងការដាក់ឲ្យទទួលខុសត្រូវបង្កឲ្យមានភាពចម្រូងចម្រាសរវាងសហនាយករដ្ឋមន្ត្រីទាំងពីរដែលបន្តរហូតដល់ច្រើនខែ ត្រង់ចំណុចថាតើភាគីមួយណាដែលនឹងមានប្រៀបលើតុលាការចម្រុះនេះ ។ ប៉ុន្តែភាពចម្រូងចម្រាសនេះ ក៏ទាក់ទងទៅនឹងការចោទប្រកាន់គ្នាទៅវិញទៅមកត្រង់ថា ភាគីសហនាយករដ្ឋមន្ត្រីទាំងពីរមានគម្រោងនឹងយកសម្ព័ន្ធភាពដែលជាខ្មែរក្រហមដើម្បីរួបរួមជាកម្លាំងយោធាដើម្បីប្រឆាំងគ្នាទៅវិញទៅមក ។ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៩៧ ការប្រឈមមុខដាក់គ្នាបានផ្ទុះឡើងនៅក្នុងរដ្ឋប្រហារមួយ រវាងនាយករដ្ឋមន្ត្រី ហ៊ុន សែន និងសម្តេចនរោត្តម រណឫទ្ធិ បន្ទាប់ពីកងទ័ពដែលស្មោះត្រង់នឹងទ្រង់នរោត្តម រណឫទ្ធិ ប្រកែកមិនព្រមដកអាវុធដែលទាមទារដោយកងទ័ពរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ហេតុការណ៍ក្រោយរដ្ឋប្រហារ និងការត្រៀមក្នុងការរៀបចំការបោះឆ្នោត ដែលគណបក្សប្រជាជនកម្ពុជាដើម្បីប្រឆាំងនិងគណបក្សហ៊្វុនស៊ិនប៉ិចគឺជាហេតុការណ៍ដ៏សំខាន់សម្រាប់គណបក្សទាំងពី និងអង្គការសហប្រជាជាតិនៅកម្ពុជា ។ ប៉ុន្តែ កិច្ចខំប្រឹងប្រែងរបស់គណបក្សប្រជាជនកម្ពុជាក្នុងការផ្តួលរំលំចលនាខ្មែរក្រហម រួមទាំងតាមរយៈការផ្តាច់ខ្លួនរបស់ខ្មែរក្រហម និងក្រុមក្បាលរឹងដើម្បីចុះចូលជាមួយរដ្ឋាភិបាលនៅតែបន្តស្របពេលជាមួយនិងការងារដែលចេះតែទៅមុខរបស់អង្គការសហប្រជាជាតិ ដើម្បីនាំទៅរកការទទួលខុសត្រូវពីបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តក្រោមការ

 

គ្រប់គ្រងរបស់បក្សកុម្មុយនីស្ដកម្ពុជា ។

ក្នុងខែមិនា ឆ្នាំ១៩៩៨ មានផ្ទុះហេតុការណ៍មួយនៅអន្លង់វែង ដែលធ្វើឲ្យ ម៉ុក ចេញពីអំណាចពីទីបញ្ជាការកងទ័ពរបស់គាត់ដែលបង្កឡើងដោយកងទ័ពដែលស្មោះនិង កែ ពក ដែលជាអតីតសមាជិកគណៈកម្មាធិការមជ្ឈិមរបស់បក្សកុម្មុយនីស្ដកម្ពុជា ហើយក៏ជាអ្នកដែលមានឈ្មោះនៅក្នុងបញ្ជីរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងចំណោមឈ្មោះទាំងប្រាំបីនាក់ដែលនឹងត្រូវយកទៅកាត់ទោស ។ ពេលនេះ កែ ពក ក្លាយជាអតីតកម្មាភិបាលជាន់ខ្ពស់បំផុតម្នាក់របស់បក្សកុម្មុយនីស្ដកម្ពុជា ដែលបាន "ផ្ដាច់ខ្លួនចេញ" បន្ទាប់ពី អៀង សារី ។ នៅថ្ងៃទី២៦ ខែមិនា កែ ពក និង ហ៊ុន សែន បានចេញសេចក្ដីថ្លែងការណ៍ស្របគ្នាមួយ ។ កាលនោះ កែ ពក បានប្រកាសខ្លួនឯងថា "ប្រឆាំងចំពោះមេឃាតករក្បាលរឹង ប៉ុល ពត, តាម៉ុក, ខៀវ សំផន និង នួន ជា ។ កែ ពក បន្ដទៀតថា គាត់បានបំបែកខ្លួនចេញពីការ "គ្រប់គ្រង ការដឹកនាំ និងការបញ្ជា" របស់មេខ្មែរក្រហមក្បាលរឹងទាំងអស់នោះ ហើយគាត់ចង់រួបរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាវិញ ។ កែ ពក បានអំពាវនាវដល់ ហ៊ុន សែន "សូម...មេត្តាទទួលស្គាល់" ការផ្ដាច់ខ្លួនរបស់គាត់ និងអនុញ្ញាតឲ្យគាត់ "រួបរួមក្នុងសង្គមជាតិដូច" អៀង សារី ដែរ ។ ហ៊ុន សែន បានឆ្លើយតបដោយស្វាគមន៍ "យ៉ាងកក់ក្ដៅ រំជួលចិត្ត និងសប្បាយរីករាយ" ដល់ស្មារតីស្រលាញ់សន្តិភាពនិងស្នេហាជាតិរបស់ កែ ពក ហើយ "ការសម្រេចចិត្តត្រូវរបស់ កែ ពក នេះនឹងរួមចំណែកក្នុងការបង្រួបបង្រួមជាតិ" ។ ហ៊ុន សែន បានផ្ដល់ការ "ធានា" ដល់ កែ ពក ក្នុងការទទួលបាននូវភាពរីករាយនៃ "សិទ្ធិនយោបាយនិងផលប្រយោជន៍ផ្សេងទៀតដែលពលរដ្ឋកម្ពុជាសាមញ្ញមានដោយគ្មានការរើសអើងអ្វីទាំងអស់" ហើយ ហ៊ុន សែន បានសន្យាជាមួយ កែ ពក ថានិងបញ្ចូលគាត់ទៅក្នុងកងយោធពលខេមរភូមិន្ទ ។

នៅពេលដែល តាម៉ុក គេចខ្លួនពីអន្លង់វែងទៅទិសខាងជើង ប៉ុល ពត ដែលកំពុងតែនៅក្រោមការឃុំខ្លួនរបស់ តាម៉ុក បានស្លាប់ ។ ក្រោយមក បន្ទាប់ពីកម្មាភិបាលជាន់ខ្ពស់បំផុតទីពីរក្នុងថ្នាក់ដឹកនាំបានចុះចាញ់រាជរដ្ឋាភិបាលជាមួយនឹងកងទ័ពជាច្រើននាក់ក្នុងចន្លោះខែឧសភា និងដើមខែធ្នូ ឆ្នាំ១៩៩៨ តាម៉ុក, នួន ជា និង ខៀវ សំផន ត្រូវរាយការណ៍មកថាកំពុងស្ថិតនៅក្នុងការដាក់ឃុំឲ្យនៅក្នុងផ្ទះខណៈពេលដែលបេសកជនរបស់រាជរដ្ឋាភិបាលកម្ពុជាស្វែងរកការចរចាជាមួយថ្នាក់ដឹកនាំទាំងអស់នោះដើម្បីឲ្យទទួលយកនូវការចុះចាញ់ ។ បន្ទាប់ពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ធានាអះអាងជា "ឯកជន" ចំពោះ នួន ជា និង ខៀវ សំផន ថានឹងមិនយកទៅកាត់ទោសជាអន្តរជាតិ ហើយប្រសិនបើជាអ្នកទាំងពីរនេះត្រូវកាត់ទោសដោយតុលាការក្នុងស្រុក អ្នកទាំងពីរនេះនឹងត្រូវទទួលបានការលើកលែងទោស អ្នកឃ្លាំមើលការខុសត្រូវដែលជាជនជាតិថៃបាននាំ នួន ជា និង ខៀវ សំផន ទៅប៉ៃលិនជាកន្លែងដែល អៀង សារី តាំងនៅតាំងពីគាត់ទទួលបាននូវការលើកលែងទោស និងអភ័យទោសតាំងពីឆ្នាំ១៩៩៦មក ។

ការចរចាចុងក្រោយរវាងនាយករដ្ឋមន្ត្រី ហ៊ុន សែន និង នួន ជា និង ខៀវ សំផន បណ្ដាលឲ្យមានការប្រកាសដំណឹងមួយនៅថ្ងៃទី២៥ ខែធ្នូថា នួន ជា និង ខៀវ សំផន សុខចិត្តចុះចាញ់ដោយ "គ្មានលក្ខខណ្ឌ" ។ នៅក្នុងលិខិតដែលបានផ្ញើទៅកាន់នាយករដ្ឋមន្ត្រីនៅថ្ងៃនោះ នួន ជា និង ខៀវ សំផន បានស្នើសុំត្រឹមតែ "ដើម្បីរស់នៅដូចប្រជាជនធម្មតា" ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានឆ្លើយតបដោយបញ្ជាក់អំពី "ការស្វាគមន៍ដោយកក់ក្ដៅជាទីបំផុត" ដល់អ្នកទាំងពីរ ហើយក៏ថ្លែងអំណរគុណដល់អ្នកទាំងពីរដែលមាន "ឆន្ទៈដ៏មានតម្លៃដើម្បីបញ្ចប់សង្គ្រាម និងស្វែងរកសន្តិភាព ការបង្រួបបង្រួមជាតិ និងរួបរួមជាតិ" ហើយនាយករដ្ឋមន្ត្រី ហ៊ុន សែន ជូនពរដល់អ្នកទាំងពីរឲ្យ "មានអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ" ប៉ុន្តែនាយករដ្ឋមន្ត្រីមិនបានផ្ដល់អ្វីផ្សេងទៀតដល់អ្នកទាំងពីរទេ ។ ប្រហែលជាធ្វើឲ្យប្រាកដម្ដងទៀតថា ខ្លួនមិនស្ថិតនៅក្នុងការចាប់ខ្លួនទេនោះ នួន ជា និង ខៀវ សំផន បានយល់ព្រមមកភ្នំពេញដើម្បីជួបប្រជុំជាមួយនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ក្នុងជំនួបនេះហើយដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសនៅថ្ងៃទី២៨ ខែធ្នូ ថា កម្ពុជាគួរតែ "ជីកកប់អតីតកាល" តាមបំណងរបស់ នួន ជា និង ខៀវ សំផន ។ ពេលនេះនៅសល់តែ តាម៉ុក ម្នាក់គត់ក្នុងចំណោមជនសង្ស័យទាំងប្រាំបីដែលមាននៅក្នុងបញ្ជីដើមដែលជាថ្នាក់ដឹកនាំនៅរស់ និងកំពុងគេចខ្លួន ហើយមេបញ្ជាការរងរបស់គណបក្សប្រជាជនកម្ពុជាបានប្រកាសថា ម៉ុក គួរតែ "ទទួល

 

ខុសត្រូវតែម្នាក់ឯងគត់ ពីបទអំពើប្រល័យពូជសាសន៍» នៃរបប កម្ពុជាប្រជាធិបតេយ្យ ។

នៅថ្ងៃទី៩ ខែមករា ឆ្នាំ១៩៩៩ វិទ្យុរបស់រាជរដ្ឋាភិបាល កម្ពុជាបានផ្សាយថា តាម៉ុក និងមិនមានឱកាសគេចពីការ «កាត់ទោស» បានទេ ហើយ ម៉ុក នឹងមិនមានជោគវាសនាដូច នួន ជា និង ខៀវ សំផន ឡើយ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅតែប្រកាន់ជំហរយ៉ាងមាំថា គាត់នឹង «មិនទទួលការចុះចាញ់» របស់ ម៉ុក ឡើយ ។ ការព្យាយាមរបស់ ម៉ុក ក្នុងការចរចាជាមួយរដ្ឋាភិបាល ជារឿងលែងបានការហើយ ។ បន្ទាប់ពីការធ្វើសមាហរណកម្មចុងក្រោយនៃក្រុមមេបញ្ជាការចូលក្នុងរាជរដ្ឋាភិបាលកម្ពុជាដែលនៅសេសសល់ក្នុងខែកុម្ភៈ ឆ្នាំ១៩៩៩ តាម៉ុក នៅតែគេចខ្លួន ហើយ រដ្ឋមន្ត្រីការពារជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាបានគូសបញ្ជាក់ថា «គ្មានឱកាសនឹងវាយមកលើរដ្ឋាភិបាលទៀតបានទេ» ។ យោធាកម្ពុជាចាប់ផ្តើមនិយាយឡើងវិញពីកិច្ចប្រតិបត្តិការក្នុងការនាំយក ម៉ុក ទៅកាត់ទោសដោយប្រើ «នុយដើម្បីចាប់ត្រី» ដើម្បីនាំទៅរកការចាប់ខ្លួនគាត់ ។ នៅថ្ងៃទី៦ ខែមិនា នៅពេលដែល ម៉ុក ព្យាយាមបន្ត «ការចរចាទាក់ទងនឹងលក្ខខណ្ឌនៃការចុះចាញ់ ឧត្តមសេនីយ៍ជាន់ខ្ពស់ម្នាក់របស់កងយោធពលខេមរភូមិន្ទបានប្រកាសថា ម៉ុក កំពុងស្ថិតនៅក្នុងការឃុំខ្លួននៅថ្ងៃនោះ «នៅពេលដែលគាត់កំពុងព្យាយាមឆ្លងព្រំដែនពីប្រទេសថៃទៅកាន់ប្រទេសកម្ពុជា» ។ ម៉ុក ត្រូវបានចាប់ខ្លួនដោយសារតែមានកិច្ចព្រមព្រៀងជាមួយកងយោធាថៃដែលបានផ្តល់ការជ្រកកោនដល់ ម៉ុក នៅក្នុងទឹកដីថៃ ។ ទូរទស្សន៍របស់រាជរដ្ឋាភិបាលកម្ពុជាបានរាយការណ៍ថា ការចាប់ខ្លួននោះ «ត្រូវបានធ្វើឡើងក្រោមបញ្ជារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន» ហើយថា «ពិរុទ្ធជន» ត្រូវបាននាំយកទៅភ្នំពេញ ដើម្បីឃុំឃាំង ។

ក្នុងខែមិនា ឆ្នាំ១៩៩៩ អតីតប្រធានមន្ទីរស-២១ បានចូលរួមជាមួយ ម៉ុក នៅក្នុងមន្ទីរឃុំឃាំងដែរ ។ ក្នុងខែមេសា ឆ្នាំ១៩៩៩ ឌុច ចេញបង្ហាញខ្លួនពីអ្វីដែលគេមិនសូវស្គាល់ដើម្បីនិយាយទៅកាន់អ្នកសារព័ត៌មានអន្តរជាតិ ។ នៅក្នុងការកត់សម្គាល់ដំបូងដែលបានបោះពុម្ពផ្សាយ ឌុច បានចោទ នួន ជា និង ម៉ុក ក្នុងការទទួលខុសត្រូវក្នុងការសម្លាប់ប្រជាជនកម្ពុជា ។ ភ្លាមៗនោះដែរ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា គាត់បានចេញបទបញ្ជាថា ឌុច គួរតែនាំទៅតុលាការដើម្បីធ្វើជាសាក្សី ។ នៅថ្ងៃទី៧ ឧសភា អ្នកនាំពាក្យរដ្ឋាភិបាលបាននិយាយថា ឌុច ត្រូវបានដាក់ក្រោមការឃុំខ្លួនដ៏សុវត្ថិភាពដើម្បី «ទុកជាសាក្សីសំខាន់មួយសម្រាប់សវនាការមេដឹកនាំខ្មែរក្រហម» ។ នៅថ្ងៃទី៩ ខែឧសភា ឌុច ត្រូវបាននាំទៅភ្នំពេញតាមឧទ្ធម្ភាគចក្រហើយត្រូវបានដាក់បន្ទប់រួមគ្នាជាមួយ តាម៉ុក ក្រោយ មក ឌុច ត្រូវបានចោទប្រកាន់ក្រោមមាត្រា៣នៃច្បាប់ដាក់កម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់កាលពីឆ្នាំ១៩៩៤ ។

**ស៊ីន ហេះឌី**



# រឿងរ៉ាវពិតរបស់ខ្ញុំ

**(តចប់)**



ខ្លូ ហួត

រឿងនេះបានធ្វើឲ្យខ្ញុំនឹកឃើញដល់តាដែលខ្ញុំនៅជាមួយ និយាយប្រាប់ថា មើលថែស្រឡាញ់វាថ្ងៃណាមួយវានឹងជួយយើង ។ គាត់បន្តថា គាត់ធ្លាប់ត្រូវក្របីជួយឲ្យរួចផុតពីខ្លាខាំ ក្របីចេះជួយគ្នាវា និងចេះជួយម្ចាស់របស់វា ។ ក្រោយមក ខ្ញុំបានផ្លាស់ទៅកន្លែងឃ្វាលក្របីថ្មីមួយទៀត គឺនៅវាលល្បាប់ដែលមានបឹងធំមួយក្បែរមាត់បឹងមានគុហាចាស់បូរាណដែលសង់អំពីឈើខ្មៅប្រក់ក្បឿង ហើយដែលបែកបាក់ស្ទើរតែរលំគុហាទៅហើយ ។ នៅទីនោះ ខ្ញុំមិនឃើញមនុស្សនិងផ្ទះអ្នកស្រុករស់នៅទេ គឺស្ងាត់ជ្រងំឮតែសំឡេងសត្វក្របីនិងបក្សីយំ ហើយខ្ញុំក៏មិនដឹងគេហៅថាភូមិអ្វីដែរ ។ ខ្ញុំឃ្វាលក្របីបានប្រហែលមួយសប្តាហ៍ក៏មានយោធាមួយក្រុមមកដេញខ្ញុំឲ្យកៀងក្របីចេញឆ្ងាយពីទីនេះវិញ ។ ក្រុមយោធានោះមានយកមកជាមួយនូវគ្រឿងចក្រ (អាប៊ុលដូស័រ) ដើម្បីឈូសព្រៃ ហើយមួយសន្ទុះក្រោយមកខ្ញុំឃើញកងចល័តមួយកងមកកាប់រំលើងដើមឈើតូចៗ ។

**ពស់អ្នកតា**

ខ្ញុំបានឮកងចល័តនិយាយថា អង្គការតម្រូវឲ្យមកកាស់រំលើងព្រៃដើម្បីធ្វើស្រែវិញ ។ ខ្ញុំក៏បានកៀងហ្វូងក្របីចេញឆ្ងាយពីគេធ្វើការបន្តិច ប៉ុន្តែស្រាប់តែពេលអាត្រាក់មកឈូសដើមឈើមួយដើមធំនៅក្បែរនោះទៀត ក៏ឃើញពស់មួយគូខ្មៅនិលមានទំហំប្រហែលប៉ុនក៏ជើងអើតក្បាលចេញមក ប៉ុន្តែមិនបានធ្វើឲ្យនរណាមានគ្រោះថ្នាក់ទេ ។ ទាំងកងយោធា និងកងចល័តភ័យផ្អើលរត់យកតែព្រះអាយុរៀងៗខ្លួនធ្វើឲ្យក្របីផ្អើលដោយសារមនុស្សទាំងអស់នោះដែរ ។ មួយសន្ទុះក្រោយ ពស់មួយគូរនោះបានវារចូលទៅក្នុងព្រៃបាត់ ។ ខ្ញុំមិនបានទៅកន្លែងឆ្ងាយទេ ដោយសារខ្ញុំចង់នៅមើលហេតុការណ៍នេះ ។ មួយសន្ទុះធំក្រោយមកយោធាបានត្រឡប់វិញដោយមានទាំងស្ពាយកាំភ្លើងបេ៤០មកផង ។ យោធាទាំងអស់បានផ្ទុំគ្រាប់បេបាញ់សំដៅទៅគុហាទ្រុឌទ្រោមនោះធ្វើឲ្យប៉ើងកម្ទេចកំទេចឈើ និងក្បឿងឡើងទៅលើអាកាសនិងហុយផ្សែងខ្ទូលខ្មាញ់រកមើលអ្វីពុំឃើញ ។ ខ្លាចបាត់ក្របីខ្ញុំកៀងហ្វូងក្របីចេញទៅឃ្វាលឆ្ងាយពីទីនេះ ។

រំលងមួយថ្ងៃក្រោយមក ខ្ញុំឮថាពស់មួយគូដែលប្រជាជនជឿថានៅថែរក្សាការពារគុហាចាស់ងាប់ហើយ ហើយយោធានិងកងចល័តបានយកទៅធ្វើម្ហូប ។ ប៉ុន្តែរយៈពេលបីថ្ងៃក្រោយមកយោធានិងកងចល័តនោះដែលហូបពស់នោះបានស្លាប់ជាបន្តបន្ទាប់រហូតដល់កងចល័តវើអង្គភាពចេញ ចំណែកតាដែលខ្ញុំស្នាក់នៅជាមួយបានស្លាប់ដែរ ។ ខ្ញុំដេកក្នុងរោងចាំក្របីក្បែរគាត់មិនបានដឹងថាគាត់បានស្លាប់ពីពេលណាទេ ព្រោះកាលពីព្រលប់ខ្ញុំនៅបម្រើគាត់ដូចធម្មតា ហើយរៀងរាល់ព្រឹកគាត់តែងតែក្រោកមុនខ្ញុំនិងអង្គុយដក់បារីស្លឹកសង្កែ ។ ប៉ុន្តែព្រឹកនោះ ខ្ញុំមិនឃើញគាត់ក្រោកទេ ហើយដោយមានការសង្ស័យ ខ្ញុំបានទៅដាស់និងស្ទាបគាត់ស្រាប់តែខ្លួនគាត់ឡើងត្រជាក់ស្រេបដូចទឹកកក ។ ខ្ញុំបានរត់ទៅប្រាប់ប្រធានភូមិឲ្យដឹងពីរឿងនេះ ប្រធានភូមិ និងមូលដ្ឋានមកជីករណ្តៅដើម្បីបញ្ចុះសពគាត់នៅក្បែររោងនោះដោយមានកងយោធាទៅគោរពវិញ្ញាណក្ខន្ធគាត់ទៀតផង ។ ចំណែកខ្ញុំត្រូវប្រធានភូមិឲ្យត្រឡប់មកនៅធ្វើការក្នុងភូមិវិញដោយប្រគល់ក្របីដែលខ្ញុំ

ឃ្លាលឲ្យអ្នកមូលដ្ឋានមើលថែរក្សាវិញ ។ ខ្ញុំមិនដឹងថា តាដែលខ្ញុំស្នាក់នៅជាមួយបានហូបសាច់ពស់ឬ អត់ទេ ។ កាលពីគាត់នៅរស់ គាត់បានបង្ហាត់បង្រៀនខ្ញុំឲ្យស្គាល់ដើមឈើព្រៃច្រើនប្រភេទនិងរបៀបមើលថែសត្វនិងជំងឺសត្វដោយប្រើប្រាស់រុក្ខជាតិ ។ គាត់ជាមនុស្សមានអំណាចនៅក្នុងភូមិ ហើយខ្ញុំមិនដឹងថា មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គាត់ធ្វើអ្វីមានឋានៈជាអ្វីដែរ ប៉ុន្តែចំពោះខ្ញុំគាត់មានចិត្តល្អ ។

**មកដល់ភូមិចាស់**

ក្រោយពីមរណភាពតាដែលខ្ញុំស្នាក់នៅមិនបានប៉ុន្មានផង ក៏ឮថាក្របីទាំងអស់ត្រូវបានប្រគល់ឲ្យទៅភូមិវិញ ដើម្បីជាមធ្យោបាយអូសទាញ ។ ខ្ញុំបានត្រឡប់មកភូមិបានពីរថ្ងៃ គឺនៅដើមខែមិថុនា ឆ្នាំ១៩៧៨ ប្អូនប្រុសខ្ញុំបានមកជួបខ្ញុំ ហើយបាននិយាយថា គាត់ឈប់នៅអង្គភាពកុមារយូរខែហើយ ព្រោះអង្គការបានបំបែកកុមារអាយុ១៤-១៦ឆ្នាំទៅធ្វើការនៅអង្គភាពផ្សេង ។ ចំណែកគាត់ត្រូវបានចាត់តាំងឲ្យមកកាន់អង្គភាពភ្ជួរវិញ ដោយសារកងនេះខ្វះកម្លាំង ព្រោះចាស់ដែលត្រូវទៅភ្ជួរស្លាប់អស់ច្រើន ។ នៅអង្គភាពភ្ជួរពិបាកខ្លាំងជាងអង្គភាពកុមារទៀត ព្រោះត្រូវធ្វើការងារច្រើនម៉ោង ។ ពេលយប់ជ្រៅ ខ្ញុំបាននាំប្អូនខ្ញុំទៅអង្គុយក្នុងស្រែដើម្បីនិយាយប្រាប់គាត់អំពីរឿងដែលខ្ញុំដឹងពីពួកអ្នកមូលដ្ឋាន ។ ខ្ញុំបន្តថា ខ្ញុំធ្លាប់បានតាក្របីប្រើឲ្យទៅស្នើសុំស្បៀងពីពាណិជ្ជស្រុកជាច្រើនដងដោយឲ្យខ្ញុំសរសេររួចយកទៅប្រគល់ឲ្យខាងពាណិជ្ជ ។ អ្នកទាំងនោះបានយកលិខិតខ្ទេសនាមនោះទៅពិនិត្យមើល រួចហុចមកឲ្យខ្ញុំវិញដែលមើលទៅទំនងជាមិនចេះអានអក្សរចេះផង គឺចេះតែទម្រីស្តីត់មាត់តែប៉ុណ្ណោះ ។ ពេលនោះខ្ញុំមានបំណងចង់ឲ្យប្អូនខ្ញុំគាត់ត្រឡប់មករស់នៅនិងធ្វើការក្នុងភូមិជាមួយខ្ញុំវិញ ។

**លិខិតក្លែងក្លាយ**

លុះព្រឹកឡើង ខ្ញុំក៏យកសៀវភៅនិងប៊ិចដែលសល់ពីតាដែលខ្ញុំស្នាក់នៅជាមួយមកសរសេរបន្លំធ្វើជាលិខិតខ្ទេសនាមរបស់ប្រធានភូមិយកទៅជូនប្រធានអង្គភាពភ្ជួរដោយស្នើថា សុំកុមារ សុខ ឲ្យត្រឡប់មកភូមិ និងសរសេរបន្លំលិខិតខ្ទេសនាមមួយទៀតដាក់ថាប្រធានអង្គភាពភ្ជួរយល់ព្រមបញ្ជូនកុមារ សុខ ត្រឡប់មកភូមិវិញ ។ ដោយមានបញ្ជាក់ថាកុមារនេះនៅតូចមិនអាចធ្វើការនៅកងភ្ជួរបានទេ ។

នៅសម័យនោះ មិនសំដៅទៅលើអ្នក១៧មេសា ឬអ្នកមូលដ្ឋានចាស់ទេ គឺឲ្យមានលិខិតខ្ទេសនាម ហើយយកទៅស្នើសុំអ្វីមួយពីពីកម្មាភិបាលនៅតាមអង្គភាពគេនឹងប្រគល់ឲ្យដោយគ្មានការសង្ស័យអ្វីឡើយ ។

ផែនការរបស់ខ្ញុំបានសម្រេចដូចបំណង ប្អូនខ្ញុំបានមករស់នៅជាមួយខ្ញុំនៅក្នុងភូមិ ប៉ុន្តែបីថ្ងៃក្រោយមក ប្រធានភូមិក៏បំបែកប្អូនខ្ញុំឲ្យទៅកងចល័តកុមារជំទង់ជាមួយក្មេងក្នុងភូមិ ចំណែកខ្ញុំត្រូវទៅក្រុមដឹកជញ្ជូនប្រចាំភូមិជាមួយភូមិវិញ ។

ក្រុមដឹកជញ្ជូននេះគ្រប់គ្រងនិងដឹកនាំដោយពួកយោធាតំបន់និងមានរបបខោអាវខ្មៅ ស្បែកជើងកង់ឡាន ក្រមាក្រហម និងកាំភ្លើងសេកាសេគ្រប់ៗគ្នា ។ ក្រុមដឹកជញ្ជូនមានកូនអ្នកមូលដ្ឋាននិងកូន១៧មេសា ប្រុសនិងស្រីអាយុចាប់ចាប់ពី១៥-២០ឆ្នាំនៅលាយឡំគ្នា ហើយប្រធានកងតែងតែប្រជុំប្រាប់ថា យើងទាំងអស់គ្នាមិនត្រូវបែកចែកអ្នកចាស់ និងថ្មីទេ គឺយើងសិទ្ធិស្មើគ្នានិងជាកងកម្លាំងរបស់បក្សទាំងអស់គ្នា ។ ខ្ញុំសប្បាយយ៉ាងខ្លាំងពេលឮពាក្យនេះ ។

យើងមានសមាជិកសរុបទាំងអស់ជាង៥០នាក់ត្រូវបែងចែកជាក្រុមតូចៗទៀតដោយមួយក្រុមមានចំនួន១២នាក់ ។ ប្រធានភូមិបានប្រគល់របស់ប្រើប្រាស់ដល់យើងដូចជា ៖ ឆ្នាំងបាយ ធុងទឹក ចបកាប់ និងបាយស្ករ ប៉ុន្តែម្នាក់ៗត្រូវយកស្លាបព្រាទៅតាមខ្លួនដោយខ្លួនឯង ។ ខណៈនោះ ប្រធានកងបានដាក់ផែនការឲ្យក្រុមខ្ញុំត្រូវធ្វើដំណើរដោយថ្មើរជើងឲ្យដល់តាឡូនៅម៉ោង៥ល្ងាចដើម្បីយកស្រូវ ហើយម៉ោងព្រឹកម៉ោង៤ត្រូវត្រឡប់មកវិញ ។ ខ្ញុំយកស្រូវបានចំនួនមួយតៅប៉ុណ្ណោះ ប្រកបាវលីមកកងវិញ ។

ខ្ញុំត្រឡប់មកដល់កងវិញ ចំថ្ងៃចូលឆ្នាំខ្មែរ ឆ្នាំ១៩៧៨ ។ ក្រោយពីចូលឆ្នាំបានមួយថ្ងៃ អឿន ជាប្រធានភូមិបានកោះហៅប្រជាជនអ្នកចាស់ទាំងអ្នកថ្មីមកប្រជុំរួមដោយគាត់បាននិយាយក្នុងអង្គប្រជុំថា «ចាប់ពីពេលនេះតទៅអង្គការលែងកំណត់ថាប្រជាជនមូលដ្ឋាននិងអ្នក១៧មេសាទៀត ហើយហើយសមមិត្តត្រូវគោរពតាមអង្គការចាត់តាំង» បន្ទាប់មកគាត់បានចោលភ្នែកសម្លឹងមកខ្ញុំ

ធ្វើឲ្យខ្ញុំភិតភ័យយ៉ាងខ្លាំងណាស់ព្រោះខ្ញុំបានសរសេរលិខិតខុសនាមត្រកូលក្លាយ ។

ខណៈនោះ អឿន បានស្រែកសួរថាមាននរណាម្នាក់ចេះអក្សរទេ? ភ្លាមនោះ ផាត ជាអ្នកមូលដ្ឋានដែលមានស្រុកកំណើតនៅកំពុងដំរី ឆ្លើយតបវិញថា សៅ ចេះ (ព្រោះតាដែលខ្ញុំធ្លាប់នៅឃ្វាលក្របីជាមួយប្រាប់គាត់) ប្រធានភូមិបានសួរបញ្ជាក់ខ្ញុំថាមិត្តឯងចេះទេ? ខ្ញុំឆ្លើយថាចេះ ។ គាត់សួរបន្តកាលនៅភ្នំពេញមិត្តឯងរៀនថ្នាក់ទីប៉ុន្មាន? ធ្វើអ្វី? ខ្ញុំឆ្លើយថារៀនថ្នាក់ទី៤ហើយពេលទំនេរដើរលក់នំប៉័ង ។

ក្រៅពីខ្ញុំ មិនមាននរណាម្នាក់ហ៊ានសារភាពថាចេះអក្សរទេដូច្នេះហើយទើបប្រធានភូមិប្រកាសសួររកនៅក្នុងអង្គប្រជុំហើយក៏មិនបានប្រាប់ឲ្យដឹងដែរ ។ អង្គប្រជុំត្រូវរំសាយ ខ្ញុំវិលត្រឡប់មកផ្ទះវិញទាំងខ្វល់ខ្វាយចិត្ត ព្រោះគិតថាប្រហែលជាប្រធានភូមិនោះយកខ្ញុំទៅសម្លាប់ចោលក៏មិនដឹងព្រោះគាត់ធ្លាប់ចាប់ខ្ញុំចងបម្រុងយកទៅសម្លាប់ចោលម្តងមកហើយ ។ ចំណែក ផាត ចេះមន្តអាគមន៍និងចេះបាលីទៀតផង ប៉ុន្តែគាត់ប្រាប់ឈ្មោះខ្ញុំទៅវិញ ។ កាលតាក្របី ខ្ញុំស្គាល់ចិត្តគាត់ច្បាស់ ផាត ខស្សរាហ៍ទៅជជែកគ្នាជាមួយជាមួយដូច្នេះរឿងអ្វីៗរបស់ខ្ញុំមិនអាចរំលងពីភ្នែកគាត់បានទេ ។

## គ្រួសារវៀតណាម

នៅក្នុងភូមិនោះមានគ្រួសារអ្នកមូលដ្ឋានមួយគ្រួសារជាជនជាតិវៀតណាម ប៉ុន្តែមិនមានកូនទេ ។ គាត់រស់នៅក្នុងផ្ទះឈើសល់ពីររបប លន់ នល់ មួយខ្នងនៅជួរនៅខាងលិចភូមិទល់មុខនឹងផ្ទះឫស្សីដែលមេភូមិចែកឲ្យខ្ញុំរស់នៅ ។ តាជនជាតិវៀតណាមនោះឈ្មោះ ណាំ ហើយមួយថ្ងៃៗគាត់ផឹកទឹកត្នោតជូរស្រវឹង ហើយគាត់មិនចេះក្រេងចិត្តនរណាទេ ជាពិសេស គាត់ចូលចិត្តរករឿងតែអ្នកមូលដ្ឋានដូចគ្នា ខ្ញុំមិនដឹងថាមូលហេតុអ្វីទេ ។ ប៉ុន្តែគាត់មានចរិតល្អណាស់នរណាៗក៏គោរពគាត់ដែរ សូម្បីតែប្រធានភូមិនិងកងសន្តិសុខនៅមន្ទីរសន្តិសុខដែលជិះសេះកាត់តាមភូមិនេះក៏ញញើតកោតក្រែងគាត់ដែរ ។ ខ្ញុំឮគាត់និយាយថា កម្មាភិបាលទាំងនេះជាអតីតកូនចៅគាត់ទាំងអស់ ហើយតែងតែយកនំចំណីម្ហូបអាហារមកជូនគាត់ ។ ពេលគាត់ស្រវឹង គាត់តែងតែនិយាយប្រាប់ទៅអ្នកភូមិហើយខ្ញុំចាំសម្តីគាត់និយាយថា «មុនរំដោះពួកឯងរាល់គ្នាខ្លាចអញណាស់ ក្រោយបដិវត្តន៍ឈ្នះពួកឯងមិនស្ដាប់អញទេ» ។ ទោះបីគាត់ដើរស្រែកដេរ និងឡូឡាយ៉ាងណាក៏មិនមានអ្នកមូលដ្ឋានណាឆ្លើយឆ្លងជាមួយដែរ ។

មានថ្ងៃមួយ តាណាំ ស្លៀកពាក់ខោអាវខ្មៅ ពាក់មួកប៉ារ៉ាំងនិងបង់កក្រមាដែលមើលទៅហាក់ដូចជាគាត់ចេញទៅបំពេញភារកិច្ចអ្វីមួយ ។ រហូតដល់ពេលព្រលប់ ខ្ញុំបានឮសំឡេងក្តុងក្តាំងលើផ្ទះរបស់គាត់ ខ្ញុំគិតថា ប្រហែលប្តីប្រពន្ធគាត់ឈ្លោះគ្នាស្រាប់តែខ្ញុំក្រឡេកមើលទៅផ្ទះគាត់ឃើញកងឈ្លបនិងកងសន្តិសុខប្រមាណជាង១០នាក់កំពុងប្រតាយត្រតប់ចាប់គាត់ដោយមានទាំងខ្សែចំណងផង ។ កងឈ្លបខ្លះចាប់គាត់និងចាប់ប្រពន្ធគាត់ចងដៃចងជើងនិងរុំមុខជាមួយក្រណាត់ខ្មៅ រួចសែងគាត់ទាំងពីរនាក់ចេញតាមក្រោយភូមិទៅកាន់មន្ទីរសន្តិសុខ ។ ក្រោយពីចាប់គ្រួសារនោះទៅបានពីរថ្ងៃគឺនៅអំឡុងខែឧសភា ឆ្នាំ១៩៧៨ ខ្ញុំឃើញប្រជាជនដែលទើបជម្លៀសមកថ្មីចូលមករស់នៅក្នុងភូមិលាជនេះទៀត ។ អ្នកថ្មីទាំងនោះមកពីខេត្តព្រៃវែង និងស្វាយរៀងនិងមានបង់កក្រមាពណ៌ខៀវដែលអ្នកមូលដ្ឋាននៅទីនោះតែងតែហៅអ្នកជម្លៀសមកថ្មីទាំងនេះថា ពួកបូព៌ា ឬពួកបញ្ញើ ហើយមិនត្រូវបានអនុញ្ញាតឲ្យធ្វើការលាយឡំជាមួយប្រជាជនមកពាយព្យទេ ។

## លង់ស្នេហ៍អ្នកក្រុង

នៅខាងជើងផ្ទះខ្ញុំមានបងប្អូនស្រីក្រមុំពីរនាក់ជាអ្នក១៧មេសាមានរូបរាងស្អាតខ្ពស់ ស្បែកសរលោង និងរៀនបានថ្នាក់ខ្ពស់នៅសម័យ លន់ នល់ ។ បងប្អូនទាំងនោះមានសម្តីទន់ភ្លន់និងរួសរាយ ហើយគាត់មិនសូវខ្វះចំណីហូបទេ ព្រោះប្រុសៗអ្នកមូលដ្ឋានរួមទាំងកងឈ្លបក្មេងៗធ្វើការនៅមន្ទីរសន្តិសុខយកអាហារឲ្យនាង ។ ចំណែកការងាររបស់គាត់ទាំងពីរនាក់ក៏មិនលំបាកដែរគឺគាត់គ្រាន់តែដាំបន្លែក្នុងភូមិនិងប្រូតស្រូវក្បែរៗភូមិប៉ុណ្ណោះ ។ ប្រធានភូមិ មិនដែលចាត់គាត់ទាំងពីនាក់ធ្វើការឆ្ងាយទេ ហើយរៀងរាល់ល្ងាចគាត់តែងតែរែកទឹកមកងូតនៅក្រោយផ្ទះនិងច្រៀងចម្រៀងរបស់អ្នកស្រី រស់ សេរី សុទ្ធា និង ប៉ែន រ៉ន ដែលហាក់ដូចជាមានសេរីភាពណាស់ ។ ខ្ញុំខស្សរាហ៍ស្តាប់ចម្រៀងគាត់និងមើលគាត់ងូតទឹកធ្វើឲ្យខ្ញុំឈប់ខ្វាយខ្វល់ពីការលំបាកក្នុងជីវិត ។

នារីទាំងពីរនាក់នោះបានចាត់ទុកខ្ញុំជាបងប្រុសរបស់នាងនិងជាគ្រួសារតែមួយ ព្រោះយើងជាអ្នក១៧មេសាដូចគ្នា ។

មានថ្ងៃមួយ ខ្ញុំបានសួរនារីនោះអំពីរឿងឪពុកម្តាយនិងបងប្អូនរបស់នាង នារីនោះប្រាប់ខ្ញុំថាមានតែពីរនាក់បងប្អូនឪពុកម្តាយគាត់រស់នៅស្រុកសង្កែខេត្តបាត់ដំបង ។ ឪពុករបស់គាត់មានតួនាទីជាឧត្តមសេនីយ៍នៃរបបសាធារណរដ្ឋខ្មែរ ។ ឪពុកម្តាយគាត់បានបញ្ជូនគាត់ឲ្យទៅរៀនបន្តនៅមហាវិទ្យាល័យនៅក្នុងទីក្រុងភ្នំពេញ ។ គាត់បានបែកពីឪពុកម្តាយចាប់តាំងពីខ្មែរក្រហមចូលទីក្រុងភ្នំពេញថ្ងៃ១៧មេសារហូតមកដល់ពេលនេះគាត់មិនបានដឹងថាឪពុកម្តាយរបស់នាងរស់នៅទីណាទេ ហើយនៅរស់ ឬក៏ស្លាប់នោះទេ ។ នារីនោះបន្តថា គាត់មិនធ្លាប់ធ្វើការងាររលំបាកដូច្នេះទេតាំងពីតូចមក ប៉ុន្តែគាត់មានសំណាងរស់នៅជុំគ្នាជាមួយបងប្អូន ។

ជារឿយៗ ខ្ញុំឃើញកងឈ្លបដែលធ្វើការនៅមន្ទីរសន្តិសុខតែងតែជិះសេះចូលមកក្នុងរបងផ្ទះនារីនោះដោយមានទាំងសម្ភារប្រើប្រាស់ ផ្លែឈើ នំចំណីយកមកឲ្យនារីនោះ និងនិយាយលេងបែបស្និទ្ធស្នាលជាមួយគាត់ មិនដែលធ្វើឲ្យគាត់អាក់អន់ស្រពន់ចិត្ត ហើយសូម្បីតែ អឿន ជាប្រធានភូមិក៏មកនិយាយជាមួយគាត់ដែរ ។ ខ្ញុំគិតថាមានប្រុសៗមិនតិចទេដែលតាមចែចង់នារីពីរនាក់បងប្អូននោះ ។

## តាមទាន់ត្រូវទណ្ឌកម្ម

ថ្ងៃមួយ ពេលខ្ញុំកំពុងអង្គុយនៅមាត់ជណ្តើរស្រាប់តែធ្វើឲ្យអារម្មណ៍ខ្ញុំចាប់នឹកទៅដល់ឪពុកម្តាយនិងបងប្អូនយ៉ាងខ្លាំង ។ រំពេចនោះ ក៏លេចរូបរាងប្អូនប្រុសខ្ញុំឈ្មោះ សុខ ដើរលបៗពីក្រោយចូលមកក្រោមផ្ទះជាមួយនឹងរូបរាងស្លេកស្លាំងនិងហើមស្ទើរមើលមិនស្គាល់មកប្រាប់ខ្ញុំអំពីអាការៈជំងឺ ។ ដោយសារអាណិតប្អូនខ្លាំងពេក ខ្ញុំបានសម្រេចចិត្តសរសេរលិខិតក្លែងក្លាយមួយទៀតឲ្យគាត់ ដើម្បីស្នើសុំស្ករត្នោត និងកន្ទក់ម៉ត់ពីអង្គភាព ។ បីបួនថ្ងៃក្រោយមក ប្អូនខ្ញុំបានត្រឡប់មកជួបខ្ញុំម្តងទៀតនិងស្រកហើមជាងមុន ។ គាត់បានប្រាប់ខ្ញុំថានៅកន្លែងជីកប្រឡាយយើងហូបបបរលាយក្តួចនិងប្រង់ធ្វើឲ្យកងចល័តជាច្រើននាក់កើតជំងឺហើម ។ ពេលនោះ ខ្ញុំក៏សរសេរសំបុត្រឲ្យគាត់លើកទីពីរ ប៉ុន្តែរយៈពេលបីបួនថ្ងៃក្រោយមក គាត់បានត្រឡប់មកជួបខ្ញុំដោយមានខ្លួនប្រាណឡើងជាំស្ទើរពេញខ្លួន ។ ប្អូនខ្ញុំបានរៀបរាប់ថា ប្រធានកងសង្ស័យលើលិខិតនោះ រួចហើយចាប់វាយធ្វើទារុណកម្មឲ្យសារភាព ។ វាបាននិយាយកុហកថាបានលួចសៀវភៅនិងប៊ិចពីកន្លែងរោងក្រឡឹងរបស់យោធាមកសរសេរ ។ ពេលឮប្អូនខ្ញុំនិយាយប្រាប់ដូច្នេះ ខ្ញុំក៏បានសម្រេចចិត្តយកសៀវភៅនិងប៊ិចទៅបោះចោលក្នុងបឹងឆ្ងាយពីភូមិដើម្បីកុំឲ្យអង្គការតាមដាន ។

## គ្រូផ្សំថ្នាំខ្មែរ

នៅពេលនោះ មានមីងម្នាក់ឈ្មោះ គាំ ជាអ្នក១៧មេសាដូចខ្ញុំដែរ ប៉ុន្តែមិនមាននរណាដឹងថាអ្នកថ្មីទេ ។ គាត់មានកូនពីរនាក់ស្រីម្នាក់និងប្រុសម្នាក់កូនស្រីម្នាក់ ។ កូនបងឈ្មោះ ស្តើង មានអាយុស្របាលខ្ញុំនិងរូបរាងស្គមខ្ពស់ស្អាតសមរម្យ ចំណែកកូនប្អូនឈ្មោះ ក្លុយ អាយុប្អូនខ្ញុំមួយឆ្នាំ និងមានរូបរាងទាបក្រអាញភ្នែកស្រឡេវជាមនុស្សមិនគ្រប់ទឹក ហើយតែងតែដើរហែកសម្លៀកបំពាក់គេ និងចាប់កេរ្តិ៍ខ្មាស់គេមិនថាប្រុសឬស្រីទេ ។

មីងគាំ ជាស្ត្រីមេម៉ាយមានប្តីជាទាហាន លន់ លន់ ស្លាប់មុនបែកក្រុងភ្នំពេញ ។ គាំ ជាគ្រូថ្នាំបូរាណ ហើយពូកែចាប់សសៃកោសខ្យល់ និងចេះនិយាយយកចិត្តពួកមូលដ្ឋានណាស់ ។ ផ្ទះគាត់មិនដែលខ្វះអ្វីបរិភោគទេ ពេលខ្លះអ្នកមូលដ្ឋានខ្វះខាតមករកគាត់វិញក៏មាន ។ អាក្លុយ ចូលចិត្តលេងសើច និងធ្វើបាបបងតែបងស្រីវាជាងគេ ។ ចំណែក ស្តើង ជាមនុស្សខ្លាចឈ្លើង និងខ្មោច ។ ពីរនាក់បងប្អូននេះមិនដែលធ្វើការឆ្ងាយពីផ្ទះ ឬទៅនៅអង្គភាពកុមារទេ គឺកូនស្រីឈ្មោះ ស្តើង ត្រូវនៅផ្ទះសោរថ្នាំឲ្យអ្នកមូលដ្ឋាននិងកងឈ្លប ចំណែក អាក្លុយ ទៅរកថ្នាំឬសឈើ ។ នៅសម័យខ្មែរក្រហម នរណាម្នាក់ ឬគ្រួសារណាចេះជំនាញអ្វីមួយច្បាស់លាស់ ដូចជាជំនាញថ្នាំបូរាណគឺអាចរស់បានស្រួល ។ ជារឿយៗ អាក្លុយ ចាប់ហែកខោអាវនិងសំពត់របស់ម្តាយនិងបងស្រីខ្លួនឯងពេលណាភ្លេចខ្លួន ហើយជួនកាលលាត់អាវជៅដោះម្តាយដូចជាក្មេងអឺចឹង ។ ទោះបីយ៉ាងណាក៏ដោយ ក៏អ្នកមូលដ្ឋាននិងប្រធានភូមិមិនកសាង អាក្លុយ ដែរ ។

នៅជំនាន់នោះ ប្រជាជនមានការខ្វះខាតផ្នែកសម្លៀកបំពាក់ខ្លាំងណាស់ ប្រជាជនដែលជម្លៀសមកពីទីក្រុងភ្នំពេញបានស្លៀកពាក់តែសម្លៀកបំពាក់យកមកជាមួយបន្តិចបន្តួចប៉ុណ្ណោះ

ចំណែកអ្នកមូលដ្ឋានមានរបបអង្ករការចែកឲ្យបានខ្លះ ។ ដូច្នេះ សម្លៀកបំពាក់របស់អ្នកថ្មីប្រើប្រាស់ភាគច្រើនសុទ្ធសឹងពុកផុយព្រោះមិនដែលបោកជាមួយសាប៊ូទេ ។ សម្លៀកបំពាក់ភាគច្រើនកងឈ្លបបានដោះយកពីសាកសពរបស់អ្នកទោសដែលយកទៅសម្លាប់ មកចែកឲ្យអ្នកខ្លះខាតសម្លៀកបំពាក់ក្នុងភូមិវិញ ហើយខ្ញុំក៏ទទួលបានសម្លៀកបំពាក់នេះដែរ ។ ចំណែក អាក្លុយ មិនដែលខ្វាយខ្វល់នឹងសម្លៀកបំពាក់ទាំងនេះទេ គឺវាស្រាតតែម្តង ។ ថ្ងៃមួយពេលបងស្រីរបស់ ក្លុយ កំពុងងូតទឹកប្រឡាយខាងក្រោយភូមិ អាក្លុយ បានលួចយកសំពត់អាវរបស់បងស្រីមកឲ្យម្តាយវានៅផ្ទះ ។ បងស្រីវាអង្គុយត្រាំទឹកប្រឡាយយំរហូតម្តាយវាយកសម្លៀកបំពាក់ឲ្យនាងវិញ ។

## ថ្នាំខ្មែរកែរោគ

ក្រោយមក គាំ បានប្រើកូនគាត់ អាក្លុយ និងខ្ញុំឲ្យទៅជីកមើមឈើនិងរើសឆ្អឹងសត្វនៅព្រៃខ្មោច ខាងលិចមន្ទីរសន្តិសុខ យកមកផ្សំថ្នាំព្យាបាលឲ្យកូនប្រធានភូមិ ។ ប្រជាជននៅក្នុងភូមិភាគច្រើនមិនដែលហ៊ានចូលព្រៃនោះទេ ព្រោះជាកន្លែងហាមឃាត់ ។ ប៉ុន្តែពេលនោះ ខ្ញុំសង្កេតឃើញថា កងឈ្លបមិនដែលចូលព្រៃខ្មោចនេះពេលព្រឹកព្រលឹមទេ គឺចូលធ្វើការនៅព្រៃនេះតែពេលរសៀលប៉ុណ្ណោះ ដូច្នេះខ្ញុំនិងក្លុយបានបបួលគ្នាដើរសំដៅទៅមាត់ស្ទឹងក្បាល៥ជាប់មន្ទីរសន្តិសុខ រួចហើយវៀងពីក្រោយចម្ការក្រូចក្បាល៥ដើម្បីសំដៅទៅកាន់ព្រៃខ្មោច ។ ព្រៃនេះជាព្រៃរិចរិលព្រោះដើមឈើធំៗត្រូវកងឈ្លបកាប់យកទៅដុតខ្មោចអស់ហើយ ។ ខ្ញុំនិង អាក្លុយ បានចូលដល់កណ្តាលព្រៃឃើញនៅសេសសល់ដើមឈើខ្លះដូចជាដើម កណ្តុរ ស្តៅ ពង្រ និងដើមឈើខ្លះទៀតដែលខ្ញុំមិនស្គាល់ ។ នៅក្បែរដើមឈើងាប់ ខ្ញុំឃើញគំនរផេះដ៏ធំធេងបីបួនពំនូកផ្សេងគ្នា និងឃើញកម្ទេចឆ្អឹងដែលឆេះមិនអស់ ។ នៅទីនោះ ឈ្លបយកអ្នកទោសមកសម្លាប់ ហើយដុតចោលតែម្តង ។ ខ្ញុំចាប់ផ្តើមភ័យខ្លាច និងព្រឺក្បាលខ្លាក ចំណែក អាក្លុយ វិញវាដូចជាធម្មតា ហើយគិតតែលេងសើច ។ ខ្ញុំប្រញាប់ជីកយកឫសឈើនិងដើររកឆ្អឹងសត្វខ្លះតាមដែលបានជួបប្រទះ ។ ព្រៃនោះសម្បូរសត្វចតុប្បាទ និងសត្វល្មូនចូលទៅរកចំណីស៊ីនៅទីនោះណាស់ ព្រោះសម្បូរទៅដោយសាកសពមនុស្ស ហើយសត្វខ្លះបានខាំដណ្តើមសាច់គ្នារហូតដល់ងាប់ក៏មាន ។ ខ្ញុំបានប្រទះឃើញឆ្អឹងដៃនិងឆ្អឹងជើងមនុស្សនៅរាយប៉ាយដែលសត្វចចក ឆ្កែព្រៃ ខ្លាត្រីអូសចេញពីគំនរខ្មោច ។

## ខ្មោចចូលក្នុងភូមិ

អាក្លុយ មិនខ្វាយខ្វល់រឿងរកឫសឈើ និងឆ្អឹងសត្វទេ វាបានទៅរើសយកក្បាលខ្មោចបោះឡើងលើដូចបោះបាល់ហើយសើចលេង ។ ឃើញដូច្នេះ ខ្ញុំរឹតតែភ័យខ្លាចថែមទៀត ហើយក៏បបួលវាត្រឡប់មកភូមិវិញ ។ អាក្លុយ មិនបានបោះក្បាលខ្មោចនោះចោលទេ វាយកក្បាលខ្មោចនោះយកមកជាមួយដែរ ។

នៅព្រលប់ៗថ្ងៃដដែលនេះ អាក្លុយ មានការៈចំឡែកដើរចុះឡើង ហើយស្រែកយំព្រុសំឡេងខ្សាវៗខុសប្លែកពីធម្មតា ។ អាក្លុយ ស្រែកថាចង់ទៅផ្ទះ! ចង់ទៅផ្ទះ! ចេះតែដើរស្រែកថាចង់ទៅផ្ទះផ្អើលដល់អ្នកមូលដ្ឋានក្នុងភូមិទាំងអស់ ។ អ្នកភូមិជាច្រើនមកចោមមើល អាក្លុយ ដោយងឿងឆ្ងល់ ព្រោះសព្វដងវាមិនដែលយំ ដូច្នេះទេ គឺវាចេះតែញ៉ោះញ៉ោះឲ្យគេខឹងប៉ុណ្ណោះ ។

ខ្ញុំបាននិយាយប្រាប់អ្នកភូមិថា អាក្លុយ ខ្មោចចូលប៉ុន្តែគ្មាននរណាម្នាក់ជឿខ្ញុំ ។ បន្ទាប់មក ស្រាប់តែខ្មោចចូលទៅសណ្ឋិតនោះបានចេញពី អាក្លុយ ទៅចូលប្រពន្ធប្រធានភូមិវិញម្តង ។ ប្រពន្ធប្រធានភូមិនោះបាននិយាយដូចក្លុយដែរ គឺចង់ទៅផ្ទះ! ចង់ទៅផ្ទះ! ដែលស្តាប់ទៅជាសំឡេងមនុស្សស្រីយ៉ាងច្បាស់ ។ អ្នកមូលដ្ឋានចាប់ផ្តើមសង្ស័យថា ខ្មោចចូលមែន រួចនាំគ្នានិយាយបន់ស្រន់ខ្មោចនោះចេញពីខ្លួនប្រពន្ធប្រធានភូមិ ។ អ្នកភូមិខ្លះ បានសែនសំណែន ប៉ុន្តែមីងនោះនៅតែបន្តនិយាយដដែល ។ ពេលនោះ មីងគាំ ជាគ្រូខ្មែរប្រចាំភូមិបានចាប់ផ្តើមនិយាយជាមួយខ្មោច ទើបដឹងថាខ្មោចនោះជាខ្មោចស្រីក្រមុំដែល អាក្លុយ បបួលមកលេងភូមិ ។ ខ្ញុំបានប្រាប់ មីងគាំ បន្ថែមថា អាក្លុយ បានយកក្បាលខ្មោចមកជាមួយនៅពេលទៅរកឫសឈើ ។ ពេលដឹងរឿងនេះ មីងគាំ ក៏បាននិយាយបែបលេងសើចជាមួយខ្មោចស្រីនោះថា អីចឹងនាងដេកជាមួយ អាក្លុយ មួយយប់ទៅចាំព្រឹកស្អែកចាំឲ្យវាជូនទៅផ្ទះវិញ ទើបខ្មោចស្រីនោះក៏យល់ព្រម ។ ភ្លាមនោះស្រាប់តែប្រពន្ធប្រធានភូមិលែងស្រែកយំទៀតនិងមានសភាពដូចធម្មតាវិញ ។

## ការងារចម្ការយុទ្ធសាស្ត្រ

នៅពាក់កណ្ដាលឆ្នាំ១៩៧៨ នៅក្នុងភូមិកាន់តែមានសភាពអ៊ូអរជាងមុន ដែលមានការបែងចែករវាងបូព៌ានិងពាយព្យ ហើយម្យ៉ាងទៀតអង្គការបានស្នើឲ្យអ្នកមូលដ្ឋានឈប់រឹតបន្តឹងទៅលើអ្នកថ្មី ។

ពួកបូព៌ាទើបនឹងចូលមកនៅក្នុងភូមិមិនទាន់បានប៉ុន្មានថ្ងៃផង ខ្ញុំត្រូវប្រធានភូមិកោះហៅឲ្យទៅជួបគាត់និងប្រាប់ថា មិត្តឯងចេះអក្សរ ដូច្នេះមិត្តឯងត្រូវទៅបំពេញភារកិច្ចនៅកន្លែងថ្មី ។ ខ្ញុំមិនហ៊ានប្រកែកទេ គ្រាន់តែខ្ញុំសួរបញ្ជាក់គាត់ថា ខ្ញុំត្រូវចាកចេញដំណើរនៅពេលណា? គាត់ប្រាប់ថា ព្រឹកនេះឯង ដូច្នេះខ្ញុំនឹកក្នុងចិត្តថាមិនដឹងជាគាត់យកទៅសម្លាប់ក៏មិនដឹង ព្រោះអ្នកដែលត្រូវបំពេញភារកិច្ចកន្លងមកច្រើនតែងតែបាត់ខ្លួនមិនឃើញត្រឡប់មកជួបជុំគ្រួសារឡើយ ។ ប៉ុន្តែ ខ្ញុំសម្រេចចិត្តថាត្រូវតែទៅ ព្រោះប្រធានភូមិចាត់តាំងគឺត្រូវតែអនុវត្តតាម បើគេយកទៅសម្លាប់ក៏ស្លាប់ទៅចុះ ។ ពេលនោះ មានរទេះក្របីមួយទើបនឹងទឹមរួចដោយនៅលើរទេះនេះមានគ្រាប់ពោត អង្ករកន្លះបាវ អំបិលមួយការ៉ុង ចប ពូថៅ និងកាំបិត ហើយគាត់បានចង្អុលបង្ហាញផ្លូវទៅតាមក្រោយភូមិ ។ ពេលទៅជិតដល់មន្ទីរសន្តិសុខមានផ្លូវបែកត្រូវទៅស្ដាំ ហើយបរតាមផ្លូវនោះនឹងមានសមមិត្តនៅចាំទទួលទីនោះហើយ ។ ខ្ញុំមិនចេះបររទេះគោ ឬក្របីម្ដងទេ គឺធ្លាប់ភ្ជួរ និងរាស់ប៉ុណ្ណោះ ។ ប៉ុន្តែ ខ្ញុំតាំងចិត្តឡើងលើរទេះបរចេញទៅទាំងព្រលឹមស្រាងៗ ។

ខ្ញុំបររទេះទៅជិតដល់មន្ទីរសន្តិសុខ ក៏ឃើញផ្ទះមួយខ្នងសង់ពីក្ដារប្រក់ក្បឿង និងគ្មានជញ្ជាំងបាំងទេ ។ ខ្ញុំមើលទៅលើផ្ទះស្រាប់តែឃើញអ្នកទោសដេកតម្រៀបពីរជួរដោយជើងទាំងពីរជាប់ខ្នោះ ចំណែកប្រឡោះកណ្ដាលជាផ្លូវសម្រាប់កងសន្តិសុខដើរត្រួតពិនិត្យ ។ ខ្ញុំឃើញអ្នកទោសខ្លះមានរូបរាងស្គមស្គាំងកំពុងកាប់ដីជាមួយនឹងសម្លៀកបំពាក់ដាច់រហែករយីករយាក ព្រមទាំងមានស្នាមដំបៅរលួយលើដងខ្លួនទៀតផង ។ ខ្ញុំបររទេះផុតមន្ទីរសន្តិសុខបន្តិចក៏លែងឃើញមានស្នាមផ្លូវទៀតប្រហែលជាផ្លូវនេះត្រូវគេបោះបង់ចោលយូរឆ្នាំមកហើយ និងផ្លូវនោះមានព្រៃស្មៅនិងព្រៃដុះស៊ុបទ្រុបមានតែពន្លឺព្រះអាទិត្យបន្តិចបន្តួចប៉ុណ្ណោះចាំងចូលតាមប្រឡោះស្លឹកឈើ ។

ការធ្វើដំណើរតាមរទេះពិបាកជាងថ្មើរជើងទៅទៀត ប៉ុន្តែខ្ញុំត្រូវតែបន្តដំណើរទៅមុខ ប្រសិនបើខ្ញុំត្រឡប់មកភូមិវិញ មុខជាអង្គការយកខ្ញុំទៅសម្លាប់ចោលជាមិនខាន ។ បន្ទាប់មក រទេះបានបន្តដំណើរទៅមុខ មួយសន្ទុះទៀតចូលដល់តំបន់ព្រៃដែលមានគេកាប់រំលំដើមឈើដាក់គរជាគំនរ ។ ខ្ញុំត្រេកអរណាស់ព្រោះបានមកដល់គោលដៅ ហើយបានជួប ពូដាត ជាម៉ដីរគ្រប់គ្រងនៅចម្ការរានថ្មីនេះ ។

នៅទីនេះ ពួកជនជាតិបាននាំគ្នាមកជញ្ជូនបាវគ្រាប់ពូជពោតនិងសម្ភារៈផ្សេងៗចុះពីរទេះ ហើយខ្ញុំដោះក្របីចេញពីរទេះចងឲ្យស៊ីស្មៅ ។ បន្ទាប់មក ខ្ញុំបានរៀបចំកន្លែងនោះដើម្បីយកដីដាំពោត ហើយប៉ុន្មានថ្ងៃក្រោយមក កូនពោតចាប់ផ្ដើមដុះចេញពន្លកពណ៌បៃតង ។ ពេលរសៀលថ្ងៃមួយ ពូដាត តម្រូវឲ្យខ្ញុំត្រឡប់មកភូមិដើម្បីមកដឹកដើមដំឡូងមីនិងយកស្បៀងដោយប្រាប់ថារយៈពេលដប់ថ្ងៃ ខ្ញុំត្រូវតែផ្លាស់ពីចម្ការទៅភូមិម្ដង ។ ដោយសារការត្រឡប់មកភូមិវិញ ពេលរសៀល ខ្ញុំមិនហ៊ានមកម្នាក់ឯងគាត់ ៏ចាត់តាំងឲ្យពូម្នាក់ជាជនជាតិព័រមកជាមួយខ្ញុំ ។

ខ្ញុំនិងគាត់ចាប់ផ្ដើមចេញដំណើរត្រឡប់មកភូមិវិញជាបន្ទាន់ព្រោះខ្លាចយប់ងងឹតតាមផ្លូវ ។ ចេញផុតពីចម្ការមកដល់តំបន់ដីក្រហមកន្លែងដែលមានជញ្ជាំងខ្ពស់ៗ គាត់ចាប់ផ្ដើមឲ្យខ្ញុំចុះពីរទេះនិងឲ្យខ្ញុំដើរនៅខាងមុខ ចំណែកគាត់ដើរក្រោយរទេះ ព្រោះក្របីចង់ផ្អើលមិនចង់ដើរទៅមុខ ។ កំពុងធ្វើដំណើរយ៉ាងញាប់ជើងស្រាប់តែខ្ញុំឃើញសត្វខ្លាធំមួយប៉ុនកូនគោកំពុងចេញចាប់សត្វទន្សាយព្រៃជាអាហារ ។ សល់ចម្ងាយប្រហែលសាមសិបម៉ែត្រទៀតនឹងមកចំមុខខ្ញុំហើយ ខ្ញុំស្រែកទាំងភិតភ័យថា ខ្លាធំណាស់មកចំពីមុខខ្ញុំហើយ ។ ពូជនជាតិចំណាស់ដែលនៅក្រោយរទេះបានរត់មកឈរទន្ទឹមខ្ញុំ ហើយបានឈប់ស្ងៀម រួចប្រាប់ខ្ញុំថាឈរឲ្យស្ងៀម កុំកម្រើកឲ្យសោះ ចំណែកគាត់ឈរបន្ទន់ជង្គង់របៀបត្រៀមវាយសត្វពេលបម្រុងសំដៅមកយើង ហើយភ្នែកសម្លឹងសត្វខ្លាចំមិនព្រិច ។ បន្ទាប់មក សត្វទន្សាយបោលតាមក្រោមរទេះទៅបាត់ស្រមោល ឯសត្វខ្លាធំក៏ឈប់ដេញតាម ហើយថយក្រោយរត់សំដៅគុម្ពោតព្រៃ ។

ពេលល្ងាចទៅដល់ភូមិ ប្រធានភូមិបានឲ្យចុងភៅដាំបាយសម្រាប់ខ្ញុំពីរនាក់និងឲ្យសម្រាកនៅក្នុងរោងបាយ ។ លុះព្រឹកឡើងខ្ញុំបានដញ្ជូនដើមដំឡូងឈើនិងស្បៀងដាក់លើរទេះសម្រាប់រយៈពេលដប់ថ្ងៃដើម្បីត្រឡប់ទៅចម្ការវិញ ។ បន្ទាប់មក គាត់និយាយប្រាប់ជនជាតិព័រគ្នារបស់គាត់ថា កាលពីព្រលប់យើងបានជួបខ្លានៅតំបន់ដីប្រាប ។ តែសំណាងល្អខ្ញុំស្រែកថា ឆ្មាធំ បើស្រែកថាខ្លាវិញ គឺស្លាប់ទាំងអស់គ្នាបាត់ទៅហើយ ។ ប៉ុន្តែតាមពិតខ្ញុំមិនស្គាល់សត្វខ្លាទេ ដោយខ្ញុំស្រែកច្រឡំ ។ អ្នកស្រុកលើប្រាប់ទៀតថា នៅស្រុកព្រៃភ្នំបើជួបសត្វសាហាវដូចជាខ្លាគេហៅថាឆ្មា បើជួបពស់វែកហៅថាពស់ព្រលិត ដើម្បីឲ្យសត្វសាហាវក្លាយទៅជាស្លូត ។ បានតែប្រហែលជាមួយខែ តំបន់នេះកាន់តែមានមនុស្សច្រើនទៅ ។ ខ្ញុំគ្មានគ្រួសារទេ ពូដាត ឲ្យចូលក្នុងគ្រួសាររបស់គាត់ហូបតាមរបបអង្គការកំណត់ឲ្យគឺអង្ករមួយកំប៉ុងបីថ្ងៃ ។

ពេលបាយ ខ្ញុំទទួលបានដុំបាយប៉ុនផ្លែក្រសាំងប៉ុណ្ណោះ ។ តែទោះយ៉ាងណាក៏ដោយវាគ្រាន់បើជាងនៅភូមិហូបបបររាវដែរ ។ ក្រោយមក ជនជាតិនេះបានសង់រោងសម្រាប់កន្លែងឆ្នាំងបាយរួមដែលមានប្រពន្ធគាត់ជាចុងភៅ ។ នៅទីនេះ យើងសម្បូរម្ហូបណាស់មានត្រីដុត សាច់ដុត និងអណ្តើកដុតរហូតមួយខែក្រោយមក ខ្ញុំឡើងសាច់និងមិនមានសុខភាពល្អទៀត ។

មួយរយៈពេលក្រោយមក ពោតចាប់ផ្តើមទុំ ដំឡូងជ្វាក៏ដល់ពេលត្រូវគាស់យកមើម ចំណែក ដំឡូងក៏ដុះមើម ហើយបែកគុម្ពត្រឡាចនិងល្ពៅក៏ដល់ពេលប្រមូលផលដែរ ។ ពូដាត បានចាត់តាំងឲ្យខ្ញុំគ្រប់គ្រងផលដំណាំទាំងនេះដោយត្រូវកត់ចំនួនផលដែលទទួលបានទាំងអស់ ។ ប៉ុន្តែខ្ញុំប្រាប់គាត់ថាមិនអាចចុះបញ្ជីអ្វីៗគ្រប់ចំនួនទេ គឺចុះបញ្ជីបានតែចំនួនពាក់កណ្តាលប៉ុណ្ណោះ ។ ពេលនោះគាត់ស្រាប់តែចោទខ្ញុំថា «មិត្តឯងចង់ក្បត់ អង្គការហើយ» ។ គាត់ខឹងខ្ញុំខ្លាំងណាស់រហូតដល់ចង់រាយការណ៍ទៅឲ្យប្រធានភូមិដឹងទៀត ។ បន្ទាប់មក ខ្ញុំបាននិយាយពន្យល់គាត់ថា ខ្ញុំមិនមែនក្បត់អង្គការទេ ព្រោះភោគផលទាំងអស់នេះខ្លះបេះមកស្ទើរ ហើយបើកាលណាទុកលើសពីប្រាំពីរថ្ងៃអាចក្លាយទៅជារលួយដល់ពេលយើងប្រគល់មិនបានគ្រប់ចំនួនតាមរបាយការណ៍តើពូឯងគិតយ៉ាងម៉េច ។ ឮដូច្នេះ ជនជាតិទាំងអស់យល់ស្របគ្នា ហើយ ពូដាត ក៏សប្បាយចិត្តដែរ ។ ចាប់ពីថ្ងៃនោះមក ខ្ញុំលែងខ្វះអាហារបរិភោគទៀតហើយ ។

ប្រហែលជាខែកក្កដា ឆ្នាំ១៩៧៨ យើងបានផលពោតនិងសណ្តែកមុនគេ ។ ចំណែកដំឡូងមីនិងចេកមិនទាន់បានផលនៅឡើយទេ ។ ឯដំណាំវារដូចជាត្រឡាច និងល្ពៅ ខ្ញុំបានដឹកទៅផ្តល់ឲ្យភូមិជាបណ្តើរៗនិងមួយចំនួនជាល្ពៅទុំ ត្រឡាចទុំ គឺទុកបម្រុងសម្រាប់ការស្នើសុំពីអង្គភាពផ្សេងៗ ។

មានពេលមួយ ខ្ញុំមានភ័ព្វសំណាងណាស់ដែលបានជួបប្អូនប្រុសខ្ញុំនៅពេលខ្ញុំត្រូវបានចាត់តាំងឲ្យដឹកពោតទុំផ្តល់ឲ្យអង្គភាពកងចល័តកុមារជំទង់ដែលជាអង្គភាពប្អូនប្រុសរបស់ខ្ញុំ តែយើងទាំងពីរនាក់បងប្អូនធ្វើដូចមិនស្គាល់គ្នាទេ ។ ក្រោយពេលប្រគល់ពោតឲ្យប្រធានអង្គភាពរួច ខ្ញុំបានស្រែកប្រាប់ប្រធានអង្គភាពថាពោតនេះមកពីភូមិលាចចម្ការនៅតំបន់បាក់ត្រកួន ដើម្បីជាសញ្ញាឲ្យប្អូនប្រុសរបស់ខ្ញុំដឹង ។ បានតែរយៈពេលពីរថ្ងៃក្រោយមកប្អូនប្រុសរបស់ខ្ញុំបានមករកខ្ញុំនៅចម្ការពេលថ្ងៃត្រង់ ។ ខ្ញុំបានឲ្យដំឡូងដុតទៅប្អូន ហើយប្រាប់ឲ្យប្រញាប់ត្រឡប់ទៅវិញ ចាំថ្ងៃណាមានឱកាសល្អនិយាយគ្នាទៀត ។ បានតែមួយថ្ងៃប្អូនប្រុសខ្ញុំត្រឡប់មករកខ្ញុំទៀត ។ ខ្ញុំបានសួរគាត់ថា ម៉េចក៏ត្រឡប់មកទៀត? ប្អូនប្រុសខ្ញុំបានឆ្លើយថា «ឥឡូវនេះនៅអង្គភាពមិនតឹងតែងជាមួយអ្នក១៧មេសាទេ ដោយរឹតត្បិតតែជាមួយក្មេងៗមកពីខាងភូមិភាគបូព៌ាទេ» ។ នៅក្នុងភូមិនេះអង្គការមិនតឹងតែងជាមួយពួកបូព៌ា ចំណែកអ្នក១៧មេសាត្រូវបានអនុញ្ញាតឲ្យដើរហើរជាងមុន ។ ដូច្នេះ ប្អូនប្រុសខ្ញុំបានមករកខ្ញុំរៀងរាល់បីថ្ងៃម្តងហើយខ្ញុំក៏ចេះតែផ្តល់ដំឡូង ពោត ត្រី សាច់ខ្លះៗ ដែលសល់ពីពួកជនជាតិឲ្យ ។ អ្នកនៅទីនេះដឹងថា ខ្ញុំមានប្អូន ដូច្នេះពេលគាត់ហូបឆ្អែតអ្វីៗដែលនៅសល់ត្រូវខ្ញុំប្រមូលទុកឲ្យប្អូនខ្ញុំទាំងអស់ ។ ខ្ញុំក៏បានផ្តាំប្អូនប្រុសខ្ញុំយកចំណីដែលសេសសល់នេះទៅចែកឲ្យប្អូនស្រីតូចក្នុងភូមិនិងប្អូនស្រីម្នាក់ទៀតនៅអង្គភាពកុមារហូបដែរ ។ ចំណែក ពូដាត ជាប្រធានចម្ការក៏មិនថាអ្វីដែរ រហូតដល់យូរៗទៅខ្ញុំមានសិទ្ធិប្រហែលពូ ដាត ដែរ ។ ក្រោយមក ប្រធានភូមិបានចែកសម្លៀកបំពាក់ខ្មៅជាឯកសណ្ឋានកងឈ្លបថ្មីឲ្យខ្ញុំមួយសម្រាប់មានទាំងមួក ស្បែកជើងកង់ឡាន និងក្រមាក្រហមថ្មី

មួយ ។ កាលពីខ្ញុំទៅហាត់ធ្វើជាកងជីកជញ្ជូន ខ្ញុំបានទទួលរបបខោអាវបែបនេះមួយសម្រាប់ហើយ ដូច្នេះខ្ញុំមានខោអាវខ្មៅក្រហមពីរសម្រាប់ផ្លាស់ប្តូរ ។

## មីងណាំ និងបងស្រីហ្គេច

ដោយខ្វះអ្នកមើលខុសត្រូវផលដំណាំនិងអ្នកដាំបាយខ្ញុំបានស្នើកម្មាភិបាលនារីពីរនាក់ ។ បន្ទាប់មក អឿន បានចាត់តាំង មីងណាំ និងបង ស្រីហ្គេច ឲ្យជួយខ្ញុំក្នុងការបំពេញភារកិច្ចការងារដំណាំយុទ្ធសាស្ត្រ ។ គាត់ទាំងពីរនាក់គ្រាន់តែបានឮថាទៅធ្វើចម្ការសប្បាយចិត្តខ្លាំងណាស់រួចរៀបចំអីវ៉ាន់បន្តិចបន្តួចឡើងរទេះភ្លាមដោយមិនសួរនាំអ្វីទាំងអស់ ។ មីងណាំ ជាស្ត្រីមេម៉ាយមានកូនបីនាក់និងជាជនជាតិខ្មែរកាត់យួនមានស្រុកកំណើតនៅខេត្តស្វាយរៀងនិងកូនៗសុទ្ធតែធ្វើការតាមអង្គភាពកងចល័តទាំងអស់ ។ ចំណែកបង ស្រីហ្គេច ជាកូនចៅចិននិងជាស្ត្រីក្រមុំរស់នៅម្នាក់ឯង ព្រោះក្រុមគ្រួសារស្លាប់ចោលអស់ ហើយស្នាក់នៅផ្ទះជាមួយប្រធានភូមិ ។

យើងទាំងបីនាក់មានខ្ញុំ មីងណាំ និងបងស្រីហ្គេច ដេកនៅរោងផលដំណាំទាំងអស់គ្នាដោយគាត់ទាំងពីរដេកក្នុងរោង ចំណែកខ្ញុំដេកក្រៅរោង ។ គាត់ទាំងពីរនាក់ទើបតែមកដេកនៅទីនេះមួយយប់សោះក៏ចាប់ផ្តើមខ្លាច ហើយបានហៅខ្ញុំទៅដេកជាមួយ ។ យើងទាំងបីនាក់ដេកក្នុងមុងមួយដូចម្តាយនិងកូន ដូចបងនិងប្អូនបង្កើត ។ ការងារ មីងណាំ គឺជាចុងភៅ និងរែកទឹកស្រោចបន្លែ ការងារបង ស្រីហ្គេច ទុកដាក់ផលដំណាំនិងដាំដុះដំណាំដែលជាការងារស្រាល ។

## រោងផលដំណាំ

រោងនេះសង់ជាប់ដីដំបូកដ៏ធំមួយមិនមានសែនព្រេនអ្វីទាំងអស់ ។ កាលពីខ្ញុំមកនៅចម្ការពីដំបូងនិងក្រោយពីរោងផលដំណាំបានសង់រួច រាល់យប់ពេលបិទភ្នែកដេករលីវៗចង់លក់ខ្ញុំឃើញស្រមោលមនុស្សស្រីម្នាក់ចេញពីដីដំបូកចូលមកក្នុងរោងរួចដើរសំដៅមករកខ្ញុំ ។ ពេលខ្ញុំដឹងខ្លួនក៏ភ្ញាក់ក្រញាងញ័រពេញរាងកាយយប់ណាក៏ដូចគ្នាទោះនិយាយបន់ស្រន់ក៏មិនបាត់ដែរ លុះគ្រាខ្ញុំមកដេកក្រៅរោងទើបដេកលក់ ។ មីងណាំ ជាមនុស្សចាស់ដឹងរឿងអបិយជំនឿច្រើនបាននិយាយថា យើងសែនឲ្យតែជំនាងរោងមិនដែលសែនឲ្យគេកន្លងមកទើបមានខ្មោចលងបែបនេះ ។

មានថ្ងៃមួយ យើងខ្ញុំទាំងបីនាក់ជំនុំគ្នាលេងថា ចង់ឃើញជំនាងដំបូកដោយឮចាស់ៗតំណាលថា បើចង់ឃើញខ្មោចឲ្យដេកជិះគ្នាក្នុងចំណោមអ្នកដេកជិះគ្នាត្រូវតែមានម្នាក់មើលឃើញ ។ យប់នោះ យើងនាំគ្នាសុំខបកិច្ចនិយាយបួងសួង ។ ពេលនោះខ្ញុំបានឃើញស្រមោលមនុស្សស្រីស្គមៗចេញមកពីដំបូកធំក្បែរជើងចង្ក្រានបាយ សក់វែង ស្លៀកពាក់ស ឥតមានម្រាមដៃជើរហើបៗផុតពីដីសំដៅឆ្នាំងបាយដែល មីងណាំ ដាំទុកដាក់លើគ្រែក្បែរចង្ក្រានជាការពិសោធន៍ ។

មនុស្សស្រីនោះដៃម្ខាងបើកគម្របឆ្នាំង ឯដៃម្ខាងទៀតលូកចាប់ដុំបាយដាក់ក្នុងមាត់ហាក់បីដូចជាឃ្លានខ្លាំងណាស់តែដុំបាយដែលកាន់ដាក់ចូលមាត់នោះក្លាយទៅជាមានភ្លើងឆេះ ហើយក៏ត្រឡប់ចូលទៅដំបូកវិញបាត់ ។ ចាប់ពីខ្ញុំប្រាប់ មីងណាំ និងបងស្រីហ្គេច អំពីរឿងនេះមក មីងណាំ និងខ្ញុំបានដាក់បាយលើស្លឹកចេកនិងម្ហូបសែនថ្វាយជំនាងដំបូករាល់ថ្ងៃដើម្បីជួយការពារពួកខ្ញុំនិងបងប្អូនកូនចៅឲ្យបានសេចក្តីសុខគ្រប់គ្នា ។

## បងប្អូនខ្ញុំ និងកូនមីងណាំ

ប្អូនប្រុសខ្ញុំដែលតែងតែស្កាត់មកជួបខ្ញុំនៅចម្ការក៏ស្គាល់កូន មីងណាំ ម្នាក់ដែរឈ្មោះ ហេង នៅអង្គភាពកងចល័តកុមារជំទង់ជាមួយគ្នា ហើយក៏បបួលគ្នាមករកចំណីនៅចម្ការជារឿយ ។ យូរៗទៅ ទាំងប្អូនប្រុសប្អូនស្រីខ្ញុំ និងកូន មីងណាំ បីនាក់ (សរុបទាំង៥នាក់) ជួនកាលមកដាន់ថ្ងៃគ្នាទាំងអស់ធ្វើឲ្យខ្ញុំពិបាកដោះស្រាយជាខ្លាំង ហើយក៏បានបែកការណ៍ដឹងដល់ ពូផាត និងក្រុមជនជាតិ ។ តែជនជាតិនេះបែរជាមិនខឹង ឬប្រណែនអ្វីទាំងអស់ ។

## ជនជាតិនៅចម្ការ

ចូលដល់ខែតុលាឆ្នាំ១៩៧៨ ជនជាតិក្ងួយនិងព័រគ្រប់ៗគ្រួសារដូចជាមានទឹកមុខសប្បាយរីករាយខុសពីធម្មតាហើយបានមកនិយាយលេងជាមួយខ្ញុំថា គាត់ជិតបានទៅស្រុកវិញហើយព្រោះអង្គការបានរំសាយគាត់ឲ្យទៅរស់នៅដោយខ្លួនឯង ចំណែកគ្រួសារ ពូផាត ក៏ត្រូវទៅស្រុកកំពង់ធំវីដែលជាស្រុកកំណើតរបស់គាត់ដែរ រួចប្រគល់នាទីជាប្រធានមកឲ្យខ្ញុំជាអ្នកទទួលខុសត្រូវ ។ ខ្ញុំមិនហ៊ានទទួលតំណែងនេះទេ តែគាត់បាននិយាយថា គាត់ទទួលបណ្តាំ ពូអឿន មកប្រាប់ខ្ញុំ ។ ខ្ញុំមានការចម្លែកក្នុងចិត្តតែមិនហ៊ានសួរ ហើយសុខចិត្តទទួលនាទីជាប្រធានចម្ការភូមិលាច ។

ក្រោយពីទទួលតួនាទីនេះបានបីថ្ងៃ ជនជាតិនេះបានចាប់ផ្តើមរៀបចំសម្ភារជាកម្មសិទ្ធិដ៏តិចតួចរបស់ខ្លួនមានខោអាវមួយបន្ទាស់ ស្ពាកាំបិតបន្ទោះនិងឆ្នាំងស្ពាន់មួយ ហើយលាខ្ញុំម្តងបីប្អូនគ្រួសារដោយក្នុងរយៈពេលមិនដល់១០ថ្ងៃផងបានចាកចេញរហូតដល់ស្ងាត់ចម្ការ ។ គ្រួសារ ពូផាត បានចាកចេញ ក្រោយគេបំផុតដោយមួយគ្រួសារៗបន្សល់ផ្ទះឬស្សី ត្បាល់បុកស្រូវ អង្រែ បំពង់ឬស្សី ឈ្នាង និងស្រូវដែលកំពុងដាក់គ្រាប់ជិតបានច្រូត ។

## សភាពការណ៍នៅភូមិ

ក្រោយពីជនជាតិនេះចេញស្ងាត់ពីចម្ការផលដំណាំនៅចម្ការមានច្រើនរហូតធ្វើឲ្យខ្ញុំព្រួយបារម្ភព្រោះគ្មានអ្នកការពារថែរក្សា ។ ពេលនោះ ប្អូនខ្ញុំនិងកូន មីងណាំ មកជួបយើងហើយទៅលើកឈ្នាងត្រាំយកត្រី ។ ថ្ងៃនោះ គ្រួសារខ្ញុំ មីងណាំ និងបងស្រីហ្គេចបានជួបជុំគ្នាហូបបាយជាមួយត្រីអាំងឆ្អែតគ្រប់គ្នា ។ ការជួបជុំគ្នានេះធ្វើឲ្យខ្ញុំនឹកឃើញថា ថ្ងៃណាមួយខ្ញុំបានវិលត្រឡប់មកក្រុងភ្នំពេញដូចជនជាតិនេះដែរ ។ ខ្ញុំហូបបណ្តើរនិយាយផ្តាំប្អូនប្រុសប្អូនស្រីខ្ញុំបណ្តើរថា បើកងទ័ពខាងក្រៅវាយចូលមកត្រូវនាំគ្នាទៅភូមិជួបប្អូនស្រីតូចសិនពេលជុំគ្នាគ្រប់ទើបអាចមកភ្នំពេញបាន ។

ដល់ថ្ងៃខ្ញុំត្រូវដឹកផលដំណាំមកភូមិនិងយករបបអង្ករត្រឡប់ទៅចម្ការពេលនោះខ្ញុំឃើញក្នុងភូមិមានសភាពចម្លែកខុសប្រក្រតីដោយគ្រួសារអ្នកមូលដ្ឋានទាំងប៉ុន្មានដែលខ្ញុំធ្លាប់ស្គាល់ដូចជាគ្រួសារ មីងយេន យាយអោន និងគ្រួសារប្រធានភូមិបាត់ទាំងគ្រួសារបែរជាឃើញប្រជាជនមកពីភូមិភាគផ្សេងមករស់នៅយ៉ាងកុះករ ប៉ុន្តែមិនមែនជាពួកបូព៌ាទេ ។

## ប្រធានភូមិថ្មីមកពីខាងនិរតី

ខ្ញុំបានបររទេះក្របីមានដឹកដំឡូងមីពេញរទេះឆ្លងកាត់ភូមិរបស់ប្រជាជនចំណូលថ្មីទាំងចម្លែកក្នុងចិត្តព្រោះខ្ញុំឃើញយោធាដែលមានសម្លៀកបំពាក់ពណ៌ត្រួយចេកជាយុវជនក្មេងៗកំពុងសម្លឹងមើលមករទេះដំឡូងរបស់ខ្ញុំបែបឃ្លានខ្លាំង ហើយនិយាយគ្នាថាច្រើនណាស់ ។ ខ្ញុំបានបររទេះមកដល់រោងការដ្ឋានបាយរួមក្រឡេកភ្នែកទៅឃើញស្គាល់ ពូសូត្រ និងមីងម៉ៅ ពីរនាក់ប្តីប្រពន្ធនិងអ្នកមូលដ្ឋានដែលមកថ្មីនិយាយសំនៀងអ្នកកំពតបួនប្រាំទៀតកំពុងធ្វើការ ។

គាត់ទាំងពីរនាក់មើលទៅហាក់ដូចជាស្និទ្ធស្នាលជាមួយអ្នកមូលដ្ឋានមកថ្មីទាំងនេះខ្លាំងណាស់ (គាត់ទាំងពីរជាអ្នក១៧មេសាដូចខ្ញុំនិងជាមនុស្សពូកែអែបអបខ្លាំងណាស់) ។ គ្រាន់តែខ្ញុំចុះពីរទេះភ្លាមគាត់ប្រាប់គេថា នេះ មិត្តសៅ ជាអ្នកទទួលខុសត្រូវនៅចម្ការ (ពេលនោះឈ្មោះរបស់ខ្ញុំគឺ សៅ) ។ បន្ទាប់មក ខ្ញុំបានសួរទៅមីង ម៉ៅ ថា ប្រធានភូមិ អឿន មីង យេន និងចុងភៅចាស់ៗទៅណាអស់ហើយ? គាត់ក៏ប្រាប់ថា អង្គការចាត់តាំងឲ្យទៅស្រុកលើពង្រីងមូលដ្ឋាន ឥឡូវនេះយើងមានប្រធានភូមិថ្មីមកពីខាងនិរតី ។ ខ្ញុំបានពឹងគាត់ឲ្យជូនខ្ញុំទៅជួបប្រធានភូមិថ្មី ប៉ុន្តែគាត់ប្រាប់ថា ឲ្យខ្ញុំទៅជួបខ្លួនឯងចុះព្រោះគាត់រវល់ ។ បន្ទាប់មកខ្ញុំបានប្រគល់ដំឡូងមួយរទេះនេះទៅគាត់ទាំងពីរនាក់ ។

ខ្ញុំបានដើរទៅផ្ទះប្រធានភូមិថ្មីជាមួយទឹកមុខមាំជាមនុស្សដាច់ខាត ហើយណែនាំខ្លួនប្រាប់ដល់គាត់ ។ គាត់គិតមួយស្របក់ហើយនិយាយថា សមមិត្តឯងទទួលការងារនេះដដែលចុះ ហើយក៏សួរថា នៅចម្ការមានកម្លាំងប៉ុន្មាននាក់ ។ ខ្ញុំប្រាប់គាត់ថាមានតែបីនាក់ទេ គឺខ្ញុំ មីងណាំ និងនារីហ្គេច ។

ព្រឹកស្អែកឡើង មានយុវជននិរតីម្នាក់មកប្រាប់ខ្ញុំថា ចាំទទួលកម្លាំងបន្ថែម ។ ខ្ញុំបានរង់ចាំគាត់នៅផ្ទះប្រធានភូមិ បន្ទាប់មកក៏ឃើញបុរសៗអាយុពី៣០-៥០ឆ្នាំចំនួនប្រហែល៥០នាក់មានចបកាំបិតនិងរបស់កម្មសិទ្ធិបន្តិចបន្តួចជាប់ខ្លួនដូចជាក្រមាបៃតងសនិងម្ហូបមកអង្គុយតម្រៀបគ្នាជាបីជួរម្ខាងទៀតមានទ័ពក្មេងៗអាយុចាប់១៥-២៥ឆ្នាំស្ថិតនៅក្នុងសម្លៀកបំពាក់ពណ៌ត្រួយចេកឈរតម្រៀបជាពីរជួរប្រដាប់ ដោយកាំភ្លើងអាកាបេ៤០គ្រប់ដៃ ដែលជាកងទ័ពខ្ញុំមិនធ្លាប់ជួបក្នុងនោះក៏មានប្តីប្រពន្ធពីរនាក់គឺពូសូត្រ និង មីងម៉ៅ ផងដែរ ។

ប្រធានភូមិថ្មីដែលមានអាយុសាមសិបឆ្នាំ ស្លៀកពាក់ឯកសណ្ឋានពណ៌ត្រួយចេកដូចជាមេកងពលនេះ បានឲ្យយោធាពីរក្រុមចំនួនជាងម្ភៃនាក់និងប្រុសៗបូព៌ាបីក្រុមមានចំនួនជាងសែសិបនាក់ព្រមទាំងពូ សូត្រ និងមីង ម៉ៅ ជាចុងភៅសរុបទៅចិតសិបនាក់មក ខ្ញុំគ្រប់គ្រងរហូតដល់ខ្ញុំភ័យញ័រខ្លួន ។ ក្នុងពេលព្រឹកនោះពូសូត្រ បានជញ្ជូនអង្ករ ចាន ឆ្នាំង និងសម្ភារផ្សេងដាក់លើរទេះហើយមុនចេញដំណើរមកមេភូមិបានបញ្ជាមកខ្ញុំថាការងារដឹកផល

ដំណាំត្រូវប្រគល់នាទីមកមិត្តយើងខាងនេះជាអ្នកធ្វើ ចំណែកមិត្តនារីជាអតីតកងចល័តត្រូវបញ្ជូនត្រឡប់មកភូមិវិញជាមួយផ្នែកដឹកជញ្ជូន ។

## វ៉ាសនានារីកងចល័តកូនក្រមុំចិន

ខ្ញុំចាប់ផ្ដើមនាំកងកម្លាំងទាំងអស់នេះចេញដំណើរទាំងព្រឹកព្រលឹមសំដៅទៅចម្ការ ។ ពេលថ្ងៃត្រង់យើងបានទៅដល់ចម្ការហើយប្ដីប្រពន្ធពូសូត្រចាប់ផ្ដើមកល់ជើងក្រាននិងរកខសដាំបាយភ្លាម ។ ខ្ញុំបាននាំក្រុមយោធាឲ្យស្នាក់នៅផ្ទះជនជាតិដែលនៅក្បែររោង ចំណែកប្រជាជនមូលដ្ឋានបូព៌ាដែលត្រូវបំបែកចេញពីគ្រួសារទៅស្នាក់នៅផ្ទះម្ខាងទៀតដែលកន្លែងនេះនៅក្បែរមាត់ស្ទឹងឆ្ងាយពីកន្លែងយោធាស្នាក់នៅប្រហែលជា២០០ម៉ែត្រនិងយករោងនេះជាកន្លែងជួបជុំគ្នានិងជារោងបាយផង ។

បងស្រីហ្កេច មិនទាន់បានដឹងគាត់ថាត្រូវត្រឡប់ទៅភូមិវិញទេ ។ បន្ទាប់មក ខ្ញុំបានប្រាប់ បងស្រីហ្កេច ឲ្យហូបបាយមុនគេទៅ ព្រោះគាត់ត្រូវត្រឡប់ទៅភូមិវិញ ។ ឮដូច្នេះគាត់ហូបបាយលែងចូល ហើយទឹកមុខរីករាយក្លាយជាស្រងូតស្រងាត់ ។ ក្រោយពីហូបរួច និរសារក៏បានមកតៀនថាប្រញាប់ ។ ខ្ញុំបាននិយាយលួងលោមគាត់ឲ្យឡើងជិះរទេះ ហើយនិយាយថា មានសំណាងគង់តែជួបគ្នាថ្ងៃណាមួយជាមិនខាន ។ បន្ទាប់មក បងស្រីហ្កេច បានឡើងលើរទេះទាំងទឹកភ្នែកហូរស្រក់លើផ្ទៃមុខ ចំណែកខ្ញុំបានដើរមើលគាត់ទាំងក្ដុកក្ដួលក្នុងចិត្ត ។

ប្រមាណជាប្រាំថ្ងៃក្រោយមក ខ្ញុំបានដើរទៅត្រួតពិនិត្យចម្ការដំឡូងមីរហូតដល់ដើមផ្លូវចូលចម្ការក្បែរអូរស្លួតដែលនៅម្ខាងអូរស្លួតគឺជាព្រៃស្រោងខ្ញុំក៏ប្រទះឃើញខោឡាញ់ពណ៌ខ្មៅដែលបងស្រី ហ្កេច ធ្លាប់ប្រើត្រូវហែកជាច្រើនចម្រៀកទើរលើគុម្ពដំឡូង ។ ខ្ញុំគិតថាគាត់ប្រហែលជាត្រូវនិរសារបួននាក់នោះចាប់រំលោភហើយសម្លាប់ចោលហើយ ព្រោះតាំងពីពេលនោះមករហូតដល់ថ្ងៃបែកខេត្តពោធិ៍សាត់ ខ្ញុំមិនដែលបានជួបគាត់ទេ ហើយក៏គ្មាននរណាបានឃើញឬឮដំណឹងពីគាត់ទេ ។

នៅវេលាថ្ងៃមួយ និរសារបានដឹកនំបញ្ចុកនិងនំកូរមកឲ្យអ្នកចម្ការបញ្ជាក់ឲ្យដឹងថាជាថ្ងៃបុណ្យចូលឆ្នាំសាកលព្រោះរាល់ឆ្នាំសាកលតែងតែធ្វើនំបញ្ចុកឲ្យប្រជាជនហូប ។ ក្រោយពីហូបនំបញ្ចុកបានពីរថ្ងៃទាំងពួកនិរតីនិងកម្លាំងពូៗបូព៌ាត្រូវខ្ញុំហៅឲ្យទៅកាប់ដីចម្ការថ្នាំជក់ទាំងអស់គ្នា ។ បន្ទាប់មក ខ្ញុំបាននិយាយប្រាប់គាត់ឲ្យប្រឹងធ្វើការព្រោះជិតដល់ម៉ោងសម្រាកបាយថ្ងៃត្រង់ហើយ ប៉ុន្តែបែរជាគាត់ទាំងអស់គ្នានាំឈប់សម្រាកអស់ ។ ពេលនោះខ្ញុំឆ្ងល់ណាស់ថាហេតុអ្វីបានជានាំគ្នាឈប់ធ្វើការទៅវិញ ក្រោយមកទើបខ្ញុំដឹងថាមានន័យឈប់សម្រាក ។

ដល់ម៉ោងហូបបាយថ្ងៃត្រង់ តាមធម្មតាម្នាក់ៗត្រូវមានចានមួយនិងស្លាបព្រាមួយជាកម្មសិទ្ធិឯចានសម្លជានាទីរបស់ចុងភៅដោយក្នុងមួយវង់មានគ្នាបួននាក់ ។ ដល់ម៉ោងបាយថ្ងៃត្រង់ពួកបូព៌ាត្រូវមីង ម៉ៅ កាត់របបអាហារអស់កណ្ដាលដល់ពេលរសៀលម៉ោងមួយពួកបូព៌ាមិនព្រមចេញទៅធ្វើការទៀត (ព្រោះត្រូវកាត់របបបាយថ្ងៃត្រង់អស់ពាក់កណ្ដាល) ដល់ពេលល្ងាចម៉ោងបាយក៏ត្រូវ ពូ សូត្រ និងមីង ម៉ៅ កាត់របបអាហារទាំងស្រុង ។

## ការបាត់កម្លាំងបូព៌ានៅចម្ការ

ក្រោយពីការតវ៉ាជាមួយចុងភៅពួកបូព៌ាត្រូវបានផ្ដល់របបពាក់កណ្ដាលដូចពេលថ្ងៃត្រង់តែយើងហូបបាយទាំងអស់គ្នា ។ ល្ងាចថ្ងៃដដែលនោះ យោធាបានប្រើវិទ្យុទាក់ទងនិយាយទៅកាន់ក្រុមផ្សេងទៀតទំនងដូចជាមានសកម្មភាពចុះប្រតិបត្តិការលុះដល់យប់ជ្រៅខ្ញុំឃើញមានពន្លឺភ្លើងពិលចាំងទៅជុំផ្ទះជនជាតិដែលពួកពូៗអ្នកស្វាយរៀងស្នាក់នៅ ។ ស្អែកឡើងដល់ម៉ោងចេញទៅធ្វើការខ្ញុំមិនបានឃើញពូៗស្វាយរៀងចេញទៅធ្វើការទេ ដែលមានន័យថាប្រជាជនមូលដ្ឋានភូមិភាគបូព៌ាត្រូវយោធាភូមិចាប់យកទៅសម្លាប់ចោលអស់ហើយ ។

## ព័ត៌មានតាមវិទ្យុ វី.អូ.អេ

ក្រោយពីបាត់ពួកបូព៌ាយើងធ្វើការក្នុងចម្ការដូចធម្មតា ។ យប់នោះម៉ោងប្រាំបីកន្លះ យោធាបានបើកវិទ្យុវី.អូ.អេតិចៗ ខ្ញុំក៏ឮយ៉ាងច្បាស់ថា ទីក្រុងភ្នំពេញត្រូវបានកងទ័ពវៀតណាមនិងកងទ័ពរណសិរ្សរំដោះជាតិកម្ពុជាវាយកាន់កាប់បានថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ព័ត៌មាននេះបានធ្វើឲ្យខ្ញុំ មីងណាំ និងប្ដីប្រពន្ធពូសូត្រ សប្បាយរីករាយខ្លាំងណាស់សង្ឃឹមថាថ្ងៃណាមួយកងទ័ពរំដោះជាតិកម្ពុជានឹងមករំដោះយើងទាំងអស់គ្នានៅខេត្តពោធិ៍សាត់ជាមិនខាន ។

ក្រោយពេលស្តាប់ព័ត៌មាននេះ ដាំងដប់ថ្ងៃក្រោយមក យោធាក្មេងៗដែលមានអាយុស្របាខ្ញុំបាននិយាយបង្ហើបឲ្យខ្ញុំដឹងថា ដល់ពេលចេញវៃយួនឈ្នានពានហើយ ។ ក្រោយពីស្តាប់ឮថា ទៅវៃយួនតែមួយយប់ យោធាក៏រៀបចំសម្ភាររបស់គេមានកាំភ្លើង និងអង្រឹងចេញអស់ពីចម្ការ ។ ពេលនោះ នៅចម្ការដ៏ធំល្វឹងល្វើយ សល់តែពួកខ្ញុំអ្នក១៧មេសាប្រូននាក់ប៉ុណ្ណោះធ្វើការ ។ បន្ទាប់មក ខ្ញុំក៏សម្រេចចិត្តទៅភូមិដើម្បីជួបប្រធានភូមិ ។ ពេលទៅដល់ ស្រាប់តែស្ងាត់មនុស្សអស់សល់តែអ្នក១៧មេសាជាង១០គ្រួសារប៉ុណ្ណោះ ។ ខ្ញុំបានជួបបង សុន ជាស្រីមេម៉ាយមានកូនស្រីតូចអាយុប្រូនប្រាំឆ្នាំបានយកប្អូនស្រីខ្ញុំមកនៅជាមួយគាត់ដែរ ។ ខ្ញុំបានសួរគាត់ថា ហេតុអ្វីបានជាភូមិយើងស្ងាត់ម្ល៉េះ គាត់បាននិយាយថាពួកបុព៌ត្រូវពួកនិរតីយកទៅសម្លាប់ចោលទាំងគ្រួសារៗនៅឯព្រៃខ្មោចខាងលិចមន្ទីរសន្តិសុខតាំងពីក្រោយថ្ងៃហូបនំបញ្ចុកម្ល៉េះ ។

## ក្នុងភូមិគ្មានអ្នកមូលដ្ឋានគ្រប់គ្រង

អ្នកភូមិបានជួបជុំគ្នាធ្វើការដូចសព្វដងដោយគ្មានអ្នកមូលដ្ឋានដឹកនាំទេ ។ ដូច្នេះគ្រប់គ្នាសប្បាយរីករាយយ៉ាងខ្លាំង ប៉ុន្តែយើងធ្វើស្រែរួមគ្នានិងហូបរួមគ្នាដូចកាលមុនដដែល ។ នៅថ្ងៃទីបីខ្ញុំទៅភូមិដើម្បីយកអង្ករប្រហែលជាមួយតៅត្រឡប់ទៅចម្ការវិញ ។ ពេលទៅដល់ ខ្ញុំបានប្រាប់មីង ណាំ និងប្តីប្រពន្ធពូ សូត្រ ថាក្នុងភូមិក៏ដូចនៅចម្ការដែរគឺគ្មានអ្នកមូលដ្ឋានណាម្នាក់នៅគ្រប់គ្រងទេ ។ មានថ្ងៃមួយ ពេលខ្ញុំកំពុងលើកបំពង់ឫស្សីដែលដាក់ត្រាំទឹកយកត្រីនៅក្នុងស្ទឹងក្រឡេកមើលទៅប្រាំងក៏ឃើញទាហានស្ថិតក្នុងឯកសណ្ឋានពណ៌ស្លឹកឈើប្លែកខុសពីទាហានខ្មែរក្រហមមើលមកខ្ញុំដូចកងឈ្លបខ្មែរក្រហមក៏បានប្រុងប្រយ័ត្នចំពោះខ្ញុំខ្លាំងណាស់ ហើយបានតម្រង់កាំភ្លើងមករកខ្ញុំ ព្រោះខ្ញុំស្លៀកពាក់ខោអាវខ្មៅដែលប្រធានភូមិ អឿន ចែកឲ្យ ។ ដោយទាហានពីរនាក់នោះនៅចម្ងាយតែប្រាំម៉ែត្រពីខ្ញុំប៉ុណ្ណោះ ខ្ញុំក៏ចាប់ផ្តើមនិយាយទៅកាន់ទាហានពីរនាក់នោះថា ខ្ញុំជាអ្នក១៧មេសាទើបទាហានពីរនាក់នោះដាក់កាំភ្លើងចុះ ហើយសួរខ្ញុំថា «នៅទីនេះគេហៅអ្វី»? «មានពួកខ្មែរក្រហមទេ?» ខ្ញុំប្រាប់ថា «តំបន់នេះគេហៅថាចម្ការបាក់ត្រកួន កាលពីកន្លះខែមុនមានទាហានខ្មែរក្រហមនិរតីខ្លះដែរ តែឥឡូវនេះគេដកទៅវៃខ្មាំងយួនអស់ហើយ សល់តែខ្ញុំនិងចាស់ៗជាអ្នកថ្មីប៉ុន្មាននាក់ប៉ុណ្ណោះ ។

## សភាពការណ៍ប្រែប្រួល

ក្រោយពីជួបទាហានចម្លែកបានប្រាំថ្ងៃកន្លងមកខណៈពេលដែលខ្ញុំកំពុងកាប់ព្រៃពោត ខ្ញុំក៏ឮសូរសំឡេងយន្តហោះហោះយ៉ាងខ្ពស់កំពុងទម្លាក់របស់អ្វីតូចៗជាច្រើនរាយពេញមេឃ ។ ខ្ញុំដើរទៅរើសក្រដាសទាំងនោះមកមើលក៏ដឹងថា ជាខិតប័ណ្ណដែលមានសរសេរអក្សរខ្មៅថា រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ បន្ទាប់មក ខ្ញុំបានយកមកចែកពូសូត្រ និងមីង ម៉ៅ មើលរហូតធ្វើឲ្យគាត់សប្បាយរីករាយយ៉ាងខ្លាំង ហើយក៏ប្រមូលយកទៅដុតចោលអស់ខ្លាចក្រែងមានខ្មែរក្រហមណាម្នាក់មកចម្ការឃើញខិតប័ណ្ណនេះ ។

នៅក្នុងភូមិគ្មានអ្នកគ្រប់គ្រងពេលថ្ងៃប្រជាជនចេញទៅប្រូតស្រូវនិងរកបន្លែព្រៃរៀងៗខ្លួន នរណារកបានអ្វីធ្វើហូបតាមគ្រួសារតាមគ្នាតិចឬច្រើនទៅ ។ ខ្ញុំរស់នៅជាមួយបងស្រីមេម៉ាយឈ្មោះ សុន ហើយខ្ញុំនិងគាត់ក៏រាប់អានគ្នាដូចបងប្អូនបង្កើតដែរ ។ ភូមិដ៏ធំមួយធ្លាប់មានមនុស្សរាប់រយនាក់នៅសល់តែមនុស្សជាង៣០នាក់រាប់ទាំង មីងណាំ ប្តីប្រពន្ធពូ សូត្រ និងខ្ញុំបន្តរស់នៅរហូតដល់កងទ័ពវៀតណាមរំដោះ ។

## កងទ័ពវៀតណាមវាយកាន់កាប់ពោធិ៍សាត់

ព្រឹកព្រលឹមថ្ងៃមួយឮអ្នកភូមិនិយាយគ្នាថា ជាថ្ងៃចូលឆ្នាំខ្មែរខ្ញុំគិតថាត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៩ វេលាម៉ោងប្រហែល៩ព្រឹកស្រាប់តែមានយន្តហោះពីរគ្រឿងបានហោះយ៉ាងទាបរំលងភូមិលាចហើយបានហោះត្រឡប់មកវិញធ្វើឲ្យយើងទាំងអស់គ្នាភ័យផង និងអរផង ។ មិនបានប៉ុន្មាននាទី យន្តហោះទាំងពីរគ្រឿងបានហោះមកម្តងទៀតឆ្ពោះទៅខាងលិចដដែលរួចបានទម្លាក់គ្រាប់បែកលាន់ឮទ្រហឹងយ៉ាងខ្លាំងនៅក្បែរភូមិ ។ ការប្រយុទ្ធគ្នារវាងទ័ពខ្មែរក្រហមនិងកងទ័ពម្ខាងទៀតបានចាប់ផ្តើមឡើងហើយខ្មែរក្រហមបានកៀរអ្នកភូមិចេញពីផ្ទះឲ្យសំដៅទៅទិសខាងលិចដោយក្នុងនោះមានខ្ញុំនិងប្អូនស្រីតូចរបស់ខ្ញុំម្នាក់ដែរ ។ ក្រោយពីស្នូរកាំភ្លើងបានស្ងៀយទៅវិញ ខ្ញុំឃើញកងទ័ពវៀតណាមត្រូវគ្រាប់កាំភ្លើងជាច្រើននាក់ ចំណែកប្រជាជនក៏ស្លាប់ខ្លះដែរ ។ ការកៀង

ប្រជាជនចេះតែបន្តរហូតទៅដល់ស្ពឹងក្បាល៥ ហើយឆ្លងស្ពឹងចូលព្រៃសំដៅទៅភ្នំ ។ ប៉ុន្តែជាសំណាងល្អ ខ្ញុំមិនបានឆ្លងស្ពឹងនេះទេ ព្រោះកងទ័ពវៀតណាមកក៏មកទាន់ ។

បន្ទាប់មក ស្រាប់តែមានកងទ័ពវៀតណាមពីរនាក់យកកាំភ្លើងភ្ជង់ខ្ញុំ ហើយស្រែកថា ប៉ុល ពត ដោយម្នាក់ចាប់ខ្ញុំចងក្រណាត់ដៃទៅក្រោយ ឯប្អូនស្រីខ្ញុំវានៅតូចស្រែកយំយ៉ាងខ្លាំង និងរត់តាមខ្ញុំរហូត ។ ពេលនោះ ស្ត្រីមេម៉ាយមានកូនតូចមួយឈ្មោះ អាថៃ ដែលកាលពីខ្ញុំនៅចម្ការខ្ញុំខស្សាហ៍ឲ្យដំឡូងទៅគាត់ ក៏ស្ទុះមកចាប់ខ្ញុំហើយនិយាយភាសាយួនជាមួយកងទ័ពវៀតណាមមួយសន្ទុះក្រោយមក កងទ័ពទាំងនេះ ក៏បានស្រាយចំណងខ្ញុំ ។ បន្ទាប់មកគាត់ប្រាប់ខ្ញុំថា ឲ្យឈប់ស្លៀកពាក់សម្លៀកបំពាក់ខ្មៅនេះទៀត ដើម្បីកុំឲ្យកងទ័ពវៀតណាមច្រឡំថា ប៉ុល ពត ។ ក្រោយពីប្រាប់រួច គាត់ក៏បានទៅតាមកងទ័ពវៀតណាម ចំណែកខ្ញុំនាំប្អូនស្រីខ្ញុំត្រឡប់មកផ្ទះវិញ ។

ចូលដល់ក្នុងភូមិ ខ្ញុំបានឃើញប្អូនស្រីឈ្មោះ លួង ដែលនៅអគ្គភាពកុមារកំពុងដើររេរាសម្លឹងមើលផ្ទះដែលគ្មានមនុស្សរស់នៅ ។ បន្ទាប់មក ខ្ញុំបានប្រាប់ប្អូនស្រីខ្ញុំទាំងពីរនាក់ឲ្យអង្គុយចាំមួយកន្លែងរង់ចាំបងប្អូនម្នាក់ទៀត ចំណែកខ្ញុំដើររកសាច់និងរបស់អ្វីផ្សេងទៀតយកមកហូប ។ លុះដើរឆ្លងខាងកើតភូមិបានបន្តិច ខ្ញុំក៏ជួបប្តីប្រពន្ធពូសូត្រ និងប្តីប្រពន្ធ ពូហួយ កំពុងសម្លាប់គោនិងវះពោះគោយកសាច់ហូប ។ ឃើញបែបនេះខ្ញុំបានចូលទៅជិតគាត់ ហើយសុំសាច់គាត់ខ្លះ ។ ប៉ុន្តែគាត់មិនត្រឹមតែមិនឲ្យទេ ថែមទាំងស្តីឲ្យខ្ញុំថាមិនចេះដើររកស៊ីខ្លួនឯងទេ ។ បន្ទាប់មក ខ្ញុំបានដើរត្រឡប់មករកប្អូនខ្ញុំវិញ ហើយក៏ប្រទះឃើញកូនឆ្នាំងមួយមានអំបិលពេញ និងមានស្លាបព្រាពីរផងក៏រើសយកទុក ។ នៅម៉ោងមួយរសៀល ខ្ញុំឃើញប្អូនប្រុសខ្ញុំមកពីកងចល័តមានស្ពាយអង្ករមួយថៃនិងដៃម្ខាងទៀតកាន់មេមាន់មួយ ។ ពេលនោះក្នុងចិត្តខ្ញុំ និងប្អូនៗរបស់ខ្ញុំត្រេកអរយ៉ាងខ្លាំង ហើយនឹកដល់គុណឪពុកម្តាយនិងបងប្អូនផ្សេងទៀតដែលបានស្លាប់ទៅនៅចាំជួយថែរក្សា ។

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៩ បងប្អូនខ្ញុំជួយគ្នាបង្កាត់ភ្លើងដាំបាយនិងស្ងោរមាន់ខទ្ទិសដល់វិញ្ញាណក្ខន្ធអ្នកមានគុណរួចទាំងអស់គ្នាបានហូបបាយជុំគ្នាជាលើកដំបូង ។ នៅរសៀលម៉ោង៤ បងប្អូនខ្ញុំទាំងបួននាក់បានចាកចេញពីភូមិលាចសំដៅទៅផ្លូវដីក្រហមនៅមន្ទីរឃុំលាច ឯគ្រួសារ ពូសូត្រ និងពូហួយ មិនទាក់ចាកចេញទេ ។ ទៅដល់ថ្នល់ក្រួសក្រហមមានប្រជាជនច្រើនកំពុងស្នាក់នៅក្រោមអគារ បងប្អូនខ្ញុំទាំងបួននាក់ក៏បានស្នាក់នៅរោងដំដែកមួយកែងផ្លូវចូលភូមិលាចដែលក្នុងរោងនេះមានខោអាវចាស់ៗប្រឡាក់ផ្សែងជាច្រើន មានអណ្តូងទឹកមួយ សម្ភារផ្សេងៗដែលគេបោះបង់ចោលនៅពេលប្រយុទ្ធគ្នា ។

ព្រឹកព្រលឹមស្រាងៗ អ្នកភូមិផ្សេងទៀតនៅជាប់ភូមិលាចនេះបាននាំគ្នាដើរចេញមកទាំងទឹកមុខភ័យស្លេកស្លាំងហើយនិយាយថាប្តីប្រពន្ធពីរគូដែលកាប់គោនៅភូមិលាចត្រូវឈ្លបចាប់អារ-កសម្លាប់ហើយ ព្រោះទុកមិនចំណេញ ដកចេញក៏មិនខាត ។ នៅថ្ងៃបន្ទាប់ ខ្ញុំស្នាក់នៅរោងដំដែកដដែល ។ ថ្ងៃ១៥មេសា មានផ្គរំកិនស្អុយខ្មោចភាយៗតាមខ្យល់បក់ព្រមទាំងរុយក្បាលខៀវហើរទាំងហ្វូង ។ តែទោះបីយ៉ាងណាក៏ដោយ គ្រួសារខ្ញុំនិងប្រជាជនដទៃទៀត ត្រៀមចេញដំណើរត្រឡប់ទៅស្រុកកំណើតវិញដោយមានរៀបចំដាំបាយធ្វើម្ហូបខ្លះៗទុកហូបតាមផ្លូវ ។

តាមដងផ្លូវ យើងឃើញមានខ្សែរថក្រោះនិងរថយន្តកងទ័ពវៀតណាមកំពុងបើកចូលមកជាហូរហែ ។

## តុលាការប្រជាជនមហាជន

ព្រឹកព្រលឹមថ្ងៃ១៦ មេសា ឆ្នាំ១៩៧៩ ប្រជាជនទាំងអស់ភាគច្រើនជាមនុស្សប្រុសវ័យកណ្តាលបានឈរអមសងខាងផ្លូវក្រួសក្រហមក្នុងដៃប្រដាប់ដោយកាំបិត ពូថៅ ដំបង និងដុំថ្មក្នុងចិត្តពោរពេញទៅដោយកំហឹងរង់ចាំកម្មាភិបាលខ្មែរក្រហមដែលបម្រើឲ្យរបបនេះដើម្បីសងសឹកវិញ ។ បន្ទាប់មក អ្នកដែលកំពុងឈរសងខាងផ្លូវចំណាំបានថា អ្នកដែលយកបងប្អូនប្តីម៉ែរបស់គេទៅសម្លាប់និងធ្វើបាបក៏ស្រែកឆោឡោឡើងថា រួចក៏នាំគ្នាទៅចោមវាយសម្លាប់ដោយក្នុងនោះមានប្រធានអគ្គភាពម្នាក់ត្រូវបានសម្លាប់នៅកណ្តាលទ្រូងផ្លូវម្នាក់ ។ ភាពអនាធិបតេយ្យការកាប់សម្លាប់អ្នកមូលដ្ឋាននិងការដណ្តើមទ្រព្យគ្នាៗគ្នាបានកើតឡើងជាហូរហែ ។ ចំណែកខ្ញុំនៅក្មេង មិនហ៊ានធ្វើដូចមនុស្សពេញវ័យឡើយ ។ ខណៈដំណើរត្រឡប់មកលំនៅដ្ឋាន

នៅរសៀលម៉ោងពីរ ពេលខ្ញុំកំពុងលាបស្លឹកគលើខ្លួន

ប្អូនស្រីតូច ប្អូនប្រុសខ្ញុំក៏បានសាច់គោនិងក្រណាត់ក្រហមមួយ ក៏ប្រាប់ថា រើសបាន ។ បន្ទាប់មក ប្អូនស្រីពៅខ្ញុំបានប្រឡាក់សាច់គោនោះនិងដាំបាយទុកចេញដំណើរ ។ រសៀលម៉ោង២ជាង ទៅហើយភាពវឹកវរនៅតែកើតមានឡើងដដែល ដោយប្រជាជននាំគ្នាយកដុំថ្មគប់កងទ័ពខ្មែរក្រហមបួននាក់ដែលត្រូវបានកងទ័ពវៀតណាមចាប់បានរហូតដល់ស្លាប់ ។

ក្រោយហេតុការណ៍នេះ ខ្ញុំបានចាកចេញពីតំបន់មនុស្សកកកុញសំដៅទឹរួមខេត្តពោធិ៍សាត់ដោយអៀវប្អូនស្រីដែលកើតជំងឺគ្រុនក្តៅ ។ យើងទាំងបួននាក់ធ្វើដំណើរទៅមុខរហូតដល់កន្លែងមួយហៅថា ចម្ការម៉ៃសាក់ ឃុំលលកស ។ នៅទីនោះមានខ្ទមនិងស្រះទឹកមួយព្រមទាំងស្រីបីនាក់ជាអ្នកដំណើរកំពុងស្នាក់នៅ ។ ពេលនោះខ្ញុំសម្រេចចិត្តចូលទៅសុំស្រីៗទាំងបីនាក់នោះស្នាក់នៅជាមួយ ។ បន្ទាប់មក ប្អូនប្រុសរបស់ខ្ញុំក៏ប្រញាប់ទៅរកទឹកយកមកដឹកទាំងអស់គ្នាហើយបេះស្លឹកឈូកមកដាក់បាយនិងសាច់គោដុត ។ ក្រោយពេលហូបបាយរួច យើងក៏នាំគ្នាទៅដេក ក្បែរស្រះឈូក ។ នៅពេលយប់ថ្ងៃទី១៦ប្អូនស្រីដែលកើតគ្រុនក្តៅបានធូរស្រាលពីជំងឺ ។

នៅពេលរសៀលម៉ោងបី គ្រួសារយើងទាំងពីរក៏ចាប់ផ្តើមចេញដំណើរ ។ ពេលដើរទៅដល់ចិញ្ចើមផ្លូវមានរថយន្តកងទ័ពវៀតណាមមួយគ្រឿងកំពុងបើកបរក្នុងទិសពីលិចទៅកើតស្របទិសខ្ញុំ យើងសុំកងទ័ពទាំងនេះជិះរថយន្តទៅជាមួយ ។ រថយន្តបើកទៅមុខមានអ្នកដំណើរសុំជិះជាហូរហែតែរថយន្តនេះមិនឈប់សោះ ។ ពេលរថយន្តបើកដល់ព្រៃអមសងខាងមួយកន្លែងទំនងជាចម្ការម៉ៃសាក់នោះ ខ្ញុំបានឃើញសាកសពប្រជាពលរដ្ឋចំនួនបួននាក់នៅក្បែរព្រៃជាមួយនឹងអីវ៉ាន់ខ្លះៗនៅក្បែរសាកសពនោះ ។ បន្ទាប់មក រថយន្តបានបើកយឺតៗទៅទិសខាងត្បូងសំដៅទៅទឹរួមខេត្តពោធិ៍សាត់ទៅដល់ក្បែរមាត់ស្ទឹងរថយន្តក៏ឈប់ហើយដាក់ឲ្យពួកខ្ញុំចុះ ។

មកដល់ទីនេះពេលវេលាម៉ោង៤រសៀល ប្រជាពលរដ្ឋយ៉ាងច្រើនកុះករនៅមាត់ស្ទឹង និង អាគារ ដោយខ្លះដាំបាយ និងស្លខ្លះកំពុងងូតទឹកស្ទឹង និងខ្លះច្រៀងរាំជាក្រុមជារង់យ៉ាងសប្បាយរីករាយ ។ ប្អូនប្រុសខ្ញុំឃើញដូច្នេះ ក៏យកក្រណាត់ក្រហមមួយគីនោះហែកប្រវែងពីរម៉ែត្រៗយកទៅដូរបានជាមាន់ អង្ករ និងរបស់ចាំបាច់ខ្លះៗទៀត ។ យប់ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៩ បងប្អូនខ្ញុំទាំងបួននាក់បាននាំគ្នាទៅស្នាក់នៅរោងធំមួយកន្លែងហៅថាក្បាលហាន់ជាមួយអ្នកធ្វើដំណើរផ្សេងទៀត ។

សព្វថ្ងៃនេះ គ្រួសាររបស់ខ្ញុំនៅរស់រានមានជីវិតតែពីរនាក់ប៉ុណ្ណោះ គឺរូបខ្ញុំដែលជាជនពិការ និងប្អូនស្រីឈ្មោះ ប៉ៅ លួង ក៏ក្លាយជាមនុស្សពិការនិងជាស្ត្រីមេម៉ាយ ។

**ឡៃ ហួត**

# ដំណឹងស្វែងរកគ្រួសារ

ខ្ញុំបាទឈ្មោះ វង្ស ទ្រង់ ហៅ អួង ដេង ភេទប្រុស អាយុ៤៧ឆ្នាំ សព្វថ្ងៃរស់នៅផ្ទះលេខ ២៦៥A ផ្លូវ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ក្រុងភ្នំពេញ ។ ខ្ញុំបាទសូមស្វែងរកគ្រួសារដែលបានបាត់ខ្លួនក្នុងរបបខ្មែរក្រហម ១) ឪពុកឈ្មោះ វង្ស ត្រុងយ៉ុង ពេលបែកគ្នាអាយុប្រហែល៤៣ឆ្នាំ) ២)ម្តាយឈ្មោះ លឹម បូទី (កាលបែកគ្នាអាយុ៤០ឆ្នាំ) ៣) បងប្រុសទីមួយ មិនចាំឈ្មោះ ៤)បងប្រុសទីពីរ វង្ស បូឃី ឬ អួង បូឃី (កាលបែកគ្នាអាយុ១៨ឆ្នាំ) ៥)បងប្រុសទីបី វង្ស ម៉េង ឬ អួង ម៉េង (កាលបែកគ្នាអាយុ១៤ឆ្នាំ) ៦)ប្អូនប្រុសទីប្រាំ វង្ស រឿង ឬ អួង រឿន (កាលបែកគ្នាអាយុ៨ឆ្នាំ) ។ កាលពីមុនឆ្នាំ១៩៧៥ គាត់រស់នៅសង្កាត់លេខ៣ក្រុងភ្នំពេញ ត្រង់ផ្លូវសុខហុក កែងនឹងផ្លូវបត់ទៅផ្សារឌុយមិច ។ ពេលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ គាត់ត្រូវបានជម្លៀសតាមបណ្តោយផ្លូវជាតិលេខ៤ត្រង់ម្តុំពោធិចិនតុង ។

ប្រសិនបើបងប្អូនណាបានឮ ឬបានអានសេចក្តីប្រកាសនេះ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០៩២ ៤២៥ ៥៣៤ ឬ ០៧៧ ៦០ ៦០ ៣០ ឬអាសយដ្ឋានដូចខាងលើកុំបីខាន ។ សូមអរគុណ ។

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាងមួយលាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់ ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់ ៤) ភេទអ្នកស្លាប់ ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន) ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ ៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី) ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?) ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ ៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ ៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន ២) ភេទ ៣) អាយុ ៤) ត្រូវជាអ្វី ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ ៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










*ដើម្បីយុត្តិធម៌និងការចងចាំ*

*ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ*

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 144, December 2011 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.